ព្រឹត្តិការណ៍ "រំលឹកគុណអង្គរ" ប្រចាំឆ្នាំ២០២៣..............................................................៣១៣
- ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ក្រុមការងារសម្អាតបរិស្ថាននៃអាជ្ញាធរជាតិអប្សរា
មមាញឹកសម្អាតសំរាមស្លឹកឈើ និងកាត់ស្មៅនៅខាងលិចជ្រុងខាងជើងកសិន្ធុប្រាសាទអង្គរវត្ត............៣១៤
- ចាប់តាំងពីដើមខែធ្នូ មកដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣នេះ សម្ភារប្រើប្រាស់មាន កាបូប ទូរស័ព្ទដៃ
និងសម្ភារមួយចំនួនទៀត ត្រូវបានភ្នាក់ងារទេសចរណ៍ប្រចាំការនៅគោលដៅប្រាសាទអង្គរវត្ត
បានប្រទះឃើញ និងប្រគល់ជូនម្ចាស់ដើមវិញ.......................................................................៣១៥
- ទស្សនិកជនច្រើនកុះកររីករាយជាមួយការទស្សនាល្ខោនយីកេ ក្នុងព្រឹត្តិការណ៍បុណ្យរំលឹកគុណអង្គរ..........៣១៦
- ក្រុមការងារអាជ្ញាធរជាតិអប្សរា បានជួសជុលកាំជណ្តើរផ្នែកកណ្តាលចំណុចស្ពានហាលអង្គរវត្ត
ឱ្យមានភាពរឹងមាំឡើងវិញសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរ កាំជណ្តើរថ្មីបានជំនួស
កាំជណ្តើរចាស់ជាផ្នែកមួយនៃការលើកកម្ពស់សុវត្ថិភាព សោភ័ណភាពនៃរមណីយដ្ឋានអង្គរ................៣១៧
- អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងជំនាញបដិសណ្ឋារកិច្ច
សម្រាប់ភ្នាក់ងារទេសចរណ៍..........................................................................................៣១៨
- អាជ្ញាធរជាតិអប្សរាចូលរួមធ្វើបទបង្ហាញស្តីពីបេតិកភណ្ឌអង្គរ និងអារាមព្រះពុទ្ធសាសនា
ក្នុងអង្គពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣១...........................................៣១៩
- ក្រុមសិល្បករ យុវជន និងវិស័យឯកជនចូលរួមដង្ហែក្បួនព្យុហយាត្រា
ដើម្បីអបអរសាទរព្រឹត្តិការណ៍រំលឹកគុណអង្គរ.....................................................................៣២០
- សូមអញ្ជើញទស្សនាកម្រងរូបភាពកម្មវិធី "រាត្រីចងចាំ" លើកទី៤ ដែលប្រព្រឹត្តទៅ
នាល្ងាចថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ នាព្រះលានជល់ដំរី ក្រុងអង្គធំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់
សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអនឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
និងការអញ្ជើញចូលរួម លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ....៣២១
- សារលិខិត របស់អាជ្ញាធរជាតិអប្សរា គោរពជូនពរ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន
ប្រធានកាកបាទក្រហមកម្ពុជាក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រសើរថ្លៃថ្លាវិសេសវិសាលនៃពិធីខួបចម្រើនជន្មាយុ
របស់ សម្តេចកិត្តិព្រឹទ្ធ បណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា
ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២៣នេះ...............................................................៣២២
- សិស្សានុសិស្សសាលាបឋមសិក្សានគរក្រៅ ហ្វឹកហាត់គំនូរបេតិកភណ្ឌនៅប្រាសាទបាយ័ន..................៣២៣
- សាធារណជនជាច្រើនរីករាយអង្គុយទស្សនាការសម្តែងសិល្បៈស្បែកធំ ដែលសម្តែងដោយក្រុមសិល្បៈ
ស្បែកធំវត្តរាជបូណ៌ខេត្តសៀមរាប នាយប់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ នៅខាងត្បូងប៉ារីសអង្គរវត្ត..........៣២៤
- ព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ នៅចំណុចក្បែរខ្លោងទ្វារកណ្តាលលោកតារាជនៃប្រាសាទអង្គរវត្ត
មានភ្ញៀវទេសចរជនជាតិអឺរ៉ុប ភេទប្រុសគ្រិចកជើង ខណៈកំពុងដើរទស្សនាភ្លាមៗក្រុមការងារ
ភ្នាក់ងារទេសចរណ៍បានជួយសង្គ្រោះបឋមបន្ទាប់មកគាត់ក៏អាចបន្តដំណើរទស្សនាជម្មតាវិញ.............៣២៥
- ភ្ញៀវទេសចរជិត៨ម៉ឺននាក់ បានមកទស្សនាពិព័រណ៌ និងការសម្តែងទស្សនីយភាពសិល្បៈចម្រុះនានា
នៃព្រឹត្តិការណ៍រំលឹកគុណអង្គរ........................................................................................៣២៦

- ការជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្មជួសជុលសម្រេចបាន៦០ភាគរយហើយ................៣២៨
- ប្រាសាទបាយ័ននៅតែជាទីតាំងដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរ....................................................៣២៩
- ប្រទះឃើញចម្លាក់បដិមាថ្មភក់ចំនួន៦នៅខ្លោងទ្វារខាងត្បូងរបស់ប្រាសាទតាព្រហ្ម...........................៣៣០
- ប្រាសាទតុបខាងកើត.........................................................................................................៣៣១
- ប្រាសាទព្រៃប្រាសាទ ឬប្រាសាទតាអួន.....................................................................................៣៣២
- អាជ្ញាធរជាតិអប្សរា កំណាយស្រាវជ្រាវគ្រឹះខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្ម
ដើម្បីឈានទៅដល់ការជួសជុល.............................................................................................៣៣៣
- អាជ្ញាធរជាតិអប្សរាសូមធ្វើសេចក្ដីបំភ្លឺជុំវិញការផ្សព្វផ្សាយព័ត៌មានផ្ទុយពីការពិត
អំពីសកម្មភាពទប់ស្កាត់សំណង់មិនស្របច្បាប់នៅភូមិសណ្ដាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប
ខេត្តសៀមរាប......................................................................................................................៣៣៤
- ប្រាសាទនាគព័ន្ធនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិតែងតែប្រាថ្នាមកទស្សនាមិនដែលរំលង..............៣៣៦
- ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣
បានដឹកនាំក្រុមការងារចុះតាមការដ្ឋានការងារនានាក្នុងរមណីយដ្ឋានអង្គរ ដើម្បីពិនិត្យ កែលម្អ
និងរៀបចំទិសដៅការងារបន្ទាប់នាពេលអនាគត.......................................................................៣៣៧
- សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤.................៣៣៨
- សារលិខិតជូនពរ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤......................................៣៣៩
- សារលិខិតជូនពរ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤.........................................................................៣៤០
- សារលិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤.........................................................................៣៤១
- សារលិខិតជូនពរ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤.........................................................................៣៤២
- ប្រាសាទបន្ទាយធំ លាក់ខ្លួនក្នុងព្រៃរងចាំភ្ញៀវទេសចរទៅទស្សនា..................................................៣៤៣
- រូបភាពប្រចាំសប្ដាហ៍÷ ប្រាសាទធម្មនន្ទ......................................................................................៣៤៤
- រូបភាពប្រចាំសប្ដាហ៍÷ ប្រាសាទលាក់នាង....................................................................................៣៤៥
- ថ្ងៃចុងក្រោយនៃឆ្នាំ២០២៣ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាកម្សាន្តប្រាសាទអង្គរវត្ត
យ៉ាងច្រើនកុះករ.................................................................................................................៣៤៦

# ព្រឹត្តិការណ៍ព័ត៌មាន
# ប្រចាំខែកក្កដា

# អរុណសួស្តី...
# សូមអញ្ជើញទស្សនាទិដ្ឋភាពថ្ងៃរះដ៏ស្រស់ស្អាតនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣

# ប្រាសាទចៅសាយទេវតា
# ប្រាសាទតូចច្រលឹងដ៏ស្រស់ស្អាត ដែលទេសចរពុំគួរមើលរំលង

ផ្សាយនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣

# អតីតប្រធានាធិបតីនៃប្រទេសស្រីលង្កា អញ្ជើញធ្វើទស្សនកិច្ចសិក្សានៅក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣

កាលពីពេលថ្មីៗនេះ អតីតប្រធានាធិបតីស្រីលង្កាអមដំណើរដោយ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអញ្ជើញធ្វើទស្សនកិច្ចនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីស្វែងយល់អំពីការអភិវឌ្ឍ និងការងារអភិរក្សប្រកបដោយចីរភាព នៅក្នុងតំបន់រមណីយដ្ឋានអង្គរ៕

# អាជ្ញាធរជាតិអប្សរា សហការជាមួយវិស័យឯកជន បន្តដាំស្មៅ និងកូនឈើ នៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣

នៅថ្ងៃទី០១-០២ ខែកក្កដា ឆ្នាំ២០២៣ ក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរា បានបន្តសហការជាមួយក្រុមហ៊ុន Minebea (Cambodia)Co., Ltd. និងសាលាអន្តរជាតិ WESTGATE ខេត្តសៀមរាប ដាំកូនឈើចម្រុះចំនួន១,២០០ដើមនិងស្មៅចំនួន៧០០ម៉ែត្រការ៉េ នៅបរិវេណខាងជើង ឆៀងខាងលិចប្រាសាទអង្គរវត្ត (អតីតផ្សារយាងធំ)៕

# សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ បានទទួលវត្ថុបុរាណចំនួន៧៧ ពីប្រជាពលរដ្ឋរស់នៅក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣

នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣នេះ សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ បានទទួលវត្ថុបុរាណចំនួន៧៧បន្ថែមទៀត ដែលប្រជាពលរដ្ឋរស់នៅក្នុងខេត្តសៀមរាប បានស្ម័គ្រចិត្តប្រគល់ជូនមកកាន់សារមន្ទីរ ដើម្បីធ្វើការថែរក្សា និងអភិរក្សបន្ត។ ដោយវត្ថុបុរាណទាំង៧៧នោះ ខ្លះនៅរក្សបានរូបរាងពេញ និងខ្លះទៀតបានបែកបាក់ជាបំណែក មានដូចជា៖

ឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជននាសម័យបុរាណ មានកុលាលភាជន៍ ឧបករណ៍សម្រាប់ដាក់ទឹក និងម្ហូបអាហារផ្សេងៗ គ្រឿងអលង្ការដូចជា៖ កងដៃ និងឧបករណ៍ប្រើប្រាស់ផ្សេងៗទៀតដូចជា៖ កាំបិត ពូថៅ និងចានជាដើម។

លោក ណាក់ បូរុន ជាអ្នកប្រកបរបររកស៊ីមួយរូប រស់នៅក្នុងខេត្តសៀមរាបបានឱ្យដឹងថាវត្ថុបុរាណមានចំនួន៧៧នេះ វត្ថុខ្លះលោកបានទិញបន្តពីប្រជាពលរដ្ឋ និងខ្លះទៀតប្រជាពលរដ្ឋបានប្រគល់ជូនលោកយកមករក្សាទុកបន្ត ដែលមានប្រភពនៅក្នុងខេត្តសៀមរាបខ្លះ និងមកពីខេត្តបន្ទាយមានជ័យខ្លះ។ ប៉ុន្តែលោកមិនបានដឹងអំពីអាយុកាលនៃវត្ថុនីមួយៗឡើយ ការរក្សាទុកនេះដោយយល់ថាវត្ថុទាំងនោះ ជារបស់មានតម្លៃពីបុរាណគួរបន្តថែរក្សា។

លោក ភួយ សារឿត នាយកស្តីទីនៃសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ បានឱ្យដឹងថា វត្ថុសិល្បៈដែលប្រជាពលរដ្ឋបានប្រគល់មកកាន់សារមន្ទីរ ភាគច្រើនជាកុលាលភាជន៍ ប្រហែលជាឧបករណ៍ដីដុតនៅក្នុងសម័យបុរេប្រវត្តិសាស្ត្រ និងសម័យអង្គរ និងឧបករណ៍ ជាប្រភេទលោហៈ ភាគច្រើនជាឧបករណ៍ប្រើប្រាស់។ ដោយភាគច្រើននៃវត្ថុសិល្បៈដែលបានប្រគល់ជូនមានច្រើនជាងគេ គឺកងដៃចំនួន២៤បំណែក និងពូថៅចំនួន១៨បំណែក ប៉ុន្តែក្រុមអ្នកជំនាញពុំទាន់អាចកំណត់អាយុកាលនៃវត្ថុបុរាណទាំងនោះច្បាស់លាស់នៅឡើយ។

# ក្រុមការងារព្រៃឈើកំពុងកាត់ក្រី និងព្យាបាលជំងឺដើមស្លង់ចំណាស់នៅប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣

ក្រុមការងារព្រៃឈើ នៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ពន្ធ នៃអាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រីមែក និងព្យាបាលដើមនិងឫសដើមស្លង់ចំណាស់មួយដើម នៅជ្រុងខាងកើតប្រាសាទតាព្រហ្ម។

លោក គង់ សុវណ្ណារិទ្ធ មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងទឹកព្រៃឈើនិងហេដ្ឋារចនាសម្ពន្ធបានលើកឡើងថា ដើមស្លង់ចំណាស់ដែលក្រុមការងារលោកកំពុងកាត់ក្រី និងព្យាបាលនេះ មានសភាព ទ្រុឌទ្រោម និងត្រូវការការថែទាំព្យាបាល ដើម្បីទប់ស្កាត់ហានិភ័យ។ លោកបន្តថា ប្រសិនកង្វះខាតការ ថែទាំជិតដល់ ដើមឈើនេះអាចនឹងប្រឈមធាប់ងាប់ និងបង្កគ្រោះថ្នាក់ដល់ប្រាសាទដូចគ្នា ព្រោះតួដើម និងឫសរបស់វាដុះជាប់យ៉ាងជិតស្និទ្ធជាមួយប្រាសាទ។ បន្ថែមពីនេះ ក៏អាចនឹងបាត់បង់សោភ័ណភាព ដែលទីតាំងនេះជាកន្លែងទាក់ទាញទេសចរ ដែលតែងឈរថតជានិច្ចនៅពេលបានមកដល់។

ចំពោះការព្យាបាល និងថែទាំ ក្រុមការងារព្រៃឈើបានដំឡើងរន្ទាឡើងកាត់មែកផ្នែកខាងចុង ដែលពុកផុយចំណែកនៅផ្នែកឫស គេបានចាំងនិងចោះសាច់ស្អុយឬពុកផុយចេញ បន្ទាប់មកគេព្យាបាលវាដោយប្រើជីរទឹកលាយជាមួយខ្លាញ់គោ និងជីដំបូកបិទផ្ចិតរន្ធ។ ធ្វើដូច្នេះ គេអាចទប់ស្កាត់ការពុកផុយបន្តទៀត និងអាចធ្វើអោយសាច់ដើមឈើដុះគ្របឡើងវិញផងដែរ។ នេះជាការលើកឡើងរបស់លោក គង់ សុវណ្ណារិទ្ធ ដែលធ្វើការផ្នែកកាត់ក្រីមែកឈើ និងព្យាបាលដើមឈើជាង១០ឆ្នាំមកហើយ។

គ្រឹះប្រាសាទនៅតំបន់រមណីយដ្ឋានអង្គរ មានទំនាក់ទំនងខ្លាំងជាមួយទឹកក្រោមដី។ ហើយតំបន់ដែលមាន ទឹកក្រោមដីច្រើន ជាតំបន់ដែលសម្បូរដើមឈើដូចគ្នា។ ដូច្នេះហើយ ទើបការអភិរក្សប្រាសាទនៅ តំបន់រមណីយដ្ឋានអង្គរ ក៏ត្រូវការចាំបាច់នូវដើមឈើ និងទឹកដូចគ្នា។ លោក សុវណ្ណារិទ្ធ បន្ថែមថា៖« ប្រាសាទត្រូវការសំខាន់ប្រព័ន្ធទឹកក្រោមដី ហើយដើមឈើមានមុខងារសំខាន់ក្នុងតំបន់ឧទ្យានអង្គរ ដែលជួយទាក់ទាញទឹកភ្លៀង ទប់ទឹកភ្លៀង និងជួយទឹកជ្រាបក្រោមដីល្អបំផុត ធៀបនឹងតំបន់ទីវាល តំបន់មានដើមឈើមានទឹកយូរជាង មិនងាយខ្សោះទឹកដូចនៅតំបន់ទីវាលទេ»។

# ឧទ្យានអង្គរ នារដូវវស្សា

ផ្សាយនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣

ដើមរដូវវស្សាបានចូលមកដល់មានភ្លៀងធ្លាក់ញឹកញាប់ ធ្វើឱ្យរុក្ខជាតិ ដើមឈើរីកលូតលាស់ត្រួយ ស្លឹកបៃតងខៀវខ្ចី ខ្លះចេញផ្កាចម្រុះពណ៌នាំឱ្យទេសភាពនៅបរិវេណប្រាសាទអង្គរវត្ត ផ្នែកមួយនៃរមណីយដ្ឋានអង្គរកាន់តែស្រស់បំព្រងទ្វេឡើងមួយកម្រិតទៀត។

ចំណែកឯការយកចិត្តទុកដាក់ទៅលើសោភ័ណភាព ក៏ដូចជាការរៀបចំសម្អាតបរិស្ថានជាប្រចាំ គឺជាចំណុចមួយដ៏សំខាន់ដែរ ធ្វើយ៉ាងណាឱ្យតំបន់រមណីយដ្ឋានអង្គរមានភាពស្រស់ស្អាតដើម្បីជាការទាក់ទាញភ្ញៀវទេសចរ។

# អាជ្ញាធរជាតិអប្សរារៀបចំកិច្ចប្រជុំស្តីពី ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងសិទ្ធអំពីការបម្រែបម្រួលអាកាសធាតុ និងការបន្សាំនៅតំបន់បេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣នេះ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា សហការជាមួយស្ថាប័នមូលនិធិប្រាសាទពិភពលោក ( World Monument Fund-WMF ) បានរៀបចំកិច្ចប្រជុំមួយស្តីពី ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងសិទ្ធអំពីការបម្រែបម្រួលអាកាសធាតុ និងការបន្សាំនៅតំបន់បេតិកភណ្ឌ ដោយមានការចូលរួមពី **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយករងតំណាង**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោកស្រី Ginevra Boatto តំណាងអង្គការ World Monuments Fund ( WMF ) ប្រចាំតំបន់អាស៊ីអាគ្នេយ៍ លោកប្រធាន អនុប្រធាននាយកដ្ឋាន តំណាងស្ថាប័នអង្គការដៃគូ តំណាងអង្គភាពនគរបាលបេតិកភណ្ឌ តំណាងមន្ទីរបរិស្ថានខេត្ត អាជ្ញាធរក្នុងតំបន់ ព្រមទាំងមន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាជាច្រើនរូបទៀត។

កិច្ចប្រជុំនេះផ្តោតសំខាន់ទៅលើ ការចូលរួមចំណែកផ្សព្វផ្សាយ ការចែករំលែកចំណេះដឹង ការពិភាក្សារួមគ្នាអំពី ការបម្រែបម្រួលអាកាសធាតុដែលអាចមានផលប៉ះពាល់ជាមួយនិងបេតិកភណ្ឌ។

សកម្មភាពដាំដើមឈើឡើងវិញនៅតំបន់រមណីយដ្ឋានអង្គរ បានធ្វើឡើងជារៀងរាល់ឆ្នាំរហូតមកដល់បច្ចុប្បន្នសម្រេចបានប្រមាណ២លានដើម បន្ថែមពីនេះការចែកជូនកូនឈើជូនសាធារណជនទូទៅយកទៅដាំដុះបន្ត។ ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រពីបុរាណ ជាការងារមួយដ៏ធំរបស់អាជ្ញាធរជាតិអប្សរា ដោយបានស្តារប្រឡាយបុរាណ ត្រពាំងបុរាណ ការស្តារនិងបញ្ចូលទឹកក្នុងកសិន្ធុធំៗនៅក្នុងតំបន់អង្គរ។ ការបន្តសកម្មភាពជួសជុល និងបញ្ចូលទឹកនៅតាមបារាយណ៍បុរាណជាច្រើនទៀតនៅជុំវិញរមណីយដ្ឋានអង្គរ និងបន្តសហការជាមួយស្ថាប័នដៃគូនានា តាមដានអំពីគុណភាពខ្យល់ នៅតំបន់រមណីយដ្ឋានអង្គរជាដើម៕

# អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាស្តីពី «ការរៀបចំ និងការកែលម្អសារមន្ទីរឱ្យក្លាយជាកន្លែងទាក់ទាញគួរឱ្យចង់ទស្សនា»

ផ្សាយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌នៃអាជ្ញាជាតិអប្សរា រៀបចំសិក្ខាសាលាស្តីពី «ការរៀបចំ និងការកែលម្អសារមន្ទីរឱ្យក្លាយជាកន្លែងទាក់ទាញគួរឱ្យចង់ទស្សនា» រយៈពេល៤ខែ ចាប់ពីខែកក្កដារហូតដល់ខែតុលា ឆ្នាំ២០២៣ ជូនដល់មន្ត្រីមកពីស្ថាប័នពាក់ព័ន្ធស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន២៥នាក់ ក្នុងនោះរួមមានមន្ត្រី និងបុគ្គលិកអាជ្ញាធរជាតិអប្សរា ចំនួន២១នាក់ មន្ត្រីសារមន្ទីរ Eco-Global អាជ្ញាធរជាតិព្រះវិហារ ចំនួន០១នាក់ មន្ត្រីអាជ្ញាធរជាតិសំបូរព្រៃគុក ចំនួន០១នាក់ មន្ត្រីសារមន្ទីរជាតិកម្ពុជា ចំនួន០១នាក់ និងមន្ត្រីសារមន្ទីរប្រល័យពូជសាស្ត្រទួលស្លែង ចំនួន០១នាក់។

**លោកជំទាវ ចៅ ស៊ុនកិរិយា** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញចូលរួមបើកសិក្ខាសាលា មានប្រសាសន៍ថាសិក្ខាសាលានេះពិតជាមានសារសំខាន់ណាស់ក្នុងការរៀបចំនិងការកែលម្អសារមន្ទីរឱ្យក្លាយជាកន្លែងទាក់ទាញគួរឱ្យចង់ទស្សនា គឺត្រូវទាមទារឱ្យមានភាពជំនាញ ក៏ដូចជា ចំណេះធ្វើច្បាស់លាស់ ហើយអ្វីដែលសំខាន់នោះ គឺអ្នកដែលអនុវត្តផ្ទាល់។ ដូច្នេះហើយ គោលបំណងថ្ងៃនេះដែលនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌បណ្តុះបណ្តាលជំនាញបន្ថែមដើម្បីឱ្យចំណេះជំនាញទាំងអស់នោះត្រូវបានបន្តត្រូវបានចែករំលែកជាគុណតម្លៃសម្រាប់ខ្លួនយើងដែលជាអ្នកអនុវត្ត យើងមានសេចក្តីរីករាយ មានមោទកភាពចំពោះខ្លួនយើង និងស្ថាប័ន។

លោក ប៉ែន ចំរ៉ុង អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ មានប្រសាសន៍ថា វគ្គសិក្ខាសាលានេះ ជាជំនួយក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយអង្គការយូណេស្កូ និងតាមរយៈគណៈកម្មការជាតិយូណេស្កូកម្ពុជា។ ក្នុងគោលបំណងសិក្ខាសាលា ដើម្បីពង្រឹង និងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីដែលបម្រើការនៅសារមន្ទីរក្នុងការរៀបចំធ្វើយ៉ាងណាបន្ថែមក្នុងការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញដើម្បីទាក់ទាញភ្ញៀវទេសចរមកទស្សនាសារមន្ទីរ។

លោកបន្តទៀតថា សិក្ខាសាលានេះបានផ្តោតទៅលើខ្លឹមសារចំណុចរួមមាន ការណែនាំអំពីតួនាទី គោលបំណង និងការគ្រប់គ្រងសារមន្ទីរ វិធីសាស្ត្រ និងបច្ចេកទេសអំពីការរៀបចំ និងការតាំងពិព័រណ៌សារមន្ទីរ វិធីសាស្ត្រ និងបច្ចេកទេសនៃគោលនយោបាយគ្រប់គ្រងសមុច្ច័យ ការធ្វើទីផ្សារ ការផ្សព្វផ្សាយ និងការរចនាក្រាហ្វិកសម្រាប់ការផ្សាយពាណិជ្ជកម្ម៕

# ក្រុមអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ បានរកឃើញថា ឡដុតកុលាលភាជន៍នៅក្នុងតំបន់អង្គរ បានចាប់ដំណើរការតាំងពីពាក់កណ្តាលសតវត្សរ៍ទី១២មក

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា ដែលសហការជាមួយសាកលវិទ្យាល័យហាវ៉ៃ និង Flinders University ដោយប្រើឧបករណ៍វាស់ស្ទង់រករចនាសម្ពន្ធឡដុតកុលាលភាជន៍នៅខ្លោងទ្វារដីឆ្នាំងនៃអង្គរធំ បានរកឃើញថា មានឡដុតកុលាលភាជន៍ជាច្រើននៅជ្រុងពាយព្យនាភូមិនគរក្រៅ សង្កាត់គោកចក នៃក្រុងសៀមរាប ខេត្តសៀមរាប។

បណ្តុំក្រុមឡដុតកុលាលភាន៍ទាំងនោះ ស្ថិតនៅលើទួលធំវែងមួយកន្លែង ដែលលាតសន្ធឹងពីកើតទៅលិចប្រវែង២៣០ម៉ែត្រនិងទទឹងមានប្រវែង៨៤ម៉ែត្រ កម្ពស់ប្រហែល២,៧០ម៉ែត្រ។ ទួលនេះ សន្ធឹងស្របគ្នានិងកំពែងនៃកសិន្ធុទឹកភាគខាងជើងផ្នែកខាងលិចរបស់ខ្លោងទ្វារដីឆ្នាំងនៃអង្គរធំ មានចម្ងាយ១២៣ម៉ែត្រពីខ្លោងទ្វារដីឆ្នាំង។

លោក ទិន ទីណា អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ មានប្រសាសន៍ថា ក្រោយពីបានចុះពិនិត្យផ្ទៀងផ្ទាត់ និងស្រង់ទិន្នន័យបុរាណវិទ្យា ដោយក្រុមអ្នកស្រាវជ្រាវនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា បានរកឃើញថាមានទួលឡដុតកុលាលភាន៍មានចំនួន២៥ដែលពុំទាន់មានការធ្វើកំណាយស្រាវជ្រាវ ដើម្បីបញ្ជាក់ថា ទីនេះជាអ្វីពិតប្រាកដនៅឡើយទេ គ្រាន់តែអ្នកស្រាវជ្រាវមួយចំនួនបានរើសយកអំបែងភាជន៍យកទៅសិក្សាតែប៉ុណ្ណោះ។ ទើបតែកាលពីឆ្នាំ២០២០ និងឆ្នាំ២០២២ ក្រុមអ្នកស្រាវជ្រាវនៃអាជ្ញាធរជាតិអប្សរា បានធ្វើកំណាយលើទួលឡនោះចំនួនពីរ ដើម្បីប្រមូលទិន្នន័យដែលអាចឱ្យអ្នកជំនាញបញ្ជាក់ថា ទីតាំងនេះជាអ្វីឱ្យពិតប្រាកដ ?។

យោងតាមលទ្ធផល ដែលទទួលបានពីការធ្វើកំណាយទាំងពីរលើកកន្លងមក បានបញ្ជាក់ថា ទីតាំងនេះជាឡដុតកុលាលភាជន៍នៅក្នុងតំបន់អង្គរ ដែលចាប់ដំណើរការតាំងពីពាក់កណ្តាលសតវត្សរ៍ទី១២ និងឈប់ដំណើរការនៅដើមសតវត្សរ៍ទី១៥នៃគ្រិស្តសករាជ។ ក្រុមអ្នកស្រាវជ្រាវមានគោលបំណងពង្រីកការស្រាវជ្រាវពីបណ្តុំឡដុតកុលាលភាជន៍នេះឱ្យបានវែងឆ្ងាយទៅទៀត ហើយថ្មីៗនេះ អ្នកស្រាវជ្រាវនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលនិងផ្សព្វផ្សាយ អាជ្ញាធរជាតិអប្សរា បានសហការជាមួយសាកលវិទ្យាល័យហាវ៉ៃ និង **Flinders University** បានប្រើឧបករណ៍វិទ្យាសាស្ត្រទំនើបដើម្បីវាស់ស្ទង់រករចនាសម្ពន្ធឡដុតកុលាលភាជន៍នៅតំបន់ទ្វារជីផ្នាំងនៃអង្គរធំនេះ ដោយប្រើឧបករណ៍ **Magnetometer** ដើម្បីស្វែងរកសញ្ញាណម៉ាញ៉េទិកនៃរចនាសម្ពន្ធឡ។

ក្រុមអ្នកស្រាវជ្រាវបានចាត់ទុកថា ទិន្នន័យដែលទទួលបានពីការវាស់ស្ទង់នេះ គឺមានសារសំខាន់សម្រាប់អ្នកជំនាញយកធ្វើជាមូលដ្ឋានក្នុងការធ្វើកំណាយស្រាវជ្រាវឡដុតកុលាលភាជន៍នៅតំបន់នេះតទៅថ្ងៃមុខទៀត៕

# អាជ្ញាធរជាតិអប្សរា សហការជាមួយសាលាគណរាជធានីភ្នំពេញ និងគ្រឹះស្ថានសិក្សានានា បន្តដាំស្មៅ និងកូនឈើនៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៣ ដើម្បីចូលរួមពិធី «យុទ្ធនាការដាំដើមឈើ និងស្មៅ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក» អាជ្ញាធរជាតិអប្សរា បានសហការជាមួយសាលាគណរាជធានីភ្នំពេញ និងគ្រឹះស្ថានសិក្សានានាដូចជា ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន(ព.ស.ហ.ស) សាកលវិទ្យាល័យឯកទេសនៃកម្ពុជា(CUS) វិទ្យាស្ថានខ្មែរជំនាន់ថ្មី វិទ្យាស្ថានអាស៊ីកម្ពុជា និងវិទ្យាល័យបាយ័ន បានដាំកូនឈើចម្រុះចំនួន១,៥៥០ដើម និងស្មៅចំនួន១,០០០ម៉ែត្រការ៉េ នៅបរិវេណខាងជើងធៀងខាងលិចប្រាសាទអង្គរវត្ត(អតីតផ្សារយាងធំ)។

ពិធីនេះមានការនិមន្តនិងចូលរួមពីព្រះសង្ឃ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មន្ត្រី បុគ្គលិក និងពលករ ចំនួន ២៥០អង្គ/នាក់៕

# សត្វសំពោចក្រអូបមួយគូ ត្រូវបានដោះលែងបន្ថែមក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ គម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា រដ្ឋបាលព្រៃឈើភ្នំពេញ និងអង្គការ Wildlife Alliance បានដឹកជញ្ជូនសត្វសំពោចក្រអូប( Common palm civets ) មួយគូ( ញី១ និងឈ្មោល១ ) ពីមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ យកមកផ្សាំងក្នុងទ្រុង ដែលក្រុមការងារគម្រោងនឹង ដោះលែងចូលទៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរនៅពេលខាងមុខ។

កន្លងមកគម្រោងទទួលបានជោគជ័យក្នុងការដោះលែងសត្វព្រៃជាច្រើនប្រភេទចូលក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ មានដូចជា សត្វទោចមកុដ ( Pileated gibbon ) ចំនួន១៥ក្បាល ( កើតកូនបានចំនួន៧ក្បាល ) សត្វឈ្លូស( Red muntjac ) ចំនួន៦ក្បាល សត្វស្វាព្រាម ( Silvered langurs ) ចំនួន១២ក្បាល សត្វសំពោចក្រអូប( Common palmcivets ) ចំនួន៥ក្បាល សត្វភេខ្លួនរលោង( Smooth-coated otter ) ចំនួន៨ក្បាល( កើតកូនបានចំនួន៥ក្បាល ) សត្វឆ្មារដាវ ( Leopard Cat ) ចំនួន២ក្បាល កេងកងតូច( Oriental Pied Hornbill ) ចំនួន៧ក្បាល កេងកងធំ( Great Hornbill ) ចំនួន៦ក្បាល ព្រាំង( Wreathed Hornbill ) ចំនួន៧ក្បាល សត្វក្ងោក( Peafowl ) ចំនួន៩ក្បាល សត្វអន្សង( Common Water Monitor ) ចំនួន១ក្បាល និងសត្វផ្សេងៗមួយចំនួនទៀត ដែលមកដល់ឥឡូវសត្វទាំងអស់នេះនៅតែមានវត្តមាននៅទីនោះនៅឡើយ ក្រោមការយកចិត្តទុកដាក់តាមដាន និងថែទាំជាប្រចាំពីក្រុមការងារ។

ដើម្បីឲ្យសត្វព្រៃទាំងអស់បន្តវត្តមាននៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរយើង និងបង្កើនចំនួនបន្ថែមទៀត អាជ្ញាធរជាតិអប្សរា និងគម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ សូមអំពាវនាវជូនសាធារណជន ភ្ញៀវជាតិ អន្តរជាតិ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ចូលរួមថែរក្សាសត្វព្រៃទាំងនោះទាំងអស់គ្នា ជៀសវាងពេលប្រទះឃើញមានបំណងមិនល្អ បញ្ឈប់ការដាក់អន្ទាក់សត្វគ្រប់ប្រភេទ និងមេត្តាកុំផ្ដល់ចំណីឲ្យសត្វទាំងនោះ។

## លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន១៥០នាក់ធ្វើទស្សនកិច្ចសិក្សា ការធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យា នៅបរិវេណវត្តកោះកែវជុលាមុនីព្រះធម្មចេតិយ ក្នុងក្រុងសៀមរាប

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣នេះ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សសរុបចំនួន១៥០នាក់ មកពីវិទ្យាល័យចំនួន៣ ក្នុងខេត្តសៀមរាប មាន៖ វិទ្យាល័យអង្គរ វិទ្យាល័យ ១០មករា និងវិទ្យាល័យ ហ៊ុន សែន ប្រាសាទបាគង បានមកធ្វើទស្សនកិច្ចសិក្សា ការធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យា នៅបរិវេណវត្តកោះកែវជុលាមុនីព្រះធម្មចេតិយ (ហៅវត្តចេតិយ) ស្ថិតក្នុងសង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ក្រោមការជួយសម្របសម្រួលពីអាជ្ញាធរជាតិអប្សរា។

លោក អ៊ឹម សុខរិទ្ធី បុរាណវិទូ និងជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល ផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា បានប្រសាសន៍ក្នុងឱកាសនោះថា ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា ជាមួយដៃគូអន្តរជាតិ មន្ទីរអប់រំយុវជន និងកីឡា បានបង្កើតឱ្យមានកម្មវិធីអប់រំបេតិកភណ្ឌ ជូនដល់សិស្សានុសិស្សនៅតាមសាលាបឋមសិក្សា និងវិទ្យាល័យមួយចំនួន ដែលមានទីតាំងក្នុងតំបន់បេតិកភណ្ឌ ចាប់តាំងពីអំឡុងឆ្នាំ២០០៧មក ក្នុងនោះមាន ខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ កំពង់ធំ និងខេត្តសៀមរាប។ លោកបន្តថា កម្មវិធីអប់រំបេតិកភណ្ឌ សម្រាប់ខេត្តសៀមរាប ត្រូវជ្រើសរើសតំបន់ពីរផ្សេងគ្នា មាន៖ តំបន់ប្រាសាទបាគង និងសង្កាត់ក្របីរៀល ក្នុងគោលបំណងចង់ឱ្យសិស្សានុសិស្ស ដែលជាយុវជនជំនាន់ក្រោយ បានស្គាល់អំពីប្រវត្តិសាស្ត្រ និងសហគមន៍ដែលខ្លួនរស់នៅក្នុងតំបន់បេតិភណ្ឌ។

សូមបញ្ជាក់ថា ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យហាវ៉ៃ នៃសហរដ្ឋអាមេរិក បានធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យាមួយ នៅបរិវេណវត្តកោះកែវជុលាមុនីព្រះធម្មចេតិយ (ហៅវត្តចេតិយ )មានរយៈពេល ៣សប្តាហ៍ ដោយចាប់ផ្តើមពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ គ្រោងនិងបញ្ចប់នៅចុងខែកក្កដា ឆ្នាំ២០២៣ខាងមុខ ដើម្បីសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រសម័យក្រោយអង្គរ ដោយការធ្វើកំណាយផ្តោតសំខាន់ អំពីទួលមនុស្សរស់នៅបុរាណ ការរស់នៅរបស់មនុស្សនៅលើទួល និងសង្គម និងសកម្មភាពសេដ្ឋកិច្ចនានា ក្នុងតំបន់៕

# កំណាយស្រាវជ្រាវក្នុងកំពែងប្រាសាទអង្គរវត្ត ទិសនិរតី សិក្សាទីតាំងមនុស្សរស់នៅសម័យអង្គរ និងការផ្លាស់ប្តូរសាសនាពីព្រហ្មញ្ញមកជាពុទ្ធសាសនាថេរវាទ

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា សាកលវិទ្យាល័យហាវ៉ៃ រួមនិងសាកលវិទ្យាល័យកាលីហ្វ័រញ៉ានៃសហរដ្ឋអាមេរិក បានសហការធ្វើកំណាយបុរាណវិទ្យាស្រាវជ្រាវរួមគ្នាមួយនៅទីទួលវិហារបុរាណស្ថិតនៅទិសនិរតីមិនឆ្ងាយប៉ុន្មានពីប្រាង្គប្រាសាទអង្គរវត្ត។ ការស្រាវជ្រាវនេះ ធ្វើឡើងដើម្បីសិក្សាអំពីទួលមនុស្សរស់នៅក្នុងទីក្រុងអង្គរផង ព្រមទាំងចង់ដឹងថា តើមានការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងសហគមន៍ទីក្រុងនៅពេលមានការផ្លាស់ប្តូរសាសនា និងការប្តូរទីក្រុងពីតំបន់អង្គរទៅភាគខាងត្បូងផង។

លោកបណ្ឌិត ហេង ពិភាល់ បុរាណវិទូនៃសាកលវទ្យល័យហាវ៉ៃ និងជាប្រធានគម្រោងស្រាវជ្រាវបានឱ្យដឹងថា ការធ្វើកំណាយស្រាវជ្រាវពេលនេះ គឺធ្វើឡើងនៅលើរចនាសម្ពន្ធនៃខឿនព្រះវិហារបុរាណ។ រចនាបថសន្លឹកសីមាអាចឱ្យយើងកំណត់អាយុកាលទួលវិហារនេះទៅអំឡុងសតវត្សរ៍ទី១៤ ដល់ទី១៦ ដូច្នេះ ព្រះវិហារពុទ្ធសាសនាថេរវាទបុរាណនេះ គេកសាងនៅក្នុងបរិវេណប្រាសាទដែលឧទ្ទិសទៅដល់អាទិទេពធំនៃព្រហ្មញ្ញសានា គឺព្រះវិស្ណុ ឬព្រះនារាយណ៍។ បណ្ឌិតរូបនេះបញ្ជាក់ទៀតថា តាមការស្រាវជ្រាវពីមុនបង្ហាញថា នៅក្នុងបរិវេណប្រាសាទអង្គរវត្ត គឺជាកូនក្រុងមួយរបស់រាជធានីអង្គរ ដូច្នេះហើយទើបខ្មែរយើងអ្នកសៀមរាបហៅថា «អង្គរតូច»។ កូនក្រុងនេះ មានប្រព័ន្ធទួល ស្រះ និងផ្លូវខ្វាត់ខ្វែងជាក្រឡាចត្រង្គនៅក្នុងបរិវេណប្រាសាទអង្គរវត្ត។ ប្រសិនជាមើលតាមស្នាមក្រឡាចត្រង្គរបស់ក្រុងនេះ យើងឃើញថា ទួលព្រះវិហារធ្វើនៅលើទួលដែលធ្លាប់ជាទួលផ្ទះមានមនុស្សរស់នៅតាំងពីសតវត្សរ៍ទី១២មកម្ល៉េះ។ ដូច្នេះហើយ អ្នកស្រាវជ្រាវចម្រុះស្ថាប័នចង់ដឹងថា តើទីតាំងមនុស្សរស់នៅកន្លែងនេះ អាចបន្សល់នូវភស្តុតាងអ្វីខ្លះទាក់ទងជាមួយនិងការផ្លាស់ប្តូរសាសនាពីព្រហ្មញ្ញ និងពុទ្ធសាសនាមហាយានទៅជាពុទ្ធសាសនាថេរវាទនៅចុងសម័យអង្គរ ដែលស្រុកខ្មែរកំពុងតែប្រតិបត្តិរហូតមកដល់សព្វថ្ងៃនេះ?

គេដឹងថា ជាយូរមកហើយអ្នកភូមិ អ្នកក្រុងអង្គរ ធ្លាប់គោរពបូជាលទ្ធិព្រហ្មញ្ញសាសនា ដូច្នេះ សំណួរពីក្រុមអ្នកស្រាវជ្រាវគឺថា តើខឿនព្រះវិហារព្រះពុទ្ធសាសនានៅក្នុងបរិវេណប្រាសាទអង្គរវត្តនេះ គេធ្វើឡើងដើម្បីអ្វី? សម្រាប់អ្នកណា? ឬមួយក៏នៅអំឡុងសតវត្សរ៍ទី១៣-១៤ ទីក្រុងអង្គរបានដូរពីការគោរពព្រហ្មញ្ញសាសនាមកកាន់ពុទ្ធសាសនាថេរវាទនៅក្នុងពេលដែលទីក្រុងអង្គរនៅមានប្រជាជនរស់នៅច្រើននៅឡើយនោះ? ឬព្រះវិហារនេះគេកសាងនៅសម័យក្រោយនាសតវត្សរ៍ទី១៦ នៅពេលដែលព្រះអង្គច័ន្ទយាងមកក្រុងអង្គរវិញ?

# អាជ្ញាធរជាតិអប្សរា រៀបចំទិសដៅទស្សនាសម្រាប់ភ្ញៀវទេសចរនៅប្រាសាទតាកែវ

ផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា បានរៀបចំទិសដៅសទស្សនានៅប្រាសាទតាកែវ ដើម្បីឱ្យការចរាចររបស់ភ្ញៀវទេសចរជាតិ អន្តរជាតិ ធានាដល់ការលើកតម្លៃបេតិកភណ្ឌ ការថែរក្សាសណ្តាប់ធ្នាប់ភ្ញៀវទេសចរទទួលបានបទពិសោធន៍ល្អៗ និងទស្សនីយភាពគ្រប់ជ្រុងជ្រោយ និងបញ្ចៀសរាល់ការកកស្ទះជូនភ្ញៀវទេសចរពេលចូលទស្សនាប្រាសាទតាកែវ។



កញ្ញា ចំរើន វិនា មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ មានប្រសាសន៍ថា ក្រុមការងារបានរៀបចំទិសដៅវង់ទស្សនានៅប្រាសាទតាកែវ ដោយកែលម្អបរិស្ថាននៅជុំវិញប្រាសាទ ដើម្បីលើកកម្ពស់សោភ័ណភាពជុំវិញប្រាសាទ ដូចជា ការកាត់លះមែកឈើខ្លះៗរៀបចំជាផ្លូវថ្មើជើងជុំវិញប្រាសាទ ដាក់ស្លាកសញ្ញាបង្ហាញទិស រៀបចំផ្ទាំងព័ត៌មានស្តីពីប្រវត្តិនៃប្រាសាទ ដើម្បីឱ្យអ្នកទេសចរអាចស្វែងយល់ដោយខ្លួនឯងបាន។

កញ្ញា វិនា បន្តទៀតថា ការរៀបចំវង់ទស្សនានេះ ផ្តល់អត្ថប្រយោជន៍ដល់ភ្ញៀវទេសចរបានច្រើន ដោយខ្សែទស្សនាក្នុងប្រាសាទនឹងនាំភ្ញៀវទេសចរឱ្យដើរទស្សនាបានគ្រប់ជ្រុងនៃប្រាសាទនេះ ព្រមទាំងអាចផ្តិតយករូបភាពរូមស្អាតៗនៃប្រាសាទផងដែរ។ មុននឹងមកដល់ប្រាសាទភ្ញៀវទេសចរដើរក្រោមម្លប់ឈើយ៉ាងត្រជាក់ ដែលជាលក្ខណៈពិសេសមួយនៅប្រាសាទតាកែវនេះ។ កញ្ញាបន្តថា សំណើខ្សែទស្សនាខាងលើត្រូវបានដាក់ជូនអ្នកជំនាញការអាយស៊ីស៊ី-អង្គរ និងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាពិនិត្យ និងវាយតម្លៃអនុម័តរួចរាល់ហើយដែរ មុននឹងឈានទៅដាក់ដំណើរការ។

ជាមួយគ្នានេះដែរ អាជ្ញាធរជាតិអប្សរាសូមអំពាវនាវដល់ភ្ញៀវទេសចរជាតិ អន្តរជាតិទាំងអស់ ដែលចូលមកទស្សនាប្រាង្គប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ សូមមេត្តាគោរពនូវក្រមប្រតិបត្តអង្គរ និងស្លាកសញ្ញាផ្សេងៗនៅតាមប្រាសាទ ដើម្បីធានាបាននូវសុខសុវត្ថិភាព សេចក្តីថ្លៃថ្នូ ព្រមទាំងលើកតម្លៃបេតិកភណ្ឌអង្គរផង៕

# ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ កំពុងរៀបចំវង់ទស្សនានៅក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣

ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា កំពុងរៀបចំវង់ទស្សនាបន្ថែមទៀត នៅក្រុងអង្គរធំ ក្នុងន័យសម្រួលការទស្សនារបស់ភ្ញៀវទេសចរ ឱ្យកាន់តែល្អប្រសើរ។

កញ្ញា ឡាយ ស្រីពេញ បុគ្គលិកនៃនាយកដ្ឋានអភិវឌ្ឍន៍ ទេសចរណ៍ និងវប្បធម៌ និងជាក្រុមការងាររៀបចំវង់ ទស្សនា បានឱ្យដឹងថា នេះជាខ្សែទស្សនាទី៣ ក្នុងក្រុង អង្គរធំ ដែលចាប់ផ្តើមពីទីសក្ការៈព្រះអង្គងោក និងបញ្ចប់ នៅប្រាសាទទេពប្រណម្យ។ កញ្ញាពន្យល់ថា នេះជាខ្សែ ទស្សនាភ្ជាប់ពីប្រាសាទបាយ័ន្តដែលភ្ញៀវទេសចរអាចចូល ទស្សនាចាប់ពីព្រះអង្គងោក រួចបន្តតាមផ្លូវថ្មបាយក្រៀម ឆ្ពោះចូលតាមច្រកខាងមុខប្រាសាទបាភួន។ បន្ទាប់មក ទេសចរអាចបន្តទស្សនាក្នុងព្រះបរមរាជវាំង នៃប្រាសាទ ភិមានអាកាស ទស្សនាស្រះស្រីស្រះប្រុស ព្រះលានជល់ដំរី ស្តេចគំលង់ ប្រាសាទបាលិលេយ្យ និងបញ្ចប់ការទស្សនានៅ ប្រាសាទទេពប្រណម្យ។

តាមការបញ្ជាក់ពីកញ្ញា ឡាយ ស្រីពេញ កន្លងមក ក្រុមការងាររបស់ខ្លួនក៏បានរៀបចំវង់ទស្សនារួចហើយ នៅក្នុងប្រាសាទបាយ័ន្ត ដែលបង្កើតជា៣ជម្រើសដល់ ទេសចរ គឺមានខ្សែទស្សនាវែង ខ្សែទស្សនាមធ្យម និងខ្សែ ទស្សនាខ្លី ដែលចំណុចចាប់ផ្តើមនៅច្រកខាងកើត និងបញ្ចប់ នៅច្រកខាងជើង។ ចំណែកវង់ឬខ្សែទស្សនាទី២ នៅ កំពែងក្រុងអង្គរធំ ដែលចាប់ផ្តើមពីខ្លោងទ្វារទន្លេអុំ បន្តទៅ រន្ធត្រដេវបឹងធំ ប្រាសាទជ្រុងនិរតី ខ្លោងទ្វារតាការ និងបញ្ចប់ ការទស្សនានៅប្រាសាទតុបខាងលិច។

ក្រុមការងាររៀបចំខ្សែទស្សនាតាមប្រាសាទ កញ្ញា ឡាយ ស្រីពេញ បញ្ជាក់ថា ការរៀបចំនេះមានសារសំខាន់ណាស់ ក្នុងន័យ លើកតម្លៃប្រាសាទ ពន្យារពេលការទស្សនារបស់ភ្ញៀវ ការគ្រប់គ្រងលំហូរភ្ញៀវកុំឱ្យមានការកកស្ទះ សុវត្ថិភាព ទេសចរនិងប្រាសាទ និងផ្តល់បទពិសោធន៍ល្អៗដល់ទេសចរ ក៏ដូចជាការបកស្រាយប្រវត្តិប្រាសាទបានទូលំទូលាយ ជាដើម។ ដើម្បីជោគជ័យខ្សែទស្សនាខាងលើនេះ ក្រុមការងារ អាជ្ញាធរជាតិអប្សរា ស្នើឱ្យទេសចរទាំងអស់ចូលទស្សនា ប្រាសាទតាមស្លាកសញ្ញាដែលបានរៀបចំ គោរពតាម ការណែនាំរបស់ភ្នាក់ងារទេសចរណ៍ និងគោរពតាមក្រម ប្រតិបត្តិអង្គរជាដើម៕

# នៅពាក់កណ្តាលឆ្នាំ២០២៤ ខ្មែរនឹងមានអ្នកជំនាញផ្នែកអភិរក្សថ្មប្រាសាទបុរាណកើនចំនួនឡើងថែមទៀត

ផ្សាយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញមកពីស្ថាប័នGIZ នៃប្រទេសអាល្លឺមង់ កំពុងខិតខំយ៉ាងខ្លាំង ក្នុងការជួយបណ្តុះបណ្តាលជំនាញដល់សិក្ខាកាមខ្មែរចំនួន២០រូប ដើម្បីឱ្យក្លាយទៅជាអ្នកជំនាញផ្នែកអភិរក្សថ្មប្រាសាទបុរាណនៅក្នុងរមណីយដ្ឋានអង្គរ ខេត្តសៀមរាប នៅពេលអនាគតខាងមុខ។

គ្រូបង្រៀនជនជាតិអាល្លឺម៉ង់ កញ្ញា **Helen Jacobsen** មានប្រសាសន៍ក្នុងពេលដែលនាំសិក្ខាកាមចុះអនុវត្តន៍ផ្ទាល់នៅការដ្ឋានថា កញ្ញាកំពុងប្រឹងប្រែងបង្រៀនកូនខ្មែរឱ្យចេះលាងសម្អាតថ្មប្រាសាទបុរាណ ចេះបន្សាបជាតិអំបិលចេញពីថ្ម ព្រមទាំងចេះជំនាញពង្រឹងថ្មប្រាសាទបុរាណឱ្យរឹងមាំឡើងវិញផង។

កញ្ញា **Helen Jacobsen** មានប្រសាសន៍ទៀតថា ជំនាញអភិរក្សថ្មប្រាសាទបុរាណនេះ មានដូចជា ការលាងសម្អាតថ្មដោយប្រើទឹក និងការលាងដោយប្រើសារជាតិគីមីជាដើម។ សិក្ខាកាមខ្មែរចំនួន២០រូប ដែលជ្រើសរើសចេញពីបុគ្គលិក និងមន្ត្រីនៃអាជ្ញាធរជាតិអប្សរាមកពីតាមបណ្តាផ្នែកនានានោះ កំពុងប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់លើជំនាញអភិរក្សថ្មនេះ រយៈពេលជាង១ឆ្នាំមកហើយ។ ស្ថាប័ន **GIZ** អាល្លឺម៉ង់ឱ្យដឹងថា វគ្គបណ្តុះបណ្តាលជំនាញអភិរក្សថ្មជំនាន់ទី២នេះ មានកម្មវិធីដែលត្រូវសិក្សាទាំងអស់ចំនួន១៣។ បច្ចុប្បន្ននេះ ក្រុមសិក្ខាកាមបានសិក្សាដល់កម្មវិធីទី៧ហើយ។ ស្ថាប័ន **GIZ** អាល្លឺម៉ង់រំពឹងថា នៅអំឡុងពាក់កណ្តាលឆ្នាំ២០២៤ខាងមុខ វគ្គបណ្តុះបណ្តាលជំនាញអភិរក្សថ្មជំនាន់ទី២អាចនឹងបញ្ចប់ ហើយនៅពេលអនាគតខ្មែរនឹងមានអ្នកជំនាញផ្នែកអភិរក្សថ្ម ប្រាសាទបុរាណបានកើនឡើងមួយចំនួនថែមទៀត។

មន្ត្រីបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា លោក រីក រ៉េត ឱ្យដឹងថា វគ្គបណ្តុះបណ្តាលជំនាញផ្នែកអភិរក្សថ្មប្រាសាទបុរាណ ដែលមានរយៈពេលជាង២ឆ្នាំនេះ គឺជាកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន GIZ អាល្លឺម៉ង់ជាមួយនិងនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា។ លោក រីក រ៉េត យល់ថា វគ្គបណ្តុះបណ្តាលនេះ មានសារសំខាន់យ៉ាងខ្លាំង អាចផ្តល់អត្ថប្រយោជន៍ដល់សិក្ខាកាមទាំងឡាយឱ្យយកចំណេះដឹងទាំងនេះទៅប្រើប្រាស់លើការងារថែរក្សា និងការពារប្រាសាទបុរាណនៅតាមកន្លែងផ្សេងៗសម្រាប់ពេលអនាគត ហើយពួកគេក៏អាចផ្សព្វផ្សាយជំនាញនេះទៅកាន់កូនខ្មែរជំនាន់ក្រោយឱ្យចេះដឹងកាន់តែទូលំទូលាយផងដែរ។

សូមបញ្ជាក់ថា កាលពីឆ្នាំ២០១៣ ស្ថាប័ន GIZ អាល្លឺម៉ង់ធ្លាប់បានសហការជាមួយអាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលជំនាញអភិរក្សថ្ម ប្រាសាទបុរាណនេះម្តងមកហើយ ដោយសិក្ខាកាមជំនាន់ទី១នោះ បានក្លាយទៅជាក្រុមអ្នកជំនាញខ្មែរ និងកំពុងយកជំនាញទាំងនេះទៅអនុវត្តន៍ការងារនៅតាមប្រាសាទបុរាណនានាយ៉ាងត្រឹមត្រូវ៕

# វិទ្យាស្ថានសាលាបារាំងចុងបូព៌ា (EFEO) ប្រគល់វត្ថុបុរាណជូនអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ សាលាបារាំងចុងបូព៌ា (EFEO) ដែលជាដៃគូកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីបំពេញការងារអភិរក្ស និងស្រាវជ្រាវនៅរមណីយដ្ឋានអង្គរ បានប្រគល់វត្ថុបុរាណចំនួន៣១កេស បដិមាព្រះពុទ្ធចំនួន០១ និងបំណែកសន្លឹកសីមាចំនួន០១ ជូនអាជ្ញាធរជាតិអប្សរា ដើម្បីរក្សាទុកបន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងរៀបចំបញ្ជីសារពើភណ្ឌរួចរាល់។

លោក ទិន ទីណា ជាអនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ បានឱ្យដឹងថា វត្ថុបុរាណទាំងអស់ដែលវិទ្យាស្ថានសាលាបារាំងចុងបូព៌ា (EFEO) ប្រគល់មកអាជ្ញាធរជាតិអប្សរា បានរកឃើញដោយការធ្វើកំណាយនៅតាមការដ្ឋានស្រាវជ្រាវមួយចំនួននៅក្នុងរមណីយដ្ឋានអង្គរ ដូចជា គោកតាសៀម បឹងជូនប៉ា ប្រាសាទអ៊ុងម៉ុង ប្រាសាទបាភួន និងប្រាសាទព្រៃមន្ទីរ។

លោកបានបញ្ជាក់ទៀតថា វត្ថុទាំងនេះរួមមាន ទី១ កុលាលភាជន៍មកពីប្រាសាទបាភួនចំនួន២៧កេស ដែលក្នុងនោះ មានប្រភេទកុលាលភាជន៍រឹង កុលាលភាជន៍ផុយជារបស់ខ្មែរ និងកុលាលភាជន៍ចិន សៀម យួនជាដើម។ ទី២ ថ្មភក់ចំនួន២កេស ដែលមកពីគោកតាសៀម។ ទី៣ បំណែកថ្មភក់មានក្បាច់លម្អខ្លះៗចំនួន២កេស មកពីបឹងជូនប៉ា និងគោកតាសៀម ព្រមទាំងប្រាសាទអ៊ុងម៉ុង។ ទី៤ បដិមាព្រះពុទ្ធចំនួន០១ មកពីប្រាសាទអ៊ុងម៉ុង និងបំណែកសន្លឹកសីមាចំនួន០១ មកពីប្រាសាទព្រៃមន្ទីរ។

លោក ទិន ទីណា បន្តឱ្យដឹងទៀតថា ក្រោយពីទទួលបានវត្ថុទាំងអស់នេះ ក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរានឹងរៀបចំទុកដាក់អភិរក្សតាមលក្ខណៈបច្ចេកទេស ហើយនៅថ្ងៃខាងនេះ អាជ្ញាធរជាតិនឹងរៀបចំពិព័រណ៌មិនអចិន្ត្រៃយ៍នៅក្នុងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដើម្បីតាំងបង្ហាញឱ្យសាធារណជនជាតិ និងអន្តរជាតិបានទស្សនាសិក្សាស្វែងយល់ពីវត្ថុសិល្បៈខ្មែរ។

សូមរំឭកដែរថា នេះជាលើកទី៣ហើយ ដែលវិទ្យាស្ថានសាលាបារាំងចុងបូព៌ា (EFEO) បានប្រគល់បុរាណវត្ថុដែលបានមកពីកំណាយនៅតាមការដ្ឋានស្រាវជ្រាវ និងការដ្ឋានជួសជុលប្រាសាទមួយចំនួននៅក្នុងរមណីយដ្ឋានអង្គរមកដល់អាជ្ញាធរជាតិអប្សរា៕

# លោកគ្រូ និងសិស្សានុសិស្ស ចំនួន២០នាក់ មកពីវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង បានចូលមកទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ លោកគ្រូ និងសិស្សានុសិស្សថ្នាក់ទី១០ សរុបចំនួន២០នាក់ មកពីវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង បានចូលមកទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ក្រោមការជួយសម្របសម្រួលពីអាជ្ញាធរជាតិអប្សរា បន្ទាប់ពីបានសិក្សាអំពីមូលដ្ឋានគ្រឹះស្ដីពី៖ ការអប់រំ បេតិកភណ្ឌរួចមក។

លោក ប្រេន ប្រេន នាយកវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង ក្នុងឱកាសដឹកនាំសិស្សានុសិស្សចូលមកទស្សនកិច្ចសិក្សា បានឱ្យដឹងថា លោកគ្រូពិតជាសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយអាជ្ញាធរជាតិអប្សរាបានបណ្ដុះបណ្ដាលសិស្សនៅសាលារៀនលោកគ្រូ អំពីកម្មវិធីអប់រំបេតិកភណ្ឌ។ ជាក់ស្ដែងកម្មវិធីចុះទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរនាពេលនេះ គឺជាលើកទីមួយ សម្រាប់លោកគ្រូ និងសិស្សានុសិស្ស។ ក្រោយពេលបានឃើញការរក្សាទុកបុរាណវត្ថុមានតម្លៃមិនអាចកាត់ថ្លៃជាច្រើនរាប់រយប្រភេទ លោកគ្រូ បានកោតសសើរអាជ្ញាធរជាតិអប្សរាដែលបានខិតខំប្រឹងប្រែងថែរក្សាមរតកទាំងនេះ ទុកជាកេរដំណែលសម្រាប់កូនចៅជំនាន់ក្រោយបានឃើញ បានស្គាល់ និងសិក្សាស្វែងយល់ អំពីមរតកវប្បធម៌របស់ជាតិខ្លួន។

យុវតី យាន យ៉ាន់ សិស្សថ្នាក់ទី១0Bនៃវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង បានឱ្យដឹងថា ការសិក្សាកម្មវិធីអប់រំបេតិកភណ្ឌដែលអាជ្ញាធរជាតិអប្សរាបានរៀបចំនេះ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត ព្រោះថាប្អូនគឺប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បេតិកភណ្ឌផ្ទាល់តែម្ដង។ ក្រោយពេលសិក្សាចប់ ប្អូនទទួលបានចំណេះដឹងអំពីការចូលរួមថែរក្សា អភិរក្សបេតិកភណ្ឌ ជាពិសេសក្រោយបានចូលមកទស្សនានៅសារមន្ទីរ ធ្វើឱ្យប្អូនបានដឹងកាន់តែច្បាស់ អំពីជីវភាពរស់នៅរបស់បុព្វបុរសនាសម័យបុរាណ។ ។ យុវតី យាន យ៉ាន់ ប្ដេជ្ញានាំយកចំណេះដឹងទាំងនេះ ទៅចែករំលែកបន្តដល់បងប្អូនក្នុងសហគមន៍ខ្លួន។

សូមជម្រាបថា ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរាជាមួយដៃគូអន្តរជាតិ មន្ទីរអប់រំយុវជននិងកីឡា បានបង្កើតឱ្យមានកម្មវិធីអប់រំបេតិកភណ្ឌ ជូនដល់សិស្សានុសិស្សនៅតាមសាលាបឋមសិក្សា និងវិទ្យាល័យមួយចំនួន ដែលមានទីតាំងក្នុងតំបន់បេតិកភណ្ឌ ចាប់តាំងពីអំឡុងឆ្នាំ២០០៧មក មាននៅ ខេត្តឧត្ដរមានជ័យ បន្ទាយមានជ័យ កំពង់ធំ និងខេត្តសៀមរាប។

# សេចក្តីជូនដំណឹង ស្តីពីការដាក់ដំណើរការសាកល្បងខ្សែទស្សនាថ្មី នៅប្រាសាទអង្គរវត្ត និងបន្ទាយស្រី នៃរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣








# អាជ្ញាធរជាតិអប្សរាបន្តជួសជុលនិងផ្គុំឡើងវិញចម្លាក់បង្កាន់ដៃនាគ នៅប្រាសាទបន្ទាយសំរ៉ែ

ផ្សាយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរាបន្តជួសជុលនិងផ្គុំឡើងវិញចម្លាក់បង្កាន់ដៃនាគនៅប្រាសាទបន្ទាយសំរ៉ែក្រុមអភិរក្សថ្មនៃអាជ្ញាធរជាតិអប្សរា កំពុងបន្តជួសជុលចម្លាក់បង្កាន់ដៃនាគប្រវែង២៤ម៉ែត្រ ស្ថិតនៅខាងជើង ឈៀងខាងកើតនៃប្រាសាទបន្ទាយសំរ៉ែ ដែលធ្លាក់បាក់ជាច្រើនកំណាត់រយៈពេលជាយូរមកហើយនោះឱ្យប្រសើរឡើងវិញ។ កិច្ចការងារជួសជុលនេះ ធ្វើឡើងដើម្បីលើកតម្លៃឡើងវិញនូវប្រាសាទបន្ទាយសំរ៉ែ ក៏ដូចជា ធ្វើឱ្យមាននិរន្តរភាពសម្រាប់ការអភិរក្សប្រាសាទខ្មែរ។

ប្រធានក្រុមការងារអភិរក្សថ្មនៃនាយកដ្ឋានអភិរក្សប្រាសាទនិងបុរាណវិទ្យាលោក ឡុង ណារី ពន្យល់ថា ការងារជួសជុលចម្លាក់បង្កាន់ដៃនាគនៅប្រាសាទបន្ទាយសំរ៉ែនេះ បានចាប់ផ្តើមរយៈពេលជិត២ខែមកហើយ។ ក្រុមការងារបានប្រមូលបំណែកតូចធំរបស់ចម្លាក់ដើមមកផ្គុំគ្នា ដោយព្យាយាមមិនយកថ្មថ្មីមកជំនួសទេ ដោយកំពុងតែខំប្រឹងប្រែងស្វែងរកបំណែកចម្លាក់ទាំងនេះមកពីទីផ្សេងៗតាមដែលអាចស្វែងរកបាន។

លោក ឡុង ណារី ទៀតថា ការជួសជុលថ្ម ព្យាបាលថ្មតភ្ជាប់បំណែកថ្មឡើងវិញនោះ គឺប្រើប្រាស់ការស្វានដាក់ស្នូលតភ្ជាប់បំណែកដងខ្លួននាគ។ ការជួសជុលនេះ ផ្តោតសំខាន់ទៅលើការដាប់ជើងទម្រចាស់ៗជាច្រើនបំណែកនិងដងខ្លួននាគដែលបានប្រេះបែកទាំងស្រុងចេញពីគ្នាប្រឈមនឹងការលំបាក។ បន្ទាប់មក ក្រុមការងារបានពង្រឹងផ្ទៃថ្មដែលពុកផុយឱ្យរឹងមាំឡើងវិញ ចាក់បំពេញបាយអចូលក្នុងប្រហោង និងតំណបិទភ្ជិតរន្ធតូចធារស្នាមប្រេះ និងប្រហោងតូចៗនៅលើផ្ទៃថ្មចម្លាក់ សម្អាតស្លែនិងបន្សាបយកជាតិអំបិលចេញពីផ្ទៃថ្ម ដាប់យកចេញនូវដែកទាមចាស់ៗ និងស៊ីម៉ង់ត៍អស់គុណភាព រៀបដំឡើងបង្កាន់ដៃនាគឡើងវិញស្របតាមទីតាំងដើម។

សូមបញ្ជាក់ថា ការជួសជុលបង្កាន់ដៃនាគជ្រុងខាងត្បូងឈៀងខាងលិច មានប្រវែង១២ម៉ែត្រ ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ ជួសជុលបង្កាន់ដៃនាគនៅមុខខាងលិច មានប្រវែង០៨ម៉ែត្រឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧ បង្កាន់ដៃនាគប្រវែង៦ម៉ែត្រនៅមុខខាងកើតឈៀងខាងត្បូង ឆ្នាំ២០២០។ ប្រវែង២២ម៉ែត្រនៅមុខខាងជើងកណ្តាល និងឈៀងខាងកើត ឆ្នាំ២០២០។ ប្រវែង៣០ម៉ែត្រ នៅជ្រុងនិរតីខាងក្នុងរោងទងទី១ ឆ្នាំ២០២១។

# អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋ ដែលបានដាក់ពាក្យស្នើសុំសាងសង់ ឬរុះរើផ្ទះចាស់សាងសង់ផ្ទះថ្មីជំនួស នៅក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ មេត្តាជ្រាបថា៖ ក្រោយពីការចុះពិនិត្យដល់ទីតាំង ពិនិត្យនូវរាល់ឯកសារពាក់ព័ន្ធចាំបាច់ទាំងឡាយ អាជ្ញាធរជាតិអប្សរាសូមធ្វើការបដិសេធនូវពាក្យស្នើសុំទាំងនោះដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋ ដែលបានដាក់ពាក្យស្នើសុំសាងសង់ ឬរុះរើផ្ទះចាស់សាងសង់ផ្ទះថ្មីជំនួស នៅក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ មេត្តាជ្រាបថា៖ ក្រោយពីការចុះពិនិត្យដល់ទីតាំង និងពិនិត្យនូវរាល់ឯកសារពាក់ព័ន្ធចាំបាច់ទាំងឡាយ អាជ្ញាធរជាតិអប្សរាសូមធ្វើការអនុញ្ញាតនូវពាក្យស្នើសុំទាំងនោះដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

APSARA

សេចក្តីជូនដំណឹង
ស្តីពី
លិខិតអនុញ្ញាតសាងសង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

APSARA

សេចក្តីជូនដំណឹង
ស្តីពី
លិខិតអនុញ្ញាតសាងសង់

# ជំនាញជាអ្នកអភិរក្ស និងជួសជុល ព្យាបាលថ្មប្រាសាទបុរាណ ទាមទារការអត់ធ្មត់ទឹកចិត្តតស៊ូខ្ពស់

ផ្សាយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣

លោក សៅ រតនៈ អាយុ២៩ឆ្នាំ ជាអតីតសិក្ខាកាមដែលធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល «ជំនាញអភិរក្សថ្ម» ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរាជាមួយក្រុមអភិរក្សថ្ម និងអង្គការ GIZ ចាប់ពីឆ្នាំ២០១៣ ដល់២០១៥ ហើយមានដើមកំណើតជាអ្នកសៀមរាប មានប្រសាសន៍ថា ការងារអភិរក្ស និងជួសជុល ព្យាបាលថ្ម ជួបនូវការលំបាកជាច្រើន ទាំងការផ្គុំថ្ម ការព្យាបាលថ្ម ការលាងសម្អាតថ្ម ព្រោះថ្មខ្លះមានការពុកផុយលើក្បាច់ ដោយវាទាមទារឱ្យចិត្តទុកដាក់ខ្លាំង។ ប្រសិនបើសម្អាតមិនត្រឹមត្រូវ គឺវាអាចធ្វើឱ្យបាត់បង់នូវក្បូរក្បាច់ដើម ហើយបានប្រែក្លាយទៅជាបំផ្លាញរបស់ទាំងនោះទៅវិញ។

ក្នុងរយៈពេល១០ឆ្នាំមកនេះ លោក សៅ រតនៈ បានរួមចំណែកធ្វើការងារអភិរក្ស និងជួសជុលប្រាសាទមួយចំនួននៅក្នុងតំបន់អង្គរ រួមទាំងប្រាសាទនៅក្រៅតំបន់អង្គរផង។

អ្នកស្រី គី ស្រីណោះ ជាអ្នកខេត្តសៀមរាបនិងអតីតសិក្ខាកាមចូលរួមរៀនក្នុងវគ្គបណ្តុះបណ្តាលជំនាញអភិរក្សថ្ម ម្នាក់ទៀត ក៏បានឱ្យដឹងដែរថា អ្នកស្រីបានបម្រើការងារក្នុងវិស័យនេះរយៈពេលជាង១០ឆ្នាំមកហើយ។ អ្នកស្រី មានប្រសាសន៍ថា អ្នកជំនាញអភិរក្សថ្មទាំងបុរស និងស្ត្រី គឺសុទ្ធតែចេះជំនាញគ្រប់ផ្នែកដូចគ្នា និងអាចធ្វើការងារគ្រប់យ៉ាងបានទាំងអស់។ អ្នកស្រីឱ្យដឹងថា ភាគច្រើនស្រីៗគឺច្រើនទទួលបន្ទុកការងារផ្តោតទៅលើការចងក្រងឯកសារ ដូចជា សម្រង់ប្លង់មុន និងក្រោយពេលជួសជុលព្រមទាំងតាមដានគ្រប់ដំណាក់កាលនៃការរើរុះថ្មដើម្បីកុំឱ្យមានភាន់ច្រឡំដោយប្រការណាមួយជាដើម។ ការងារនេះ ថ្វីត្បិតតែមិនសូវប្រើកម្លាំងដូចក្រុមការងារបុរសក៏ពិតមែន តែក៏មានការលំបាក និងត្រូវចេះបត់បែន ដូចជាទីតាំងខ្លះបាត់ថ្ម យើងត្រូវការបង្កើតថ្មី ទាមទារឱ្យមានការអត់ធ្មត់ និងសហការនៅក្នុងក្រុមផង។ អ្នកស្រី ស្រីណោះ បញ្ជាក់ថា វគ្គបណ្តុះបណ្តាលជំនាញអភិរក្សថ្ម ក៏បានផ្តល់ចំណេះដឹងឱ្យគ្រប់សិក្ខាកាមនូវចំណេះដឹងលើប្រភេទថ្ម និងប្រវត្តិសាស្ត្រដែរ ដែលជំរុញទឹកចិត្តឱ្យកាន់តែស្រលាញ់បន្ថែមទៀត ហើយលោកស្រីក៏ចង់ឱ្យចំណេះជំនាញផ្នែកអភិរក្សថ្មផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនដើម្បីបណ្តុះគំនិតឱ្យពួកគាត់ស្រឡាញ់ និងបានចូលរួមអភិរក្សគ្រប់រូបភាពជាមួយអ្នកជំនាញ។

បច្ចុប្បន្ននេះនៅកម្ពុជា គឺមានក្រុមអ្នកជំនាញអភិរក្ស និងជួសជុលថ្មប្រាសាទបុរាណចំនួនតិចតួចនៅឡើយ។ អាជ្ញាធរជាតិអប្សរា កំពុងសហការជាមួយស្ថាប័នGIZ អាល្លឺម៉ង់ ក្នុងការបណ្តុះបណ្តាលជំនាញនេះលើកូនខ្មែរជំនាន់ក្រោយមួយចំនួនថែមទៀត ដើម្បីឈានទៅរកការបង្កើនធនធានមនុស្សផ្នែកនេះឱ្យកាន់តែសំបូរឡើងនៅពេលអនាគតឆាប់ៗ៕

# ព្រះមេធានុរក្ស វជិរប្បញ្ញោ បណ្ឌិត គូ សុភាព និមន្តទស្សនាសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣

ព្រះមេធានុរក្ស វជិរប្បញ្ញោ បណ្ឌិត គូ សុភាព ព្រះគ្រូសូត្រស្តាំវត្តនិគ្រោធវ័ន ហៅ វត្តគល់ទទឹង និងជាសាស្ត្រាចារ្យសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា បាននិមន្តទស្សនាសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដើម្បីទស្សនាស្វែងយល់ពីសារមន្ទីរដែលមានតាំងពិព័រណ៍បង្ហាញពីកុលាលភាជន៍ផ្នូរសពបុរាណ សាកសព ឬឆ្អឹងខ្មោចមនុស្សសម័យយុគសំរិទ្ធនិងយុគដែក ពុទ្ធបដិមា រួមទាំងវត្ថុសិល្បៈផ្សេងកម្រៗជាច្រើនទៀត ដែលបានពីកំណាយស្រាវជ្រាវនៅក្នុងរមណីយដ្ឋានអង្គរ និងទទួលបានពីប្រជាពលរដ្ឋប្រគល់ជូនសារមន្ទីរ ជាកន្លែងដែលផ្តុំនូវចំណេះដឹងផ្នែកប្រវត្តិសាស្ត្រប្រវត្តិសិល្បៈ និងបម្រែបម្រួលនៃសាសនាខ្មែរនាអតីតកាល។

ក្រៅពីទស្សនានៅតាមសាលពិព័រណ៍នីមួយៗ ព្រះមេធានុរក្សវជិរប្បញ្ញោ បណ្ឌិត គូ សុភាព បាននិមន្តទស្សនារោងជាងជួសជុលលោហៈដែលមានវត្ថុសិល្បៈចំនួន១០៥៥សមុច្ច័យភាគច្រើនជារូបចម្លាក់ព្រះពុទ្ធស្ថិតក្នុងសតវត្សរ៍ទី១២ និងទី១៣នៃគ្រឹស្តរាជ និងសម័យក្រោយអង្គរ ដែលបច្ចុប្បន្នក្រុមការងារកំពុងធ្វើការសម្អាត និងអភិរក្ស។

ក្រោយពីបាននិមន្តទស្សនា ព្រះមេធានុរក្ស វជិរប្បញ្ញោ បណ្ឌិត គូ សុភាព បានសម្តែងនូវទឹកព្រះទ័យរីករាយ និងកោតសរសើរចំពោះការរៀបចំបានស្អាត សមស្របតាមបច្ចេកទេស តម្កល់នូវវត្ថុសិល្បៈដ៏មានតម្លៃ។ នេះជាលើកទីមួយ ក្នុងការនមន្តទស្សនានៅទីនេះ ព្រះអង្គ ក៏មានបំណងនឹងជួយផ្សព្វផ្សាយដល់ព្រះសង្ឃដទៃទៀត ក៏ដូចជាពុទ្ធបរិស័ទដែលបានមកលេងខេត្តសៀមរាប សូមកុំរំលងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដែលជាសារមន្ទីរបុរាណវិទ្យាបែបព្រះពុទ្ធសាសនាដំបូងគេនៅក្នុងខេត្តសៀមរាប៕

# អាជ្ញាធរជាតិអប្សរា មានគម្រោងស្តារស្រះទឹកនៅភាគខាងកើតរបស់ប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣

ក្រុមការងាររបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងតែខិតខំប្រឹងប្រែងរុះរើផ្ទាំងថ្មនៃប្រាសាទបុរាណចំនួនច្រើនម៉ឺនដុំចេញពីគំនរដែលធ្លាប់តែធ្លាក់នៅក្នុងស្រះទឹកនាភាគខាងកើតនៃប្រាសាទបាយ័ន ដើម្បីផ្លាស់ប្តូរទៅកាន់ទីតាំងថ្មីមួយផ្សេងទៀត។

បុគ្គលិកបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាជាធរជាតិអប្សរា លោកស្រី ទឹម ធីតា មានប្រសាសន៍ថា ការរុះរើបំណែកថ្មនៃប្រាសាទបុរាណចេញពីស្រះទឹកនេះ គឺក្នុងបំណងរៀបចំសណ្តាប់ធ្នាប់គំនរថ្ម និងដឹកជញ្ជូនទៅរក្សាទុកនៅទីតាំងសមស្រប។ ម្យ៉ាងទៀតគឺដើម្បីលើកតម្លៃ នឹងស្តារស្រះទឹកទាំង២នៅភាគខាងកើតប្រាសាទបាយ័នឡើងវិញ ឱ្យដូចទៅនឹងអត្តសញ្ញាណដើម និងទម្រង់ស្ថាបត្យកម្មដើមនៃប្រាសាទបាយ័នទាំងមូលផង។

លោកស្រី ឱ្យដឹងទៀតថា គំនរថ្មនៃប្រាសាទបុរាណនេះមួយផ្នែក ធ្លាប់បានប្រមូលនៅក្នុងបរិវេណរូតទី៣ និងនៅរោងទងទី១នៃប្រាសាទបាយ័នដោយអ្នកអភិក្សជនជាតិបារាំង កាលពីចន្លោះឆ្នាំ១៩១៩-១៩៣០ម្តងមកហើយ។ ក្រុមអ្នកជំនាញឱ្យដឹងថា ថ្មប្រាសាទបុរាណភាគច្រើនដែលធ្លាក់ជាគំនរនៅក្នុងស្រះទឹកនាភាគខាងកើតនៃប្រាសាទបាយ័ននោះ គឺជាប្រភេទថ្មដំបូល៥០ភាគរយ ក្រៅពីនេះមាន ថ្មហោជាង ផ្ទឹម សសរ ថ្មកំពូលព្រហ្ម ខឿន និងថ្មចម្លាក់តូចៗដែលបានបាក់បែកមុខជាដើម។ ស្ថានភាពថ្មមុនពេលរើ គឺមានសភាពនៅរាយប៉ាយគរគ្នា និងគុណភាពថ្ម ឃើញនៅល្អភាគច្រើន។

ដំណាក់កាលដំបូង គឺក្រុមការងារនឹងរើគំនរថ្មយកទៅដាក់នៅបរិវេណមុខប្រាសាទសិន បន្ទាប់ពីរើថ្មអស់ហើយ គឺក្រុមការងារនឹងត្រូវបែងចែកប្រភេទថ្មថា មួយណាជាប្រភេទថ្មដំបូល ថ្មណាជាសសរ ដោយត្រូវយកទៅដាក់នៅផ្នែកខាងជើងនៃប្រាសាទបាយ័ន។ រហូតមកដល់ពេលនេះ ក្រុមការងារនៃអាជ្ញាធរជាតិអប្សរាបានរើផ្ទាំងថ្មនៃប្រាសាទបុរាណទៅដាក់នៅផ្នែកខាងជើងនៃប្រាសាទបាយ័ន បានចំនួនប្រហែលជាង៤ពាន់ដុំហើយ។

ក្រុមការងារបានសន្និដ្ឋានថា ថ្មប្រាសាទបុរាណ ដែលគេត្រូវរើចេញពីគំនរទាំងអស់មានប្រហែល២ម៉ឺនដុំ។ ការងាររុះរើផ្ទាំងថ្មនៃប្រាសាទបុរាណចេញពីគំនរដែលធ្លាប់តែនៅក្នុងស្រះទឹកនាភាគខាងកើតនៃប្រាសាទបាយ័ន គឺបានចាប់ផ្តើមតាំងពីដើមឆ្នាំ២០២៣មកម្ល៉េះ ដោយដំណាក់កាលដំបូងចាប់ផ្តើមពីការសិក្សាស្វែងរកឯកសារ ការសម្រង់ប្លង់ថតរូបស្ថានភាពថ្មមុនពេលរើ ហើយក៏គ្រោងនឹងបញ្ចប់នៅខែសីហាឬខែកញ្ញាខាងមុខនេះ ៕

# ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់ នៃអាជ្ញាធរជាតិអប្សរា សូមប្រកាសគាំទ្រប្រសាសន៍សម្តេចតេជោ ហ៊ុន សែន និងគាំទ្រឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីថ្មី សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា

ផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋ ដែលបានដាក់ពាក្យស្នើសុំសាងសង់ ឬរុះរើផ្ទះចាស់សាងសង់ផ្ទះថ្មីជំនួស នៅក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ មេត្តាជ្រាបថា

## ក្រោយពីការចុះពិនិត្យដល់ទីតាំង និងពិនិត្យនូវរាល់ឯកសារពាក់ព័ន្ធចាំបាច់នានាទាំងឡាយ អាជ្ញាធរជាតិអប្សរាសូមធ្វើការអនុញ្ញាតនូវពាក្យស្នើសុំទាំងនោះដូចខាងក្រោម

ផ្សាយនៅថ្ងៃទី២៨ខែកក្កដា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ០៦៤/ អស.ភរ
/២៣

ថ្ងៃព្រហស្បតិ៍ ១០កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០២៣

**សេចក្តីជូនដំណឹង**
**ស្តីអំពី**
**លិខិតអនុញ្ញាតសាងសង់**

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋ ដែលបានដាក់ពាក្យស្នើសុំស្តារត្រពាំង នៅក្នុងតំបន់ការពារនៃរមណីយដ្ឋានសៀមរាប-អង្គរ មេត្តាជ្រាបថា៖ ក្រោយពីពិនិត្យលើពាក្យស្នើសុំ និងលក្ខខណ្ឌនានាដែលកំពុងអនុវត្តជាធរមាន សំណើមួយចំនួន ត្រូវបានអនុញ្ញាត ឱ្យបន្តសុពលភាពស្តារត្រពាំង ដែលមានដូចខាងក្រោម៖

| ល.រ | ឈ្មោះអ្នកស្នើសុំ | អាសយដ្ឋានស្នើសុំ | ប្រភេទនៃការអនុញ្ញាត | លេខលិខិតអនុញ្ញាត | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | លោក ឈុត ឈា (មេភូមិថ្មី) | ភូមិថ្មី ឃុំខ្នាស់ ស្រុកសូទ្រនិគម | បន្តសុពលភាពក្នុងការសម្អាតផ្លូវទឹក និងជួសជុលខ្នងទំនប់ត្រពាំងតាឧៃ | ១៦៤/ អស.ភរ /២៣ | ប្រយោជន៍សាធារណៈ |

អាជ្ញាធរជាតិអប្សរា

ចម្លងជូន៖
- រដ្ឋបាលស្រុកសូទ្រនិគម
- រដ្ឋបាលឃុំខ្នាស់
- នាយកដ្ឋានសណ្តាប់ធ្នាប់
- នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ
- នាយកដ្ឋានគ្រប់គ្រងដីធ្លី លំនៅឋាន ក្នុងតំបន់អង្គរ និងសហគមន៍
- ឯកសារ/កាលប្បវត្តិ

បញ្ជាក់៖
- សូមមកយកលិខិតអនុញ្ញាតនៅច្រកចេញចូលតែមួយរបស់អាជ្ញាធរជាតិអប្សរា ។
- ពិនិត្យលទ្ធផលអនុញ្ញាតលើគេហទំព័ររបស់អាជ្ញាធរជាតិអប្សរា www.apsaraauthority.gov.kh និង Facebook: អាជ្ញាធរជាតិអប្សរា Apsara Authority
- [illegible]

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបាគង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
[illegible]
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

## អរុណសួស្ដី សូមអញ្ជើញទស្សនាទិដ្ឋភាពថ្ងៃរះគួរឱ្យគយគន់នៅស្រះស្រង់

ផ្សាយនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣

# ព្រឹត្តិការណ៍ព័ត៌មាន
# ប្រចាំខែសីហា

# អាជ្ញាធរជាតិអប្សរាជួសជុលពង្រឹងខឿនជណ្តើរនៃខ្លោងទ្វារខាងកើតប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣

ក្រុមការងារបច្ចេកទេសជួសជុលនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា កំពុងជួសជុលពង្រឹងខឿនជណ្តើរនៃខ្លោងទ្វារខាងកើតប្រាសាទអង្គរវត្ត ក្នុងបំណងជួយលើកតម្លៃសំណង់បុរាណនេះ ឱ្យប្រសើរឡើងវិញ។

បុរាណវិទូលោកស្រី ភិន វិជ្ជាសច្ចា៉ ឱ្យដឹងថា ការជួសជុលនេះ ក្នុងបំណងដើម្បីពង្រឹងខឿនជណ្តើរឱ្យរឹងមាំឡើងវិញ ដោយសារតែស្ថានភាពកម្រាលថ្មភក់ខឿនជណ្តើរនៃខ្លោងទ្វារខាងកើតប្រាសាទអង្គរវត្តនេះ មានការហែកញែកចេញពីគ្នាសសរទ្រេត ថ្មខ្លះបានធ្លាក់ចុះ និងខ្លះទៀតក៏បម្រុងនឹងធ្លាក់ ហើយក្រុមការងារនឹងរៀបចំរុញថ្មទាំងនោះឱ្យទៅចូលទីតាំងដើមវិញ ក្នុងន័យពង្រឹងខឿនឱ្យមានភាពរឹងមាំគង់វង្សតទៅមុខទៀត។

លោកស្រី វិជ្ជាសច្ចា៉ មានប្រសាសន៍ទៀតថា កត្តាដែលបណ្តាលឱ្យខឿនជណ្តើរនេះរងការខូចខាត គឺដោយសារអាយុកាល និងធម្មជាតិដែលធ្វើឱ្យរលុះរចនាសម្ពន្ធគ្រឹះខូចរូបរាង។ ក្រុមការងារបានចាប់ផ្តើមកិច្ចការដំបូង គឺសិក្សាទៅលើសម្រង់ប្លង់ ចុះបញ្ជីលេខ ស្វែងរកថ្ម ការផ្តុំថ្ម ថាតើថ្មចេញពីប្រភពណា? បន្ទាប់ពីផ្តុំចេញរូបរាងរួចហើយ ទើបក្រុមការងារសិក្សាទៅលើគ្រឹះ ថាតើគួរជុសជុស ឬគួររើ គួរពង្រឹងដើម្បីយកទៅដាក់កន្លែងដើមវិញឬក៏យ៉ាងណា? ក្រៅពីនេះក្រុមការងារបានធ្វើការទល់ទ្រដំបូលកណ្តាលកុំឱ្យរលុះធ្លាក់ថែមទៀតផង៕

# ក្រុមការងារបច្ចេកទេស និងអភិរក្សកំពុងប្រឹងប្រែងជួយខ្លោងទ្វារខាងជើង នៅរួតទី២ប្រាសាទមេបុណ្យខាងកើត

ផ្សាយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣

ក្រុមអ្នកបច្ចេកទេសរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា កំពុងមមារញឹកជួសជុលខ្លោងទ្វារខាងជើងនៅរួតទី២នៃប្រាសាទមេបុណ្យខាងកើត ដែលកំពុងមានសភាពទ្រុឌទ្រោមខ្លាំង។

លោក សូរ ប៉ោត ជាបុរាណវិទូ និងជាស្ថាបត្យករ នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា មានប្រសាសន៍ថា ដោយសារកត្តាអាយុកាលធ្វើឱ្យរចនាសម្ពន្ធឥដ្ឋផ្នែកខ្លះនៃខ្លោងទ្វារខាងជើងនៅរួតទី២នៃប្រាសាទមេបុណ្យខាងកើតប្រឈមនឹងបញ្ហាជ្រុះធ្លាក់ និងដួលរលំ។ ដោយមើលឃើញនូវស្ថានភាពបែបនេះ អាជ្ញាធរជាតិអប្សរា បានទល់ទ្រជញ្ជាំងឥដ្ឋដែលនៅសេសសល់សងខាង ដើម្បីទប់លំនឹងនៃតួខ្លោងទ្វារទាំងមូល ដែលកំពុងតែមានសភាពស្រុតផ្អៀងខ្លាំងប្រឈមនឹងការដួលរលំ ព្រមទាំងបិទបាយអបំពេញតាមចន្លោះស្នាមឥដ្ឋប្រេះបែកនិងញែកចេញពីគ្នា ដើម្បីការពារទឹកកុំឱ្យជ្រាបចូលបន្តទៀត។
លោកលោក សូរ ប៉ោត ឱ្យដឹងទៀតថា កត្តាដែលធ្វើឱ្យខ្លោងទ្វារនេះខូចខាតខ្លាំង គឺដោយសារទឹកភ្លៀងជ្រាបចូល។ បញ្ហាសំណើមក៏ធ្វើឱ្យជញ្ជាំងពុកផុយខ្លាំង និងរុក្ខជាតិដែលដុះនៅពីលើក៏ធ្វើឱ្យគ្រឹះស្រុតបណ្តាលឱ្យមានស្នាមប្រេះតូចធំជាច្រើនកន្លែង និងផ្នែកខ្លះមានឫសឈើចាក់ចូលជញ្ជាំងបណ្តាលឱ្យស្នាមប្រេះកាន់តែរីកធំឡើង។

ក្នុងពេលដែលខ្លោងទ្វារខាងកើតរបស់ប្រាសាទមេបុណ្យខាងកើតកំពុងមានហានិភ័យនៃតួប៉មនេះ ក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាបានសម្រង់ប្លង់កំណត់សម្គាល់ទីតាំងដែលមានហានិភ័យ និងពង្រឹងគ្រឹះ គ្រឹបខ្សែកាបធ្វើរន្ធខាងក្នុងដើម្បីជួយអបលំនឹង។ មកដល់ពេលនេះ ការសង្គ្រោះពង្រឹងខ្លោងទ្វារខាងជើងរបស់ប្រាសាទមេបុណ្យខាងកើតសម្រេចបាន៥០ភាគរយហើយ។

សូមបញ្ជាក់ថា គម្រោងជួសជុលខ្លោងទ្វារខាងជើងប្រាសាទមេបុណ្យខាងកើត បានឆ្លងយោបល់ពីគណៈកម្មាធិការអាយស៊ីស៊ី-អង្គរផងដែរ៕

# លិខិតគោរពជូនពររបស់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរជាតិអប្សរា គោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ចម្រើនជន្មាយុគម្រប់ ៧១ឆ្នាំ ឈានចូល ៧២ឆ្នាំ

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៥៤៤៧/រប.លជ៣ /២៣

សូមគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លា នៃថ្ងៃចម្រើនជន្មាយុគម្រប់៧១ឆ្នាំ ឈានចូល៧២ឆ្នាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសម្តែងនូវមនោសញ្ចេតនារីករាយឥតឧបមា និងសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត ព្រមទាំងសូមគោរពជូនពរ បវរមហាប្រសើរជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមានជន្មាយុយឺនយូរ សុខមាលភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ដើម្បីដឹកនាំ និងតម្រង់ទិសប្រទេសជាតិទទួលបានជោគជ័យដ៏ត្រចះត្រចង់ថ្មីៗថែមទៀត ជាពិសេសវឌ្ឍនភាព និងកិត្យានុភាពល្បីរន្ទឺលើឆាកអន្តរជាតិ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពកោតសរសើរយ៉ាងស្មោះអស់ពីដួងចិត្តចំពោះគំរូនៃភាពជាអ្នកដឹកនាំដ៏អង់អាចក្លាហាន ការលះបង់ និងពលិកម្មគ្រប់បែបយ៉ាង យកអស់កម្លាំងកាយចិត្តដឹកនាំនាវាកម្ពុជាប្រកបដោយគតិបណ្ឌិត និងដោយពុំចេះនឿយហត់ក្នុងការបំពេញនូវបេសកកម្មជាប្រវត្តិសាស្ត្រ ដើម្បីជាតិមាតុភូមិ និងប្រជាជន ជាពិសេសការផ្សះផ្សាបង្រួបបង្រួមជាតិ នាំមកនូវឯកភាពជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ។

ជាថ្មីម្តងទៀតតាងនាមថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសម្តែងនូវកតញ្ញុតាធម៌ សូមលំឱនកាយបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំ សព្វសាធុការ ពរ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ព្រមទាំងក្រុមគ្រួសារ សូមបានប្រកប ដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជាមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃពុធ ១រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២៣
អគ្គនាយក
ហង់_ពៅ

អាជ្ញាធរជាតិអប្សរា
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province

# អាជ្ញាធរជាតិអប្សរាសហការជាមួយ ក្រុមហ៊ុនមេនូឡាយហ្វ៍ ខេមបូឌា ដាំដើមឈើ និងស្មៅនៅបរិវេណជ្រុងពាយ័ព្យ នៃកសិន្ធុអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣នេះ អាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមហ៊ុនមេនូឡាយហ្វ៍ខេមបូឌា រួមគ្នាដាំស្មៅ និងដើមឈើបន្ថែមនៅបរិវេណជ្រុងពាយ័ព្យនៃកសិន្ធុអង្គរ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកឱ្យកាន់តែមានទេសភាពស្រស់បំព្រងគ្រប់រដូវកាល។

អញ្ជើញចូលរួមក្នុងឱកាសនោះ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាង**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោកស្រី កាន់ ណារ៉ា នាយិកាគ្រប់គ្រងនាយកដ្ឋានអតិថិជននិងទីផ្សារខេមបូឌា បុគ្គលិក និងទីប្រឹក្សារបស់ក្រុមហ៊ុនមេនូឡាយហ្វ៍ លោកប្រធាននាយកដ្ឋាន អនុប្រធាន ព្រមទាំងមន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរាជាច្រើនរូបទៀត។

លោកស្រី កាន់ ណារ៉ា នាយិកាគ្រប់គ្រងនាយកដ្ឋានអតិថិជន និងទីផ្សារ នៃក្រុមហ៊ុនមេនូឡាយហ្វ៍ ខេមបូឌា បានលើកឡើងថា មេនូឡាយហ្វ៍ជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដំបូងគេនៅកម្ពុជា ដែលមានបេសកម្មក្នុងការកសាងអនាគតហិរញ្ញវត្ថុដ៏រឹងមាំ និងកាន់តែប្រសើរជូនប្រជាជនកម្ពុជា។ លោកស្រីថា ការគាំទ្រ និងចូលរួមចំណែកក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅជាមួយអាជ្ញាធរជាតិអប្សរានាពេលនេះ បានដើរស្របគ្នានិងគោលដៅរយៈពេលវែងរបស់ក្រុមហ៊ុនក្នុងការជួយដល់ប្រជាជនកម្ពុជា។ ជាពិសេសក្នុងយុទ្ធនាការដាំស្មៅ និងដើមឈើនេះ បានចូលរួមចំណែកបង្កើនគម្របបៃតង ក្នុងតំបន់រមណីយដ្ឋានអង្គរ។ ព្រោះថា ដើមឈើ និងស្មៅជាទ្រនាបដ៏សំខាន់ក្នុងការទប់ទល់ការបម្រែបម្រួលអាកាសធាតុ និងកាត់បន្ថយភាពសឹករិករឹលនៃប្រាង្គប្រាសាទបុរាណរបស់យើង។

# សេចក្តីជូនដំណឹង ស្តីពីការបិទការប្រើប្រាស់ជណ្តើរឈើនៅផ្នែកខាងត្បូង នៃប្រាសាទភ្នំបាខែង ជាបណ្តោះអាសន្ន នៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរជាតិអប្សរា
APSARA
លេខ: ៤៦៩/២៣ [illegible]

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបិទការប្រើប្រាស់ជណ្តើរឈើនៅផ្នែកខាងត្បូងនៃប្រាសាទភ្នំបាខែង ជាបណ្តោះអាសន្ន នៅក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា អាជ្ញាធរជាតិអប្សរានឹងបិទការប្រើប្រាស់ជណ្តើរឈើនៅផ្នែកខាងត្បូងនៃប្រាសាទភ្នំបាខែងជាបណ្តោះអាសន្ន **ចាប់ពីថ្ងៃ០៤ ខែសីហា ឆ្នាំ២០២៣តទៅ** ដើម្បីអនុញ្ញាតឱ្យក្រុមការងារបច្ចេកទេសបំពេញការងារអភិរក្សមួយចំនួន តាមរយៈការពង្រឹងស្ថិរភាពរចនាសម្ព័ន្ធ និងដោះស្រាយបញ្ហាជម្រាបទឹកនៅកាំជណ្តើរថ្មភក់ផ្នែកខាងត្បូងនៃប្រាសាទភ្នំបាខែង។ អំឡុងពេលនៃការបិទនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិអាចប្រើប្រាស់ជាបណ្តោះអាសន្ននូវជណ្តើរផ្នែកខាងកើតនៃប្រាសាទភ្នំបាខែង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ..សុក្រ ៣រោច......ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី.....០៤.....ខែ...សីហា......ឆ្នាំ២០២៣
**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kaeng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

## ប្រាសាទលលៃ កំពុងបង្ហួតសម្រស់ដល់ភ្ញៀវទេសចរ ជាមួយនិងធម្មជាតិស្រស់បំព្រង

ផ្សាយនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣

## អាជ្ញាធរជាតិអប្សរាកំពុងរៀបចំជួសជុល និងដំឡើងកាំជណ្តើរថ្មី នៅច្រកខាងកើត ប្រាសាទមេបុណ្យខាងកើតឡើងវិញ

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣

ក្រុមការងារអាជ្ញាធរជាតិអប្សរាកំពុងរៀបចំជួសជុល និងដំឡើងកាំជណ្តើរថ្មីនៅច្រកខាងកើត ប្រាសាទមេបុណ្យខាងកើត ដើម្បីលើកតម្លៃ និងសម្រួលការធ្វើដំណើររបស់ភ្ញៀវទេសចរចូលទស្សនាប្រាសាទនេះកាន់តែប្រសើរ។

ជាមួយនេះដែរ ដើម្បីសម្រួលកុំឱ្យអាក់ខានចូលទស្សនាប្រាសាទ ក្រុមភ្នាក់ងារទេសចរណ៍ សហការជាមួយក្រុមការងារសម្អាតបរិស្ថាន **HCC Angkor** បានសម្អាតរុក្ខជាតិនិងកាត់ស្មៅ ត្រង់ចំណុច ច្រកខាងត្បូងជាន់ទីមួយនៃប្រាសាទមេបុណ្យខាងកើត ខណៈដែលជណ្តើរច្រកចូលខាងកើត កំពុងជួសជុល កែលម្អ និងលើកតម្លៃឡើងវិញ។

## សកម្មភាពក្រុមការងារសម្អាតរុក្ខជាតិតាមប្រាសាទ កំពុងឡើងដកកូនរុក្ខជាតិតូចធំ ដែលដុះនៅលើប្រាសាទបាគួន និងប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣

# លិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរជាតិអប្សរា គោរពអបអរសាទរ ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ដែលត្រូវបានព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់ចាត់តាំងជា នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

**លិខិតអបអរសាទរ**
**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

តាងនាមថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិក កម្មករ ឆ្មាំ និងពលករ នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសម្តែងនូវអំណរសាទរដ៏ស្មោះអស់ពីដួងចិត្ត ក្នុងឱកាសដែល **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ត្រូវបានចាត់តាំងជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។

**ឯកឧត្តមបណ្ឌិត** ជាបញ្ញវន្តខ្មែរពោរពេញដោយសមត្ថភាព និងសីលធម៌ថ្លៃថ្នូរ ស័ក្តិសមជាអ្នកដឹកនាំបន្តវេននៃនាវាកម្ពុជា។ យើងខ្ញុំទាំងអស់គ្នា មានជំនឿយ៉ាងមុតមាំថា **ឯកឧត្តមបណ្ឌិត** នឹងបន្តដឹកនាំកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍលើគ្រប់វិស័យ បន្តរក្សាបាននូវស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងសុខសន្តិភាព ស្របតាមមាគ៌ា និងមគ្គនយោបាយដ៏ថ្លៃថ្លា ដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រមទាំងវេជនជាថ្នាក់ដឹកនាំផ្សេងៗទៀត ដែលជាស្ថាបនិកសន្តិភាព នាំឱ្យជាតិមាតុភូមិមានភាពសម្បូរសប្បាយ ប្រជាពលរដ្ឋរស់នៅប្រកបដោយសុភមង្គល និងវិបុលភាព។ តាមរយៈសមត្ថភាព ឧត្តមគតិស្នេហាជាតិ ឆន្ទៈដ៏មោះមុតក្នុងការបម្រើប្រជាជន និងចក្ខុវិស័យដ៏វែងឆ្ងាយរបស់ **ឯកឧត្តមបណ្ឌិត** យើងខ្ញុំជឿជាក់ថា ព្រះរាជាណាចក្រកម្ពុជានឹងសម្រេចបានគោលដៅកំណត់ទុកនាពេលអនាគត ព្រមទាំងសម្រេចបាននូវជោគជ័យថ្មីៗបន្ថែមទៀត ដើម្បីលើកកម្ពស់កិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិ។

ជាថ្មីម្តងទៀត ឆ្លៀតឱកាសដ៏ឧត្តុង្គឧត្តមវិសេសវិសាលនេះ យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមតាមបីបាច់ថែរក្សា ប្រោះព្រំប្រទានសព្ទសាធុការពរជ័យ ជូន **ឯកឧត្តមបណ្ឌិត** និង **លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ ព្រមទាំងសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។

ថ្ងៃចន្ទ ០៦រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣
**អគ្គនាយក**
**ហង់ ពៅ**

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

1/1

## សម្រស់ថ្ងៃរះ នៅអង្គរវត្តនៅតែជាមន្តស្នេហ៍ទាក់ទាញភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣

សម្រស់ថ្ងៃរះ នាពេលព្រឹកព្រលឹមនៅតែទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យចូលទៅទស្សនានៅក្នុងបរិវេណប្រាសាទអង្គរវត្តឥតដាច់ជារៀងរាល់ថ្ងៃ។ បើទោះបីជាបច្ចុប្បន្ននេះ ចំនួនភ្ញៀវទេសចរបានថយចុះបន្តិចក្នុងការចូលទៅទស្សនាតំបន់រមណីយដ្ឋានអង្គរក៏ដោយ ប៉ុន្តែសម្រស់ថ្ងៃរះ នាពេលអរុណោទ័យនៅប្រាសាទអង្គរវត្តនៅតែជាមន្តស្នេហ៍ទាក់ទាញធ្វើឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិមិនអាចបំភ្លេចនិងខកខានចូលទៅទស្សនាបានឡើយ៕

# អាជ្ញាធរជាតិអប្សរាកំពុងបន្តការងារជួសជុលតួប៉មខាងជើង នៃប្រាសាទត្រពាំងល្ពៅ

ផ្សាយនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣

មន្ត្រីជំនាញនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា កំពុងធ្វើការជួសជុលតួប៉មខាងជើង នៃប្រាសាទត្រពាំងល្ពៅ បន្ទាប់ពីបានធ្វើការងារជួសជុលតួប៉មផ្នែកខាងត្បូង កាលពីខែវិច្ឆិកា ឆ្នាំ២០២២ និងបានបញ្ចប់ការជួសជុលក្នុងខែមីនា ឆ្នាំ២០២៣កន្លងមក។

លោកស្រី ឈុន រតនា មន្ត្រីនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ប្រាសាទត្រពាំងល្ពៅ មានតួប៉មចំនួន៣ដែលនៅឈរមានរូបរាង។ ដូច្នេះក្រុមអ្នកជំនាញបានចំណាយពេលវេលាប្រមាណ៥ខែ ដើម្បីជួសជុលតួប៉មផ្នែកខាងត្បូងរួចរាល់។ បន្ទាប់មកក្នុងខែមេសា ឆ្នាំ២០២៣ ក៏បន្តការងារជួសជុលតួប៉មផ្នែកខាងជើងវិញម្តងដើម្បីពង្រឹងរចនាសម្ពន្ធប្រាសាទឱ្យរឹងមាំឡើងវិញ បន្ទាប់ពីពិនិត្យឃើញថា រចនាសម្ពន្ធនៃប្រាសាទបានបែកបាក់ ហែកចេញពីគ្នា ស្ទើរតែមិនសល់រូបរាងដើម ដោយសារកត្តាជាច្រើន។

លោកស្រី បញ្ជាក់ទៀតថា មកដល់ដើមខែសីហា ឆ្នាំ២០២៣នេះ ដំណើរការជួសជុលសម្រេចបានលទ្ធផលប្រមាណ៧០ភាគរយហើយ។ ដោយគ្រោងនឹងបញ្ចប់គម្រោងជួសជុល នាចុងឆ្នាំ២០២៣ខាងមុខនេះ។ បន្ទាប់មកនឹងចាប់ផ្តើមការងារជួសជុលប្រាង្គកណ្តាល នៃប្រាសាទត្រពាំងល្ពៅនេះជាបន្តទៀត។

ប្រាសាទត្រពាំងល្ពៅ (ឯកសារមុនៗហៅថា ប្រាសាទត្រពាំងរពៅ) គឺជាប្រាសាទឥដ្ឋមួយមានប្រាង្គចំនួន៣បែរទៅទិសខាងកើត ហើយនៅទិសអាគ្នេយ៍មានស្នាមឥដ្ឋរៀបជាបន្ទប់ ដែលប្រហែលជាត្រូវនឹងគេសព្វថ្ងៃហៅថា «ហោត្រៃ» ត្រូវបានកសាងឡើងប្រហែលឆ្នាំ៩៤៤-៩៦៨ ក្នុងសតវត្សរ៍ទី១០ ក្នុងរាជព្រះបាទរាជេន្ទ្រវរ្ម័នទី២៕

# ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរជាតិអប្សរា សូមគោរពជូនពរ និងអបអរសាទរ ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ក្នុងឱកាសដែលឯកឧត្តមបណ្ឌិត ត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់ផ្តល់គោរមងារកិត្តិយស ដ៏ឧត្តុង្គឧត្តមបំផុតនៃរាជបណ្ឌិតសភាកម្ពុជា ជា កិត្តិទេសាភិបាលបណ្ឌិត

ផ្សាយនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំសូមគោរពជូនពរដោយភាពស្មោះស្ម័គ្រជាទីបំផុត ជូនចំពោះឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត សូមមានជន្មាយុយឺនយូរ សុខមាលភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ដើម្បីបន្តនិរន្តរភាពក្នុងការបម្រើបុព្វហេតុ ជាតិមាតុភូមិនៃយើង ឲ្យទទួលបាននូវជោគជ័យត្រចះត្រចង់ថ្មីៗថែមទៀតដែលជាឧត្តមប្រយោជន៍ នៃការអភិវឌ្ឍន៍ ប្រទេសជាតិទៅអនាគត។

ជាថ្មីម្តងទៀត យើងខ្ញុំសូមគោរពជូនពរចំពោះ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត និង លោកជំទាវ ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ទាំងអស់ សូមបានប្រកបដោយពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។



# ក្រុមការងារសម្អាតរុក្ខជាតិលើប្រាសាទកំពុងកាត់ជករុក្ខជាតិនៅប្រាសាទបាលិលេយ្យ

ផ្សាយនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

ក្រុមការងារសម្អាតរុក្ខជាតិលើប្រាសាទ នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា បានចុះសម្អាតរុក្ខជាតិនៅប្រាសាទបាលិលេយ្យ នៅក្នុងអតីតរាជធានីក្រុងអង្គរធំ។

លោក ងិន ធី ប្រធានក្រុមការងារសម្អាតបានឱ្យដឹងថា រុក្ខជាតិដែលសម្បូរនារដូវវស្សានេះមានប្រភេទរុក្ខជាតិ ស្មៅ និងរុក្ខជាតិធំៗ។ លោកបន្តថា ប្រភេទស្មៅឬរុក្ខជាតិតូចៗ មិនប៉ះពាល់ដល់ថ្មប្រាសាទទេ តែប្រសិនទុកវាឱ្យដុះរៀងស្កុកនោះ វានឹងធ្វើឱ្យបាត់បង់សោភ័ណភាពប្រាសាទបាន។

នៅក្នុងខែវស្សានេះទាំងរុក្ខជាតិស្មៅ និងរុក្ខជាតិដើមឈើធំៗវាដុះលឿនខុសពីធម្មតា។ លោក ងិន ធី បញ្ជាក់ថា ប្រសិនបើយើងសម្អាតវាបានស្អាត វាក្រដុះវិញដែរ។ ដោយឡែក ទាក់ទងនឹងផែនការសម្អាតវិញ ខែវស្សានេះមានភាពមមាញឹកជាងខែប្រាំង។ លោកបញ្ជាក់ថា ខែវស្សាគឺប្រាសាទមួយវិលជុំក្នុងពេលមួយខែ តែសម្រាប់ខែប្រាំងអាចមួយខែកន្លះឯណោះទើបចូលសម្អាតម្តងទៀត៕

## ទិដ្ឋភាពស្រស់ស្រាយនាពេលព្រឹកព្រលឹម ក្នុងអតីតព្រះរាជវាំងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣

# សម្រស់ប្រាសាទបាលិលេយ្យ ដែលជាសំណង់ព្រះពុទ្ធសាសនាមួយ ក្នុងចំណោមសំណង់ព្រះពុទ្ធសាសនាបុរាណផ្សេងទៀត ក្នុងអតីតរាជធានីអង្គរធំ

ផ្សាយនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាកំពុងជួយសង្គ្រោះតួប្រាង្គទី២២របស់ប្រាសាទបាគង

ផ្សាយនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

ក្រុមអ្នកបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរា កំពុងជួសជុលពង្រឹងគ្រឹះប្រាសាទឥដ្ឋ ប្រាង្គទី២២របស់ប្រាសាទបាគង ដែលបានសាងឡើងពីឥដ្ឋនៅផ្នែកខាងជើងដោយមានសភាពទ្រុឌទ្រោម និងកំពុងតែប្រឈមនឹងគ្រោះថ្នាក់ខ្លាំង។

បុរាណវិទូ និងជាប្រធានអភិរក្សតំបន់រលួស នៃអាជ្ញាធរជាតិអប្សរា លោក សារាយ គឹមហួល ឱ្យដឹងថា ស្ថានភាពនៃការខូចខាតប្រាង្គទី២២ នៃប្រាសាទបាគងនេះ កំពុងប្រឈមនិងហានិភ័យខ្លាំង ទើបអាជ្ញាធរជាតិអប្សរាធ្វើការជួសជុលពង្រឹងរចនាសម្ពន្ធប្រាង្គ ដើម្បីលើកតម្លៃសំណង់បុរាណ។ មន្ត្រីដដែលបញ្ជាក់ទៀតថា ប្រាង្គទី២២ មានបញ្ហាប្រឈមខ្ពស់ដោយប្រាង្គកណ្តាលនៅជួរទី៣ ទី៤ផ្នែកខាងលិច និងនៅតាមជញ្ជាំងប្រាង្គនាទិសឦសានមានស្នាមប្រេះហែកចេញពីគ្នាតាំងតែពីលើរហូតដល់ក្រោម ដែលអាចនឹងដួលរលំប្រសិនបើមានការប្រែប្រួលអាកាសធាតុ។

បច្ចុប្បន្ន ក្រុមការងារកំពុងជួយសង្គ្រោះពង្រឹងរចនាសម្ពន្ធឥដ្ឋ ជញ្ជាំង តួប្រាង្គដែលរងការពុកផុយខ្លាំងតាំងពីក្រោមរហូតដល់កំពូលលើជាមួយនិងបច្ចេកទេសបិទស្នាមប្រេះនៅតាមជញ្ជាំងដើម្បីការពារជម្រាបទឹក និងធ្វើការពង្រឹងឡើងវិញនូវរចនាសម្ពន្ធពាក់ពន្ធ័មួយចំនួនទៀតដោយប្រើខ្សែកាបចងគ្រីបនៅខាងក្រៅកុំឱ្យរលុះផង។

លោក សារាយ គឹមហួល ឱ្យដឹងថា ដំណាក់ដំបូងដែលត្រូវសង្គ្រោះបន្ទាន់ គឺត្រូវពង្រឹងគ្រឹះឬសង្គ្រោះត្រង់ចំណុចណាដែលមានហានិភ័យខ្ពស់ បន្ទាប់មកត្រូវសង្គ្រោះនៅកន្លែងផ្សេងៗទៀតដែលមានហានិភ័យបន្តបន្ទាប់។ ការងារមួយទៀតគឺត្រូវសម្អាតស្លួតដោយដកយកកូនរុក្ខជាតិតូចៗដែលដុះនៅលើប្រាង្គ បោសសម្អាតដីចេញពីកន្លែងដែលត្រូវពង្រឹងបន្ទាប់ទៀត ត្រូវកោសស្លែចេញអស់ហើយ និងត្រូវសម្អាតដោយទឹកដើម្បីងាយស្រួលតភ្ជាប់ជាមួយកំបោរបាយអជាដើម។

កាលពីឆ្នាំ២០១៩មក អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមធ្វើការទល់ទ្រដើម្បីទប់លំនឹងរចនាសម្ពន្ធប្រាង្គទី២២ នៃប្រាសាទបាគងនេះដែរ៕

# អាជ្ញាធរជាតិអប្សរា ជួសជុលកំពង់ទឹកប្រាសាទព្រះខ័ន ដំណាក់កាលទី២

ផ្សាយនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមអនុវត្តគម្រោងជួសជុលកំពង់ទឹក ដែលស្ថិតនៅលើច្រាំងនៃទំនប់ខាងលិចបារាយជ័យតដាក នាទិសខាងកើតរបស់ប្រាសាទព្រះខ័នទំហំ១៥.២០ម៉ែត្រគុណនិង១៥.២០ម៉ែត្រ ជាដំណាក់កាលទី២ ដោយនឹងត្រូវចំណាយពេលមួយឆ្នាំ ចាប់ផ្តើមពីដើមឆ្នាំ២០២៣ ហើយគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៣នេះ។

បុរាណវិទូ និងជាអ្នកគ្រប់គ្រងគម្រោងជួសជុលការដ្ឋានកំពង់ទឹកប្រាសាទព្រះខ័នលោក ជា សារិទ្ធ ឱ្យដឹងថា ខឿនកំពង់ទឹក នាទិសខាងកើតរបស់ប្រាសាទព្រះខ័ន មានរាងជាចតុកោណកែង ដោយចែកចេញជាបីផ្នែក ផ្នែកខាងកើតមានប្លង់ជារាងការ៉េ មានទំហំ ១៥.២០ម៉ែត្រគុណនិង១៥.២០ម៉ែត្រ ដែលមានកាំជណ្តើរចំនួន៥កាំ។ មុននឹងឈានដល់ការជួសជុល ក្រុមការងារបានស្វែងរកឯកសារចាស់ៗមកសិក្សា ព្រមទាំងកំណាយបុរាណវិទ្យា សម្អាតកំណកដី ធ្វើសម្រង់ប្លង់ ការកត់ត្រា ការថតរូប ដើម្បីបង្ហាញពីស្ថានភាពអភិរក្សមុនពេលជួសជុលដោយប្រៀបធៀបស្ថានភាពក្រោយពេលជួសជុលផង។ លោក ជា សារិទ្ធ ឱ្យដឹងទៀតថា បច្ចេកទេសនៃការជួសជុលកំពង់ទឹកផ្នែកខាងកើតនេះ អ្វីដែលបានសិក្សារកឃើញនៅទីនេះ គឺត្រូវយកមកប្រើក្នុងវិធីសាស្ត្រជួសជុលពង្រឹងខឿននេះទាំងស្រុង គឺជួសជុលតាមបច្ចេកទេសបុរាណ។ បច្ចុប្បន្ននេះ សម្រេចបាន៣០ទៅ៤០ភាគរយហើយ ដោយបានបញ្ចប់ការរៀបចំផ្តុំកាំជណ្តើរផ្នែកខាងជើង និងខឿនជាន់ទី១ ហើយបន្តទៅខឿនជាន់ទី២។ រីឯ ជណ្តើរខាងកើត ក្រុមការងារកំពុងរៀបចំបាន៥០ភាគរយ ដោយបានរៀបចំបានជណ្តើរចំនួន៤កាំ នៅសល់កាំទី៥ និងខឿនជាន់ទី១ និងទី២ប៉ុណ្ណោះ។ កាលពីឆ្នាំ២០២២កន្លងទៅ ក្រុមអ្នកជំនាញធ្លាប់បានជួសជុលខឿនកណ្តាលមានទំហំបណ្តោយប្រវែង២១.៦០ម៉ែត្រគុណនិង២១.៦០ម៉ែត្រ និងរចនាសម្ព័ន្ធកាំជណ្តើរចុះទៅកាន់ប្រាសាទព្រះខ័នក្នុងដំណាក់កាលទី១។

កំពង់ទឹកផ្នែកខាងកើតនៃប្រាសាទព្រះខ័ន មានស្ថានភាពទ្រុឌទ្រោមខ្លាំង ដោយសារខឿនផ្នែកនេះ កាលពីសម័យសាងសង់ក្នុងដំណាក់កាលទី១ ប្រហាក់ប្រហែលគ្នា និងសម័យកាលនៃការកសាងប្រាសាទព្រះខ័ន ប្រាសាទនាគព័ន្ធ និងប្រាសាទតាសោមនោះ ដោយការរៀបចំរាជធានីជ័យស្រីមានប្រព័ន្ធធារាសាស្ត្រដែលកសាងក្នុងដំណាក់កាលជាមួយគ្នា ហើយខឿនជណ្តើរនៃតួកំពង់ទឹក ធ្វើអំពីថ្មភក់បិទជាជញ្ជាំងពីខាងក្រៅមានឆ្លាក់ចម្លាក់ជាសត្វហង្ស និងនាគស្រដៀងគ្នាទៅនិងស្ពានហាលឆ្លងកាត់ទៅកាន់ប្រាសាទព្រះខ័ន។ ប៉ុន្តែ ក្រោយពីរាជ្យព្រះបាទជ័យវរ្ម័នទី៧ ផ្នែកខ្លះនៃកំពុងទឹកនេះ ត្រូវបានគេដកយកថ្មភក់ ទៅប្រើនៅកន្លែងផ្សេង។

ក្រុមអ្នកបុរាណវិទូ បានសិក្សាឃើញថាការប្រើប្រាស់ថ្មចាស់ ឬក៏ថ្មបុរាណឃើញមានជាហូរហែរាប់ចាប់តាំងពីរាជ្យព្រះបាទជ័យវរ្ម័នទី៧ រហូតមកដល់ចុងសម័យអង្គរ។ ដូច្នេះ ក្រោយពីការដកយកថ្មភក់ជញ្ជាំងជុំវិញរបស់ខឿនខាងកើតចេញធ្វើឱ្យខឿនផ្នែកនេះរងនូវការបាក់ស្រុត ដោយសារទឹកហូរច្រោះដីខាងក្នុងធ្វើឱ្យថ្មបាយក្រៀមដែលនៅសល់បានស្រុតចុះក្រោមស្ទើរតែបាត់រូបរាងទាំងស្រុង។

នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ កំពង់ទឹកនេះ ធ្លាប់មានការកែប្រែម្តងរួចមកហើយ បន្ទាប់ពីការសាងសង់ហើយភ្លាមៗ នៅក្នុងរាជ្យរបស់ព្រះអង្គ។ យោងទៅតាមព័ត៌មាននៅលើសិលាចារឹកប្រាសាទព្រះខ័ន ឱ្យដឹងថា ប្រាសាទព្រះខ័ន ប្រាសាទនាគព័ន្ធ និងបារាយជ័យតដាក ត្រូវបានកែប្រែនៅក្នុងដំណាក់កាលទី២ មានន័យថាបារាយត្រូវបានគេលើកឱ្យខ្ពស់ជាងមុន ដើម្បីបន្ថែមបរិមាណទឹកឱ្យបានច្រើនសម្រាប់យកទៅប្រើប្រាស់ក្នុងវិស័យកសិកម្ម និងជីវភាពប្រចាំថ្ងៃនៅរាជធានី។ ខឿននៃកំពង់ទឹកនេះ ក៏ត្រូវបានគេលើកឱ្យខ្ពស់ជាងមុនដែរ ដើម្បីជៀសផុតពីជំនន់ ពីព្រោះទឹកបារាយត្រូវបានគេបន្ថែមឱ្យច្រើន ហើយខឿននេះប្រហែលមានការជួសជុល ឬកែប្រែធ្វើឱ្យខ្ពស់ជាងដំណាក់កាលទី១។ ក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៧ កំពង់ទឹកនេះ ត្រូវបានទុកចោលមួយអន្លើ ហើយប្រហែលជានៅក្រោយសម័យអង្គរ ឬមុននេះបន្តិច ឃើញមានស្លាកស្នាមជួសជុលដើម្បីប្រើប្រាស់បន្ត។

អ្នកគ្រប់គ្រងការដ្ឋានជួសជុលកំពង់ទឹកនាទិសខាងកើតរបស់ប្រាសាទព្រះខ័ន ឱ្យដឹងទៀតថា ការជួសជុលកំពង់ទឹកនេះ គឺជួសជុលអន្តរាគមន៍ក្នុងកម្រិតមួយអតិបរិមា ធ្វើយ៉ាងណារៀបចំជណ្តើរ រៀបចំថ្មកម្រាល រៀបចំជញ្ជាំងនៃខឿនឱ្យរឹងឡើងវិញ ដើម្បីបង្ហាញអំពីតួនាទីរបស់កំពង់ទឹក និងទំនាក់ទំនងរវាងប្រាសាទព្រះខ័ន ជាមួយបារាយជ័យតដាក និងប្រាសាទនាគព័ន្ធ។ គោលបំណងនៃការជួសជុល គឺពង្រឹងតែផ្នែកខូចខាតទ្រុឌទ្រោមខ្លាំងឱ្យរឹងមាំ ដើម្បីបង្ហាញឱ្យឃើញនូវគ្រប់ស្រទាប់ប្រវត្តិសាស្ត្រ ចាប់តាំងពីសម័យកសាង រហូតមកដល់បច្ចុប្បន្ន៕

## ក្រុមការងារសម្អាតបរិស្ថានចុះកាត់ស្មៅនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣

ក្រុមការងារសម្អាតបរិស្ថាននៅតំបន់រមណីយដ្ឋានអង្គរ បានចុះកាត់ស្មៅនៅកសិន្ទុមុខប្រាសាទអង្គរវត្តដែលជាការងារប្រចាំថ្ងៃរបស់ពួកគេ ដោយចល័តពីទីតាំងមួយទៅមួយ ដើម្បីបរិស្ថានអង្គរមានសោភ័ណភាពស្រស់បំព្រង។ ជ្បិតរដូវវស្សាស្មៅឆាប់ដុះវែងបន្តិចពិតមែន តែក្រុមការងារសម្អាតនៅតែប្រឹងប្រែងចុះកាត់ដកដោយមិនឱ្យស្គុកពេកនោះទេ៕

# ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក អាជ្ញាធរជាតិអប្សរា ចំនួនជិត៥០០នាក់ បានរួមគ្នាដាំកូនឈើ និងស្មៅ នៅខាងមុខប្រាសាទអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣

កូនឈើចម្រុះចំនួន១២០០ដើម និងស្មៅចំនួន៤០០ម៉ែត្រការ៉េ ត្រូវបានដាំដុះនៅលើផ្ទៃដីចំនួនកន្លះហិកតា នាបរិវេណខាងមុខប្រាសាទអង្គរវត្ត ក្បែរស្រះត្រពាំងសេស។ នៅព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣នេះ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយក រួមទាំងអគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាន ព្រមទាំងមន្ត្រី បុគ្គលិក នាយកដ្ឋានចំណុះនៃអាជ្ញាធរជាតិអប្សរា ប្រមាណ៥០០នាក់ បានរួមគ្នាដាំកូនឈើចម្រុះចំនួន១,២០០ដើម និងស្មៅចំនួន៤០០ម៉ែត្រការ៉េ នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ក្បែរស្រះទឹកត្រពាំងសេស។

**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ក្នុងឱកាសនោះថាក្រោយការបង្កើតឱ្យមាននាយកដ្ឋានគ្រប់គ្រងទឹកនិងព្រៃឈើ នាអំឡុងឆ្នាំ២០០៤មក នាយកដ្ឋាននេះបានរៀបចំផែនការធ្វើយ៉ាងណាឱ្យតំបន់រមណីយដ្ឋានអង្គរ មានដើមឈើកាន់តែច្រើន។

ដោយក្នុងរយៈពេល១៩ឆ្នាំកន្លងមកនេះ ដើមឈើសរុបប្រមាណ២លានដើមហើយ ត្រូវបានដាំដុះនៅក្នុងតំបន់អង្គរ នេះមិនបានរាប់បញ្ចូលការចែកចាយកូនឈើ ទៅកាន់ស្ថាប័នរដ្ឋនិងឯកជនឡើយ។ឯកឧត្តមបានបញ្ជាក់ទៀតថា នៅក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣នេះ ក្រោយការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំឡើងវិញនៅក្នុងតំបន់អង្គរ ដោះស្រាយនូវបញ្ហាផលប៉ះពាល់ទេសភាពវប្បធម៌ និងតម្លៃជាសកលរបស់អង្គរ ទើបអាជ្ញាធរជាតិអប្សរា មានឱកាសដើម្បីបង្កើនការថែទាំនិងលើកតម្លៃតំបន់រមណីយដ្ឋានអង្គរ។ ក្នុងនោះចាប់ពីអំឡុងចុងឆ្នាំ២០២២ មកដល់បច្ចុប្បន្ន កូនឈើចម្រុះចំនួនជាង៤៧,០០០ដើម ត្រូវបានដាំដុះយ៉ាងឆាប់រហ័ស លើផ្ទៃដីទំនេរ នៅជុំវិញតំបន់អង្គរ។

ឯកឧត្តម បានគូសបញ្ជាក់បន្ថែមអំពីអត្ថប្រយោជន៍ជាច្រើនរបស់ដើមឈើ ជាពិសេសសម្រាប់ប្រាសាទបុរាណ ក្នុងនោះធាតុបីដែលមិនអាចចែកដាច់ពីគ្នាបាន រួមមាន៖ ទឹក ព្រៃឈើ និងប្រាសាទ។ ដូចយើងដឹងហើយថា ស្ថេរភាពរបស់ប្រាសាទត្រូវមានទំនាក់ទំនងនឹងទឹកក្រោមដី ដូច្នេះបើសិនជាយើងដាំដើមឈើ ដើមឈើទាំងនោះនឹងជួយកាត់បន្ថយភាពរំហួតនៃទឹកនៅក្រោមដី។ ក្នុងនោះដើមឈើ ដុះនៅជិតប្រាសាទ នឹងបញ្ចេញសំណើម ធ្វើស្មើសំយោគ ជួយកាត់បន្ថយកម្ដៅនៃប្រាសាទ ជាហេតុនាំឱ្យថ្មមិនងាយនិងប្រេះ ឬរលំ ឬភាពសិករិករឹលនៃប្រាសាទ។ មួយវិញទៀត ព្រៃឈើ នឹងជួយកាត់បន្ថយល្បឿនខ្យល់ ដែលអាចមានផលប៉ះពាល់ទៅដល់ប្រាសាទបុរាណផងដែរ។ឯកឧត្តមអគ្គនាយកមានប្រសាន៍បន្ថែមទៀតថា ទីតាំងដែលបានដាំស្មៅ និងកូនឈើឡើងវិញនេះ ជាទីតាំងល្អបំផុតនៅបរិវេណខាងមុខប្រាសាទអង្គរ ព្រោះទីនេះកន្លងមកជាកន្លែងដែលអាជ្ញាធរជាតិអប្សរា រៀបចំជាសំណង់សម្រាប់ដាក់សម្ភារៈ ដើម្បីបម្រើការងារជួសជុលស្ថានហាល និងការប្រើប្រាស់ផ្សេងៗ។

អាជ្ញាធរជាតិអប្សរា មានក្ដីសង្ឃឹមថា ពីមួយថ្ងៃទៅមួយថ្ងៃ តំបន់អង្គរ នឹងកាន់តែមានភាពស្រស់បំព្រង ពោពេញទៅដោយព្រៃឈើ មានលក្ខណៈលម្អដល់ប្រាសាទ និងបន្ថែមគុណភាពនៃជីវិត សម្រាប់ភ្ញៀវទេសចរដែលចូលមកទស្សនាតំបន់រមណីយដ្ឋានអង្គរ៕

# ក្រុមការងារពិនិត្យសម្បទាទេសចរណ៍ក្នុងតំបន់អង្គរ ជួសជុលជណ្តើរថ្មីមួយកន្លែងនៅប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣

ក្រុមការងារពិនិត្យសម្បទាទេសចរណ៍ (TSC) ក្នុងតំបន់អង្គរនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ និងវប្បធម៌ បានជួសជុលជណ្តើរមួយកន្លែងនៅប្រាសាទតាព្រហ្ម។ លោក ប៊ូ ផានេត នៃក្រុមការងារ TSC បានឱ្យថា ជណ្តើរដែលបានដំឡើងថ្មីនេះស្ថិតនៅចំណុចដើមឈើពស់ ចុះទៅកន្លែងគក់ទ្រូង នៃប្រាសាទតាព្រហ្ម។ លោកបន្ថែមថា ជណ្តើរនេះជំនួសជណ្តើរចាស់ដែលមានសភាពទ្រុឌទ្រោម និងមានប្រវែងបណ្តោយ ៣.៣០ម៉ និងទទឹង ១.៥០ម៉។

លោក ប៊ូ ផានេត បានបញ្ជាក់ថា គោលបំណងនៃការរៀបចំខាងលើនេះ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ ដល់ភ្ញៀវទេសចរ ខណៈជណ្តើរចាស់មានសភាពរង្គើ ពុកផុយ និងមានភាពរអិលផងដែរនារដូវវស្សានេះ៕

# ក្រុមអ្នកជំនាញកំពុងធ្វើការពង្រឹងរចនាសម្ពន្ធខឿនជ្រុងនិរតី និងទប់ស្កាត់ការហូរច្រោះនៃល្បាយដីខ្សាច់ពីខាងក្នុងគ្រឹះ នៃរួតទី៣ប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញ នៃអាជ្ញាធរជាតិអប្សរាបានកត់សម្គាល់ឃើញថា មានទីតាំងមួយចំនួននៅជុំវិញខឿនរួតទី៣របស់ប្រាសាទបាយ័នឃើញមានល្បាយដីខ្សាច់ហូរច្រោះចេញតាមចន្លោះជញ្ជាំងក្រោយពេលមានភ្លៀង ដែលវាអាចនឹងបង្កជាហានិភ័យដល់ប្រាសាទបុរាណមួយនេះបាន។ ក្រុមស្ថាបត្យករ និងវិស្វករកំពុងតែធ្វើការសិក្សា និងស្វែងរកវិធីសាស្ត្រដើម្បីទប់ស្កាត់ការហូរច្រោះនៃល្បាយដីខ្សាច់ព្រមទាំងធ្វើការពង្រឹងរចនាសម្ពន្ធខឿនដែលមានហានិភ័យនោះឡើងវិញ។

ស្ថាបត្យករ និងជាក្រុមការងារបច្ចេកទេសជួសជុលខឿនរួតទី៣របស់ប្រាសាទបាយ័ន កញ្ញា ម៉េង សុវណ្ណលីលីន មានប្រសាសន៍ថា  កាលពីចុងឆ្នាំ២០២១ក្រុមការងារធ្លាប់បានសម្អាតកំណកដីនៅតាមប្រព័ន្ធបង្ហូរទឹកជុំវិញរួតទី៣ប្រាសាទបាយ័នម្តងរួចហើយ ប៉ុន្តែមួយឆ្នាំក្រោយមក យើងនៅឃើញមានល្បាយដីខ្សាច់នៅតែបន្តហូរច្រោះចេញមកតាមជញ្ជាំងខឿនរួតទី៣នៃប្រាសាទបាយ័នដដែលដែលវាជាមូលហេតុចម្បងនាំឱ្យមានការពង្រឹងខឿនជ្រុងនិរតីនៃរួតទី៣នេះឡើងវិញ។

កញ្ញាបន្តទៀតថា ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាបានសិក្សាស្រាវជ្រាវដើម្បីរកឱ្យឃើញថា មូលហេតុអ្វីដែលបណ្តាលឱ្យដីខ្សាច់ហូរច្រោះបែបនេះ?។ ក្នុងនោះមានមូលហេតុសំខាន់ៗមួយចំនួនដូចជា ទី១.បញ្ហាឫសឈើកាលពីអតីតកាលបានដុះចាក់ចូលទៅក្នុងរចនាសម្ពន្ធធ្វើឱ្យថ្មមួយចំនួនរំកិលចេញពីទីតាំងដើម និងបង្កើតបានជាប្រហោងនៅតាមចន្លោះថ្ម។ទី២.បញ្ហាទឹកហូរច្រោះចូលទៅតាមប្រហោងថ្មដែលអាចនាំល្បាយដីខ្សាច់ចេញមកក្រៅបាន ទី៣.បាយអស៊ីម៉ងត៍ដែលបានបំពេញនៅតាមចន្លោះថ្មកម្រាលដោយអ្នកអភិរក្សជនជាតិបារាំងដល់បច្ចុប្បន្នអស់គុណភាពដែលធ្វើឱ្យបរិមាណទឹកភ្លៀងហូរចូលទៅខាងក្នុងខឿនច្រើនលើសកម្រិតនិងទី៤.ដីគ្រឹះខាងក្នុងជាប្រភេទដីខ្សាច់សុទ្ធនិងមានគ្រាប់រាងធំ កាលណាខ្សាច់មានគ្រាប់ធំពុំមានគ្រាប់ទំហំតូចគឺវាមិនសូវមានភាពស្អិតល្អទេពេលមានភ្លៀងម្តងៗទឹកងាយនឹងហូរនាំល្បាយដីខ្សាច់ចេញទៅតាមប្រហោងថ្ម។ កិច្ចការនេះ បានចាប់ផ្តើមតាំងពីចុងឆ្នាំ២០២២មក ដោយធ្វើការរើថ្មដែលក្រៀកចេញរួចរៀបចូលទីតាំងវិញ និងការយកសំណាកដីផ្នែកខាងក្នុងខឿនទៅធ្វើការវិភាគដើម្បីឱ្យដឹងថាតើស្រទាប់ដីជម្រៅណាមានសភាពខ្សោយដែលត្រូវពង្រឹងឡើងវិញ?។

# ស្ត្រីចូលរួមជួសជុលប្រាសាទបុរាណដោយទឹកចិត្តតស៊ូ និងស្រឡាញ់

ផ្សាយនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣

នៅតាមការដ្ឋានជួសជុលប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ ក្រៅតែពីឃើញមានបុរសនិងស្ត្រីជាប្រធានគ្រប់គ្រងការដ្ឋាន ក្នុងនោះក៏មានបុរស និងស្ត្រី ដែលជាកម្មការិនីចូលរួមធ្វើការងារនេះចម្រុះគ្នា។ តួយ៉ាង នៅការដ្ឋានជួសជុលប្រាសាទត្រពាំងល្ពៅ ឬត្រពាំងរពៅ គេឃើញមានស្ត្រីជាច្រើនជិតស្មើនិងក្រុមបុរស មានសកម្មភាពមមាញឹកបម្រើការងារលើវិស័យអភិរក្ស និងជួសជុលប្រាសាទឥដ្ឋ។ ករណីនេះបញ្ជាក់ឱ្យឃើញថា ស្ត្រីក៏ជាផ្នែកមួយសំខាន់ក្នុងការចូលរួមអភិរក្ស និងជួសជុលប្រាសាទបុរាណដែរ។

ពលការិនីម្នាក់ក្នុងចំណោមអ្នកបម្រើការងារនៅប្រាសាទត្រពាំងល្ពៅ អ្នកស្រី ម៉ែន រើន រស់នៅភូមិនគរក្រៅ អាយុ៤៣ឆ្នាំ បានចូលបម្រើការងារនៅអាជ្ញាធរជាតិអប្សរាតាំងតែពីឆ្នាំ២០០០ម្ល៉េះ ដោយធ្វើជាភ្នាក់ងារទេសចរណ៍នៅតាមប្រាសាទ។ លុះដល់ឆ្នាំ២០១៣ អ្នកស្រីម៉ែន រើន ត្រូវបានផ្លាស់ប្តូរការងារពីភ្នាក់ងារទេសចរណ៍នៅតាមប្រាសាទមកជាអ្នកជួសជុលប្រាសាទឥដ្ឋវិញម្តង។ អ្នកស្រី ម៉ែន រើន ឱ្យដឹងថា ក្នុងពេលចាប់ផ្តើមធ្វើការងារជាអ្នកជួសជុលប្រាសាទដំបូង គឺអ្នកស្រីជួបការលំបាកខ្លាំងណាស់ ព្រោះមិនមានបទពិសោធន៍លើផ្នែកនេះពីមុនមក។ កាលពីដំបូងសូម្បីតែលាយកំបោរបាយអរក៏មិនងាយស្រួល។ នៅពេលលាយការស្បែកគោម្តងៗ វាមានក្លិន កំបោរក៏ហ៊ុយ។ ពេលក្រុមការងារកាត់ឥដ្ឋក៏ហ៊ុយហើយអ្នកស្រីគិតក្នុងចិត្តថា មិនដឹងជានៅតស៊ូធ្វើបានប៉ុណ្ណានោះទេ ក៏ប៉ុន្តែដោយសារតែទឹកចិត្តស្រឡាញ់ ចេះតែជំនះធ្វើការងារជួសជុលប្រាសាទនេះ រហូតមកដល់សព្វថ្ងៃបានចំនួន១០ឆ្នាំហើយ និងបានចូលរួមជួសជុលប្រាសាទគោកចក ប្រាសាទក្រវ៉ាន់ និងបច្ចុប្បន្នជួសជុលនៅប្រាសាទត្រពាំងល្ពៅនេះ។

រយៈពេល១០ឆ្នាំមកនេះ អ្នកស្រី ម៉ែន រើន មានភាពស្ទាត់ជំនាញជាច្រើនផ្នែកដូចជា បច្ចេកទេសជួសជុលប្រាសាទឥដ្ឋ របៀបផលិតកំបោរបាយអរ ការសម្អាតទីតាំងជួសជុល ការបិទពង្រឹងឥដ្ឋ និងរៀនពីការសម្រង់ប្លង់ជាដើម ហើយក៏មិនមានចិត្តនឹងបោះបង់ការងារនេះឡើយ។

# ប្រាសាទបេងមាលា- រមណីយដ្ឋានប្រវត្តិសាស្ត្រ ដែលផ្សារភ្ជាប់ជាមួយនិងធម្មជាតិស្ងប់ស្ងាត់គួរជាទីគយគន់

ផ្សាយនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣

# រមណីយដ្ឋានក្បាលស្ពាន-បុរាណស្ថានដែលគេមានជំនឿថានាំមកនូវទឹកមន្តស័ក្តិសិទ្ធិ

ផ្សាយនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរា បើកសិក្ខាសាលាផ្ទៃក្នុង ស្តីពីដំណើរអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ

ផ្សាយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣

នៅស្នាក់ការអាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាផ្ទៃក្នុងស្តីពី «ដំណើរអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ (សម្បត្តិវប្បធម៌ បរិស្ថាន និងសង្គមមនុស្ស)» ដើម្បីផ្សព្វផ្សាយសៀវភៅប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ រួមទាំងស្វែងយល់ និងចូលរួមការពារបរិស្ថានក្នុងតំបន់អង្គរ ដល់មន្ត្រី-បុគ្គលិក សរុបចំនួន ១០០នាក់ ក្រោមអធិបតីភាព**ឯកឧត្តម សុខ លក្ខិណា** តំណាង**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងជាអ្នកតំណាងគ្រប់គ្រងបរិស្ថានអង្គរ នៅព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣។

សិក្ខាសាលានាឱកាសនេះមានបទបង្ហាញចំនួន៣សំខាន់ៗ ពីវាគ្មិនដែលជាមន្ត្រីជំនាញរបស់អាជ្ញាធរជាតិអប្សរា។ ទី១ បទបង្ហាញស្តីពី សម្បត្តិវប្បធម៌-បរិស្ថាន និងសង្គមមនុស្ស។ ទី២ បទបង្ហាញស្តីពី ការរួមចំណែករបស់នាយកដ្ឋានគ្រប់គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍ ក្នុងដំណើរការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ។ ទី៣ បទបង្ហាញស្តីពី ប្រាសាទក្នុងរមណីយដ្ឋានអង្គរ និងការជួសជុល។ បន្ថែមពីលើនេះ ក៏មានសំណួរ-ចម្លើយ និងមតិសំណូមពរផ្សេងៗ ដើម្បីឱ្យសិក្ខាសាលាកាន់តែមានប្រសិទ្ធិភាពខ្ពស់។

សូមរំឭកថា អាជ្ញាធរជាតិអប្សរា តែងតែរៀបចំសិក្ខាសាលាស្តីពីដំណើរការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរជាទៀងទាត់ ៤ដងក្នុងមួយឆ្នាំ ដល់មន្ត្រី-បុគ្គលិកគ្រប់រូប ដើម្បីការចូលរួមអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ជួយថែរក្សាការពារមរតក និងបរិស្ថានអង្គរឱ្យបានគង់វង្ស៕

# អាជ្ញាធរជាតិអប្សរាកំពុងជួយសង្គ្រោះគ្រឹះ និងបង្កាន់ដៃនាគនៅជាន់ផ្ទាល់ដី ភាគខាងត្បូងនៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរាកំពុងតែប្រឹងប្រែងជួយសង្គ្រោះដោយជួសជុល និងបង្ហាប់គ្រឹះបង្កាន់ដៃនាគដែលធ្វើអំពីថ្មភក់នៅជាន់ផ្ទាល់ដីនាភាគខាងត្បូងរបស់ប្រាសាទអង្គរវត្ត ត្រង់ប្រកកណ្តាលចេញពីខ្លោងទ្វារតាពេជ្រ ដើម្បីឱ្យរួចផុតពីហានិភ័យខ្ពស់។

បុរាណវិទូ និងជាភ្នាក់ងារអភិរក្សប្រាសាទអង្គរវត្ត នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា លោក សយ សុភារិទ្ធ ឱ្យដឹងថា បច្ចុប្បន្នបង្កាន់ដៃនាគ និងជើងទម្រធ្វើពីថ្មភក់របស់ប្រាសាទអង្គរវត្តភាគខាងកើត នៃជណ្តើរខាងត្បូងដែលមានអាយុកាលជិតពាន់ឆ្នាំប្រវែងប្រហែល ១០ម៉ែត្រ កំពុងមានហានិភ័យខ្ពស់ ដោយកន្លែងខ្លះថ្មបានបាក់បែក និងគ្រឹះរបស់វាត្រូវទឹកភ្លៀងហូរច្រោះដីបណ្តាលឱ្យដុំថ្មរបស់ខឿនធំៗញែកចេញពីគ្នាធ្វើឱ្យទ្រេតខ្លាំង ប្រឈមមុខនឹងការរលំក្បាលនាគ។

លោកឱ្យដឹងទៀតថា ចាប់តាំងតែពីដើមខែកក្កដា មកក្រុមការងារបានរុះរើបង្កាន់ដៃ និងក្បាលនាគនៅទីនោះជាបណ្តោះអាសន្ន ក្រោយពីមានការឯកភាពពីអ្នកជំនាញការអាជហុក ហើយចាប់ពីដើមខែសីហានេះ ក្រុមការងារក៏បានចាប់ផ្តើមរុះរើផ្ទាំងថ្ម ខឿនរបស់បង្កាន់ដៃនាគទីនោះដើម្បីរើថ្មក្រៀកចេញហើយសម្អាតកម្ទេចដីរួចដាក់ចូលទីតាំងដើមវិញ។

ក្រុមអ្នកជួសជុលឱ្យដឹងថា ក្នុងការងារជួយសង្គ្រោះបង្កាន់ដៃនាគនៅជាន់ផ្ទាល់ដីនាភាគខាងកើតនៃជណ្តើរខាងត្បូងរបស់ប្រាសាទអង្គរវត្តនោះ គឺគេធ្វើការងារជាច្រើនទៅតាមបច្ចេកទេសដូចជា ត្រូវដកជាតិអំបិលចេញពីថ្មនៅតាមកន្លែងខ្លះ រីឯខ្លួននាគដែលបាក់បែក គឺត្រូវប្រើបច្ចេកទេសតភ្ជាប់និងផ្គុំថ្មឡើងវិញហើយត្រង់កន្លែងណាដែលបាត់បង់គឺត្រូវឆ្លាក់ថ្មថ្មីមកដាក់ជំនួស។ ចំណែកឯជើងទម្រនាគដែលបាក់បែក ក៏ត្រូវពង្រឹងឡើងវិញ ដើម្បីប្រែក្លាយពីហានិភ័យឱ្យទៅជាសុវត្ថិភាព។

បុរាណវិទូលោក សយ សុភារិន្ទ មានប្រសាសន៍ថាដើម្បីជួសជុលនិងជួយសង្គ្រោះគ្រឹះ និងបង្កាន់ដៃនាគដែលធ្វើអំពីថ្មភក់នៅជាន់ផ្ទាល់ដីនាភាគខាងកើតរបស់ប្រាសាទអង្គរវត្តត្រង់ច្រកកណ្តាលចេញពីខ្លោងទ្វារតាពេជ្រនោះឱ្យរឹងមាំឡើងវិញ គឺក្រុមការងារអាចនឹងចំណាយពេលប្រហែល៣ខែ។ បុរាណវិទូដដែលឱ្យដឹងទៀតថា បច្ចុប្បន្ននេះគឺមានបង្កាន់ដៃនាគនៅតាមច្រកចូលជុំវិញប្រាសាទអង្គរវត្តជាច្រើនកន្លែងកំពុងស្ថិតក្នុងហានិភ័យ ប៉ុន្តែពេលនេះក្រុមការងារបានចាប់ផ្តើមជួសជុលគ្រឹះបង្កាន់ដៃនាគនៅជាន់ផ្ទាល់ដីនាភាគខាងកើតនៃជណ្តើរខាងត្បូងរបស់ប្រាសាទអង្គរវត្តត្រង់ច្រកកណ្តាលចេញពីខ្លោងទ្វារតាពេជ្រមួយសិន បន្ទាប់ពីបញ្ចប់ជួសជុលបង្កាន់ដៃនាគនេះ គឺក្រុមការងារនឹងចាប់ផ្តើមជួយសង្គ្រោះបង្កាន់ដៃនាគនៅតាមច្រកចូលជុំវិញប្រាសាទអង្គរវត្តជាបន្តបន្ទាប់ទៀត៕

# សេចក្ដីជូនដំណឹង ស្ដីពីការកាត់ជកហូតដើមឈើ និងកាត់ក្រីមែកឈើ មានហានិភ័យខ្ពស់ នៅបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៦១៣/២៣ រ.ប.អស្ឋា

**សេចក្ដីជូនដំណឹង**
**ស្ដីពី**
**ការកាត់ជកហូតដើមឈើនិងកាត់ក្រីមែកឈើ**
**មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ**

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ និងក្នុងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរានឹងកាត់ជកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ជកហូតដើមឈើ និងកាត់ក្រីមែកឈើចំនួន០៨ដើម (ជកហូតដើមស្វាយ៤ដើម និងកាត់ក្រីដើមសិរមាន់០១ដើម ប្រេងខ្យល់០១ដើម ដើមឆ្កោត០១ដើម គគីរ០១ដើម) ស្ថិតនៅខាងត្បូង និងខាងកើតប្រាសាទបាគង។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន០៥ដើម (កាត់ជកហូតពង្រងាប់០១ដើម និងកាត់ក្រីឈើទាល០៤ដើម ចាមរ៉ែ០៣ដើម បេង០១ដើម) ស្ថិតនៅប្រាសាទចៅសាយទេវតា និងប្រាសាទធម្មនន្ទ។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន១៥ដើម (កាត់ជកហូតឈើទាល២ដើម ស្វាយ០១គុម្ព សង្កែ១ដើម និងកាត់ក្រីឈើទាល៥ដើម ស្លែង០១ដើម រការ១ដើម) ស្ថិតនៅខាងត្បូងឆៀងខាងកើត និងខាងត្បូងប្រាសាទបាយ័ន។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន០៥ដើម (កាត់ជកហូតក្រឡាញ់១ដើម និងកាត់ក្រីគគីរ១ដើម ក្រាច១ដើម ឈើទាល២ដើម ស្វាយព្រៃ៤ដើម) ស្ថិតនៅតាមផ្លូវខាងជើងប្រាសាទបាគង និងក្បែរគួបលក់ដូរប្រាសាទព្រះគោ។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន៥២ដើម (កាត់ជកហូតដើមស្វាយ១គុម្ព ដើមឈើទាល៣ដើម និងកាត់ក្រីឈើទាល៤២ដើម ចាមរ៉ែ១ដើម គគីរ១ដើម ដើមស្វាយ១ដើម ដើមពោធិ៍១ដើម ដើមក្រសាំង២ដើម)។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន៥ដើម (កាត់ជកហូតអាកាស្យា២ដើម ប្រេងខ្យល់១ដើម និងកាត់ក្រីឈើទាល៥ដើម ចំបក់១ដើម) ស្ថិតនៅបរិវេណប៉ុស្ដិ៍នគរបាលស្រះស្រង់ និងតាមផ្លូវមុខប្រាសាទបន្ទាយក្ដី។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន៧ដើម (កាត់ជកហូតដើមក្រាយ១ដើម និងកាត់ក្រីឈើទាល៥ដើម ធ្នង់១ដើម) ស្ថិតនៅចំណតរថយន្តថ្មីប្រាសាទតាកែវ។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន២ដើម (កាត់ជកហូតម្កាក់ព្រៃងាប់១ដើម និងកាត់ក្រីចាមរ៉ែ១ដើម) ស្ថិតនៅជាប់មាត់ស្រះប្រាសាទស្រៀក្រខាងត្បូង។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្ដើមអនុវត្តការងារខាងលើ ចាប់ពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអាទិត្យ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣
**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

# សេចក្តីជូនដំណឹង ស្តីពីការផ្អាកចរាចរយានជំនិះគ្រប់ប្រភេទជាបណ្តោះអាសន្ន នៅកំណាត់ផ្លូវចាប់ពីចំណុចផ្លូវបំបែកវិថីព្រះនរោត្តមសីហមុនី (ផ្លូវក្កូម៉ែ) ហូតដល់កែងកសិន្ទុប្រាសាទអង្គរវត្តទិសនិរតី

ផ្សាយនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ: ៦១៤/ស.អ.សជណ
/២៣

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការផ្អាកចរាចរយានជំនិះគ្រប់ប្រភេទជាបណ្តោះអាសន្ន នៅកំណាត់ផ្លូវចាប់ពីចំណុចផ្លូវបំបែកវិថីព្រះនរោត្តមសីហមុនី (ផ្លូវក្កូម៉ែ) ហូតដល់កែងកសិន្ទុ ប្រាសាទអង្គរវត្តទិសនិរតី**

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបថា ក្នុងគោលបំណងអនុវត្តគម្រោងលើកកម្ពស់ផ្ទៃរាបស្មើរាយកៅស៊ូ ស្តារប្រព័ន្ធធារាសាស្ត្របុរាណនាសម័យអង្គរ និងរៀបចំប្រព័ន្ធរំដោះទឹកជំនន់ពីទិសខាងត្បូងប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរានឹងផ្អាកចរាចរយានជំនិះគ្រប់ប្រភេទជាបណ្តោះអាសន្ន នៅកំណាត់ផ្លូវចាប់ពីចំណុចផ្លូវបំបែកវិថីព្រះនរោត្តមសីហមុនី (ផ្លូវក្កូម៉ែ) រហូតដល់កែងកសិន្ទុប្រាសាទអង្គរវត្តទិសនិរតី ដូចមានផែនទីជូនភ្ជាប់ ចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ រហូតដល់ចប់ការងារជាស្ថាពរ។ ក្នុងអំឡុងពេលអនុវត្តគម្រោងរៀបចំហេដ្ឋារចនាសម្ព័ន្ធនេះ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋអាចចរាចរលើផ្លូវជុំវិញនោះបានជាធម្មតា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៦ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០២៣
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province
1/1

# លិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ឆ្មាំ កម្មករ និងពលករ នៃអាជ្ញាធរជាតិអប្សរា គោរពអបអរសាទរ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត ក្នុងឱកាសដែលសម័យប្រជុំរដ្ឋសភាជាតិលើកទី១ នីតិកាលទី៧ បានផ្តល់សេចក្តីទុកចិត្តបោះឆ្នោតអនុម័តទាំងស្រុងលើសមាសភាពគណៈរដ្ឋមន្ត្រីថ្មី ដែលមានឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត ជា នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតអបអរសាទរ

សូមគោរពជូន

ហ៊ុន ម៉ាណែត

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## អង្គការ Norwegian People´s Aid ចូលរួមដាំកូនឈើនៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ អង្គការ Norwegian People´s Aid ដែលជាអង្គការដោះមីននៃប្រទេសណ័រវេស ក្នុងឱកាសដឹកនាំបុគ្គលិកធ្វើដំណើរកម្សាន្តក្នុងខេត្តសៀមរាប បានចូលរួមដាំកូនឈើ នៅខាងត្បូងកសិន្ធុអង្គរវត្ត។

ថ្នាក់ដឹកនាំ និងបុគ្គលិកនៃអង្គការ Norwegian People´s Aid ចំនួន៩០នាក់ បានចូលរួមដាំកូនឈើចំនួន ១៨០ដើម និងស្មៅ៣០០ម៉ែត្រការ៉េ នៅក្នុងរមណីយដ្ឋានអង្គរ។ ដើមឈើដែលដាំនៅពេលនេះរួមមាន ដើមបេង ធ្នង់ រំដួល និងគគីរ។ សកម្មភាពនេះកំពុងចូលរួមលើកតម្លៃបរិស្ថាន និងបង្កើតភាពបៃតង ក្នុងតំបន់រមណីយដ្ឋានអង្គរ ស្របពេលអាជ្ញាធរជាតិអប្សរារៀបចំ កែលម្អ តំបន់ពុំមាន របៀបរៀបរយ ដោយដាំបំពេញដើមឈើ និងស្មៅឡើងវិញ។

លោក ជូ រ៉ាឌីណា អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹកព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានលើកឡើងថា គិតពីឆ្នាំ២០២២មក អាជ្ញាធរជាតិអប្សរា បានដាំកូនឈើបានជាង ៤៨,៧៨៨ដើម និងដាំស្មៅបាន ៣៥,៥៣១ម៉ែត្រការ៉េ គឺដាំនៅតាមដីដែលបានសម្អាតលើទីតាំងចាស់ ពលរដ្ឋរស់នៅ បន្ទាប់ពីពួកគេព្រមទទួលយកគោលនយោបាយពីរាជរដ្ឋាភិបាល ចេញទៅរស់នៅ តំបន់ រុនតាឯក និងពាក់ស្នែង៕

## សូមភ្ញៀវទេសចរទាំងអស់ បង្កើនការប្រុងប្រយ័ត្នចំពោះសត្វស្វានៅក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣

សត្វស្វាមួយចំនួននៅរមណីយដ្ឋានអង្គរ ជាពិសេស នៅប្រាសាទអង្គរវត្ត និងក្រុងអង្គរធំ បានខាំ ឬខ្វាច និងដណ្តើមរបស់របរពីភ្ញៀវទេសចរជាច្រើនករណី។ ជាក់ស្តែងនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារភ្នាក់ទេសចរបានជួយសង្គ្រោះបឋមដល់ភ្ញៀវជនជាតិថៃ ឈ្មោះ Mr.Jiraweth អាយុ៣៩ឆ្នាំ ដែលត្រូវបានស្វាខាំនៅខាងត្បូងបណ្ណាល័យខាងត្បូង។

លោក ចាន់ សំណាង ប្រធានគ្រប់គ្រងរួមភ្នាក់ងារទេសចរណ៍បានឱ្យដឹងថា ក្រោយពីមានករណីភ្ញៀវម្នាក់ត្រូវបានស្វាខាំ ភ្នាក់ងារទេសចរណ៍ប្រចាំនៅគោលដៅបានសង្គ្រោះបឋម ដោយជូតសម្អាតមុខរបួសដែលស្វាខាំ ឬខ្វាចនោះ និងឱ្យអ្នករងរបួសទៅចាក់ថ្នាំបង្ការផង។

ប្រធានគ្រប់គ្រងរួមភ្នាក់ងារទេសចរណ៍ បញ្ជាក់ថា កន្លងមកមានស្វាកាចៗមួយចំនួនដែលខាំភ្ញៀវទេសចរ ជាស្វាដែលសាំនិងមនុស្ស ព្រោះការផ្តល់ចំណីបានប្រែពីប្រភេទសត្វព្រៃមកជាសត្វចិញ្ចឹម និងស្វាមួយចំនួនទៀត ត្រូវបានគេលួចយកមកព្រលែងនៅព្រៃអង្គរ៕

# ប្រាសាទបាយ័ន គោលដៅទេសចរដ៏សំខាន់មួយ បន្ទាប់ពីប្រាសាទអង្គរវត្ត ដែលភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិ មិនដែលរំលង

ផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣

# ស្ទឹងលិង្គ ១000 គឺជាតំបន់ទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ ដែលមានចម្លាក់លិង្គជាច្រើន ត្រូវបានឆ្លាក់លើថ្មតក់បាតស្ទឹងដ៏ស្រស់ស្អាត ប្លែក មិនគួរឱ្យជឿ

ផ្សាយនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣

# ទិដ្ឋភាពថ្ងៃរះ ថ្ងៃលិច គួរឱ្យគយគន់នៅស្រះស្រង់ ជាបទពិសោធន៍ថ្មីមួយទៀត សម្រាប់ភ្ញៀវទេសចរទស្សនា មិនចាំបាច់ប្រជ្រៀតជាមួយទេសចរដទៃទៀត

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣

ស្រះស្រង់ ជាទីកន្លែងមួយដែលភ្ញៀវទេសចរ និយមមកទស្សនាទេសភាពដ៏ស្រស់ស្អាត ជាពិសេស ប្រាសាទកណ្តាលស្រះស្រង់ ភូមិឋានប្រជាពលរដ្ឋដែលរស់នៅជុំវិញនោះ និងប្រាសាទបន្ទាយក្តី ដែលមានទីតាំងនៅក្បែរនោះផង។ ទន្ទឹមនឹងនេះ នៅពេលព្រឹកព្រលឹម និងពេលល្ងាច ស្រះស្រង់ក៏ជាកន្លែងដែលអាចគយគន់ទិដ្ឋភាពថ្ងៃរះ និងថ្ងៃលិចបានយ៉ាងស្រស់ស្អាត មិនចាញ់នៅប្រាសាទអង្គរវត្ត ឬប្រាសាទភ្នំបាខែងឡើយ។

លោក ម៉ៃ សុរៈភិរុណ ប្រធានភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទបន្ទាយក្តី និងស្រះស្រង់ បានឱ្យដឹងថានៅពេលព្រឹកព្រលឹមព្រះអាទិត្យចាប់ផ្តើមរះមក មើលទៅផ្ទៃមេឃ និងផ្ទៃទឹកបញ្ចេញពន្លឺពណ៌មាសយ៉ាងស្រស់បំព្រង អាច ផ្តិចយករូបភាពទាំងនេះបាននៅ បរិវេណកំពង់ទឹក និងរានហាល ភ្ជាប់ជាមួយរូបសត្វតោឈរបែរមុខទៅរកប្រាសាទកណ្តាលស្រះស្រង់មើលទៅស្រស់ស្អាតគួរជាទីគយគន់។ ទិដ្ឋភាពថ្ងៃរះ និងថ្ងៃលិច នៅស្រះស្រង់ អាចជាកន្លែងទទួលយកបទពិសោធន៍ថ្មីមួយទៀត មានភាពខុសប្លែកពីនៅប្រាសាទអង្គរវត្ត ឬប្រាសាទភ្នំបាខែង ដោយមិនចាំបាច់ប្រជ្រៀតជាមួយទេសចរដទៃទៀតឡើយ។

ស្រះស្រង់ មានទីតាំងស្ថិតនៅទល់មុខខាងកើតប្រាសាទបន្ទាយក្តី ខាងត្បូងឆៀងខាងលិច នៃបារាយណ៍ខាងកើត។ មានបណ្តោយ៧៨០ម៉ែត្រ និងទទឹង៣៨០ម៉ែត្រ ត្រូវបានដូនតាខ្មែរជីកឡើងនៅចុងសតវត្សរ៍ទី១២ និងដើមសតវត្សរ៍ទី១៣ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧៕

# ស្វែងយល់ពីការកាត់ក្រីដើមឈើនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

ក្រុមការងារគ្រប់គ្រងហានិភ័យដើមឈើនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ កំពុងចុះកាត់ក្រីដើមឈើហានិភ័យធំៗនៅរមណីយដ្ឋានអង្គរ ខណៈដែលរដូវវស្សាការងារនេះ មានភាពមមាញឹកខុសពីរាល់ដង។

លោក ទៀន សុធី បុគ្គលិកបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានឱ្យដឹងថា ក្រុមការងាររបស់លោកបានប្រើប្រាស់ឡានស្ទូចដងវែង ដើម្បីកាត់ក្រី និងដកដើមឈើ ហានិភ័យនៅខ្លោងទ្វារជ័យ ដែលបានដុះគ្របបង្កាន់ដៃនាគ និងអាចមានហានិភ័យជាយថាហេតុ។

លោក សុធី បញ្ជាក់ថា ការកាត់ និងដកដើមឈើមានបីរបៀបដែលបាននិងកំពុងអនុវត្តន៍ ក្នុងនោះរួមមាន ប្រើឡានស្ទូច ដំឡើងរន្ទា និងឡើងដោយកម្លាំងមនុស្ស។ លោកពន្យល់ថា ការប្រើឡានស្ទូចមានភាពរហ័ស និងលឿន តែអាចប្រើប្រាស់បាននៅលើដងផ្លូវស្រឡះៗប៉ុណ្ណោះ។ ចំណែកនៅក្នុងប្រាសាទច្រើនប្រើរន្ទា និងមនុស្សឡើង ដូចជាករណីបាក់មែក ឬទ្រេតគ្របលើតួប្រាសាទ ជាដើម។ល។

ដ្បិតថា មានភាពងាយស្រួលក៏ពិតមែន តែការប្រើមធ្យោបាយឡានស្ទូចនេះ ក៏ត្រូវការកម្លាំងច្រើននាក់ មិនខុសពីមធ្យោបាយផ្សេងទៀតដែរ ពិសេសអ្នកឡើងចងខ្សែ ត្រូវការអ្នកមាន

ជំនាញស្ទាត់ ដឹងពីរបៀបចង ក្នុងនោះកម្លាំងច្រើននាក់ចាំទាញខ្សែនៅផ្នែកខាងក្រោម។ លោក សុធី បន្ថែមថា មែកឈើខ្លះត្រូវការចងខ្សែតែមួយទេ តែមែកខ្លះរៀងធំត្រូវការចងខ្សែដល់៤ក៏មានដែរ ដើម្បីធានាពីហានិភ័យមនុស្ស និងប្រាសាទ។ យ៉ាងណារបៀបនេះ អាចកាត់ដើមឈើដែលមានកម្ពស់ ៣០ម៉ែត្រចុះប៉ុណ្ណោះ លើសពីនោះគេត្រូវដំឡើងរន្ទាដើម្បីឡើងកាត់ដដែល ដូចជាដើមឈើខ្លះនៅប្រាសាទបាយ័នដែលមានកម្ពស់រហូតដល់ជាង៥០ម៉ែត្រ។

ចំពោះបច្ចេកទេសដំឡើងរន្ទាវិញ ភាគច្រើនធ្វើនៅក្នុងប្រាសាទ ដូចករណីដើមស្ពង់នៅប្រាសាទបាយ័ន។ ការប្រើរន្ទានេះ ត្រូវចំណាយពេលយូរទាំងការដំឡើង និងការរើវិញ គឺអាចប្រើពេលខ្ទង់ខែដើម្បីកាត់ក្រី ដើមឈើមួយៗបាន៕

# អាជ្ញាធរជាតិអប្សរាបានកាត់ក្រីមែកឈើ ដើម្បីសម្រួលឱ្យភ្ញៀវទេសចរ អាចមើលឃើញទិដ្ឋភាព និងចូលទស្សនាប្រាសាទក្រោលគោ

ផ្សាយនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

នៅក្នុងតំបន់រមណីយដ្ឋានអង្គរ មានប្រាសាទបុរាណចំនួនជិត១០០ប្រាសាទ ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ក្នុងនោះ ភ្ញៀវទេសចរតែងបានស្គាល់ និងនិយមទៅទស្សនាតែនៅតាមប្រាសាទបុរាណធំៗដូចជាប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទភ្នំបាខែង និងប្រាសាទបន្ទាយស្រីជាដើម។ ខណៈនៅមានប្រាសាទបុរាណជាច្រើនទៀតដែលភ្ញៀវទេសចរភាគច្រើនមិនបានស្គាល់ឬមើលរំលង។ ជាក់ស្តែង ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា បានកាត់ក្រីមែកឈើខ្លះៗនៅតាមផ្លូវចូល និងបរិវេណជុំវិញប្រាសាទ ដើម្បីអាចមើលឃើញទេសភាពនៃប្រាសាទក្រោលគោ។

លោក ទេស សុធីរ អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងវប្បធម៌នៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា សព្វថ្ងៃនេះ អាជ្ញាធរជាតិអប្សរាកំពុងតែជំរុញឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិបានស្គាល់ និងចូលទស្សនាប្រាសាទជាច្រើន ដែលសុទ្ធសឹងតែមានគុណតម្លៃជាបេតិកភណ្ឌពិភពលោក មិនចាញ់ការចូលទស្សនាប្រាសាទធំៗមួយចំនួនក្នុងតំបន់អង្គរឡើយ។ តួយ៉ាង នៅតាមផ្លូវទស្សនាវង់ធំ មានប្រាសាទបុរាណជាច្រើន ក្រៅពីប្រាសាទព្រះខ័ន និងប្រាសាទនាគព័ន្ធ ក៏នៅមានប្រាសាទខ្លះទៀតដូចជាប្រាសាទប្រើ ប្រាសាទបន្ទាយប្រើ ប្រាសាទក្រោលគោ និងប្រាសាទក្រោលរមាស ដែលភ្ញៀវទេសចរភាគតិចណាស់បានស្គាល់។

លោកសុធីរ បន្តថា ដើម្បីជំរុញកំណើនភ្ញៀវទេសចរឱ្យបានស្គាល់ទីតាំងប្រាសាទទាំងនោះកាន់តែច្រើន កាត់បន្ថយការកកស្ទះនៅប្រាសាទធំៗ ការងារចម្បងរបស់មន្ត្រីជំនាញ នៃអាជ្ញាធរជាតិអប្សរា កំពុងតែកាត់ក្រីមែកឈើខ្លះនៅតាមដងផ្លូវ និងបរិវេណជុំវិញប្រាសាទទាំងនោះ មានប្រាសាទប្រើ ប្រាសាទបន្ទាយប្រើ និងប្រាសាទក្រោលគោ ដើម្បីអាចមើលឃើញទេសភាពនៃប្រាសាទបាន។ ក្រោយពេលការងារកាត់ក្រីមែកឈើឱ្យស្រឡះល្អ ក៏ឃើញមានទេសចរខ្លះៗដើរឆ្លងកាត់បានឃើញប្រាសាទនេះ ក៏ចូលមកទស្សនាតាមច្រកកំពែងខាងលិចនៃប្រាសាទក្រោលគោ។

សូមជម្រាបថា ប្រាសាទក្រោលគោ គឺជាប្រាសាទបុរាណបែបព្រះពុទ្ធសាសនាខ្មែរ ដែលត្រូវបានកសាងឡើងនៅចុងសតវត្សរ៍ទី១២ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧។ ប្រាសាទនេះ មានទីតាំងស្ថិតនៅខាងជើងប្រាសាទនាគព័ន្ធ។ ប្រាសាទក្រោលគោ មានប្រាង្គតែមួយ ស្ថិតនៅលើលានរាងកាកបាទ និងមានបណ្ណាល័យមួយធ្វើអំពីថ្មបាយក្រៀម និងថ្មភក់បែរមុខទៅទិសខាងត្បូង។ កំពែងប្រាសាទធ្វើអំពីថ្មបាយក្រៀម ដែលមានគោបុរៈនៅទិសខាងកើត និងមានគូទឹកព័ទ្ធជុំវិញ៕

## ជណ្តើរនៅប្រាសាទបន្ទាយសំរ៉ែត្រូវជួសជុល និងកែលម្អឡើងវិញ

ផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣

ថ្មីៗនេះ ក្រុមការងារពិនិត្យសម្បទាទេសចរណ៍ (TSC) ក្នុងតំបន់អង្គរនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ និងវប្បធម៌ បានជួសជុលជណ្តើរមួយកន្លែងនៅប្រាសាទបន្ទាយសំរ៉ែ។ លោក ប៊ូ ផានេត នៃក្រុមការងារ TSC បានឱ្យថាជណ្តើរដែលបានដំឡើងថ្មីនេះ មានទំហំបណ្តោយ៤.៥០X១.៥០ម៉ែត្រ ស្ថិតនៅចំណុះវាលស្មៅខាងក្នុងប្រាសាទមុខកំពែងទី២ នៃប្រាសាទបន្ទាយសំរ៉ែ។

លោក ប៊ូ ផានេត បានបញ្ជាក់ថា គោលបំណងនៃការរៀបចំខាងលើនេះ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ សម្រួលភ្ញៀវដើរទស្សនា ខណៈជណ្តើរចាស់មានសភាពរង្គឹ ពុកផុយ និងមានភាពអិលផងដែរនារដូវវស្សានេះ៕

# ព្រឹត្តិការណ៍ព័ត៌មាន
# ប្រចាំខែកញ្ញា

# អាជ្ញាធរជាតិអប្សរា រៀបចំសិក្ខាសាលាស្តីពី វត្តអារាមនៅក្នុងឧទ្យានអង្គរ និងវត្តអារាមដទៃទៀត ស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ នៅវត្តរាជបូណ៌ អាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាស្តីពី «វត្តអារាមនៅក្នុងឧទ្យានអង្គរ និងវត្តអារាមដទៃទៀត ស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា» ក្នុងគោលបំណងបណ្តុះគំនិតស្រឡាញ់ ថែរក្សា និងអភិរក្សឧទ្យានអង្គរ ដែលជាតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក តាមរយៈការចូលរួមពីវត្តអារាម និងកែប្រែភាពអវិជ្ជមានផ្សេងៗ ដែលកើតមានតាមទីវត្តអារាម។

សិក្ខាសាលានេះ ប្រារព្ធក្រោមការនិមន្តចូលរួមដ៏ខ្ពង់ខ្ពស់របស់**សម្តេចព្រះព្រហ្មរតនមុនីសិរីសុវណ្ណោ ពិន សែម** គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តរាជបូណ៌ ក្រុង/ខេត្តសៀមរាប សម្តេចព្រះពុទ្ធជ័យមុនី បណ្ឌិត ឃឹម សន សម្តេចព្រះឧត្តមចរិយា បណ្ឌិត ឈឹង ប៊ុនឈា ព្រះមេគណ ព្រះអនុគណ ព្រះចៅអធិការ ព្រះថេរានុថេរៈ និមន្តមកពីវត្តអារាមចំនួន៦១ នៃវត្តអារាមនៅក្នុងឧទ្យានអង្គរ និងវត្តអារាមដទៃទៀត ស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា **ឯកឧត្តម នរៈ រតនវឌ្ឍនោ** រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា និង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមទាំងសហការី អាចារ្យ គណៈកម្មការវត្តអារាម សរុបប្រមាណ២០០អង្គ/នាក់។

នៅក្នុងសិក្ខាសាលាក៏មានបទបង្ហាញស្តីពី«វត្តអារាមនៅក្នុងឧទ្យានអង្គរ និងវត្តអារាមដទៃទៀត ស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា» និងឱវាទណែនាំរបស់គណៈសង្ឃនាយក **សម្តេចព្រះព្រហ្មរតនមុនីសិរីសុវណ្ណោ ពិន សែម** គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តរាជបូណ៌ ក្រុង/ខេត្តសៀមរាប **សម្តេចព្រះពុទ្ធជ័យមុនី បណ្ឌិត ឃឹម សន សម្តេចព្រះឧត្តមចរិយា បណ្ឌិត ឈឹង ប៊ុនឈា**។ លុះដល់ពេលរសៀល សិក្ខាសាលាទាំងមូលនឹងធ្វើដំណើរទស្សនកិច្ចរបស់អង្គសន្និបាតទៅកាន់វត្តពោធិ៍ពីរដើម វត្តគោកតាលន់ វត្តអង្គរខាងត្បូង និងវត្តតាព្រហ្មមានជ័យដែរ៕

## សម្រស់ធម្មជាតិខៀវខ្ចី ក្នុងបរិវេណប្រាសាទអង្គរវត្ត កំពុងរង់ចាំស្វាគមន៍ទេសចរ ជិតឆ្ងាយមកលំហែអារម្មណ៍ បន្ទាប់ពីសម្រាក់ពីកិច្ចការងារ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៣

## ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១នៃរដ្ឋសភា អញ្ជើញទស្សនកិច្ចនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៣

នៅរសៀលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** អនុប្រធានទី១នៃរដ្ឋសភា អមដំណើរដោយឯកឧត្តម លោកជំទាវជាគណៈប្រតិភូ និងមានការចូលរួមពីសំណាក់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអញ្ជើញចុះពិនិត្យនិងឈ្វេងយល់អំពីជួសជុល អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយដោយចីរភាពរមណីយដ្ឋានអង្គរ។

## ទិដ្ឋភាពផ្លូវវង់តូច អមដោយទេសភាពដ៏ស្រស់ត្រកាល កំពុងបញ្ចេញសម្រស់ទាក់ទាញភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពប្រាសាទអង្គរវត្តនាពេលព្រឹកព្រលឹមថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពថ្ងៃរះនៅស្រះស្រង់នាព្រឹកថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

# ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ និងពលករ នៃអាជ្ញាធរជាតិអប្សរា សូមគោរពអបអរសាទរជូនចំពោះ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត ដែលត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ប្រោសព្រះរាជទានគោរមងារដ៏ឧត្តុង្គឧត្តម ខ្ពង់ខ្ពស់បំផុត ជា សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

យើងខ្ញុំទាំងអស់គ្នាសូមគោរពបួងសួងដល់បារមីវត្ថុស័ក្តិសិទ្ធិក្នុងលោក តាមបីបាច់រក្សា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ព្រមទាំងបុត្រាបុត្រី សូមមាននូវសុខភាពល្អបរិបូរណ៍ ពលានុភាពមាំមួនក្លៀវក្លា បញ្ញាញាណភ្លឺថ្លា ដើម្បីដឹកនាំនាវាកម្ពុជារក្សាបាននូវសុខសន្តិភាព និងរីកចម្រើនរុងរឿងថ្កុំថ្កើង។



ព្រះរាជក្រឹត្យ

នស/រកត/០៩២៣/៤១១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ...
- បានទ្រង់យល់ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ... នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រោសព្រះរាជទានគោរមងារ

ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត

ជា

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

នរោត្តម សីហមុនី

ធ្វើនៅថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាបន្តគម្រោងជួសជុលខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញអភិរក្សនៃអាជ្ញាធរជាតិអប្សរា បានបន្តជួសជុលស្លាបខាងត្បូងនៃខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី ស្ថិតនៅដំណាក់កាលទី២។

បុរាណវិទូ និងជាអ្នកមើលការខុសត្រូវនៅការដ្ឋានជួសជុលខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី លោកស្រី នេត ស៊ីមន មានប្រសាសន៍ថា ដំណាក់កាលទី២នៃការងារជួសជុល គឺត្រូវប្រើ២ដំណាក់កាល ដោយដំណាក់កាលទី១ គឺសិក្សាទាំងរូបរាង ទម្រង់នៃស្ថានភាពរបស់ខ្លោងទ្វាររួចហើយ ព្រមទាំងបានប្រមូលព័ត៌មាន និងរៀបចំឯកសាររួចរាល់ដែរ។ ចំណែកដំណាក់កាលទី២ គឺចាប់ផ្តើមអនុវត្តគម្រោងជួសជុលតែម្តង ក្នុងនោះ គឺមានការរុះរើថ្មចាប់ពីផ្នែកដំបូលរហូតដល់គ្រឹះ ត្រូវពង្រឹងគ្រឹះរួចហើយត្រូវរៀបចំផ្គុំថ្មទាំងនោះចូលតាមស្ថានភាពដើមវិញ ដោយប្រើបច្ចេកទេសដូចសម័យបុរាណ និងប្រើជំនួយគ្រឿងចក្រចាំបាច់មួយចំនួន។ ហើយការជួសជុលខ្លោងទ្វារប្រៀបធៀបដូចជារៀបប្រាសាទពីរនៅជិតគ្នា ហើយបញ្ចូលគ្នាតែ១ ដោយផ្នឹមភ្ជាប់គ្នារួចទើបរៀបថ្មមានមុខ៤ដាក់ពីលើ។ ការងាររបៀបនេះ បានធ្វើឱ្យក្រុមការងារជួបការលំបាកមួយចំនួនដែរ។

សូមរំឭកថា ខ្លោងទ្វារខាងលិចរបស់ប្រាសាទបន្ទាយក្តី ទទួលរងការខូចខាតទ្រុឌទ្រោមខ្លាំង ដោយសារកត្តាអាយុកាលរបស់ថ្ម ដើមឈើដុះចាក់ឫសចូលតាមថ្នេរថ្មចូលខឿន និងចូលក្នុងគ្រឹះ ជាហេតុធ្វើឱ្យថ្មរបើកគ្រេចចេញពីគ្នា។ បញ្ហាមួយទៀត គឺសត្វកណ្តៀរ ក៏បានពាំដីចេញពីគ្រឹះ បណ្តាលឱ្យមានរន្ធប្រហោងខាងក្រោម ដែលនាំទឹកភ្លៀងហូរជ្រាបចូលតាមចន្លោះថ្មទៅក្នុងគ្រឹះ បណ្តាលឱ្យគ្រឹះខ្សោយមិនរឹងមាំ និងទ្រេតស្រុតតាមនោះដែរ៕

## ភ្នាក់ងារទេសចរណ៍ និងភ្នាក់ងារសណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា ដែលប្រចាំការនៅតាមគោលដៅនីមួយៗ តែងតែយកចិត្តទុកដាក់ចំពោះភ្ញៀវទេសចរ ពិការ ឬចាស់ជរា ដែលបានមកទស្សនានៅក្នុងរមណីយដ្ឋានអង្គរ

## ជាក់ស្តែង ក្រុមការងារភ្នាក់ងារទេសចរណ៍ និងភ្នាក់ងារសណ្តាប់ធ្នាប់ ប្រចាំនៅប្រាសាទនាគព័ន្ធ បានជួយសម្រួលដល់ទេសចរ ដែលមានវ័យចំណាស់ក្នុងកំឡុងពេលទស្សនាប្រាសាទ

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញមកទស្សនាព្រះលានជល់ដំរី ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញមកទស្សនាប្រាសាទបាយ័ន ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញមកទស្សនាប្រាសាទអង្គរវត្ត ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញមកទស្សនាប្រាសាទបាពួន ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញមកទស្សនាប្រាសាទភិមានអាកាស ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

## ការរៀបចំជួសជុលជណ្តើរឈើថ្មី ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរ នៅប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

# ក្រៅពីមើលការខុសត្រូវភ្ញៀវមកទស្សនាប្រាសាទ ក្រុមការងារឆ្មាំចាំទេសចរណ៍គោលដៅប្រចាំនៅប្រាសាទភ្នំបាខែង បានចូលរួមបោសសម្អាតរានហាលសម្រាប់ទស្សនាទេសភាព និងថ្ងៃលិចនៅប្រាសាទភ្នំបាខែង និងទីតាំងផ្សេងៗទៀតជាប្រចាំ ដើម្បីរក្សាបាននូវសោភ័ណភាពគួរជាទីទាក់ទាញ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

# ក្រុមការងារភ្នាក់ងារទេសចរណ៍ និងក្រុមការងារភ្នាក់ងារសណ្តាប់ធ្នាប់ រួមគ្នាជាមួយក្រុមការងារ HCC Angkor គោលដៅប្រចាំនៅប្រាសាទតាកែវ ប្រាសាទចៅសាយទេវតា និងប្រាសាទធម្មនន្ទ បានកាត់សម្អាតស្មៅ កូនរុក្ខជាតិ បោចវល្លិ៍នៅគ្រប់ស្បូននៃចំណតខាងជើងប្រាសាទតាកែវ ដើម្បីរក្សាបាននូវសោភ័ណភាព នឹងទេសភាពស្រស់ស្អាតជាប្រចាំ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

# ភ្នាក់ងារទេសចរណ៍សហការជាមួយក្រុមការងារសណ្តាប់ធ្នាប់ តែងតែជួយសម្រួលដល់អ្នកទេសចរមានវ័យចំណាស់ និងពិការ ដែលមកទស្សនានៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញចូលទស្សនាប្រាសាទតាព្រហ្មនាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

# សកម្មភាពក្រុមការងារខាងហេដ្ឋារចនាសម្ព័ន្ធបន្តជួសជុលផ្លូវនៅទីតាំងមួយចំនួន ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

# ក្រុមអ្នកជួសជុលប្រាសាទបុរាណ បង្ហាញការតាំងចិត្តក្នុងការជួសជុល ដោយប្រើបច្ចេកទេសបុរាណ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមការងារជួសជុលមួយក្រុមនៅការដ្ឋានជ្រុងនិរតីនៃប្រាសាទបាយ័ន កំពុងមានសកម្មភាពមមាញឹករៀបចំថ្មដែលបានរើចេញដោយសារក្រៀកហែក និងរៀបចំទៅតាមកន្លែងដើមវិញម្តងមួយដុំៗយ៉ាងយកចិត្តទុកដាក់ និងអត់ធ្មត់បំផុត។ពេលខ្លះក្រុមការងារនេះ ក៏ត្រូវរៀបផ្គុំថ្មជាច្រើនសារដើម្បីឱ្យត្រូវតាមលំនាំដើម និងមានភាពរឹងមាំ មិនមានការក្រៀកហែកជាថ្មី តាមរបៀបការជួសជុលប្រាសាទបុរាណដោយធ្វើទៅតាមក្បួនខ្នាត និងបច្ចេកទេសត្រឹមត្រូវ ដើម្បីរក្សាតម្លៃដើមរបស់ប្រាសាទនិងគោរពតាមធម្មនុញ្ញអង្គរផង។

លោក ឆម ប្រុញ ជាអ្នកភូមិតាប៉ាង ឃុំអំពិល ស្រុកប្រាសាទបាគង ដែលបានចូលបម្រើការងារនៅអាជ្ញាធរជាតិអប្សរា ដំបូងពីឆ្នាំ២០០២ធ្វើជាភ្នាក់ងារទេសចរណ៍នៅប្រាសាទអង្គរវត្ត ហើយបន្ទាប់មកបានផ្លាស់ប្តូរទៅជាអ្នកជួសជុលប្រាសាទវិញនោះ មានប្រសាសន៍ថា ការងារជួសជុលនៅជ្រុងនិរតីនៃប្រាសាទបាយ័ន មានទីធ្លាតូចចង្អៀត ដែលគ្រប់ពេលត្រូវតែប្រុងប្រយ័ត្ន ជៀសវាងគ្រោះថ្នាក់ណាមួយ ដល់ក្រុមការងារ និងប៉ះពាល់ដល់ថ្ម។ លោកមានប្រសាសន៍បន្តទៀតថា បន្ទាប់ពីការងាររើថ្មដែលក្រៀកហែក និងបុកបង្ហាប់គ្រឹះ រួចហើយត្រូវរៀបថ្មឡើងវិញ។ ក្នុងកិច្ចការងារនេះ លោកក៏ធ្វើការងាររៀបថ្មផង ហើយពេលណាខ្វះកម្លាំងលោកក៏ជួយអូសថ្មដែរ។

ការងារជួសជុលប្រាសាទបុរាណនេះ ក្រៅតែពីប្រើជំនាញនិងបច្ចេកទេស ការផ្តល់យោបល់រកដំណោះស្រាយពេលជួបបញ្ហានិងការស្តាប់យោបល់ទាំងអស់គ្នាក៏ជាវឌ្ឍនភាពការងាររលូនទៅមុខដែរ។

លោក ភី ផាន ជាអ្នកភូមិស្រះស្រង់ខាងត្បូង ឃុំក្រវ៉ាន់ ស្រុកនគរធំ ជាអ្នកជួសជុលប្រាសាទបុរាណម្នាក់ទៀតនៅក្នុងរមណីយដ្ឋានអង្គរជាង២០ឆ្នាំហើយ។ លោកមានប្រសាសន៍ថា អ្វីដែលលំបាកសម្រាប់ក្រុមការងារជួសជុលថ្មភក់ គឺការរៀបចំផ្គុំថ្មមិនត្រូវតាមលំនាំដើម ដែលទាមទារពេលវេលា ការអត់ធ្មត់ និងការសាមគ្គីជាចាំបាច់។ ពេលខ្លះលោកក៏អន់ចិត្តនិងខ្លួនឯងដែលរៀបថ្មមិនត្រូវ។

បើទោះបីជាការងារជួសជុលប្រាសាទបុរាណ មានការលំបាកយ៉ាងណា ក៏កម្មករជំនាញ ដែលកំពុងរួមគ្នាធ្វើការងារជួសជុលប្រាសាទជាច្រើនមិនបានបង្ហាញអារម្មណ៍នឿយណាយទេ គឺពួកគាត់តែងយកមនសិការ បង្ហាញអារម្មណ៍រីករាយសប្បាយចិត្ត ដែលបានចូលរួមអភិរក្សជួសជុលប្រាសាទបុរាណរបស់ដូនតាខ្មែរ ពីព្រោះថារបស់ទាំងនោះមិនមែនជារបស់ក្រុមអ្នកជួសជុលតែម្នាក់ឯងនោះទេ។ ប៉ុន្តែជារបស់មនុស្សខ្មែរគ្រប់រូប ហើយពួកយើងអាចចូលរួមអភិរក្សបាន តាមរយៈរូបភាពផ្សេងៗគ្នា៕

# ការចតយានជំនិះឱ្យមានរបៀបរៀបរយ ជាការចូលរួមលើកកម្ពស់សោភ័ណភាព នៅក្នុងតំបន់បេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

ភ្ញៀវទេសចរជាតិ និងអ្នកប្រកបរបរដឹកភ្ញៀវទេសចរ ដែលបានយកយានយន្តរបស់ខ្លួនចូលទៅចតនៅក្នុងទីចំណត ដែលបានរៀបចំ និងជួយសម្រួលដល់សណ្ដាប់ធ្នាប់សាធារណៈក្នុងតំបន់រមណីយដ្ឋានអង្គរ ជាពិសេសបញ្ចៀសការកកស្ទះ និងគ្រោះថ្នាក់ដោយយថាហេតុនៅលើដងផ្លូវ។

លោកស្រី ចាន់ ឧត្តមបញ្ញា ប្រធានក្រុមរួមផ្នែកសណ្ដាប់ធ្នាប់គ្រប់គ្រងគោលដៅក្រុងអង្គរធំ បានឱ្យដឹងថា ជារៀងរាល់ថ្ងៃ កិច្ចការងារស្នូលរបស់ក្រុមការងារសណ្ដាប់ធ្នាប់តែងតែរៀបចំការចតយានយន្ត រ៉ឺម៉ក ម៉ូតូឱ្យចូលចតនៅក្នុងចំណត និងរៀបចំការលក់ដូរនៅក្បែរៗនោះជាដើម។ ចំពោះមុខ ក្រុមការងារនៅតែប្រឈមបញ្ហាខ្លះៗ ដោយសារអ្នកបើកបរដឹកភ្ញៀវទេសចរមួយចំនួនមិនសូវចូលរួមសហការ ក្រោយពេលដាក់ភ្ញៀវឱ្យចូលទស្សនាប្រាសាទហើយ ពួកគាត់មិនបានយកយានជំនិះចូលមកចតនៅក្នុងចំណតដែលបានរៀបចំឡើយ។ ដោយអ្នកបើកបរមួយចំនួន បែរជាទៅចតនៅតាមដងផ្លូវសាធារណៈ។ ចំណែកខ្លះទៀត ពេលឃើញភ្ញៀវចេញពីទស្សនាប្រាសាទ មិនបានឱ្យភ្ញៀវដើរមកកាន់ចំណតដើម្បីបន្តដំណើរទៅមុខ តែបែរជាបើកយានជំនិះទៅទទួលភ្ញៀវដល់បរិវេណខាងមុខប្រាសាទ។ ដែលនេះជាហេតុ ធ្វើឱ្យបាត់បង់សោភ័ណភាពតាមដងផ្លូវ អាចបង្កគ្រោះថ្នាក់ដោយយថាហេតុ និងកកស្ទះ ធ្វើឱ្យប៉ះពាល់ដល់ភ្ញៀវដទៃដែលធ្វើចរាចរណ៍លើដងផ្លូវ។ បើទោះបីជាកន្លងមក ធ្លាប់មានការណែនាំជាច្រើនលើកច្រើនសារក៏ដោយ បញ្ហានេះនៅតែកើតឡើងស្ទើរតែជារៀងរាល់ថ្ងៃ។

ប្រធានក្រុមរួមផ្នែកសណ្ដាប់ធ្នាប់គ្រប់គ្រងគោលដៅក្រុងអង្គរធំ បានបញ្ជាក់ថា គ្រប់ទីតាំងប្រាសាទនីមួយៗក្នុងរមណីយដ្ឋានអង្គរ តែងតែមានចំណតសម្រាប់ភ្ញៀវទេសចរ ឬអ្នកដឹកភ្ញៀវចូលចតនៅទីនោះ ដោយមិនតម្រូវឱ្យបង់ថវិកាឡើយ។ ជាក់ស្ដែង បរិវេណក្រុងអង្គរធំ មានទីតាំងចំណតចំនួន៣កន្លែងរួមមាន៖ នៅខាងកើតប្រាសាទបាយ័ន និងខាងលិចនៃប្រាសាទ និងចំណតមួយទៀតនៅក្បែរប្រាសាទព្រះវិធូរ ជាចំណតធំទូលាយ អាចដាក់យានយន្តបានច្រើនជាងគេ។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរាអំពាវនាវដល់សាធារណជនទូទៅ សូមចូលរួមតាមអ្វីដែលក្រុមការងារ ឬភ្នាក់ងារប្រចាំការតាមប្រាសាទបានណែនាំឬកំណត់ឱ្យចូលចតយានជំនិះនៅតាមចំណត ជៀសវាងការចតតាមដងផ្លូវដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ៕

## ក្រុមភ្នាក់ងារទេសចរណ៍ដែលប្រចាំការនៅប្រាសាទអង្គរវត្ត រើសបានសម្ភារមួយចំនួនរបស់ភ្ញៀវដែលភ្លេច ឬជ្រុះនៅបណ្ណាល័យខាងត្បូង សហការជាមួយប៉ូលិសបេតិកភណ្ឌ បានរកឃើញនិងប្រគល់ជូនម្ចាស់វិញ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមភ្នាក់ងារទេសចរណ៍ដែលប្រចាំការនៅប្រាសាទអង្គរវត្ត រើសបានសម្ភារមួយចំនួនរបស់ភ្ញៀវដែលភ្លេច ឬជ្រុះនៅបណ្ណាល័យខាងត្បូង សហការជាមួយប៉ូលិសបេតិកភណ្ឌ បានរកឃើញនិងប្រគល់ជូនម្ចាស់វិញ។

ម្ចាស់របស់បានថ្លែងអំណរគុណ និងកោតសរសើរដល់អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់ពីសុវត្ថិភាពភ្ញៀវ ព្រមទាំងបានបង្ហាញនូវក្តីស្រឡាញ់និងទំនុកចិត្តខ្ពស់មកលើភ្នាក់ងារទេសចរណ៍

**ភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទតាព្រហ្មសហការជាមួយក្រុមការងារអតិរក្ស នៃអាជ្ញាធរអប្សរា បានធ្វើការស្ដារលូយកដី ស្លឹកឈើ និងកម្ទេចឈើចេញ បន្ទាប់ពីភ្លៀងធ្លាក់នៅបរិវេណប្រាសាទ**

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣

# ក្រុមគ្នាក់ងារទេសចរណ៍ សហការណ៍ជាមួយគ្នាក់ងារសណ្តាប់ធ្នាប់ បានធ្វើការទល់ទ្រដើមបេងមួយដើម ដែលបានដួលរលំនៅចំនុចខ្លោងទ្វារខាងលិច ឈៀងខាងជើងប្រាសាទតាព្រហ្ម ព្រមទាំងធ្វើការរៀបតម្រង់ជុំបេតុង នៅចំនុចជុំវិញតូបលក់ដូរអាជីវករខាងលិចប្រាសាទតាព្រហ្មផងដែរ

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣

**ក្រុមការងារអភិរក្សព្រៃមន្ទីរនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣នេះ កំពុងសម្អាតបោចស្មៅ និងកាត់រុក្ខជាតិតូចៗនៅបរិវេណប្រាសាទបន្ទាយស្រី**

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣

**ក្រុមឆ្មាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទភ្នំបាខែង ធ្វើការចាក់ដីបំពេញតាមផ្លូវ និងជណ្តើរ ដើម្បីសម្រួលដល់ភ្ញៀវទេសចរ និងងាយស្រួលក្នុងការដើរឆ្លងកាត់ឡើងចុះ ប្រកបដោយសុវត្ថិភាព**

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣

**ក្រុមការងារឆ្លាក់ងារទេសចរណ៍ប្រចាំនៅគោលដៅប្រាសាទព្រះគោ និងប្រាសាទលលៃ សហការជាមួយឆ្លាក់ងារសណ្តាប់ធ្នាប់ កាត់សម្អាតស្មៅនៅបរិវេណប្រាសាទលលៃ តាមគន្លងចាស់ ដែលជាផ្លូវដើរទស្សនារបស់ភ្ញៀវឡើងវិញ**

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣

## សូមបញ្ឈប់ការផ្តល់ចំណីឱ្យសត្វស្វានៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣នេះ សត្វស្វាបានខាំភ្ញៀវទេសចរជនជាតិអាមេរិក ភេទប្រុស អាយុប្រហែល៥០ឆ្នាំ ដែលបណ្តាលឱ្យរបួសដាច់សាច់កញ្ចឹងកខាងស្តាំ ពេលបុរសរូបនោះកំពុងដើរទស្សនានៅតំបន់ប្រាសាទបាយ័ន។ ភ្លាមៗក្រុមភ្នាក់ងារទេសចរណ៍របស់អាជ្ញាធរជាតិអប្សរាបានជួយសង្គ្រោះបន្ទាន់ ដោយលាងរបួស និងណែនាំឱ្យទៅចាក់ថ្នាំវ៉ាក់សាំងនៅមន្ទីរពេទ្យដើម្បីកុំឱ្យឆ្លងជំងឺផ្សេងៗ៕

## អរុណរះឡើងចែងចាំងនៅប្រាសាទអង្គរវត្តនាព្រឹកថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

## ក្រុមការងារភ្នាក់ងារទេសចរណ៍រៀបចំផ្លូវចូលប្រាសាទបាគង

ផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមការងារភ្នាក់ងារទេសចរណ៍គោលដៅប្រចាំនៅប្រាសាទបាគង បានដីចាក់បំពេញក្រលុកដែលទឹកហូរច្រោះនៅចំនុចផ្លូវដើរចូលមុខប្រាសាទបាគងខាងកើត ដើម្បីការពារកុំអោយភ្ញៀវដើរចំពប់ជើងដួល៕

**ក្រុមការងារគ្នាក់ងារទេសចរណ៍ប្រចាំនៅគោលដៅប្រាសាទអង្គរវត្ត បានជួយសម្រួលភ្ញៀវទេសចរដែលមានវ័យចំណាស់ ដើរមិនរួច ជិះលើរទេះរុញ ដើម្បីបានចូលទស្សនាប្រាសាទអង្គរវត្ត**

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣

# វង់ទស្សនាថ្មីនៅប្រាសាទភ្នំបាខែង ធ្វើឱ្យភ្ញៀវទេសចរកាន់តែមានកន្លែងទស្សនាច្រើន ព្រមទាំងសោភ័ណភាពទាក់ទាញ

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣

ប្រាសាទភ្នំបាខែង គឺជាគោលដៅទស្សនាទិដ្ឋភាពថ្ងៃរះ និងថ្ងៃរៀបលិចយ៉ាងពេញនិយមបំផុតរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ ដោយសារតែចំនួនភ្ញៀវទេសចរណ៍កាន់តែច្រើនឡើងទៅទស្សនាថ្ងៃរះ និងថ្ងៃលិចនៅលើកំពូលនៃប្រាសាទភ្នំបាខែង ថ្មីៗនេះ អាជ្ញាធរជាតិអប្សរាបានរៀបចំទីតាំងវង់ទស្សនាថ្មីមួយទៀតដើម្បីបញ្ចៀសចំនួនកកកុញនៃការទស្សនា ក៏ដូចជា បង្កើតជាជម្រើសសម្រាប់ទេសចរដែលនិយមទស្សនាថ្ងៃលិច ព្រមទាំងផ្តល់ជូនភ្ញៀវទេសចរនូវបទពិសោធន៍ថ្មីៗ ប្រកបដោយសុវត្ថិភាព និងផាសុខភាពផង។

ប្រធានភ្នាក់ងារទេសចរណ៍នៅប្រាសាទភ្នំបាខែងលោក ហ៊ុត សុភាព មានប្រសាសន៍ថា ការរៀបចំវង់ទស្សនាថ្មីនេះគឺចាប់ពីជើងភ្នំរហូតដល់ប្រាសាទតែម្តង។ ចំពោះខ្សែទស្សនាគឺភ្ញៀវទេសចរអាចដើរទស្សនាតាំងពីជើងភ្នំ ហើយនៅពេលហត់ ភ្ញៀវក៏អាចឈប់សម្រាកតាមផ្លូវសុវត្ថិភាពដែលអាជ្ញាធរជាតិអប្សរាបានរៀបចំទីតាំងជាច្រើន ហើយកន្លែងទាំងនោះ សុទ្ធតែអាចផ្តិតយករូបភាពនានាដូចជាគោលដៅទី១អាចថតប្រាសាទបក្សីចាំក្រុង គោលដៅទី២ នៅចង្កេះភ្នំគឺមានរានហាលសម្រាប់ឱ្យភ្ញៀវអាចទស្សនាទេសភាពបារាយណ៍ខាងលិចទាំងមូល ឯខ្សែទស្សនាបន្តបន្ទាប់ពេលទៅដល់លើភ្នំ មានរានហាលមួយទៀតសម្រាប់ឱ្យទេសចរទស្សនាថ្ងៃរះ និងថ្ងៃលិចជាដើម។

ក្នុងការរៀបចំវង់ទស្សនាថ្មី អាជ្ញាធរជាតិអប្សរាក៏រៀបចំកែលម្អបរិស្ថាននៅជុំវិញប្រាសាទ ដើម្បីលើកកម្ពស់សោភ័ណភាពដូចជា ការលះមែកឈើខ្លះៗ រៀបចំផ្លូវដើរជុំវិញប្រាសាទឱ្យស្អាត ដាក់ស្លាកសញ្ញាបង្ហាញទិស ដាក់បង្គោលខ្សែការពារកន្លែងមានហានិភ័យ ដើម្បីការពារសុវត្ថិភាពអ្នកទេសចរទាំងឡាយ។ ជាមួយគ្នានេះដែរ អាជ្ញាធរជាតិអប្សរា ក៏សំណូមពរដល់ភ្ញៀវទេសចរ ឬមគ្គុទេសក៏ទេសចរណ៍ឱ្យនាំភ្ញៀវដើរទស្សនាតាមទិសដៅដែលបានរៀបចំ ដើម្បីឱ្យពួកគាត់បានឃើញនូវអ្វីដែលថ្មីៗ និងមានភាពស្រស់ស្អាតទាំងនោះផង៕

# ភ្នាក់ងារទេសចរណ៍ប្រចាំនៅគោលដៅប្រាសាទតាព្រហ្ម បានជួយសង្គ្រោះបឋមដល់ភ្ញៀវបរទេសដែលមានអាការៈខ្យល់គរ

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៣: ២៥នាទី ភ្នាក់ងារទេសចរណ៍ បានជួយសង្គ្រោះបឋមដល់ ភ្ញៀវទេសចរណ៍ជនជាតិអូស្ត្រាលីម្នាក់ ភេទ ស្រី អាយុ៧៣ឆ្នាំ ដែលមានអាការៈខ្យល់គរ នៅចំណុចតួប៉មកណ្តាលនៃប្រាសាទតាព្រហ្ម។ ក្រោយបានធូរស្រាលភ្នាក់ងារយើងបានជូនគាត់ដោយម៉ូតូទៅកាន់ឡានរបស់គាត់ នៅចំណតខាងកើតប្រាសាទតាព្រហ្មផងដែរ៕

## ទេសភាពស្រស់បំព្រងនៅប្រាសាទព្រះខ័ន ដែលជាអតីតរាជធានីបណ្ដោះអាសន្នរបស់ព្រះបាទជ័យវរ្ម័នទី៧

ផ្សាយនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣

# ភ្នាក់ងារទេសចរណ៍ប្រចាំការនៅគោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញកាបូបរបស់ភ្ញៀវ ដែលបានភ្លេច និងបានរក្សាទុកប្រគល់ជូនម្ចាស់ដើមវិញ

ផ្សាយនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣

នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣នេះ វេលាម៉ោង ១១:៥១ នាទីថ្ងៃត្រង់ ក្រុមការងារភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទអង្គរ បានប្រទះឃើញកាបូបស្ពាយចំហៀងពណ៌ខ្មៅមួយ ដែលភ្ញៀវទេចរបានភ្លេច នៅចំណុចលើរានហាលលុះប្រហែល៣៥នាទីក្រោយមក ម្ចាស់កាបូបជាជនជាតិខ្មែរភេទស្រីម្នាក់ ឈ្មោះហុង ស្រីអូន រស់នៅភូមិរលៀក ឃុំតាអូ ស្រុកគិរីវង់ខេត្តតាកែវ ដែលជាម្ចាស់កាបូបបានមករកវិញដោយក្នុងនោះមាន៖ លុយខ្មែរ ចំនួន៦០,០០០រៀល លុយវៀតណាម ១៩៥០០ដុង លុយឡាវ១០០០គីបឡាវ លុយដុល្លារ២ដុល្លារ។ កាតធនាគារ៣ អត្តសញ្ញាណប័ណ្ណមួយ កាត AEONមួយ កាត បសសមួយ កាតធានារ៉ាប់រងមួយ និងទូរស័ព្ទ iphone១១ promax មួយគ្រឿង។

ដោយពិនិត្យឃើញថា ពិតជាកាបូបរបស់គាត់ និងមិនមានការបាត់បង់ហើយ ក្រុមភ្នាក់ងារបានសហការជាមួយក្រុមការងារសណ្តាប់ធ្នាប់ និងនគរបាលបេតិកភណ្ឌ បានធ្វើការប្រគល់ជូនគាត់វិញ នៅវេលាម៉ោង១២:៣០នាទី៕

# ប្រាសាទបន្ទាយស្រីជាមួយនិងចម្លាក់ដ៏អស្ចារ្យផុសពីផ្ទាំងថ្មភក់ពណ៌ផ្កាឈូកក្រមាន ដែលទស្សនីយភាពនេះបានដឹតជាប់ក្នុងក្រអៅបេះដូងភ្ញៀវទេសចរគ្រប់ៗរូប

ផ្សាយនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣

# លោកព្រឹទ្ធាចារ្យ ស៊ឹម អឿម ២៩ឆ្នាំក្នុងការងារអភិរក្សប្រាសាទបុរាណ

ផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

លោកព្រឹទ្ធាចារ្យ ស៊ឹម អឿម គឺជាអ្នកជំនាញម្នាក់ក្នុងចំណោមមនុស្សជាច្រើនទៀត ដែលបានចូលរួមធ្វើការងារជាអ្នកជួសជុលប្រាសាទឥដ្ឋបុរាណជាច្រើននៅខេត្តសៀមរាប។ ស្ថិតក្នុងវ័យ៧១ឆ្នាំ មានពាក់មួកការពារសុវត្ថិភាព ព្រមទាំងនៅក្នុងដៃមានកាន់ដុំឥដ្ឋធ្វើការនៅក្នុងការដ្ឋានផង ព្រឹទ្ធាចារ្យ ស៊ឹម អឿម ធ្វើការបណ្ដើរនិយាយបណ្ដើរថា លោកបានធ្វើជាអ្នកជួសជុលប្រាសាទឥដ្ឋបុរាណតាំងតែពីឆ្នាំ១៩៩៤ មកម្ល៉េះ។

មូលហេតុដែលលោកសម្រេចចិត្តចូលធ្វើជាអ្នកជួសជុលប្រាសាទបុរាណនេះ ដោយសារតែរូបលោកមានចិត្តស្រឡាញ់ប្រាសាទបុរាណ និងចង់បំពេញការងារថែរក្សាអភិរក្សប្រាសាទបុរាណដែរ។ ម្យ៉ាងទៀត ការជួសជុលប្រាសាទនេះក៏ជាការបន្តពីជីតា ឪពុករបស់គាត់ ហើយក៏ធ្លាប់ទទួលបានការបណ្ដុះបណ្ដាលពីអ្នកជំនាញបរទេសតាំងពីឆ្នាំ១៩៩៤មកដែរ។ ក្នុងរយៈពេលជាង២៩ឆ្នាំមកនេះ លោកព្រឹទ្ធាចារ្យបានបំពេញការងារជួសជុលប្រាសាទឥដ្ឋ ដូចជា ប្រាសាទព្រះគោ ប្រាសាទបាគង និងប្រាសាទលលៃ។ល។

ជាការចែករំលែកព័ត៌មាន លោកព្រឹទ្ធាចារ្យបានលើកពីវិធីសាស្ត្រនៃការជួសជុល និងការតភ្ជាប់ប្រាសាទឥដ្ឋ ដោយរៀបរាប់ថា ការជួសជុលប្រាសាទបុរាណដែលធ្វើអំពីឥដ្ឋនីមួយៗ គឺត្រូវប្រុងប្រយ័ត្នខ្ពស់ ត្រូវសិក្សាពីទិសឬជ្រុងរបស់ឥដ្ឋ ថាតើ មានចំណុចណាខ្លះដែលក្រៀកចេញ ឬស្រុតចុះ? ត្រូវមើលឱ្យច្បាស់លាស់ថាតើដុំឥដ្ឋមួយណាដែលខូចខាតត្រូវដកចេញ និងមួយណាត្រូវទុកវាដើម្បីធ្វើការជួសជុលជាដើម។ ចំណែកលក្ខណៈនៃការតភ្ជាប់ឥដ្ឋទៀតសោត មុនដំបូង គឺត្រូវកោសកម្ទេចដី សម្អាតឬសឈើកម្ទេចកម្ទីរួចហើយ លាងទឹកឱ្យស្អាត ដោយត្រូវមើលកម្រាលឥដ្ឋ តើឥដ្ឋនេះមានកម្រាស់ប៉ុណ្ណា? ជួនកាលឥដ្ឋខ្លះមានកម្រាស់២ហ៊ុន ៣ហ៊ុន ៤ហ៊ុន រួចហើយត្រូវដាប់កម្រាស់ឥដ្ឋឱ្យស្មើៗគ្នា៕

# អាជ្ញាធរជាតិអប្សរាកំពុងធ្វើការងារជួសជុលប្រាសាទព្រហ្មកិល ឱ្យមានភាពរឹងមាំឡើងវិញ

ផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមការងារជំនាញនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យាចាប់ផ្តើមបន្តការងារជួសជុលប្រាសាទព្រហ្មកិល ដើម្បីធ្វើយ៉ាងណាឱ្យរចនាសម្ព័ន្ធរបស់ប្រាសាទទាំងមូល អាចងើបឈររឹងមាំឡើងវិញ។

លោក ម៉ៅ សុខនី ប្រធានការដ្ឋានជួសជុលប្រាសាទព្រហ្មកិល និងជាស្ថាបត្យករ នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យា បានឱ្យដឹងថា ប្រាសាទព្រហ្មកិល បានរងការខូចខាតទ្រុឌទ្រោមខ្លាំង ដោយថ្មខ្លះធ្លាក់កប់ដី និងនៅរាយប៉ាយ ហើយតួប៉មកណ្តាលបានបាក់រលុះអស់មួយចំហៀង នៅជ្រុងខាងត្បូង និងខាងលិច។ ដើម្បីឱ្យរចនាសម្ព័ន្ធនៃប្រាសាទ បានរឹងមាំឡើងវិញ បន្ទាប់ពីពិនិត្យឃើញស្ថានភាពខូចរាល់រួចរាល់ បច្ចុប្បន្នក្រុមអ្នកជំនាញកំពុងធ្វើការងារជួសជុលប្រាសាទព្រហ្មកិល ដោយចាប់ផ្តើមពីចុងខែសីហា ឆ្នាំ២០២៣មក ។

លោកបានបន្តទៀតថា ឈានចូលមកដល់ដំណាក់កាលនេះ ក្រុមអ្នកជំនាញបានបន្តធ្វើកំណាយបុរាណវិទ្យា ដើម្បីសិក្សាអំពីរចនាសម្ព័ន្ធ ផ្នែកខាងក្នុងនៃខឿនប្រាសាទ សិក្សាអំពីកម្ពស់ និងស្ថានភាពស្រុតរបស់ប្រាសាទ។ ទើបចាប់ផ្តើមចុះលេខរបស់ថ្ម រួចរើថ្មមួយចំនួនដែលនៅសល់ទាំងពីរជ្រុង គឺជ្រុងខាងកើត និងខាងជើង រួចបង់លេខថ្មទៅតាមស្រទាប់នីមួយៗ ដើម្បីរើចេញ ទើបចាប់ផ្តើមពង្រឹងគ្រឹះតាំងពីក្រោមឡើងទៅដល់ខាងលើ។

លោកបានបញ្ជាក់ទៀតថា បន្ទាប់ពីរើថ្មដល់ខឿនគ្រឹះប្រាសាទរួចរាល់ អ្នកជំនាញនិងសិក្សាបន្ថែមទៀតអំពីស្រទាប់ថ្ម ដើម្បីដឹងថា ផ្នែកណាមួយស្រុតខ្លាំងជាងគេ ឬពុកផុយជាងគេ ទើបចាប់ផ្តើមធ្វើការពង្រឹងខឿនគ្រឹះ ដោយបន្ថែមថ្មបាយក្រៀមថ្មី ជំនួសថ្មចាស់ដែលពុកផុយ ។បើទោះបីជាយកថ្មីខ្លះៗមកជំនួសថ្មចាស់ ប៉ុន្តែអ្នកជំនាញនឹងព្យាយាមធ្វើយ៉ាងណាជួសជុលខឿនគ្រឹះរបស់ប្រាសាទទៅតាមលំនាំដើម។

សូមបញ្ជាក់ថា ប្រាសាទព្រហ្មកិល ជាហោសម្រាប់មនុស្សបន់ស្រន់ នៅក្នុងមន្ទីរពេទ្យមួយ ក្នុងចំណោមមន្ទីរពេទ្យទាំង៤ជុំវិញក្រុងអង្គរធំ កសាងឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ នាចុងសតវត្សទី១២ នៃគ្រឹស្តសករាជ ប្រាសាទតូចមួយនេះ មានទីតាំងនៅផ្នែកខាងលិចឈៀងខាងជើង នៃប្រាសាទអង្គរវត្ត៕

# អាជ្ញាធរជាតិអប្សរាសូមជម្រាបជូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនមេត្តាជ្រាបថា៖ នាព្រឹកថ្ងៃអង្គារ ទី១២ ខែកញ្ញា ឆ្នាំ២០២៣ វិទ្យុអាស៊ីសេរី បានផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្ដាញទំនាក់ទំនងសង្គមនូវខ្លឹមសារ ស្ដីពី "អង្គការលើកលែងទោសអន្តរជាតិ ស្នើគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ពិនិត្យមើលការបណ្ដេញចេញដោយបង្ខំនៅតំបន់អង្គរ ដើម្បីឱ្យសាធារណជនជ្រាបច្បាស់នូវព័ត៌មានពិតជាក់ស្ដែង ចៀសវាងការយល់ច្រឡំ តាមការផ្សព្វផ្សាយដែលមានខាងលើ អាជ្ញាធរជាតិអប្សរា

សូមបញ្ជាក់ជូនដូចខាងក្រោម៖ ផ្សាយនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ២៤៤/រប.សបក/២៣

**សេចក្ដីប្រកាសព័ត៌មាន**

អាជ្ញាធរជាតិអប្សរាសូមជម្រាបជូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនមេត្តាជ្រាបថា៖ នាព្រឹកថ្ងៃអង្គារ ទី១២ ខែកញ្ញា ឆ្នាំ២០២៣ វិទ្យុអាស៊ីសេរី បានផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្ដាញទំនាក់ទំនងសង្គម នូវខ្លឹមសារស្ដីពី "អង្គការលើកលែងទោសអន្តរជាតិ ស្នើគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ពិនិត្យមើលការបណ្ដេញចេញដោយបង្ខំនៅតំបន់អង្គរ"។ ដើម្បីឱ្យសាធារណជនជ្រាបច្បាស់នូវព័ត៌មានពិតជាក់ស្ដែង ចៀសវាងការយល់ច្រឡំតាមការផ្សព្វផ្សាយដែលមានខាងលើ អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនដូចខាងក្រោម៖

១- ក្នុងពេលថ្មីៗនេះ អាជ្ញាធរជាតិអប្សរាបានទទួលនូវសំណើសុំកិច្ចសម្ភាសន៍តាម Zoom ពីអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ស្ដីពីការបម្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋទៅកាន់តំបន់ធម្មជាតិរុនតាឯក។ ទទួលបានសំណើនេះ អាជ្ញាធរជាតិអប្សរា ក៏បានស្នើសូមឱ្យអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ឬអ្នកតំណាង អញ្ជើញមកជួបពិភាក្សាជាមួយអាជ្ញាធរជាតិអប្សរានៅទីតាំងផ្ទាល់នៅតំបន់អង្គរ និងតំបន់ធម្មជាតិរុនតាឯកតែម្ដង ប្រសើរជាងការទទួលបានព័ត៌មានចម្ងាយរាប់ពាន់គីឡូម៉ែត្រពីស្ថានភាពជាក់ស្ដែង។ ជាការគួរឱ្យសោកស្ដាយដោយសំណើរបស់អាជ្ញាធរជាតិអប្សរា ពុំទទួលបានការយល់ព្រមពីអង្គការលើកលែងទោសអន្តរជាតិ(Amnesty International) នោះឡើយ។

២- ប្រធានបទនៃការបម្លាស់ទីប្រជាពលរដ្ឋនេះត្រូវបានសិក្សា ពិភាក្សាក្នុងកិច្ចប្រជុំ ICC-Angkor នាខែធ្នូ ឆ្នាំ២០២២ និង ខែមិថុនា ឆ្នាំ២០២៣ ព្រមទាំងផ្ញើរបាយការណ៍ទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោកជាប្រចាំរាល់ពេល។ អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនថា សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើតក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងបញ្ហាដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ ត្រូវបានអនុវត្តដោយឈរលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ដែលក្នុងនោះតម្រូវឱ្យអាជ្ញាធរជាតិអប្សរា ជាសេនាធិការ មានភារកិច្ចគ្រប់គ្រង និងទប់ស្កាត់ការចូលកាន់កាប់ដោយខុសច្បាប់ សំដៅរក្សាឱ្យបាននូវតម្លៃលេចធ្លោជាសកលនៃតំបន់រមណីយដ្ឋានអង្គរ ស័ក្ដិសមជាសារវន្ត នៃការបញ្ចូលតំបន់អង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នាឆ្នាំ១៩៩២។ ក្នុងន័យនេះ ដីធ្លីនានាក្នុងតំបន់១និង២ ជាតំបន់ការពារកម្រិតខ្ពស់នៃរមណីយដ្ឋានអង្គរ ហើយទីតាំងនេះជាសម្បត្តិសាធារណៈរបស់រដ្ឋ ការរីករាលដាលនៃសំណង់ពុំស្របច្បាប់ក្នុងតំបន់ទាំងពីរនេះ បានស្ថិតក្នុងកម្រិតមួយដែលអាចប៉ះពាល់ដល់តម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋាន។ ការផ្លាស់ប្ដូរ

APSARA National Authority

១

1/2


ទីតាំងប្រជាពលរដ្ឋ ដែលមានលំនៅដ្ឋានពុំស្របច្បាប់ត្រូវបានសិក្សា និងដាក់ចេញនូវវិធានការគាំទ្រដោយរាជរដ្ឋាភិបាលតាំងពីអាណត្តិទី៦ និងជាបន្តរហូតដល់បច្ចុប្បន្ន ដើម្បីអនុញ្ញាតឱ្យបងប្អូនទាំងនោះអាចមានទីលំនៅស្របច្បាប់ មានប័ណ្ណកម្មសិទ្ធិច្បាស់លាស់ និងការគាំពារសង្គមរយៈពេល ១០ឆ្នាំ នៅលើទីតាំងតំបន់អភិវឌ្ឍន៍ប្រកបដោយផាសុកភាព និងសុខុមាលភាពអមដោយហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ដូចជា ផ្លូវ អគ្គិសនី ទឹកស្អាត ប្រព័ន្ធទូរគមនាគមន៍ សាលារៀន មន្ទីរពេទ្យ ផ្សារ វត្តអារាម និងមណ្ឌលសេវាសាធារណៈរបស់ស្រុក (ស្រុកបន្ទាយស្រី)។

៣- អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនសាធារណមតិមេត្តាជ្រាបថា ការថែរក្សាការពារ រមណីយដ្ឋានអង្គរ ពុំមានត្រឹមតែប្រាសាទបុរាណនោះឡើយ ប្រពៃណីទំនៀមទម្លាប់របស់អ្នកស្រុកដើម បរិស្ថាន ខ្សែទឹកក្រោមដី សំណល់បុរាណវិទ្យាធំៗ ដែលពុំទាន់បានរុករកនៅឡើយ គឺជាភារកិច្ចរបស់អង្គភាពជំនាញអាជ្ញាធរជាតិអប្សរា ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា និងក៏ជាភារកិច្ចរបស់កូនខ្មែរគ្រប់រូប ដែលត្រូវរួមគ្នាថែរក្សាតម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋាននេះទុកជាកេរមរតកសម្រាប់កូនខ្មែរជំនាន់ក្រោយ ជាយូរលង់តទៅ។

ដើម្បីទទួលបានព័ត៌មានពិតជាក់លាក់ពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា សូមមេត្តាទំនាក់ទំនងមកអ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា និងក្រុមជំនួយការផ្នែកច្បាប់របស់អាជ្ញាធរជាតិអប្សរា រៀងរាល់ម៉ោងធ្វើការនៅស្នាក់ការអាជ្ញាធរជាតិអប្សរា និងសូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

សៀមរាប ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០២៣

២

2/2

# នៅព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ក្នុងសម័យប្រជុំលើកទី៤៥នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក អង្គការយូណេស្កូ នាទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអូឌីត (Saudi Arabia) សម្តែងនូវការអបអរសាទរចំពោះឆន្ទៈដ៏មោះមុតនិងយន្តការប្រព្រឹត្តទៅនៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរនិងសំបូរព្រៃគុក ដែលយន្តការនេះបានក្លាយជាគំរូនៃក្របខណ្ឌកិច្ចសហការពហុភាគីក្នុងក្របខណ្ឌអង្គការយូណេស្កូ។ ទម្រង់និងយន្តការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអាយស៊ីស៊ីអង្គរនិងសំបូរព្រៃគុកនឹងក្លាយជាគំរូនៃទម្រង់កិច្ចសហប្រតិបត្តិការអភិរក្សបេតិកភណ្ឌនៅប្រទេសអ៊ូបេគីស្ថាន (Uzbekistan) និងប្រទេសនេប៉ាល់ (Nepal)

ផ្សាយនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣



# អាជ្ញាធរជាតិអប្សរាបានរៀបចំសិក្ខាសាលាស្តីពី តួនាទីអ្នកគ្រប់គ្រងប្រាសាទ ជូនដល់មន្ត្រី បុគ្គលិក នៃនាយកដ្ឋានជំនាញ ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងប្រាសាទ ប្រកបដោយប្រសិទ្ធភាព

ផ្សាយនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣

កាលព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣នេះ អាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាមួយ ស្តីពី «តួនាទីអ្នកគ្រប់គ្រងប្រាសាទ» ជូនដល់ប្រធាន និងអនុប្រធាន ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ និងភ្នាក់ងារទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងគោលបំណង ពង្រឹងសមត្ថភាពការងារ ប្រធាន អនុប្រធាន ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ និងភ្នាក់ងារទឹកព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ ឲ្យក្លាយជាអ្នកគ្រប់គ្រងប្រាសាទ ប្រកបដោយប្រសិទ្ធភាព។ សិក្ខាសាលានេះ បានរៀបចំឡើងរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ នាបរិវេណនាយកដ្ឋានសណ្តាប់ធ្នាប់ ដោយមានសិក្ខាមចូលរួមចំនួន ៥០នាក់។

លោក សេង សុធារ៉ា ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ក្នុងឱកាសបើកសិក្ខាសាលានោះថា នេះជាលើកទីពីរហើយ ដែលអាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាស្តីពី«តួនាទីអ្នកគ្រប់គ្រងប្រាសាទ»នេះឡើង។ ដោយយល់ថាពិតជាសារៈសំខាន់ខ្លាំងណាស់ ដើម្បីបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងការងារប្រចាំថ្ងៃឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក៏ដូចជាផ្តល់ចំណេះដឹងបន្ថែមដល់អ្នកគ្រប់គ្រងប្រាសាទ។ ដោយធ្វើយ៉ាងណាធានាឲ្យបាននូវកិច្ចការពារ ការងារអភិរក្ស ការលើកតម្លៃសម្បត្តិវប្បធម៌ធម្មជាតិ ដោយសហការជាមួយដៃគូនានាដូចជា៖ អាជ្ញាធរខេត្ត ស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ អង្គការជាតិ និងអន្តរជាតិនានា ដែលមានគោលដៅរួម ជាមួយអាជ្ញាធរជាតិអប្សរាក្នុងការងារអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរប្រកបដោយនិរន្តរភាព។

ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលនេះ អាជ្ញាធរជាតិអប្សរាមានក្តីរំពឹងថា សិក្ខាកាមដែលបានចូលរួម នឹងទទួលបាននូវចំណេះដឹង បទពិសោធន៍ថ្មីៗបន្ថែមទៀត ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ រួមទាំងការងារ គ្រប់គ្រងមន្ត្រី-បុគ្គលិកក្រោមឱវាទរបស់ខ្លួន កាន់តែប្រសិទ្ធភាពខ្ពស់។ ជាពិសេស សិក្ខាកាម ដែលត្រូវបានជ្រើសរើស ជាអ្នកគ្រប់គ្រងប្រាសាទបានយល់ជ្រួតជ្រាប លើការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ផ្សេងៗទៀត ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា៕

# ប្រាសាទបន្ទាយសំរ៉ែជម្រើសទស្សនាល្អសម្រាប់ទេសចរចូលចិត្តភាពស្ងប់ស្ងាត់

ផ្សាយនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣

ស្ថិតនៅក្នុងបរិវេណវង់ធំនៃតំបន់រមណីយដ្ឋានអង្គរ ប្រាសាទបន្ទាយសំរ៉ែហាក់នៅដាច់ឆ្ងាយពីគេបន្តិច ។ យ៉ាងណា ប្រាសាទនេះក៏ជាទីទាក់ទាញដល់ភ្ញៀវទេសចរមួយផងដែរ។

ប្រធានគ្រប់គ្រងភ្នាក់ងារទេសចរណ៍នៅប្រាសាទបន្ទាយសំរ៉ែ និងភ្នំបូក លោក សៀន បណ្ឌិត បានឱ្យដឹងថាប្រាសាទបន្ទាយសំរ៉ែមានលំហូរទស្សនារៀងមមាញឹកគួរសមនារយៈចុងក្រោយនេះ ពិសេសក្រោយរាជរដ្ឋាភិបាលរៀបចំតំបន់អភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក។ ការចរាចរឆ្លងកាត់ពីភូមិព្រះដាក់ឆ្ពោះទៅភូមិរុនតាឯក ក៏បានស្រូបទាញទេសចរឱ្យចូលកម្សាន្តប្រាសាទនេះដែរ។

លោកបានបញ្ជាក់ថា ក្នុងមួយថ្ងៃមានទេសចរបរទេសចន្លោះពី១០០ទៅ២០០នាក់ ដែលមកកម្សាន្តប្រាសាទបន្ទាយសំរ៉ែនេះ។មូលហេតុដែលទេសចរ ចាប់អារម្មណ៍ប្រាសាទនេះក៏ដោយសារប្រាសាទនេះមានភាពស្ងប់ស្ងាត់ល្អ ធម្មជាតិត្រឈឹងត្រឈៃ បរិយាកាសបរិសុទ្ធ។

ភ្ញៀវទេសចរដែលមកកម្សាន្តប្រាសាទបន្ទាយសំរ៉ែ គឺច្រើនផ្សារភ្ជាប់ជាមួយវង់ទស្សនាទៅកាន់ប្រាសាទបន្ទាយស្រី។ លោក បណ្ឌិត បញ្ជាក់ថា ជួនកាលពួកគេចូលទស្សនាប្រាសាទបន្ទាយសំរ៉ែមុន ទើបចេញទៅបន្ទាយស្រី ឬក៏ទៅទស្សនាបន្ទាយស្រីរួច ទើបចូលបន្ទាយសំរ៉ែ។

ចំណុចពិសេសនៃប្រាសាទបន្ទាយសំរ៉ែ ជាទីតាំងដ៏ល្អសម្រាប់ទេសចរដែលចូលចិត្តភាពស្ងប់ស្ងាត់ និងមានបរិស្ថានដ៏ស្រស់បំព្រង។ ក្រៅពីទស្សនាប្រាសាទ ទេសចរក៏អាចអង្គុយអានសៀវភៅ ដែលក្នុងនោះក្រុមការងារភ្នាក់ងារទេសចរណ៍បានរៀបចំកន្លែងសម្រាប់ទេសចរអង្គុយលេងនៅក្រោមម្លប់ដើមឈើនៅក្នុងបរិវេណប្រាសាទនេះផងដែរ៕

# អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ អញ្ជើញចូលរួមស្តាប់ បាឋកថា ក្រោមប្រធានបទ: ចម្លាក់រឿងព្រះបាទសូរ្យវរ្ម័នទី២ លើថែវខាងត្បូងអង្គរវត្ត តាមរយៈគស្តុតាងសិលាចារឹក និងបុរាណវិទ្យា នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៨កន្លះព្រឹក នៅនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ( អគារមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣



## លិខិតអញ្ជើញ

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណៈជនទូទៅ មេត្តាអញ្ជើញចូលរួមស្តាប់ បាឋកថា

ក្រោមប្រធានបទ ៖ **ចម្លាក់រឿងព្រះបាទសូរ្យវរ្ម័នទី២ លើថែវខាងត្បូងអង្គរវត្ត តាមរយៈគស្តុតាងសិលាចារឹក និងបុរាណវិទ្យា**

វាគ្មិន ៖១. លោក វង្ស សារុទ្ធី មន្ត្រី នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ (ជំនាញសិលាចារឹក) នៃអាជ្ញាធរជាតិអប្សរា

២. លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋាន ស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ (បុរាណវិទ្យា និងប្រវត្តិសាស្ត្រ)នៃអាជ្ញាធរជាតិអប្សរា

នៅថ្ងៃសុក្រ ទី១៥ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០៨:៣០នាទី ព្រឹក

នៅ នាយកដ្ឋាន ស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ(អគារមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ) នៃអាជ្ញាធរជាតិអប្សរា

កំណត់សម្គាល់ ៖ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាផ្តល់ដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ/តេឡេក្រាម៖ ០១២ ៧៣៤ ៥២០ ឲ្យបាន០១ថ្ងៃមុន

# ភ្ញៀវទេសចរចូលទស្សនាប្រាសាទក្រោលគោ កាន់តែមានភាពងាយស្រួល

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមការងារភ្នាក់ងារទេសចរណ៍ សហការជាមួយភ្នាក់ងារសណ្តាប់ធ្នាប់ ក្រុមការងាររៀបចំវង់ទស្សនា និងក្រុមបរិក្ខាទេសចរណ៍ នៃអាជ្ញាធរជាតិអប្សរា និងក្រុមការងារ HCC-Angkor កំពុងបន្តរៀបចំសម្អាតដី ធ្វើផ្លូវ កាត់ក្រីរុក្ខជាតិតូចៗ ដាំស្មៅ និងដាំដើមឈើក្នុងបរិវេណផ្លូវដើរថ្មី សម្រាប់ចូលទៅទស្សនាប្រាសាទក្រោលគោ។

លោក គឿន សុភាន់ ប្រធានគ្រប់គ្រងភ្នាក់ងារទេសចរណ៍ បានឱ្យដឹងថា ក្រុមការងារបានរៀបចំធ្វើផ្លូវដើរថ្មី និង សម្អាតរុក្ខជាតិតូចៗ ដើម្បីអាចឲ្យភ្ញៀវទេសចរមើលឃើញទេសភាពដ៏ស្រស់ស្អាតរបស់ប្រាសាទពីចម្ងាយ និងអាចទស្សនាគ្រប់ជ្រុងជ្រោយនៅក្នុងបរិវេណប្រាសាទ។ បន្ថែមពីនេះ បន្ទាប់ពីរៀបចំផ្លូវថ្មីបានជាបណ្តើរៗ ក្រុមការងារសង្កេតឃើញថា មានភ្ញៀវទេសចរជាតិ និងអន្តរជាតិចាប់ផ្តើមចូលទស្សនាប្រាសាទក្រោលគោច្រើនជាងមុន៕

## ភ្នាក់ងារទេសចរណ៍ អាជ្ញាធរជាតិអប្សរា សម្អាតគំនរដី នៅតាមជើងខឿនប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣

ក្នុងគោលគំនិតលើកតម្លៃសោភ័ណភាព និងបរិស្ថានជុំវិញប្រាសាទលលៃឱ្យកាន់តែល្អប្រសើរ ភ្នាក់ងារទេសចរណ៍និងភ្នាក់ងារសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា រួមទាំងព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តលលៃ បានសម្អាតគំនរដី និងកម្ទេចថ្មសំណង់កុដិចាស់របស់វត្តលលៃ នៅតាមជើង ខឿនប្រាសាទផ្នែកខាងលិច និងខាងត្បូង។

លោកសោម ប៊ុនធឿន ប្រធានក្រុមភ្នាក់ងារទេសចរណ៍ ដែលកំពុងដឹកនាំអនុវត្តការងារ បានឱ្យដឹងថា គំនរដី និងកម្ទេចថ្មដែលគរនៅតាមជើងខឿនប្រាសាទលលៃនេះ គឺមានជាយូរឆ្នាំមកហើយ។ កម្ទេចដីនិងថ្មសំណង់កុដិចាស់របស់វត្តលលៃទាំងនេះ យើងបានយកទៅចាក់បំពេញផ្លូវចូលប្រាសាទពីខាងជើង ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរ និងបងប្អូនប្រជាពលរដ្ឋដែលរស់នៅតាមភូមិក្បែរៗនោះ។

# ក្រៅពីការទស្សនាថ្ងៃរះ និងថ្ងៃលិច ប្រាសាទភ្នំបាខែងក៏ក្លាយជាគោលដៅហាត់ប្រាណរបស់ភ្ញៀវជាតិ

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

បើនិយាយដល់ប្រាសាទភ្នំបាខែង ភ្ញៀវទេសចរពិតជានឹកឃើញដល់ទិដ្ឋភាពថ្ងៃរះ និងថ្ងៃរៀបលិច គួរជាទីគយគន់ទស្សនាទិដ្ឋភាពដ៏ស្រស់ស្អាតពីខាងលើប្រាសាទ។ មិនតែប៉ុណ្ណោះ ប្រាសាទភ្នំបាខែង ក៏បានក្លាយជាទីតាំងដើរហាត់ប្រាណយ៉ាងសប្បាយរីករាយរបស់ភ្ញៀវជាតិ។

កញ្ញា យាង សុខេង ភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទភ្នំបាខែង បានលើកឡើងថា ចាប់ពីម៉ោងប្រមាណ៥ព្រឹកមក មានភ្ញៀវទេសចរជាតិ បានយកជម្រាលផ្លូវដើរឡើងប្រាសាទភ្នំបាខែងជាកន្លែងសម្រាប់ធ្វើលំហាត់ប្រាណ។ កញ្ញា បញ្ជាក់ថា ការដើរហាត់ប្រាណឡើងទៅទស្សនាប្រាសាទភ្នំបាខែង ព្រោះពួកគាត់អាចគយគនធម្មជាតិស្រស់បំព្រងនៅជុំវិញនោះ ស្រូបខ្យល់អាកាសល្អបរិសុទ្ធ ជាពិសេសរងចាំទស្សនាទិដ្ឋភាពថ្ងៃរះ និងថ្ងៃលិចនៅទីនោះថែមទៀតផង។

សូមបញ្ជាក់ថា ថ្មីៗនេះ អាជ្ញាធរជាតិអប្សរាក៏រៀបចំកែលម្អបរិស្ថាននៅជុំវិញប្រាសាទ ដើម្បីលើកកម្ពស់សោភ័ណភាព ដូចជាការលះមែកឈើខ្លះៗ រៀបចំផ្លូវដើរជុំវិញប្រាសាទឱ្យស្អាត ដាក់ស្លាកសញ្ញាបង្ហាញទិស ដាក់បង្គោលខ្សែការពារកន្លែងមានហានិភ័យ ដើម្បីការពារសុវត្ថិភាពអ្នកទេសចរទាំងឡាយ។ ជាមួយគ្នានេះដែរ អាជ្ញាធរជាតិអប្សរាក៏សំណូមពរដល់ភ្ញៀវទេសចរ ឬមគ្គុទេសក៍ទេសចរណ៍ឱ្យនាំភ្ញៀវដើរទស្សនាតាមទិសដៅដែលបានរៀបចំ ដើម្បីឱ្យពួកគាត់បានឃើញនូវអ្វីដែលថ្មីៗ និងមានសណ្តាប់ធ្នាប់ល្អ៕

# នៅល្ងាចថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ គណៈកម្មការបេតិកភណ្ឌពិភពលោក នៃអង្គការយូណេស្កូក្នុងសម័យប្រជុំលើកទី៤៥ ប្រព្រឹត្តទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអូឌីត បានសម្តែងនៃការអបអរសាទរចំពោះប្រទេសកម្ពុជា ជាពិសេសចំពោះ អាជ្ញាធរជាតិអប្សរាស្តីអំពីការអភិរក្សតំបន់អង្គរ តាមរយៈសេចក្តីសម្រេចលេខ 45 COM 7B.152 និងអាជ្ញាធរជាតិសំបូរព្រៃគុក ស្តីអំពីតំបន់អភិរក្សសំបូរព្រៃគុកតាមរយៈសេចក្តីសម្រេចលេខ 45 COM 7B.151

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

## បាឋកថា ស្តីពីចម្លាក់រឿងព្រះបាទសូរ្យវរ្ម័នទី២នៅលើថែវខាងត្បូងអង្គរវត្ត តាមរយៈសិលាចារឹក និងបុរាណវិទ្យា ទទួលបានការជជែកយ៉ាងផុសផុល

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ នេះ អាជ្ញាធរជាតិអប្សរាបានរៀបចំបាឋកថាមួយស្តីពី ចម្លារឿងព្រះបាទសូរ្យវរ្ម័នទី២ នៅលើថែវខាងត្បូងអង្គរវត្ត តាមរយៈសិលាចារឹក និងបុរាណវិទ្យា ដែលមានអ្នកចូលរួមប្រមាណ២០០ ភាគច្រើនជាមគ្គុទ្ទេសក៍ទេសចរណ៍នៅតំបន់អង្គរ។

បាឋកថានេះបែងចែកជាពីរវគ្គ ដោយវគ្គទីមួយវាគ្មិនគឺលោក វង្ស សារ៉ុទ្ធី ជាប្រធានស្តីទីសារមន្ទីរកុលាលភាជន៍អង្គរភូមិតានី និងជាអ្នកជំនាញសិលាចារឹក។ លោកបានបង្ហាញអំពីទិដ្ឋភាពទូទៅនៃសិលាចារឹក និងសិលាចារឹកបុរាណចារនៅលើថែវអង្គរវត្ត ព្រមទាំងបកស្រាយខ្លឹមសារសិលាចារឹកទាំងនោះផង។ អង្គរវត្តជាប្រាសាទដ៏ស្កឹមស្កៃមួយ មានសិលាចារឹកប្រមាណជាង៦០ ហើយសិលាចារឹកទាំងនោះទៀតសោត បានចារនៅសម័យអង្គរខ្លះក្បែររូបតាមថែវ ហើយភាគច្រើនទំនងចារនៅក្រោយសម័យអង្គរ។

វាគ្មិនទី២ គឺលោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលនិងផ្សព្វផ្សាយ ធ្វើបទបង្ហាញពីប្រវត្តិសកម្មភាពគ្រួសៗរបស់ព្រះបាទសូរ្យវរ្ម័នទី២ ទំនាក់ទំនងខ្មែរ ចាម្ប៉ា និងដៃវៀត។ រឿងរ៉ាវចម្បាំងរវាងទ័ពចាមទ័ពខ្មែរ និងដៃវៀត ទាក់ទងនឹងចម្លាក់លើថែវខាងត្បូងអង្គរវត្ត ព្រមទាំងភស្តុតាងបង្ហាញពីតើស្យាមកុកដែលនៅក្នុងក្បួនដំណើរចម្បាំងរបស់ព្រះបាទសូរ្យវរ្ម័នទី២ ជាអ្នកណា។ល។

## ព្រះអាទិត្យរះចំកំពូលប្រាសាទអង្គរវត្តនឹងកើតឡើងនៅខែកញ្ញានេះ

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា មានសោមនស្សជូនដំណឹងថា ព្រឹត្តិការណ៍ព្រះអាទិត្យរះនៅចំកំពូលកណ្តាល នារដូវស្សានេះនឹងកើតឡើងចំថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ខាងមុខនេះ ចាប់ពីម៉ោង៦ព្រឹកតទៅ។ គឺជាសមរាត្រីរដូវវស្សា ដែលវេលាពេលថ្ងៃ និងរយៈពេលយប់មានស្មើគ្នា ដែលជាព្រឹត្តិការណ៍កើតឡើង២ដងតែប៉ុណ្ណោះក្នុងមួយឆ្នាំ  នៅក្នុងខែកញ្ញា និងខែមីនា។

## ទិដ្ឋភាពពីលើអាកាសបង្ហាញពីធម្មជាតិខៀវស្រងាត់ គ្របដណ្តប់ជុំវិញប្រាសាទមេបុណ្យខាងកើតនារដូវវស្សា

ផ្សាយនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣

## ប្រាសាទទទឹងថ្ងៃ លាក់ខ្លួនក្នុងព្រៃឫស្សី ដែលនៅមិនឆ្ងាយពីប្រាសាទបាគង

ផ្សាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣

## ប្រាសាទទទឹងថ្ងៃ លាក់ខ្លួនក្នុងព្រៃឫស្សី ដែលនៅមិនឆ្ងាយពីប្រាសាទបាគង

ផ្សាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣

# លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ដឹកនាំគណៈប្រតិភូក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរខេត្តព្រះវិហារ ចូលរួមសម័យប្រជុំលើកទី ៤៥ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអូឌីត ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣

សម្រាប់កិច្ចប្រជុំនេះ គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនឹងពិនិត្យសម្រេចចុះបញ្ជីរមណីយដ្ឋានបេតិកភណ្ឌចំនួន៥៣ របស់រដ្ឋភាគីនានា ដែលបានស្នើសុំចុះបញ្ជី។ រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមរៀបចំឯកសារ និងស្នើសុំចុះបញ្ជីរមណីយដ្ឋានប្រាសាទកោះកេរ តាំងពីឆ្នាំ២០១៨មកម្លេះ ហើយទើបតែឆ្នាំ២០២៣គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានសម្រេចដាក់បញ្ចូលក្នុងសម័យប្រជុំដើម្បីពិនិត្យសម្រេច និងបានអនុម័តជាឯកច្ឆ័នចុះបញ្ជីរមណីយដ្ឋានប្រាសាទកោះកេរ នៅក្នុងបេតិកភណ្ឌពិភពលោក ដោយទទួលស្គាល់នូវតម្លៃលេចធ្លោជាសាកលតាមរយៈលក្ខណៈវិនិច្ឆ័យទី២ និងទី៤ ព្រមទាំងទទួលស្គាល់ថា រមណីយដ្ឋានប្រាសាទកោះកេររក្សាបាននូវភាព Integrity និង Authenticity ពេញលេញ។

នេះជាមោទនភាពថ្មីមួយទៀត សម្រាប់ប្រទេស និងប្រជាជនកម្ពុជាគ្រប់រូប ដែលសម្បត្តិបេតិកភណ្ឌជាតិដ៏ថ្លៃថ្លា ត្រូវបានទទួលស្គាល់ និងបានក្នុងចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោក បន្ទាប់ពីតំបន់រមណីយដ្ឋានប្រាសាទអង្គរចុះបញ្ជីនាឆ្នាំ១៩៩២ ប្រាសាទព្រះវិហាចុះបញ្ជីនៅឆ្នាំ២០០៨ និងតំបន់ប្រាសាទសំបូរព្រៃគុកនៅឆ្នាំ២០១៧។

កិច្ចការពារបេតិកភណ្ឌវប្បធម៌ ជាភារកិច្ចរបស់កូនខ្មែរគ្រប់រូប

## អាជ្ញាធរជាតិអប្សរា សហការជាមួយវិស័យឯកជន បន្តដាំស្មៅ និងកូនឈើ នៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

កូនឈើចម្រុះជិត៤០០ដើម និងស្មៅ៣០០ម៉ែត្រការ៉េទៀត ត្រូវបានដាំនៅបរិវេណរមណីយដ្ឋានអង្គរ នៅក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក។

នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣ អាជ្ញាធរជាតិអប្សរា បានសហការជាមួយសាលា ប៊ែលធី អន្តរជាតិ និងប៊ែលធី ទេសចរណ៍ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ បុគ្គលិក និងសិស្សានុសិស្សជ័យលាភីនៃសាលា ប៊ែលធី អន្តរជាតិ ជាង២០០នាក់ បានដាំកូនឈើចម្រុះចំនួន៣៨០ដើម និងស្មៅចំនួន៣០០ម៉ែត្រការ៉េ នៅបរិវេណខាងជើងធៀងខាងលិចប្រាសាទអង្គរវត្ត(អតីតផ្សារយោងធំ)។ ការដាំដើមឈើនេះសោត ធ្វើឡើងក្នុងបំណងដើម្បីបណ្តុះស្មារតីសិស្សានុសិស្សគ្រប់ៗរូប ស្រឡាញ់ព្រៃឈើ ស្រឡាញ់បរិស្ថាន និងដាំទុកជាអនុស្សាវរីយ៍ ក៏ដូចជាបង្កើនសោភ័ណភាពក្នុងឧទ្យានអង្គរ៕

# សត្វឆ្មាដាវញីមួយក្បាលទៀត ត្រូវបានដោះលែងបន្ថែមក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ គម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា រដ្ឋបាលព្រៃឈើភ្នំពេញ និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance) បានដឹកជញ្ជូនសត្វឆ្មាដាវ (Leopard Cat) ញីមួយក្បាល ពីមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ យកមកផ្សាំងក្នុងទ្រុង ដែលក្រុមការងារគម្រោង មានគម្រោងដោះលែងចូលទៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គនៅពេលខាងមុខ។

តាមរយៈគម្រោងនេះដែរ កន្លងមកគម្រោងទទួលបានជោគជ័យក្នុងការដោះលែងសត្វព្រៃជាច្រើនប្រភេទចូលក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ មានដូចជា សត្វទោចមកុដ (Pileated gibbon) ចំនួន១៥ក្បាល(កើតកូនបានចំនួន៧ក្បាល) សត្វឈ្លូស(Red muntjac) ចំនួន៦ក្បាល សត្វស្វាព្រាម(Silvered langurs) ចំនួន១២ក្បាល សត្វសំពោចក្រអូប(Common palm civets) ចំនួន៧ក្បាល សត្វភេខ្លួនរលោង(Smooth-coated otter) ចំនួន៨ក្បាល (កើតកូនបានចំនួន៥ក្បាល) សត្វឆ្មាដាវ(Leopard Cat) ចំនួន២ក្បាល កេងកងតូច(Oriental Pied Hornbill) ចំនួន៧ក្បាល កេងកងធំ(Great Hornbill) ចំនួន៦ក្បាល ញាំង(Wreathed Hornbill) ចំនួន៧ក្បាល សត្វក្ងោក (Peafowl) ចំនួន៩ក្បាល សត្វអន្សង(Common Water Monitor) ចំនួន១ក្បាល និងសត្វផ្សេងៗមួយចំនួនទៀត ដែលមកដល់ឥឡូវសត្វទាំងអស់នេះ នៅតែមានវត្តមាននៅទីនោះនៅឡើយ ក្រោមការយកចិត្តទុកដាក់តាមដាន និងថែទាំជាប្រចាំពីក្រុមការងារ។

ដើម្បីឲ្យសត្វព្រៃទាំងអស់បន្តវត្តមាននៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរយើង និងបង្កើនចំនួនបន្ថែមទៀត អាជ្ញាធរជាតិអប្សរា និងគម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ សូមអំពាវនាវជូនសាធារណជន ភ្ញៀវជាតិ អន្តរជាតិ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ចូលរួមថែរក្សាសត្វព្រៃទាំងនោះទាំងអស់គ្នា ជៀសវាងពេលប្រទះឃើញមានបំណងមិនល្អ បញ្ឈប់ការដាក់អន្ទាក់សត្វគ្រប់ប្រភេទ និងមេត្តាកុំផ្តល់ចំណីឲ្យសត្វទាំងនោះ៕

# ក្រុមជួសជុលនៃអាជ្ញាធរជាតិអប្សរា បានរកឃើញមានការសាងសង់ខឿនពីរជាន់ នៅរួតទីបីនៃប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមអ្នកបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរា បានប្រទះឃើញសំណង់រចនាសម្ពន្ធថ្មីមួយដែលគេពុំធ្លាប់បានដឹងពីមុនមកទាល់តែសោះ គឺការសង់ជញ្ជាំងខឿនថ្មពីរជាន់ត្រួតគ្នានៅរួតទីបីរបស់ប្រាសាទបាយ័ន។

ការប្រទះឃើញសំណង់ដែលខុសប្លែកពីប្រាសាទបុរាណនានាទាំងអស់នេះ គឺក្នុងកំឡុងពេលដែលក្រុមការងារបច្ចេកទេសជួសជុលប្រាសាទកំពុងជួសជុលពង្រឹងរចនាសម្ពន្ធប្រាសាទនៅរួតទីបីនៃប្រាសាទ។ ស្ថាបត្យករ និងជាក្រុមការងារបច្ចេកទេសជួសជុលខឿនរួតទី៣ នៅប្រាសាទបាយ័ន កញ្ញា ម៉េង សុវណ្ណលីលីន មានប្រសាសន៍ថា នេះជាលើកទី២ហើយ ដែលក្រុមអ្នកបច្ចេកទេសរកឃើញថា មានការសាងសង់ខឿនប្រាសាទបុរាណត្រួតគ្នាហូតដល់ពីរជាន់នៅរួតទីបីនៃប្រាសាទបាយ័នដែលខុសប្លែកពីសំណង់ប្រាសាទបុរាណនានា ដោយគេឃើញសង់ខឿនមួយជាន់រួចហើយ មានសង់ខឿនមួយទៀតបន្ថែមពីខាងក្រៅ ព្រមទាំងការប្តូរប្លង់ស្ថាបត្យកម្មក្នុងកំឡុងពេលសាងសង់នោះផង។

ក្រុមអ្នកបច្ចេកទេសបានសង្កេតឃើញថា ខឿនដែលសាងសង់មុន គឺអត់សូវមានក្បាច់រចនាទេ គឺមានតែស្នាមដាប់រំលីងថ្មតែប៉ុណ្ណោះ ចំណែកឯ ខឿនដែលសាងសង់ពង្រីកក្រោយ គឺឃើញមានក្បាច់រចនាជាចម្លាក់ពងត្រីយ៉ាងស្អាត។

ក្រុមស្ថាបត្យករ បានសន្និដ្ឋានថា ការសាងសង់ខឿនប្រាសាទបុរាណថែមថយបែបនេះ ប្រហែលបណ្តាលមកពីអ្នកសាងសង់ មានការផ្លាស់ប្តូរគំនិតនៃការរចនាសំណង់ឱ្យកាន់តែស្អាតជាងមុន។កញ្ញាសុវណ្ណលីលីនពន្យល់ទៀតថា ការប្រទះឃើញសំណង់ប្រាសាទបុរាណ មានខឿនពីរជាន់នេះ គឺជាប្រវត្តិសាស្ត្រថ្មីមួយទៀត ដែលបានបង្ហាញឱ្យអ្នកសិក្សាស្រាវជ្រាវសំណង់ស្ថាបត្យកម្មនៅតាមប្រាសាទខ្មែរបុរាណកាន់តែបានស្វែងយល់បន្ថែមទៀត សម្រាប់ការចងក្រងផ្នែកស្ថាបត្យកម្មសម័យអង្គរទុកជាឯកសារឱ្យអ្នកស្រាវជ្រាវជំនាន់ក្រោយ៕

# ភ្ញៀវទេសចរបរទេសពីរនាក់ ជិះម៉ូតូដួលនៅចំណុចផ្លូវខ្លោងទ្វារទន្លេអុំ បណ្ដាលឱ្យមានរបួសស្រាលលើដៃ និងជើង ភ្លាមៗនោះ ក្រុមការងារភ្នាក់ងារទេសចរណ៍ និងភ្នាក់ងារសណ្ដាប់ធ្នាប់ ប្រចាំនៅគោលដៅប្រាសាទបក្សីចាំក្រុង ខ្លោងទ្វារទន្លេអុំ ប្រាសាទបី និងប្រាសាទបាយក្អែក ជួយសម្អាតរបួសនិងអាចធ្វើដំណើរត្រលប់ទៅវិញបាន

ផ្សាយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

# នៅព្រឹកមិញនេះ មានករណីគ្រោះថ្នាក់ចរាចរណ៍ កើតឡើងដោយរថយន្តដឹកគ្រឿងសំណង់ប៉ះជាមួយនិងភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

នៅវេលាម៉ោង១០:៥០នាទីព្រឹក ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ មានគ្រោះថ្នាក់ចរាចរណ៍មួយ បានកើតឡើងនៅមុខខាងកើតប្រាសាទបន្ទាយក្តី។ ករណីនេះកើតឡើងរវាងរថយន្តដឹកគ្រឿងសំណង់ បើកបរពីត្បូងទៅជើង ដោយមិនមានការប្រុងប្រយ័ត្ន ស្របពេលភ្ញៀវទេសចរជនជាតិរុស្សីដើរឆ្លងថ្នល់ពីកើតទៅលិច (ពីស្រះស្រង់មកប្រាសាទបន្ទាយក្តី)។ ករណីនេះបណ្តាលឱ្យប៉ះភ្ញៀវទេសចរបរទេស ជនជាតិរុស្សីភេទស្រីរងរបួសស្រាល។ ខណៈពេលនោះ ភ្នាក់ងារទេសចរណ៍ និងភ្នាក់ងារសណ្តាប់ បានធ្វើការលាងរបួសជូនភ្ញៀវទេសចរ ដែលរងរបួស។

បន្ទាប់មកអ្នកបើកបររថយន្តបានធ្វើការសុំទោសដល់ភ្ញៀវទេសចរ ហើយភ្ញៀវទេសចរដែលរងគ្រោះក៏បានណែនាំដល់អ្នកបើកបរឱ្យមានការប្រុងប្រយ័ត្នផងដែរ។

ក្នុងន័យនេះសូមសំណូមពរដល់អ្នកបើកបរយានយន្តទាំងអស់ មេត្តាបើកបរដោយមានការប្រុងយ័ត្នខ្ពស់ និងកុំបើបរក្នុងល្បឿនលឿន នៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងសូមទុកអាទិភាពដល់ភ្ញៀវទេសចរ ដែលធ្វើដំណើរដោយថ្មើជើង និងជិះកង់ជាដើម៕

## ក្រុមការងារសណ្តាប់ធ្នាប់ប្រចាំនៅប្រាសាទបាយ័ន ដាំបង្គោលក្រាក់ និងដាំស្មៅ បង្កើនទេសភាពបៃតងនៅជុំវិញប្រាសាទ

ផ្សាយនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣

ក្រៅពីការងារស្នូលរបស់ខ្លួន ភ្នាក់ងារសណ្តាប់ធ្នាប់ប្រចាំនៅគោលដៅក្រុងអង្គរធំ បានចូលរួមរៀបចំដាំបង្គោលក្រាក់នៅខាងៗផ្លូវក្បែរប្រាង្គប្រាសាទ ដើម្បីបង្ការយានយន្តគ្រប់ប្រភេទចូលទៅដល់ប្រាសាទ ឬជិតប្រាសាទ និងចតមិនមានសណ្តាប់ធ្នាប់ ព្រមទាំងដាំស្មៅដើម្បីលើកសោភ័ណភាពបៃតងនៅជុំវិញប្រាសាទបាយ័នកាន់តែមានភាពស្រស់បំព្រង។

កញ្ញា នៅ ចិន្តា អនុប្រធានភ្នាក់ងារសណ្តាប់ធ្នាប់ប្រចាំនៅគោលដៅប្រាសាទបាយ័ន បានឱ្យដឹងថា ការដាំបង្គោលក្រាក់ និងដាំស្មៅនេះ មានបួនទីតាំង គឺនៅខាងលិច ខាងត្បូង ខាងកើត និងខាងជើងនៃប្រាសាទបាយ័នត្រង់ចំណុចដែលមានដើមឈើធំៗ ដីស្ងួត និងមិនមានស្មៅដុះ។ កញ្ញា ចិន្តា បន្តថា នៅមុនពេលរៀបចំដាំជាបង្គោលក្រាក់ និងដាំស្មៅឃើញថា ទីតាំងមួយចំនួនត្រូវបានចតយានយន្តដោយមិនមានសណ្តាប់ធ្នាប់។ ប៉ុន្តែ ក្រោយពីដាំស្មៅរួចរាល់ឃើញថាទីតាំងទាំងនោះមានពណ៌បៃតង និងមិនមានការចតយានជំនិះផ្តេសផ្តាសទៀតឡើយ។ ក្រុមការងារនឹងថែទាំស្មៅទាំងនោះដើម្បីរក្សាបាននូវភាពបៃតងគ្រប់រដូវកាល។

ភ្នាក់ងារសណ្តាប់ធ្នាប់ ដែលបានចូលរួមក្នុងការងារនេះ សម្តែងការសប្បាយចិត្ត ដែលជួយលើកសោភ័ណភាពប្រាសាទ រក្សាបាននូវសណ្តាប់ធ្នាប់ល្អក្នុងបរិវេណក្រុងអង្គរធំ ពិសេសចំណុចប្រាសាទបាយ័ន។ សកម្មភាពនេះក៏នឹងផ្លាស់ប្តូរពីដីទំនេរមកជាមានស្មៅពណ៌បៃតងគ្រប់រដូវកាល បង្កើននូវទេសភាពវប្បធម៌ ហើយក៏អាចទាក់ទាញអារម្មណ៍ភ្ញៀវទេសចរឱ្យចង់មកទស្សនាបន្ថែមទៀត៕

## ទិដ្ឋភាពថ្ងៃរះនៅស្រះស្រង់ នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

# ខណៈសមរាត្រីកាន់តែកៀកថ្ងៃ ទេសចរចាប់អារម្មណ៍មកមើលថ្ងៃរះនៅអង្គរកាន់តែកើនឡើង

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

# មន្ត្រី និងបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៧ព្រឹក បានរៀបចំពិធីទូងស្គរ អបអរសាទរនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលរមណីយដ្ឋានប្រាសាទកោះកេរ ត្រូវបានគណៈកម្មាធិការបេតិកភណ្ឌ នៃអង្គការយូណេស្កូ នៃកិច្ចប្រជុំលើកទី៤៥ នៃទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអូឌីត សម្រេចបញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ ត្រូវនឹងម៉ោង១២:២៨នាទីរសៀល នៅទីក្រុងរីយ៉ាដ និងត្រូវនឹងម៉ោង ៤:២៨នាទី រសៀល ម៉ោងនៅកម្ពុជា

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

# ធ្វើជាអ្នកជួសជុលប្រាសាទឥដ្ឋ ព្រោះក្ដីស្រលាញ់ និងចង់ឱ្យកេរដំណែលដូនតានៅគង់វង្ស

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា បានយកចិត្តទុកដាក់ថែរក្សា ជួសជុល អភិរក្សប្រាង្គប្រាសាទ តាមមធ្យោបាយបណ្ដុះបណ្ដាលអ្នកបន្តវេន ឱ្យយល់ដឹងពីជំនាញបច្ចេកទេសដើម្បីរួមគ្នាអភិរក្ស។ ក្នុងនោះមានកូនខ្មែរមួយចំនួនបានស្ម័គ្រចិត្តធ្វើជាអ្នកជួសជុលប្រាសាទឥដ្ឋ ព្រោះតែពួកគេមានក្ដីស្រឡាញ់ និងចង់ថែរក្សាកេរដំណែលដូនតាខ្មែរឱ្យនៅគង់វង្ស។

លោក ជួន វង្ស អាយុ ៣០ឆ្នាំ អ្នកភូមិឱឡោក ឃុំបាគង នៃស្រុកប្រាសាទបាគង គឺជាអ្នកចូលរួមជួសជុលប្រាសាទម្នាក់ ក្នុងចំណោមអ្នករួមការងារជាច្រើនទៀត។ លោកមានប្រសាសន៍ថា លោកបានធ្វើជាអ្នកជួសជុលប្រាសាទឥដ្ឋចំនួន៤ឆ្នាំមកហើយ។ លោក វង្ស បានឱ្យដឹងថា ដោយសារការស់នៅក្បែរប្រាសាទតាំងពីតូច និងការស្រឡាញ់ផងជំរុញឱ្យលោកចូលបម្រើការងារជាអ្នកជួសជុលប្រាសាទឥដ្ឋ ព្រោះតែចិត្តចង់ចូលរួមថែរក្សាកេរដូនតា សម្រាប់ក្មេងជំនាន់ក្រោយបន្តទៀត។

ចំណែកលោក សែន ស៊ុង អាយុជាង៣០ឆ្នាំ គឺជាអ្នកជួសជុលប្រាសាទឥរយៈពេលជាង១០ឆ្នាំ មានប្រសាសន៍ថា ប្រាសាទបុរាណ ដែលដូនតាខ្មែរបានកសាង គឺអស្ចារ្យគ្មានពីរនៅលើលោក។ ការចូលរួមជួសជុលប្រាសាទបុរាណគឺជាសំណាងរបស់លោក ព្រោះតែប្រាសាទបុរាណមានតម្លៃអាយុកាលខ្ទង់ពាន់ឆ្នាំ មានសាងពីឥដ្ឋ និងពីថ្មធំៗ ស្ដឹមស្ដៃ និងមិនមានមនុស្សច្រើនទេ ដែលបានចូលរួមថែរក្សាសម្បត្តិដូនតាដោយផ្ទាល់ដូច្នេះឡើយ។

លោក ជួន វង្ស និងលោក សែន ស៊ុង ផ្ដាំផ្ញើដល់កូនខ្មែរគ្រប់រូប សូមចូលរួមថែរក្សាប្រាសាទបុរាណដែលជាកេរដំណែលដូនតា កុំធ្វើសកម្មភាពណាមួយដែលនាំឱ្យបាត់បង់តម្លៃប្រាសាទ និងសូមកុំគូសវាសលើថ្ម ឬឥដ្ឋដែលនាំឱ្យខូចខាតដល់ប្រាសាទ ព្រោះប្រាសាទបុរាណ គឺជារបស់យើងទាំងអស់គ្នា៕

# សន្និសីទអន្តររដ្ឋាភិបាលលើកទី៤ស្តីពីអង្គរ និងសំបូរព្រៃគុកនឹងរៀបចំនៅទីស្នាក់ការធំនៃអង្គការយូណេស្កូ

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

ឆ្លៀតក្នុងឱកាសដ៏មមាញឹកក្នុងកិច្ចប្រជុំលើកទី៤៥នៃគណៈកម្មការបេតិកភណ្ឌពិភពលោក នាទីក្រុងរីយ៉ាដ ប្រទេសសាអូឌីអារ៉ាប៊ីត **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ផាន់ ណាឌី** រួមជាមួយប្រតិភូដែលមានលេខាធិការវិទ្យាសាស្ត្រអចិន្ត្រៃយ៍នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរនិងសំបូរព្រៃគុក បានចូលជួបប្រជុំការងារជាមួយ **ឯកឧត្តម Lazare Eloundou Assomo** ប្រធានមជ្ឈមណ្ឌលបេតិកភណ្ឌនៃអង្គការយូណេស្កូ ដើម្បីពិភាក្សាអំពីការសម្របសម្រួលនានាក្នុងការត្រៀមរៀបចំសន្និសីទលើកទី៤នៃអន្តររដ្ឋាភិបាលអំពីអង្គរដែលនឹងប្រព្រឹត្តនាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្នាក់ការធំរបស់អង្គការយូណេស្កូ នាទីក្រុងប៉ារីស ប្រទេសបារាំង។

សន្និសីទអន្តររដ្ឋាភិបាលនេះរៀបចំឡើងដើម្បីកំណត់នូវគោលនយោបាយ និងទិសដៅសកម្មភាពនានាសំដៅពង្រឹងប្រសិទ្ធភាព អភិបាលកិច្ចល្អនៃកិច្ចអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរនិងរមណីយដ្ឋានសំបូរព្រៃគុក។

សូមបញ្ជាក់ថា គណៈកម្មាធិការអាយស៊ីស៊ី-អង្គរត្រូវបានប្រារព្ធឡើងលើកទី១ នៅឆ្នាំ១៩៩៣ នាទីក្រុងតូក្យូ ប្រទេសជប៉ុន លើកទី២ នៅឆ្នាំ២០០៣ នាទីក្រុងប៉ារីស ប្រទេសបារាំង និងលើកទី៣ នៅឆ្នាំ២០១៣ ប្រទេសកម្ពុជា។ នៅឆ្នាំ២០១៩ គណៈកម្មាធិការនេះត្រូវបានពង្រីកសមត្ថកិច្ចបន្ថែមដល់រមណីយដ្ឋានសំបូរព្រៃគុក ដោយប្តូរឈ្មោះថា គណៈកម្មការអាយស៊ីស៊ី-អង្គរនិងសំបូរព្រៃគុក៕

# ទិដ្ឋភាពស្រស់បំព្រងនៃ«ឧទ្យានអនុស្សាវរីយ៍អង្គរ-តូតាល់អេនើជី»

ផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣

ក្រោមគម្រោងសហការរវាងអាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុន TotalEnergies ក្រោយពីបានដាក់ឱ្យដំណើរការគម្រោងដាំដើមឈើ ដែលមានឈ្មោះថា «Angkor-TotalEnergies Park» ដែលស្ថិតនៅខាងជើងប្រាសាទព្រះខ័ន ក្នុងភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប អស់រយៈពេល២ឆ្នាំកន្លងមក កូនឈើគ្រប់ប្រភេទចំនួនជាង ១៦០០០ដើម លើផ្ទៃដីទំហំ ៨ហិកតា បានធំលូតលាស់ល្អ និងបានប្រែក្លាយទីតាំងនេះជារមណីយដ្ឋានខៀវស្រងាត់ស្រស់បំព្រង ម្លប់ត្រឈឹងត្រឈៃគួរជាទីមនោរម្យសម្រាប់ភ្ញៀវទេសចរ និងជាកំផែងបៃតងដ៏រឹងមាំជួយការពារប្រាង្គប្រាសាទពីការខូចខាតដោយសារកត្តាអាកាសធាតុ។

# សកម្មភាពដ៏មមាញឹកនៃការស្តារពើកនៅស្រះខាងកើតប្រាសាទបន្ទាយស្រី របស់មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានសហការជាមួយក្រុមការងាររបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យា និងនាយកដ្ឋានអភិវឌ្ឍទេសចរណ៍ និងវប្បធម៌ ដើម្បីស្តារពើកស្មៅដ៏ក្រាស់ៗ ដែលកកើតឡើងដោយសាររុក្ខជាតិតូចៗក្នុងទឹក ដូចជាកំប្លោក ស្លែ កកនៅក្នុងទឹករយៈពេលយូរនៅក្នុងស្រះខាងកើតប្រាសាទបន្ទាយស្រី។ ការងារនេះធ្វើឡើង ដើម្បីបរិស្ថាន និងលើកកម្ពស់សោភ័ណភាពស្រស់ស្អាតឡើងវិញ ក៏ដូចជាដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែម។

មុនពេលមានសកម្មភាពស្តារពើកស្មៅនេះ ស្ថានភាពត្រពាំងនេះមើលទៅស្ទើរតែមិនឃើញផ្ទៃទឹកសោះ ដោយសារមានពើកស្មៅដ៏ក្រាស់ៗដុះដុំជិតនៅទីនោះ។

ក្រោយពេលការងារស្តារពើកស្មៅដ៏ក្រាសនេះ រួចរាល់ អាជ្ញាធរជាតិអប្សរារំពឹងថាបរិស្ថាន និងសោភណ្ឌភាពនៅបរិវេណត្រពាំងនេះនឹងប្រែជាស្រស់ស្អាតឡើងវិញ ហើយក៏ជាទីទាកទាញ់ភ្ញៀវទេសចរមកកម្សាន្តនៅទីនោះផងដែរ៕

# ព្រឹត្តិការណ៍សមរាត្រីរដូវវស្សាឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

ជារៀងរាល់ឆ្នាំ ព្រឹត្តិការណ៍សមរាត្រី (Equinox) តែងតែកើតមាន២ដង គឺនៅរដូវប្រាំង (Vernal Equinox) កើតឡើងនៅខែមីនា និងសមរាត្រីរដូវវស្សា (Autumnal Equinox) កើតឡើងនៅខែកញ្ញា។ ចំពោះឆ្នាំ២០២៣នេះ ថ្ងៃរះលើកំពូលអង្គរវត្តចំថ្ងៃសមរាត្រីរដូវវស្សានេះ នៅថ្ងៃទី២២ ខែកញ្ញា ដែលជាវេលាដែលថ្ងៃនិងយប់មានរយៈពេលស្មើរតែស្មើគ្នាគិតនៅប្រទេសកម្ពុជាយើង។ ក្រៅពីនេះ ខែខ្លះថ្ងៃមានរយៈពេលវែងជាងយប់ ហើយខ្លះទៀត យប់មានរយៈពេលវែងជាងថ្ងៃវិញ។

ករណីពិសេសនៅអង្គរវត្ត នាវេលាថ្ងៃនិងយប់មានរយៈពេលស្មើគ្នានេះ ព្រះអាទិត្យនឹងរះឡើងចំកំពូលកណ្តាលនៃអង្គរវត្តនាព្រឹកព្រលឹមស្រាងៗ ដែលយើងអាចមើលឃើញពីខ្លោងទ្វារកណ្តាលនៃគុហ៍តារាជ (ខ្លោងទ្វារធំខាងលិច)។

នេះជារឿងអច្ឆរិយរបស់អង្គរវត្ត ដែលបានស្ថាបនាឡើងដោយមានការសិក្សាគន់គូរយ៉ាងល្អិតល្អន់របស់អ្នកប្រាជ្ញបណ្ឌិតសម័យអង្គរ រួមផ្សំគ្នារវាងទ្រឹស្តីគណិតសាស្ត្រ វិស្វកម្ម ស្ថាបត្យកម្ម និងតារាសាស្ត្រ។ គឺជាហេតុផលវិទ្យាសាស្ត្រមួយដែលបំពេញចម្លើយចំពោះសំណួរដែលសួរមិនចេះចប់ថា ហេតុដូចម្តេចបានជាអង្គរវត្តបែរមុខទៅទិសខាងលិច?៕

# ទិដ្ឋភាពថ្ងៃរះពេលព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ ត្រូវនឹងថ្ងៃព្រឹត្តិការណ៍សមរាត្រី មានភ្ញៀវទេសចរជាតិ-អន្តរជាតិជាច្រើន បានមកទស្សនា និងផ្តិតយករូបភាពដ៏អស្ចារ្យនៅប្រាសាទអង្គរ ក្នុងខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

# ប្រាសាទព្រះគោ មូលនីយដ្ឋានដើមសម័យអង្គរ ដែលមានចម្លាក់ល្អវិចិត្រ

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

# សកម្មភាពក្រុមការងារនាយកដ្ឋានទេសចរណ៍ និងវប្បធម៌ និងនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា សហការគ្នាជួសជុលកម្រាលឈើដែលបាក់មេនិងសសរផ្នែកខាងក្រោមត្រង់ចំណុចដើមឈើនៅប្រាសាទតាព្រហ្ម ដើម្បីសម្រួលដល់ការទស្សនា និងឈរថតរបស់ភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

# ភ្ញៀវទេសចរ បង្ហាញអារម្មណ៍រំភើបពេលមកទស្សនាថ្ងៃរះនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ មានភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកពីគ្រប់ទិសទីជាច្រើនពាន់នាក់ បានមកទស្សនាទស្សនីយភាពថ្ងៃរះ នាព្រឹកព្រលឹមនៅប្រាសាទអង្គរ ដោយទឹកមុខសប្បាយរីករាយ។

លោក អ៊ុច សាវន អាយុ៦៧ឆ្នាំ មកពីខេត្តបាត់ដំបង បានបង្ហាញក្តីរំភើបពេលបានមកទស្សនាថ្ងៃរះនៅប្រាសាទអង្គរវត្ត ដ៏ស្កឹមស្កៃ ជាមួយនិងមនុស្សជាច្រើនពាន់នាក់ ជាពិសេសបរិស្ថានជុំវិញប្រាសាទ និងការរៀបចំសណ្តាប់ធ្នាប់មានរបៀបរៀបរយល្អដែលជាការទាក់ទាញ ក្រៅពីប្រាសាទ។

ទេសចរម្នាក់ទៀត លោក ម៉ុក សារិទ្ធិ រស់នៅខេត្តសៀមរាប ក្រោកតាំងពីព្រឹកមកទស្សនាថ្ងៃរះនៅប្រាសាទអង្គរ មានអារម្មណ៍ថាអស្ចារ្យចំពោះស្នាដៃរបស់ដូនតាខ្មែរដែលបានកសាងសំណង់ប្រាសាទដ៏អច្ឆរិយនេះ។ លោកសប្បាយចិត្តពេលមកឃើញមានភ្ញៀវជាតិ និងអន្តរជាតិមកពីទីជិតឆ្ងាយមកទស្សនាថ្ងៃរះនៅប្រាសាទអង្គរវត្តដែលលោករំពឹងថានឹងបន្តមានភ្ញៀវមកទស្សនាកើនឡើងបន្ថែមទៀត៕

**ក្រុមការងារភ្នាក់ងារទេសចរណ៍ សហការជាមួយប៉ូលីសបេតិកភណ្ឌប្រចាំការនៅប្រាសាទតាព្រហ្ម បានរក្សាកាបូបដែលភ្ញៀវទេសចរភ្លេច និងប្រគល់ជូនគាត់វិញ នៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣**

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

# ពន្លឺនៃអរុណរះចេញថ្មីចែងចាំងពេលព្រឹកព្រលឹមនៅស្រះស្រង់ បានធ្វើឱ្យទីឋានបុរាណដ៏ពិសិដ្ឋមួយនេះ កាន់តែបង្កើនសោភ័ណភាពទ្វេឡើង

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

## ទិដ្ឋភាពខ្លោងទ្វារទន្លេអុំពីលើអាកាស អមដោយធម្មជាតិខៀវស្រងាត់

ផ្សាយនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣

# ការជួសជុល និងពង្រឹងខឿនបាកាណប៉ែកអាគ្នេយ៍ នៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣

មន្ត្រីជំនាញអភិរក្សថ្មរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា រហូតមកដល់ត្រឹមថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣នេះ ក្រុមការងារបច្ចេកទេសជួសជុលខឿនបាកាណរបស់ប្រាសាទអង្គរវត្ត គឺបានជួសជុលពង្រឹងការខូចខាតផ្នែកខ្លះនៃខឿនថ្ម ឱ្យបានដូចដើមឡើងវិញ ដូចជា បានរុញថ្មដែលញែកចេញពីគ្នាឱ្យចូលជាប់គ្នាវិញ ពង្រឹងគ្រឹះឱ្យរឹងមាំ ដោយប្រើលោហជាតិអ៊ីណុកទាម ដើម្បីទប់លំនឹងនៅតាមទីតាំងដែលថ្មងាយនឹងរបេះ។

បច្ចុប្បន្ននេះ ខឿនបាកាណផ្នែកអាគ្នេយ៍ នៃប្រាសាទអង្គរវត្ត ដែលមានការខូចខាតទ្រុឌទ្រោមខ្លាំង ដោយសារកត្តាចលនាទម្ងន់សង្កត់ពីលើ អាយុកាលរបស់ថ្ម ដើមឈើដុះចាក់ឫសចូលតាមថ្នេរថ្មចូលខឿនពីអតីតកាល និងចូលក្នុងគ្រឹះធ្វើឱ្យថ្មរហែកញែកចេញពីគ្នា រួមផ្សំនិងកត្តាទឹកភ្លៀងហូរចូលតាមចន្លោះថ្មទៅក្នុងគ្រឹះផង បណ្តាលឱ្យរចនាសម្ពន្ធទ្រទ្រង់របស់ជាន់បាកាណថយកម្លាំងទប់ខ្លះ។

មន្ត្រីអភិរក្ស និងជាក្រុមការងារបច្ចេកទេសជួសជុលខឿនបាកានរបស់ប្រាសាទអង្គរវត្ត លោក រ៉ូ សុវណ្ណដារដ្ឋ មានប្រសាសន៍ថា ច្រើនខែមកហើយ ក្រុមការងារបច្ចេកទេសកំពុងប្រឹងប្រែងជួសជុលខឿនបាកាណរបស់ប្រាសាទអង្គរវត្ត នៅតាមកន្លែងដែលមានថ្មញែកចេញពីគ្នា ដោយក្រុមការងារបានប្រើលោហជាតិអ៊ីណុកទាមឱ្យជាប់គ្នាទៅតាមស្រទាប់ៗប្រហែល២០កន្លែង ដើម្បីជួយទប់លំនឹងកុំឱ្យរហែកតទៅទៀត។ មន្ត្រីដដែលពន្យល់ទៀតថា បច្ចេកទេសនៃការទាមដើម្បីទប់លំនឹងថ្មទៀតសោត គឺបែងចែកជា៤ថ្នាក់ទៅតាមស្រទាប់នីមួយៗ។ ចំណែកឯកន្លែងសំខាន់ដែលមានថ្មបាយក្រៀមនៅពីក្រៅ គឺត្រូវបិទភ្ជាប់កុំឱ្យទឹកជ្រាបចូល ដូចជា នៅចំណុចជ្រុងអាគ្នេយ៍ជាដើម។

មន្ត្រីជំនាញអភិរក្សថ្មរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា ឱ្យដឹងថា រហូតមកដល់ពេលនេះ ដំណើរការជួសជុល និងពង្រឹងខឿនបាកាណនៅសល់តែ២ជ្រុង ផ្នែកអាគ្នេយ៍ និងជណ្តើរប៉ុណ្ណោះ៕

# អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការ WSM/INSPIR Asia បន្តដាំស្មៅ និងកូនឈើ នៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរា បានសហការជាមួយអង្គការ WSM/INSPIR Asia ដែលមានស្នាក់ការនៅប្រទេសឥណ្ឌូនេស៊ី បានរៀបចំសិក្ខាសាលានៅក្រុងសៀមរាប និងបានដឹកនាំសិក្ខាកាមចំនួនជាង៦០នាក់ មកពី១២ប្រទេសចូលរួមដាំស្មៅនិងដើមធ្នង់ចំនួន១២ដើម នៅបរិវេណខាងជើងធៀងខាងលិចប្រាសាទអង្គរវត្ត (អតីតផ្សារយាងធំ) ដើម្បីទុកជាអនុស្សាវរីយ៍តំណាងប្រទេសនីមួយៗ៕

# សេចក្តីជូនដំណឹង ស្តីពីការថតរូបភាព ឬវីដេអូ នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា

APSARA

លេខ [illegible]

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការថតរូបភាព ឬវីដេអូ នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ**

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ជាគោលការណ៍ អាជ្ញាធរជាតិអប្សរា មិនមានការហាមឃាត់ទេ ចំពោះការថតរូបភាព ឬវីដេអូ សម្រាប់ចងក្រងជាអនុស្សាវរីយ៍ផ្ទាល់ខ្លួន ឬលក្ខណៈទេសចរណ៍ ដើម្បីផ្សព្វផ្សាយសិល្បៈ និងវប្បធម៌ ឱ្យពិភពលោកបានស្គាល់ពីភាពទាក់ទាញ និងសម្បត្តិវប្បធម៌ដ៏អស្ចារ្យរបស់កម្ពុជា។ ជាក់ស្តែង ការថតរូបភាព និងវីដេអូ តាមទម្រង់ទាំងនេះ ត្រូវបានភ្ញៀវទេសចរជាតិ-អន្តរជាតិ បង្ហោះផ្សព្វផ្សាយនៅតាមបណ្តាញសង្គមនានា ដូចជាហ្វេសប៊ុក TikTok និងបណ្តាញសង្គមជាច្រើនផ្សេងទៀតរួចមកហើយ។

ដោយឡែកក្នុងគោលបំណងបញ្ចៀសនូវកំហុសឆ្គងដោយអចេតនាកើតចេញពីការផ្សព្វផ្សាយ និងអាចធ្វើឱ្យប៉ះពាល់គុណតម្លៃនៃប្រាសាទបុរាណ មរតកមិនអាចកាត់ថ្លៃបានរបស់បុព្វបុរសខ្មែរ និងជាសម្បត្តិបេតិកភណ្ឌពិភពលោក ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ តម្រូវឱ្យដាក់ពាក្យស្នើសុំមកអាជ្ញាធរជាតិអប្សរា ចំពោះគោលបំណងមួយចំនួន ដូចមានបញ្ជាក់ជូនខាងក្រោម ដើម្បីអនុញ្ញាតឱ្យមន្ត្រីជំនាញ មានលទ្ធភាពពិនិត្យជាមុន នូវទិដ្ឋភាពបច្ចេកទេសមួយចំនួន ដូចជាខ្លឹមសារផ្សព្វផ្សាយ និងសម្ភារប្រើប្រាស់ជាដើម ៖

- ការថតរូបភាព ថតភាពយន្ត ឬវីដេអូ ក្នុងគោលបំណងផ្សព្វផ្សាយពាណិជ្ជកម្ម ផលិតផល ឬបង្កើតអាជីវកម្មនានា។
- ការប្រកបអាជីវកម្មថតសម្លៀកបំពាក់ប្រពៃណីបុរាណ (ថតរូបមុនអាពាហ៍ពិពាហ៍) ដើម្បីពិនិត្យភាពសមស្របនៃសម្លៀកបំពាក់ប្រពៃណីបុរាណ។ ការថតបែបនេះ មិនមានការបង់ប្រាក់នោះទេ។
- ការថតវីដេអូផ្សាយបន្តផ្ទាល់ដោយក្រុមហ៊ុនទេសចរណ៍ ឬមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានអាជ្ញាបណ្ណត្រឹមត្រូវពីក្រសួងទេសចរណ៍ ដើម្បីផ្សព្វផ្សាយប្រាសាទនានាតាមប្រព័ន្ធអនឡាញជូនទៅអតិថិជនរបស់ខ្លួន។ រាល់ការផ្សព្វផ្សាយបែបនេះ មិនមានការបង់ប្រាក់នោះទេ។

រាល់ការស្នើសុំថតរូប ឬវីដេអូផ្សព្វផ្សាយពាណិជ្ជកម្ម ផលិតផល ឬបង្កើតអាជីវកម្មនានា សូមភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាទំនាក់ទំនងមកមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរជាតិអប្សរា រៀងរាល់ម៉ោងបំពេញការងារ ហើយអាជ្ញាធរជាតិអប្សរា នឹងឆ្លើយតបទៅម្ចាស់សំណើវិញ ក្នុងរយៈពេលប្រាំ (៥)ថ្ងៃ នៃថ្ងៃធ្វើការងារយ៉ាងយូរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១២កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

សៀមរាប ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០២៣

**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារតំបន់ និងរៀបចំដែនដីរមណីយដ្ឋានអង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

# សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា

APSARA

លេខ: ៧២៥៨/២៣ .អប.សជណ

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការកាត់ដកហូតដើមឈើនិងកាត់ក្រីមែកឈើ**

**មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ**

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាព ភ្ញៀវទេសចរ សាធារណជន ក៏ដូចជា ដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរានឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ក្រីមែកឈើចំនួន២១ដើម (ដើមព្រីង១ដើម ដើមឈើទាល១ដើម ដើមអង្គាញ់៦ដើម ដើមចំបក់១ដើម ដើមអាទិត្យ១ដើម ដើមសិរមាន់១ដើម និងដើមធ្នង់១ដើម) ស្ថិតនៅបរិវេណប្រាសាទបន្ទាយស្រី។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន០៧ដើម (កាត់ដកហូត ដើមម្កាក់ងាប់១ដើម និងដើមល្វៀង១ដើម កាត់ក្រីមែកឈើ វល្លិយាង១ដើម ដើមព្រីង១ដើម ដើមកណ្តោល១ដើម ដើមត្រចៀកក្រៀម១ដើម ដើមពង្រ១ដើម) ស្ថិតនៅបរិវេណប្រាសាទភ្នំបាខែង។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១០ដើម (កាត់ដកហូត ដើមក្រសាំង២ដើម ដើមពង្រ១ដើម ដើមព្នៅ១ដើម ដើមគគីរ១ដើម និងកាត់ក្រីដើមឈើទាល៣ដើម ដើមស្លែង១ដើម ដើមក្រាង១ដើម) ស្ថិតនៅបរិវេណប្រាសាទបក្សីចាំក្រុង។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១៤ដើម (កាត់ដកហូតដើមក្រឡាញ់១ដើម ដើមឈើទាលងាប់១ដើម ដើមខ្នាស់ដួលរលំ១ដើម និងកាត់ក្រីដើមក្រឡាញ់៤ដើម ដើមចំបក់៦ដើម ដើមក្រាង១ដើម ) ស្ថិតនៅបរិវេណប្រាសាទព្រះគោ។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១៦ដើម (កាត់ដកហូតដើមអំពិលទឹកបាក់ង១ដើម និងកាត់ក្រីដើមឈើទាល៩ដើម ដើមអំពិលទឹកបាក់ង៣ដើម ដើមក្ងោក២ដើម ដើមល្វស១ដើម) ស្ថិតនៅក្នុងផ្សារ ចាំរីស និងចំណតរថយន្តមុខប្រាសាទអង្គរវត្ត។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន៦ដើម (កាត់ដកហូតដើមត្នោត១ដើម និងកាត់ក្រីដើមឈើទាល៤ដើម អង្គាញ់១ដើម) ស្ថិតនៅបរិវេណសាលាបឋមសិក្សាឥន្ទ្រកោសិយ៍។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន០៩ដើម (កាត់ដកហូតដើមក្រសេក១ដើម និងកាត់ក្រីដើមក្រសេក២ដើម ឬស្សីពាគម្ព ដើមអាកាស្យា១ដើម ដើមក្ងោក១ដើម ដើមឈើទាល១ដើម) ស្ថិតនៅបរិវេណចំណតរថយន្តមុខប្រាសាទមេបុណ្យខាងកើត។
- កាត់ក្រីដើមអំពិល១ដើម នៅភូមិនីឡោក ជិតប្រាសាទបាគងស្ថិតនៅខាងលិចឆៀងខាងត្បូង។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣តទៅ រហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១៣កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

សៀមរាប ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២៣

**អាជ្ញាធរជាតិអប្សរា**

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province

# អាជ្ញាធរជាតិអប្សរា បន្តជួសជុលបង្កាន់ដៃនាគ ខឿនផ្ទាល់ដីទិសខាងត្បូងប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បន្តជួសជុលបង្កាន់ដៃនាគប្រវែងជិត២០ម៉ែត្រទៅខាងកើត នៃជណ្ដើរខាងត្បូងរបស់ប្រាសាទអង្គរវត្តថែមទៀត ក្រោយបានពង្រឹងរចនាសម្ពន្ធខឿន និងផ្នែកក្បាលនាគរួចរាល់។

បុរាណវិទូ និងជាភ្នាក់ងារអភិរក្សប្រាសាទអង្គរវត្ត នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា លោក ស៊ិយ សុភារិទ្ធ ឱ្យដឹងថា បច្ចុប្បន្នសម្រេចបានការងារជួសជុលពង្រឹងគ្រឹះជណ្ដើរ និងគ្រឹះបង្កាន់ដៃនាគ ដែលស្រុតចុះដោយសារទឹកហូរច្រោះ។ ជាមួយគ្នានេះ ក្រុមការងារក៏បានកាយកំណាកដី បើកប្រព័ន្ធផ្លូវរំដោះទឹកបុរាណឡើងវិញ ការពារកុំឱ្យទឹកជ្រាបចូលតាមមុខដំណាថ្ម ដែលជាហេតុធ្វើឱ្យគ្រឹះចុះខ្សោយបន្តទៀត។

លោក សុភារិន ឱ្យដឹងទៀតថា ក្រោយពីជួសជុលពង្រឹងគ្រឹះរួចហើយ ក្រុមការងាររៀបចំដាក់ទ្រនាប់ជើងនាគ និងក្បាលនាគឡើងវិញ។ ដោយឡែកនៅក្នុងការងារនេះ ក៏ត្រូវរើបង្កាន់ដៃនាគប្រវែង១៥ម៉ែត្របន្ថែមទៀត៕

# អាជ្ញាធរជាតិអប្សរា ដាំកូនឈើចំនួន១,៣៥០ដើម ដើម្បីអបអរសាទរទិវាទេសចរណ៍ពិភពលោក ២៧កញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣នេះ អាជ្ញាធរជាតិអប្សរា បានរួមគ្នាដាំកូនឈើ ចម្រុះចំនួន១,៣៥០ដើម នៅលើផ្ទៃដីជាង២ហិកតា ក្បែរបរិវេណមណ្ឌលបដិសណ្ឋារកិច្ចសៀមរាបអង្គរ ដើម្បីចូលរួមអបអរសាទរទិវាទេសចរណ៍ពិភពលោក ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ ដែលបានប្រព្រឹត្តិទៅក្រោមប្រធានបទ "ទេសចរណ៍ និងការវិនិយោគបៃតង"៕

# ភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាប្រគល់សម្ភារជូនភ្ញៀវទេសចរដែលភ្លេច

ផ្សាយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ១២:៤៨នាទី ក្រុមភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា បានប្រគល់កាបូបតូចស្ពាយចំហៀងពណ៌ត្នោតដល់ភ្ញៀវទេសចរជនជាតិចិន ឈ្មោះ Zhao Mingwei ភេទស្រី អាយុ ២៨ឆ្នាំ ដែលភ្លេចនៅចំណុចរួតពីរខាងជើងច្រកកណ្តាលនៃប្រាសាទអង្គរវត្ត។

## សកម្មភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនា និងថតផ្តិតរូបភាពដ៏ស្រស់ស្អាត នាពេលព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

# សូមអញ្ជើញទស្សនាទិដ្ឋភាពប្រាសាទបាគង ដែលជាទម្រង់ប្រាសាទភ្នំធំដំបូងគេនៅសម័យអង្គរ

ផ្សាយនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣

# សកម្មភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនា និងថតផ្តិតរូបភាពដ៏ស្រស់ស្អាត នាពេលព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣

# ក្រុមការងារភ្នាក់ងារទេសចរណ៍ និងក្រុមការងារ ភ្នាក់ងារសណ្ដាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរាគោលដៅបារាយណ៍ទឹកថ្លា និងប្រាសាទមេបុណ្យខាងលិច សហការរួមគ្នាកាត់ក្រីសម្អាតមែកឈើដែលធ្លាក់បាំងលើជណ្ដើរបង្ហូរបើកបិទទឹក ផ្នែកខាងកើតនៃបារាយណ៍ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២៣

ផ្សាយនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣



# ព្រឹត្តិការណ៍ព័ត៌មាន
# ប្រចាំខែតុលា

## រូបភាពខ្លោងទ្វារខ្មោចនៃក្រុងអង្គរធំ ហាក់កំពុងសំងំលាក់ខ្លួនក្នុងធម្មជាតិយ៉ាងស្រស់ត្រកាល

ផ្សាយនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣

## ខ្លោងទ្វារតាកាវ កំពុងបញ្ចេញមន្តស្នេហ៍ឆក់យកបេះដូងទេសចរឱ្យចង់ទៅគយគន់

ផ្សាយនៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣

តាកាវ គឺជាឈ្មោះខ្លោងទ្វារមួយស្ថិតនៅទិសខាងលិច របស់ក្រុងអង្គរធំ ក្នុងចំណោមខ្លោងទ្វារចំនួន៤ផ្សេងទៀត ដែលកំពុងទាក់ទាញឱ្យភ្ញៀវទេសចរជាច្រើនទៅទស្សនា និងថតយករូបអនុស្សាវរីយ៍ស្ទើរតែជារៀងរាល់ថ្ងៃ។

ខ្លោងទ្វារតាកាវ បានបញ្ចេញសម្រស់រឹតតែស្រស់ស្អាត និងទាក់ទាញ បន្ទាប់ពីក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ធ្វើការជុសជុលឱ្យរួចផុតពីភាពទ្រុឌទ្រោមរួចមក។

ប្រធានភ្នាក់ងារទេសចរណ៍ដែលប្រចាំការនៅខ្លោងទ្វារ តាកាវ លោក លៀស គឹមលេខ មានប្រសាសន៍ថា ជារៀងរាល់ថ្ងៃ ភ្ញៀវទេសចរតែងទៅទស្សនាខ្លោងទ្វារនេះ ហើយបានដក់ចិត្តជាមួយនិងការថតរូបមិនចេះណាយ ដោយសារតែខ្លោងទ្វារតាកាវមានកំពូលព្រហ្មមុខ៤ ញញឹមស្វាគមន៍ ដោយមានកសិន្ធុទឹកព័ទ្ធជុំវិញ មានដើមឈើតូចធំដុះផ្តុំគ្នាបង្កើតជាទេសភាពដ៏ទាក់ទាញយ៉ាងល្អឯក។

លោក គឹមលេខ ឱ្យដឹងទៀតថា នៅខ្លោងទ្វារតាការ មានលក្ខណៈពិសេសម្យ៉ាងទៀត គឺនៅពេលព្រះអាទិត្យរៀបលិចមានពន្លឺចាំងពីលិច រំលេចចេញទៅជាពណ៌មាសក្រាលគ្របលើកំពូលសំណង់បុរាណមួយនេះ ដែលបង្កើតទៅជាសម្រស់ដ៏ស្រស់ស្អាតសម្រាប់ទេសចរឱ្យមកទស្សនា ព្រមទាំងថតរូបភាពមិនសូវអាក់ខាន។

ដោយសារតែខ្លោងទ្វារតាការ កំពុងទាក់ទាញភ្ញៀវទេសចរដូចនេះ ភ្នាក់ងារទេសចរណ៍ដែលប្រចាំការនៅទីនេះតែងតែជួយសម្របសម្រួលដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដោយរៀបចំដាក់ស្លាកសញ្ញាឱ្យដឹងពីកន្លែងទស្សនា និងកន្លែងគ្រោះថ្នាក់ជាដើម។ ជាពិសេស សំណូមពរដល់ភ្ញៀវជាតិ និងអន្តរជាតិ កុំឡើងជាន់លើដំបូលនៃស្លាបរបស់តួខ្លោងទ្វារ គោរពតាមស្លាកសញ្ញា និងក្រមប្រតិបត្តិអង្គរចៀសវាងមានបញ្ហាប៉ះពាល់ដល់ប្រាសាទ និងគ្រោះថ្នាក់ដោយយថាហេតុផ្សេង៕

# អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការមូលនិធិហ្វ្រេដហូឡូ បន្តដាំស្មៅ និងកូនឈើនៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣

នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣ ក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរា បានសហការជាមួយថ្នាក់ដឹកនាំ និងមន្ត្រីចំនួន១៦រូប នៃអង្គការមូលនិធិហ្វ្រេដហូឡូ ( The Fred Hollows Foundation ) ដែលជាអង្គការអភិវឌ្ឍន៍របស់ប្រទេសអូស្ត្រាលី ផ្តោតលើសកម្មភាពការងារសុខភាពភ្នែក បានអញ្ជើញមកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា និងចូលរួមដាំស្មៅ និងដើមធ្នង់ចំនួន១៥ដើម នៅបរិវេណខាងលិចត្រពាំងសេស ដើម្បីបន្សល់ទុកជាស្នាដៃការងារសង្គម និងទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងតំបន់រមណីយដ្ឋានអង្គរផង។

# នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារត្លាក់ងារទេសចរ និងត្លាក់ងារសណ្ដាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា គោលដៅប្រាសាទព្រះខ័ន ប្រាសាទប្រែ ប្រាសាទបន្ទាយប្រែ សហការរួមគ្នាដាំស្មៅនៅផ្លូវចូលច្រកខាងជើងនៃប្រាសាទព្រះខ័ន ជាប់និងផ្លូវវង់ធំបង្កើនភាពបៃតងកាន់តែស្រស់បំព្រង

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣

## ក្រុមភ្នាក់ងារទេសចរណ៍ និងក្រុមការងារ TSC ប្រចាំការនៅប្រាសាទតាព្រហ្ម បានរៀបចំកម្រាលថ្មបេតុងបណ្ដោះអាសន្ន សម្រាប់ភ្ញៀវចូលទស្សនាប្រាសាទ

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣

ដោយសាររដូវវស្សាមានភ្លៀងធ្លាក់ញឹកញាប់ ធ្វើឱ្យស្ថានភាពដីជ្រាយ មានភក់ជ្រាំជាច្រើន នាបរិវេណផ្លូវចូលទស្សនាប្រាសាទនោះ នៅថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០២៣ នេះ ក្រុមភ្នាក់ងារទេសចរណ៍ និងក្រុមការងារ TSC ប្រចាំការនៅប្រាសាទតាព្រហ្ម បានធ្វើការរៀបកម្រាលថ្មបេតុងបណ្ដោះអាសន្ន លើផ្លូវទស្សនានៅចំនុចបណ្ណាល័យខាងត្បូង ដើម្បីសម្រួលការទស្សនារបស់ភ្ញៀវមានភាពងាយស្រួលនារដូវវស្សា៕



# រចនាសម្ពន្ធមួយចំនួនរបស់ខ្លោងទ្វារប្រាសាទអង្គរវត្ត ប៉ែកខាងកើត កំពុងធ្វើការជួសជុល

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា កំពុងប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ជួសជុលរចនាសម្ពន្ធមួយចំនួនរបស់ខ្លោងទ្វារប្រាសាទអង្គរវត្ត ប៉ែកខាងកើត ដែលរងការខូចខាតឱ្យប្រសើរឡើងវិញ។

បុរាណវិទូ នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា លោកស្រី ភិន វិជ្ជាសច្ចា៉ មានប្រសាសន៍ថា ក្រុមការងារបានរៀបចំរៀបថ្មហោរជាង និងថ្មលើស៊ុមទ្វារទៅទីតាំងដើមវិញ។ ជាមួយគ្នានេះ ក្រុមការងារបានរៀបរន្ទាដើម្បីជួសជុលចំណុចកណ្តាលនៃដំបូលរបស់ខ្លោងទ្វារ និងពង្រឹងរចនាសម្ពន្ធខ្លោងទ្វារប្រាសាទអង្គរវត្តឱ្យទៅតាមទម្រង់ដើម៕

# សេចក្តីជូនដំណឹង ស្តីពីហានិភ័យផ្សេងៗដែលអាចកើតឡើងដោយសារហេតុ នារដូវវស្សានៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរជាតិអប្សរា
A P S A R A

លេខ៖ ៨០៣/វប.សជណ
/២៣

## សេចក្តីជូនដំណឹង
## ស្តីពី
## ហានិភ័យផ្សេងៗដែលអាចកើតឡើងដោយសារហេតុ នារដូវវស្សានៅរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងធនធានទឹក និងឧតុនិយម ស្តីពីស្ថានភាពធាតុអាកាសនៅព្រះរាជាណាចក្រកម្ពុជា កម្ពុជាកំពុងទទួលរងនូវឥទ្ធិពលខ្យល់មួយចំនួន ដែលបង្កឱ្យមានភ្លៀងធ្លាក់ជាប់ៗ ផ្គរ រន្ទះ លាយឡំជាមួយខ្យល់កន្ត្រាក់ ដែលជាហេតុបណ្តាលឱ្យដីជ្រាយ ដាយរលំ ឬបាក់មែកឈើនានាដោយសារហេតុ នៅតាមទីតាំងមួយចំនួននៃរមណីយដ្ឋានអង្គរ។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់សាធារណជន ភ្ញៀវទេសចរជាតិ-អន្តរជាតិ អ្នកបើកបរយានគ្រប់ប្រភេទ និងអ្នកដឹកភ្ញៀវទេសចរទាំងអស់ សូមមេត្តាបង្កើនការប្រុងប្រយ័ត្នឱ្យបានខ្ពស់នៅក្នុងអំឡុងពេលធ្វើដំណើរ ឬទស្សនាប្រាសាទនានានៅក្នុងតំបន់រមណីយដ្ឋានអង្គរ ជាពិសេសសូមមេត្តាកុំចតយានគ្រប់ប្រភេទ ឬឈប់ជ្រកក្រោមដើមឈើ ដើម្បីបង្ការនូវហានិភ័យនានា ដែលអាចបណ្តាលឱ្យរងរបួស ឬខូចខាតទ្រព្យសម្បត្តិ ឬអាចឈានទៅដល់ប៉ះពាល់អាយុជីវិតផងដែរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ៤ រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០២៣

**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh　Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

# សកម្មភាពក្រុមការងារសម្អាតរុក្ខជាតិតាមប្រាសាទ កំពុងឡើងដកស្មៅនិងកូនរុក្ខជាតិតូចធំដែលដុះនៅលើប្រាសាទប្រែរូប

ផ្សាយនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាកំពុងគ្រប់គ្រង និងបញ្ចៀសទឹកបាន ដោយមិនឱ្យជន់លិចតំបន់ប្រាសាទ

ផ្សាយនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣នេះ ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធនៃអាជ្ញាធរជាតិអប្សរា កំពុងមមាញឹកខ្លាំងដើម្បីគ្រប់គ្រង និងបញ្ចៀសទឹកដែលកំពុងហូរពីផ្នែកខាងលើ មកដល់តំបន់រមណីយដ្ឋានអង្គរ។

លោក គឿន សុឃីម ប្រធាននាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានឱ្យដឹងថា គិតត្រឹមថ្ងៃទី៤ ខែតុលានេះ ស្ថានភាពទឹកនៅតំបន់រមណីយដ្ឋានអង្គរកំពុងហក់ឡើងខ្លាំង។ ដើម្បីបង្ការបញ្ហាជន់លិចតំបន់ប្រាសាទ តាមការណែនាំរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា បានឱ្យមន្ត្រីបើកទ្វារទឹក និងត្រៀមបញ្ចៀសឱ្យបានទាន់ពេលវេលា។ ជាក់ស្តែងអាជ្ញាធរជាតិអប្សរាគ្រប់គ្រងទឹកបានទាំងស្រុង និងមិនមានហានិភ័យឡើយ។

លោក គឿន សុឃីម បន្ថែមថា ទឹកទាំងនោះបានបញ្ចៀសទៅតាមទ្វារទឹកសំខាន់ៗដូចជា អូរខ្លូត អូររកាជាដើម ទម្លាក់ទៅស្ទឹងពួក ស្ទឹងព្រះស្រុក និងមួយចំនួនទៀតបញ្ចូលទៅតាមកសិន្ធុ និងបារាយណ៍ក្នុងតំបន់រមណីយដ្ឋានអង្គរ។

ស្ថានភាពទឹកនៅពេលនេះ លោក គឿន សុឃីម បញ្ជាក់ថា មានស្ថានភាពខ្លាំងបើធៀបនឹងឆ្នាំ២០១៤។ យ៉ាងណាមិញលោកបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាអាចគ្រប់គ្រងស្ថានការណ៍នេះបាន ដោយមិនបារម្ភពីការជន់លិចតំបន់ប្រាសាទ និងក្រុងសៀមរាបឡើយ ដ្បិតសមត្ថភាពទ្វារទឹកដែលបានសាងសង់ថ្មី និងស្តារប្រព័ន្ធទឹកបុរាណមួយចំនួនធំឡើងវិញ បម្រើដល់ការងារគ្រប់គ្រងទឹកនេះ។

ប្រសិនគ្មានភ្លៀងធ្លាក់២ទៅ៣ថ្ងៃខាងមុខ ស្ថានភាពទឹកភ្លៀងនៅតំបន់រមណីយដ្ឋានអង្គរ នឹងធូរស្រាលទៅវិញ ទឹកនឹងស្រកវិញឆាប់ៗ។ លោក គឿន សុឃីម ស្នើឱ្យពលរដ្ឋយោគយល់កំឡុងពេលបើកទ្វារទឹកនេះ ដែលអាចឱ្យផ្ទះពលរដ្ឋនៅក្បែរអូរជន់លិចដោយសារបរិមាណទឹកហូរទៅខ្លាំង និងច្រើន តែជាក្នុងរយៈពេលខ្លីប៉ុណ្ណោះ៕

# ប្រាសាទភ្នំក្រោម ជម្រើសទស្សនាទិដ្ឋភាពថ្ងៃរះ និងថ្ងៃរៀបលិច យ៉ាងល្អប្រសើរ

ផ្សាយនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

ប្រាសាទភ្នំក្រោម ជាកន្លែងដែលភ្ញៀវទេសចរជាតិ និងអន្តរជាតិ និយមទៅទស្សនាជាហូរហែរ ដោយសារទីនោះមានចំងាយមិនឆ្ងាយប៉ុន្មានពីក្រុងសៀមរាប ពោលគឺប្រហែល១២គីឡូម៉ែត្រប៉ុណ្ណោះ ស្ថិតក្នុងសង្កាត់ចុងឃ្នៀស ជាប់ផ្ទៃបឹងទន្លេសាប។

លោក ប៉ា ឌី អនុប្រធានភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទភ្នំក្រោម បានឱ្យដឹងថា នៅលើកំពូលភ្នំក្រោម មានប្រាសាទបុរាណមួយ ដែលបានស្ថាបនាឡើងនៅចុងសតវត្សទី៩ និងដើមសតវត្សទី១០។ ប្រាសាទភ្នំក្រោម ជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាពមួយ ដែលអាចទាក់ទាញទេសចរទៅទស្សនាមិនចេះដាច់ ព្រោះថាក្រៅពីប្រាសាទបុរាណនៅលើភ្នំ អ្នកទេសចរក៏អាចទស្សនាទិដ្ឋភាពថ្ងៃរះដ៏ស្រស់ស្អាតបាន នាបរិវេណផ្នែកខាងកើតប្រាសាទ (ក្រដោម) និងទស្សនាទិដ្ឋភាពថ្ងៃរៀបលិចយ៉ាងស្រស់ស្អាតអមដោយទេសភាពព្រៃលិចទឹកដាច់កន្ទុយភ្នែកនៃបឹងទន្លេសាប នៅខាងក្រោយប្រាសាទ (ផ្នែកខាងលិច) មានភាពខុសប្លែកពីទិដ្ឋភាពថ្ងៃរះ និងថ្ងៃលិច នៅប្រាសាទអង្គរវត្ត និងប្រាសាទភ្នំបាខែង។ ដោយមិនចាំបាច់ប្រជ្រៀតជាមួយទេសចរដទៃទៀត។ ទស្សនាទិដ្ឋភាពក្រុងសៀមរាបពីចម្ងាយ វាលស្រែប្រាំងរបស់កសិករនៅជុំវិញនោះ និងផ្ទៃបឹងទន្លេសាប អមដោយសំឡេងទូកឬកាណូតបន្លឺឡើងមិនចេះដាច់ ដោយប្រជា

នេសាទរស់នៅក្បែរៗនោះ។ ជាពិសេសលំនៅឋានប្រជាពលរដ្ឋជាច្រើនដេដាស់ គួរជាទីចាប់អារម្មណ៍។

ដើម្បីសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរ អាជ្ញាធរជាតិអប្សរា បានរៀបចំទិសដៅទស្សនានៅបរិវេណប្រាសាទ ភ្ញៀវអាចដើរតាមវង់ទស្សនា នឹងមើលឃើញទិដ្ឋភាពប្លែកៗស្រស់ស្អាត ផ្តិតយករូបភាពទាំងនោះទុកជាអនុស្សាវរីយ៍បាន។ មួយវិញទៀត ក្រុមការងារអាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់ ដោយកាត់ក្រីមែកឈើ បោសសម្អាតអនាម័យបរិស្ថាននៅជុំវិញនោះជាប្រចាំ៕

# អនុលោមតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត ការផលិតភាពយន្ត ភាពយន្តភាគតាមទូរទស្សន៍ ភាពយន្តឯកសារ ចម្រៀងកាយវិការ ចាំបាច់ត្រូវសុំការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## រាល់ការស្នើសុំ ផលិតករត្រូវភ្ជាប់ពាក្យស្នើសុំ និងអត្ថបទនិពន្ធរឿង (ភាពយន្ត) និងអត្ថបទចម្រៀង (ចម្រៀងកាយវិការ) ចំពោះការផ្តល់លិខិតអនុញ្ញាតនឹងផ្តល់ជូនរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការ (សម្រាប់ភាពយន្ត) និងរយៈពេល ៥ថ្ងៃ (សម្រាប់ចម្រៀងកាយវិការ)

ផ្សាយនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
A P S A R A

លេខ: [illegible]/២៣

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការថតរូបភាព ឬវីដេអូ នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ**

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ជាគោលការណ៍ អាជ្ញាធរជាតិអប្សរា មិនមានការហាមឃាត់ទេ ចំពោះការថតរូបភាព ឬវីដេអូ សម្រាប់ចងក្រងជាអនុស្សាវរីយ៍ផ្ទាល់ខ្លួន ឬលក្ខណៈទេសចរណ៍ ដើម្បីផ្សព្វផ្សាយសិល្បៈ និងវប្បធម៌ ឱ្យពិភពលោកបានស្គាល់ពីភាពទាក់ទាញ និងសម្បត្តិវប្បធម៌ដ៏អស្ចារ្យរបស់កម្ពុជា។ ជាក់ស្តែង ការថតរូបភាព និងវីដេអូ តាមទម្រង់ទាំងនេះ ត្រូវបានភ្ញៀវទេសចរជាតិ-អន្តរជាតិ បង្ហោះផ្សព្វផ្សាយនៅតាមបណ្តាញសង្គមនានា ដូចជាហ្វេសប៊ុក TikTok និងបណ្តាញសង្គមជាច្រើនផ្សេងទៀតរួចមកហើយ។

ដោយឡែកក្នុងគោលបំណងបញ្ចៀសនូវកំហុសឆ្គងដោយអចេតនាកើតចេញពីការផ្សព្វផ្សាយ និងអាចធ្វើឲ្យប៉ះពាល់គុណតម្លៃនៃប្រាសាទបុរាណ មរតកមិនអាចកាត់ថ្លៃបានរបស់បុព្វបុរសខ្មែរ និងជាសម្បត្តិបេតិកភណ្ឌពិភពលោក ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ តម្រូវឱ្យដាក់ពាក្យស្នើសុំមកអាជ្ញាធរជាតិអប្សរា ចំពោះគោលបំណងមួយចំនួន ដូចមានបញ្ជាក់ជូនខាងក្រោម ដើម្បីអនុញ្ញាតឱ្យមន្ត្រីជំនាញ មានលទ្ធភាពពិនិត្យជាមុន នូវទិដ្ឋភាពបច្ចេកទេសមួយចំនួន ដូចជាខ្លឹមសារផ្សព្វផ្សាយ និងសម្ភារប្រើប្រាស់ជាដើម ៖

- ការថតរូបភាព ថតភាពយន្ត ឬវីដេអូ ក្នុងគោលបំណងផ្សព្វផ្សាយពាណិជ្ជកម្ម ផលិតផល ឬបង្កើតអាជីវកម្មនានា។
- ការប្រកបអាជីវកម្មថតសម្លៀកបំពាក់ប្រពៃណីបុរាណ (ថតរូបមុនអាពាហ៍ពិពាហ៍) ដើម្បីពិនិត្យភាពសមស្របនៃសម្លៀកបំពាក់ប្រពៃណីបុរាណ។ ការថតបែបនេះ មិនមានការបង់ប្រាក់នោះទេ។
- ការថតវីដេអូផ្សាយបន្តផ្ទាល់ដោយក្រុមហ៊ុនទេសចរណ៍ ឬមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានអាជ្ញាបណ្ណត្រឹមត្រូវពីក្រសួងទេសចរណ៍ ដើម្បីផ្សព្វផ្សាយប្រាសាទនានាតាមប្រព័ន្ធអនឡាញជូនទៅអតិថិជនរបស់ខ្លួន។ រាល់ការផ្សព្វផ្សាយបែបនេះ មិនមានការបង់ប្រាក់នោះទេ។

រាល់ការស្នើសុំថតរូប ឬវីដេអូផ្សព្វផ្សាយពាណិជ្ជកម្ម ផលិតផល ឬបង្កើតអាជីវកម្មនានា សូមភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាទំនាក់ទំនងមកមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរជាតិអប្សរា រៀងរាល់ម៉ោងបំពេញការងារ ហើយអាជ្ញាធរជាតិអប្សរា នឹងឆ្លើយតបទៅម្ចាស់សំណើវិញ ក្នុងរយៈពេលប្រាំ (៥)ថ្ងៃ នៃថ្ងៃធ្វើការងារយ៉ាងយូរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២៣
**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

**ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ក្រុមភ្នាក់ងារទេសចរណ៍គោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញកាបូបស្ពាយចំហៀងមួយនៅខ្លោងទ្វារតាពេជ្រ បានប្រគល់ជូនម្ចាស់វិញ**

ផ្សាយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម តេលេក្រាម (TELEGRAM) និងលេខទូរស័ព្ទ (CALL CENTER) សម្រាប់ផ្តល់សេវាកម្មផ្សេងៗក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៨៦១០/២៣ ជ.សវិធា

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការដាក់ឱ្យប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមតេលេក្រាម (TELEGRAM)**
**និងលេខទូរស័ព្ទ (CALL CENTER) សម្រាប់ផ្តល់សេវាកម្មផ្សេងៗក្នុងរមណីយដ្ឋានអង្គរ**

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទាំងអស់មេត្តាជ្រាបថា ក្នុងគោលដៅសម្រួលដល់ការស្នើសុំការអនុញ្ញាត និងនីតិវិធីនៃការរៀបចំបែបបទពាក់ព័ន្ធ នឹងការស្នើសុំផ្តល់សេវាកម្មផ្សេងៗក្នុងរមណីយដ្ឋានអង្គរ ព្រមទាំងដើម្បីកាត់បន្ថយការចំណាយពេលវេលា អាជ្ញាធរជាតិអប្សរា បានសម្រេចបង្កើត និងដាក់ឱ្យប្រើប្រាស់នូវបណ្តាញទំនាក់ទំនងសង្គមតេលេក្រាម (TELEGRAM) និងលេខទូរស័ព្ទ (CALL CENTER) នៃមជ្ឈមណ្ឌលសេវាកម្ម ដូចមានបញ្ជាក់ជូនខាងក្រោម ដែលនឹងអនុញ្ញាតឱ្យសាធារណៈជនទាំងអស់ ទទួលបាននូវការផ្តល់សេវាកម្មផ្សេងៗ របស់អាជ្ញាធរជាតិអប្សរា តាមប្រព័ន្ធអនឡាញ៖

១- មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា (ឈ្មោះនៃបណ្តាញទំនាក់ទំនងសង្គម TELEGRAM)

២- លេខទូរស័ព្ទ (CALL CENTER) ០១៤ ២២២ ៥៥៥

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០២៣
**អាជ្ញាធរជាតិអប្សរា**

សូមស្កេនកូដ QR CODE ខាងក្រោមដើម្បីចូលទៅក្នុងបណ្តាញទំនាក់ទំនងសង្គម TELEGRAM របស់មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

@APSARASERVICECENTER

អាជ្ញាធរជាតិអប្សរា
APSARA National Authority
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province

@APSARASERVICECENTER

## អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា ៖ ការថតរូបភាពនិងវីដេអូអនុស្សាវរីយ៍ផ្ទាល់ខ្លួន ពុំមានតម្រូវការសុំច្បាប់ជាមុននោះទេ

ផ្សាយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣

**ឯកឧត្តម ឡុង កុសល** អគ្គនាយករង និងជាអ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា បានបញ្ជាក់ថា ការថតរូបភាព និងវីដេអូអនុស្សាវរីយ៍ផ្ទាល់ខ្លួន ពុំមានការតម្រូវឲ្យសុំការអនុញ្ញាតជាមុននោះទេ។ ចំពោះការថតនូវសម្លៀកបំពាក់ប្រពៃណី ការថតរូបភាពមុនអាពាហ៍ពិពាហ៍ ថត YouTube ការថតផ្សាយផ្ទាល់ជាលក្ខណៈមគ្គុទ្ទេសក៍ ការថតខ្សែភាពយន្ត ការថតចម្រៀងកាយវិការ និងការថតរូបក្នុងគោលបំណងអាជីវកម្មផ្សេងៗ ចាំបាច់ត្រូវមានការអនុញ្ញាតជាមុន។ ភាពចាំបាច់នៃការតម្រូវឲ្យមានការអនុញ្ញាតជាមុន ពីព្រោះត្រូវប្រតិបត្តិនូវគោលការណ៍គតិយុត្តដែលមានជាធរមានផង និងដើម្បីឲ្យផ្នែកជំនាញរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏ដូចជាអាជ្ញាធរជាតិអប្សរា អាចជួយកែតម្រូវ ឬផ្តល់យោបល់កែលម្អនូវខ្លឹមសារផ្សេងៗដូចជា ប្រវត្តិសាស្ត្រ ទម្រង់សិល្បៈ ឲ្យបានត្រឹមត្រូវ ព្រមទាំងចៀសវាងនូវមតិរិះគន់ពីសាធារណជននៅពេលរូបភាព ឬខ្លឹមសាររឿងទាំងនោះចេញផ្សាយជាសាធារណៈ។

យោងតាមអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត បានតម្រូវឲ្យផលិតករ សុំការអនុញ្ញាតទៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាមុន។ លក្ខខណ្ឌសំខាន់ក្នុងការស្នើសុំគឺការផ្តល់អត្ថបទនិពន្ធនៃស្នាដៃដើម្បីផ្តល់លទ្ធភាពឲ្យអ្នកជំនាញពិនិត្យលើខ្លឹមសារ។ ដោយឡែក អាជ្ញាធរជាតិអប្សរាក៏បានផ្សព្វផ្សាយអំពីគោលការណ៍ នៃការប្រើប្រាស់រូបភាពអង្គរតាំងពីឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន ដើម្បីចូលរួមចំណែកក្នុងការជំរុញសេដ្ឋកិច្ចសង្គម ព្រមទាំងថែរក្សា ការពារ លើកតម្កើង និងអភិវឌ្ឍន៍វប្បធម៌ជាតិ ជាពិសេសបញ្ចៀសនូវផលប៉ះពាល់ខ្លាំង ដល់តម្លៃបេតិកភណ្ឌវប្បធម៌ជាតិ ។

ឯកឧត្តមអគ្គនាយករង និងជាអ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា បានបន្ថែមថា សម្រាប់យើងជាខ្មែរ អត្ថន័យរបស់អង្គរពិតជាធំធេងណាស់ លើសពីអាយុជីវិតទៅទៀត ពីព្រោះអង្គរជាដួងព្រលឹងនិងវប្បធម៌ជាតិ។ ដូច្នេះប្រសិនបើមានការប្រើប្រាស់រូបភាពអង្គរមិនត្រឹមត្រូវ ឬក៏ការប្រព្រឹត្តនូវកាយវិការមិនស្របណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់តម្លៃ

នៃរមណីយដ្ឋានអង្គរ នោះសាធារណជនពិតជាមិនអាចទទួលយកបាននោះទេ។ ក្នុងន័យដើម្បីបញ្ចៀសឲ្យបាននូវកំហុសឆ្គងអចេតនាណាមួយ ដែលបណ្តាលមកពីការប្រើប្រាស់រូបភាពអង្គរអាជ្ញាធរជាតិអប្សរា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានភាពចាំបាច់ត្រូវការត្រួតពិនិត្យជាមុននូវគោលបំណងនៃការប្រើប្រាស់រូបភាពអង្គរជាសាធារណៈទាំងអស់។ ដូច្នេះសូមសាធារណជន ជាលក្ខណៈក្រុមហ៊ុន ឬឯកជន ដែលជាម្ចាស់ផលិតកម្ម ឬអាជីវកម្មនានាយោគយល់ និងចូលរួមប្រតិបត្តិស្របតាមគោលការណ៍ច្បាប់ដែលមានជាធរមាន។

ជាមួយគ្នានេះដែរ ឯកឧត្តម ក៏បញ្ជាក់បន្ថែមទៀតដែរថា អាជ្ញាធរជាតិអប្សរានឹងធ្វើការកែសម្រួលអំពី យន្តការពាក់ព័ន្ធនឹងការកាត់បន្ថយពេលវេលានៃការស្នើសុំ កាត់បន្ថយដំណើរការនីតិវិធីស្នើសុំ ដើម្បីធ្វើយ៉ាងណាឲ្យសាធារណជនមានការងាយស្រួល និងបង្កើនប្រសិទ្ធភាពការងារបានកាន់តែងាយស្រួលនិងរលូនជាងមុន។

អាជ្ញាធរជាតិអប្សរា ក៏នឹងរៀបចំឲ្យមាន Call Center និងបង្កើតប្រព័ន្ធស្នើសុំ Online ដើម្បីសាធារណជនអាចស្នើសុំតាមប្រព័ន្ធបច្ចេកវិទ្យាបានយ៉ាងឆាប់រហ័ស និងចំណេញពេលវេលា៕

# ព្រឹកថ្ងៃទី០៦ តុលា ២០២៣ នៅផ្នែកខាងជើង និងផ្នែកខាងកើតឈៀងខាងជើង នៃប្រាសាទបាយ័ន មានភ្ញៀវទេសចរ២នាក់ ដែលមានឈ្មោះ Tyler Hope ជនជាតិអាមេរិក ភេទប្រុសអាយុ ២៣ឆ្នាំ និងជនជាតិឥណ្ឌាម្នាក់ទៀត ឈ្មោះ Gaurav kukreja អាយុ៤៥ឆ្នាំ បានខ្យល់គរ ភ្លាមៗនោះភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ និងនរគបាលការពារបេតិកភណ្ឌ បានសហការគ្នាជួយសង្គ្រោះបឋមជូនពួកគាត់ ក្រោយមានសភាពធូរស្បើយ ភ្នាក់ងារបានជូនគាត់ឡើងរថយន្តទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ

ផ្សាយនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣

# ក្រុមការងារប្រចាំគោលដៅប្រាសាទនាគព័ន្ធ និង តាសោម បានប្រគល់ទូរស័ព្ទដៃម៉ាក Iphone មួយគ្រឿងជូនម្ចាស់ដើមវិញ

ផ្សាយនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣នេះ វេលាម៉ោង១២:៣០នាទីថ្ងៃត្រង់ ក្រុមការងារសណ្តាប់ធ្នាប់ បានចូលរួមសហការជាមួយនគរបាលបេតិកភណ្ឌ ភ្នាក់ងារទេសចរណ៍ និងក្រុមការងារខាងបន្ទប់ទឹក ប្រគល់ទូរស័ព្ទដៃម៉ាក Iphone ពណ៌ខ្មៅ ទៅម្ចាស់ភ្លាមៗ ក្រោយពេលភ្ញៀវបានភ្លេច នៅក្នុងទីតាំងបន្ទប់ទឹកប្រាសាទនាគពន្ធ័៕

# ភ្ញៀវទេសចរ ស្គាល់ខ្លោងទ្វារតាកាវកាន់តែច្រើន បន្ទាប់ពីជួសជុលរួចរាល់

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៣

ពីមួយថ្ងៃទៅមួយថ្ងៃ មានអ្នកទេសចរជាតិ-អន្តរជាតិកាន់តែច្រើនឡើងៗទៅទស្សនា និងថតរូបនៅខ្លោងទ្វារតាកាវ បន្ទាប់ពីក្រុមការងារនៃអាជ្ញាធរជាតិអប្សរាបានជួសជុលតួខ្លោងទ្វាររួចរាល់ រួមទាំងចម្លាក់ទេវតា និងអសុរៈទាញព្រ័ត្របានមួយចំនួន ហើយកែលម្អផ្លូវផង ងាយស្រួលភ្ញៀវទេសចរអាចឆ្លងកាត់ និងមានសុវត្ថិភាព។

លោក កុយ ភិរុណ ដែលខំស្កាត់មកតាំងពីខេត្តកំពត មានប្រសាសន៍ថា ខ្លោងទ្វារតាកាវ ស្ថិតនៅទិសខាងលិចនៃក្រុងអង្គរធំ មានចំណុចពិសេសជាងខ្លោងទ្វារផ្សេងៗទៀត ដោយសារតែខ្លោងទ្វារនេះ មានពន្លឺព្រះអាទិត្យរៀបលិចចាំងលើ ធ្វើឱ្យសម្រស់ខ្លោងទ្វារកាន់តែស្រស់ស្អាត។

ខ្លោងទ្វារតាការមិនត្រឹមតែជាកេរដំណែលរបស់បុព្វបុរសខ្មែរប៉ុណ្ណោះទេ ថែមទាំងអាចទស្សនាថ្ងៃរៀបលិច កសិន្ទព័ទ្ធជុំវិញ ថតរូបជាមួយនិងប្លង់ស្អាតៗផង។ ក្រៅតែពីការថតរូប ទេសចរចំណាយពេល ចំណាយអារម្មណ៍ជាមួយទិដ្ឋភាពថ្ងៃរៀបលិច នឹងទទួលបានអារម្មណ៍ស្រស់ស្រាយទៅតាមធម្មជាតិ ផ្ទៃមេឃ ពន្លឺព្រះ អាទិត្យរៀបអស្តង្គតបូកជាមួយស្ថាបត្យកម្មដ៏អស្ចារ្យរបស់ដូនតា ដែលនេះជាការចងចាំដ៏ល្អ និងមានក្តីសុខផ្លូវចិត្ត។

ចំណែក លោក វណ្ណី ពិសិដ្ឋ មកពីភ្នំពេញ ក៏បានបង្ហាញចំណាប់អារម្មណ៍ភ្ញាក់ផ្អើលថា ពេលរូបលោក ឃើញខ្លោងទ្វារតាការ បន្ទាប់ពីអាជ្ញាធរជាតិអប្សរាបានជួសជុលតួខ្លោងទ្វាររួចរាល់នេះ មានភាពរឹងមាំ និងស្រស់ស្អាតខ្លាំងណាស់ ហើយលោកក៏មិនធ្លាប់បានឃើញ ឬស្គាល់ពីមុនសោះឡើយ។ លោក វណ្ណី សរសើរថា នេះជាមោទនភាពរបស់ខ្មែរសម្រាប់ឱ្យក្មេងជំនាន់ក្រោយបានសិក្សាស្វែងយល់។

លោក ពិសិដ្ឋ ចង់ឱ្យភ្ញៀវទេសចរគ្រប់រូបបានទៅទស្សនាទីនេះ ព្រមទាំងថតរូបភាពស្អាតៗ យកទៅចូលរួមផ្សព្វផ្សាយពីសក្តានុពលនៃកន្លែងទេសចរណ៍ថ្មីនេះ៕

ប្រាសាទសួរព្រ័ត

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរា សហការជាមួយវិស័យឯកជន បន្តដាំស្មៅ និងកូនឈើ នៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៣

នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ ក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរា បានបន្តសហការជាមួយ ក្រុមហ៊ុន អាហ្គ្រោសូឡា ខេមបូឌា( Agrosolar Cambodia ) ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិក ជិត៦០នាក់ បានដាំស្មៅ និងកូនឈើចម្រុះចំនួន២០០ដើម នៅបរិវេណខាងជើងឆៀងខាងលិចប្រាសាទអង្គរវត្ត( អតីតផ្សារយោងធំ ) ដើម្បីបន្សល់ទុកជាស្នាដៃការងារសង្គម និងទុកជាអនុស្សាវរីយ៍នៃការងចងចាំក្នុងតំបន់រមណីយដ្ឋានអង្គរផង។

# ទឹកដីកំពង់ភ្លុក និងប្រាសាទមួយចំនួនក្នុងខេត្តសៀមរាប បានក្លាយជាទីតាំងមួយសម្រាប់ថតភាពយន្តខ្នាតវែងមានចំណងជើងថា The Creator របស់ Hollywood ដែលជាភាពយន្តល្បីនិងបានចាក់បញ្ចាំងនៅរោងភាពយន្តនានាទូទាំងពិភពលោក

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៣

ដោយមានការអនុញ្ញាតថតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងដោយមានការសម្របសម្រួលពីអជ្ញាធរពាក់ព័ន្ធ ភាពយន្តខ្នាតវែងមានចំណងជើងថា The Creator ដែលជាភាពយន្តបែបវិទ្យាសាស្ត្ររបស់អាម៉េរិក ផលិតនិងដឹកនាំដោយលោក Gareth Edwards បានថតឈុតឆាកមួយចំនួននៅកំពង់ភ្លុក និងប្រាសាទមួយចំនួនទៀតក្នុងខេត្តសៀមរាប កាលពីឆ្នាំ២០២២ កន្លងមក។

ភាពយន្តនេះមានការចូលរួមសម្តែងពីតារាភាពយន្តល្បីៗមួយចំនួន ក្នុងនោះមានតួក្មេងស្រីសំខាន់ម្នាក់ អាយុ៩ឆ្នាំ គឺជាកូនកាត់ខ្មែរ។

សូមបញ្ជាក់ថា The Creator ត្រូវបានចាប់ផ្តើមចាក់បញ្ចាំងកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ហើយត្រឹមតែថ្ងៃទី០៥ ខែតុលានេះ ភាពយន្តនេះទទួលបានចំណូលពីការចាក់បញ្ចាំងទូទាំងពិភពលោករហូតដល់ ៣៧លានដុល្លារសហរដ្ឋអាម៉េរិក។

# ប្រាសាទតានៃ

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៣

# អង្គរវត្ត ជាគោលដៅវិស្សមកាលដ៏ពិសេសសម្រាប់ឆ្នាំនេះ

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៣

សារព័ត៌មានធំមួយរបស់សហរដ្ឋអាមេរិក New York Post បានផ្សព្វផ្សាយកាលពីពេលថ្មីៗថាគោលដៅទេសចរណ៍កម្ពុជាដ៏ពិសេស គឺអង្គរ ដែលជាតំបន់បេតិកភណ្ឌពិភពលោក គឺជាគោលដៅវិស្សមកាលដ៏ពិសេសសម្រាប់ភ្ញៀវទេសចរអន្តរជាតិពីគ្រប់ទិសទី។ សូមសាធារណជនអាននូវសំណេរដែលប្រកបដោយអត្ថន័យដូចបានភ្ជាប់មកជាមួយ

## ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនា និងថតយករូបភាពដ៏ស្រស់ស្អាត នាពេលព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាសហការជាមួយធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី ដាំកូនឈើ១៩០០ដើមនៅតំបន់អង្គរ

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣

នារសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ អាជ្ញាធរជាតិអប្សរា បានសហការជាមួយធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (CIMB) បានដាំកូនឈើសរុប ១៩០០ដើមនៅខាងត្បូងកសិន្ធុអង្គរវត្ត។

មានប្រសាសន៍នាពិធីនោះ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរជាតិអប្សរា បានចាត់ទុកការចូលរួមរបស់វិស័យឯកជននាពេលនេះ ថាជាការចូលរួមលើកកម្ពស់វិស័យបេតិកភណ្ឌ បរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ។ លោកជំទាវបន្ថែមថា កាយវិការរបស់វិស័យឯកជនក្នុងការចូលរួមជាមួយរដ្ឋនៅពេលនេះ ជាកាយវិការដ៏ល្អ ឆ្លុះបញ្ចាំងពីការចូលរួមអភិរក្សប្រាសាទ ហើយការដាំកូនឈើឡើងវិញ ជាផ្នែកមួយដ៏សំខាន់សម្រាប់កិច្ច ការងារអភិរក្សតំបន់បេតិកភណ្ឌរមណីយដ្ឋានអង្គរ។

លោកជំទាវ ក៏បានលើកទឹកចិត្តដល់វិស័យឯកជនដទៃទៀត ចូលរួមជាមួយអាជ្ញាធរជាតិអប្សរា លើកិច្ចការងារមួយនេះ ធ្វើយ៉ាងណាដើម្បីបរិស្ថានតំបន់រមណីយដ្ឋានអង្គរកាន់តែស្រស់ស្អាត ទាក់ទាញទេសចរកាន់តែច្រើនបន្ថែមទៀត។

លោក ប៊ុន យីន ប្រធាននាយកប្រតិបត្តិធនាគារ CIMB បានលើកឡើងថា ធនាគារ CIMB ជាធនាគារដែលលេចធ្លោ

លើសកម្មភាពសង្គម ពិសេសលើវិស័យបរិស្ថាន។ លោកបន្ថែមថា ក្រៅពីដើម្បីទទួលបានប្រាក់ចំណេញ ក្នុងនោះធនាគារក៏មានគោលការណ៍រួមចំណែកជួយបញ្ហាបរិស្ថាន និងសង្គមផងដែរ ហើយកន្លងមកស្ថាប័ននេះធ្លាប់បានជួយសង្គមទាំងការងារបរិស្ថាន អប់រំ កីឡា និងសុខាភិបាល។

សូមបញ្ជាក់ថា នេះជាលើកទី២ហើយដែលធនាគារ CIMB បានចូលរួមដាំដើមឈើនៅតំបន់រមណីយដ្ឋានអង្គរ ដែលលើកទី១ធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០២០ នៅបរិវេណខាងមុខប្រាសាទ បន្ទាយក្តី ដែលមានអ្នកចូលរួមប្រមាណ ៤០០នាក់ ហើយលើកទី២នេះមានអ្នកចូលរួមជាង ២០០នាក់។ ការដាំដើមឈើនៅពេលនេះ គឺស្របពេលដែលធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី (CIMB) រៀបចំកិច្ចប្រជុំ ក្រុមប្រឹក្សាភិបាលនៅខេត្តសៀមរាបផងដែរ៕

# អ្នកជំនាញអាជ្ញាធរជាតិអប្សរាធ្វើការជួសជុលបង្កាន់ដៃនាគនៅប្រាសាទបន្ទាយសំរ៉ែ

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣

ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា កំពុងជំរុញការងារជួសជុលបង្កាន់ដៃនាគប្រវែង៣៤ម៉ែត្រ នៅរោងទងទី១ ផ្នែកឦសានប្រាសាទបន្ទាយសំរ៉ែដែលទទួលរងការខូចខាតធ្ងន់ធ្ងរ។

ចំពោះការជួសជុល ក្រុមការងារមានការលំបាកយ៉ាងខ្លាំង ដោយសារថ្មមានការបែកបាក់ច្រើន ហើយផ្នែកខ្លះនៃចម្លាក់ត្រូវបាត់បង់តម្រូវឱ្យអ្នកជំនាញស្វែងរកយកដាក់តាមទីតាំងដើមវិញ។

ការងារជួសជុលដែលចាប់ផ្ដើមពីខែកក្កដាមកនោះ ពេលនេះសម្រេចបានជាង៨០ភាគរយហើយ ការងារដែលនៅសេសសល់គ្រោងនឹងបញ្ចប់ឱ្យបានមុនដំណាច់ឆ្នាំ២០២៣ខាងមុខ។

សូមបញ្ជាក់ថា ប្រាសាទបន្ទាយសំរ៉ែមានទីតាំងស្ថិតនៅក្នុងភូមិថ្នល់ទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ប្រាសាទនេះសាងឡើងនៅពាក់កណ្ដាលគ្រិស្តសតវត្សរ៍ទី១២ ដើម្បីឧទ្ទិសដល់ព្រះនារាយណ៍៕

# សំណល់ព្រះវិហារដ៏ចំណាស់ និងស្ថាបត្យកម្មល្អឯក នៅវត្តល្អក់ ឬអារញ្ញរង្សី ត្រូវបានអភិរក្ស

ផ្សាយនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣

វត្តល្អក់ ឬ អារញ្ញរង្សី ស្ថិតក្នុងឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ទីអារាមមួយនេះមានព្រះវិហារចំណាស់មួយ ដែលមានអាយុកាលប្រមាណ៩០ឆ្នាំ ក្នុងកំឡុងគ្រប់គ្រងវត្តនេះដោយព្រះគ្រូចៅអធិការព្រះនាមដួងនេះបើយោងតាមអក្សរចារិកនៅលើបុស្បុក ក្បែរបល្ល័ង្កព្រះ និងការផ្តល់ព័ត៌មានពីសំណាក់ព្រះគ្រូចៅអធិការ សព្វថ្ងៃ។

ព្រះវិហារបុរាណនេះជាទីសក្ការៈមួយ ដែលមានទម្រង់ស្ថាបត្យកម្ម និងសិល្បៈដ៏ល្អ និងរស់រវើកប្លែក ទៅតាមនិយមក្នុងតំបន់នោះ។ សំណង់នេះសង់ឡើងអំពីឈើរួមមានសសរខាងក្នុង និងគ្រឿងបង្គំដំបូល លើកលែងតែជញ្ជាំង និងសសរជុំវិញតួព្រះវិហារ សង់អំពីឥដ្ឋ។ ដំបូលព្រះវិហារមានសណ្ឋានជាដំបូលកឹង ប្រក់ក្បឿងស្រកាលិញ និងមានជហ្វាចំនួនបួន ដែលជហ្វានេះសាងសង់អំពីឈើ ហើយមានសណ្ឋានជារូបនាគពេញលេញ និងប្លែកត្រង់គែនៃជហ្វា បានឆ្នៃឆ្លាក់ជារូបមុខមនុស្ស។

ចំពោះហោជាងសងខាងនៃព្រះវិហារ ត្រូវបានសាងអំពីឈើ នៅហោជាងខាងកើតមានឆ្លាក់រូបព្រះចូឡាមណីចេតិយ នៅឋានត្រ័យត្រិង្ស គឺឋានសួគ៌ជាន់ទី២ ដែលតម្កល់នូវព្រះកេសាព្រមទាំងស្នៀតព្រះកេស និងព្រះចង្កូមកែវខាងស្តាំនៃព្រះសក្យមុនីសម្មាសម្ពុទ្ធ។
បច្ចុប្បន្នព្រះវិហារកំពុងធ្វើការជួសជុល និងអភិរក្សឡើងវិញ ដើម្បីរក្សានូវស្នាដៃ ដែលជាកេរដំណែលដ៏ពិសិដ្ឋ ដែលស្តែងឡើងតាមរយៈស្ថាបត្យកម្ម និងជាមរតករបស់បុព្វការីជនយើង ឲ្យនៅគង់វង្សជាបន្តទៅទៀត៕

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញមកទស្សនាប្រាសាទបន្ទាយស្រី ថ្ងៃទី១៣ តុលា ២០២៣

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរអញ្ជើញមកទស្សនាប្រាសាទអង្គរវត្ត ថ្ងៃទី១៣ តុលា ២០២៣

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣

## ទិដ្ឋភាពខ្លោងទ្វារជ័យពីលើអាកាស

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិអញ្ជើញមកទស្សនាថ្ងៃរះ នៅប្រាសាទអង្គរវត្ត នាថ្ងៃទី១៤ តុលា ២០២៣

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣

## សកម្មភាពប្រជាពលរដ្ឋអញ្ជើញចូលរួមពិធីបុណ្យភ្ជុំបិណ្ឌ នៅប្រាសាទលលៃ នាថ្ងៃទី១៤ តុលា ២០២៣

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣

## ទិដ្ឋភាពមមាញឹកនៃការធ្វើដំណើរទស្សនារបស់ភ្ញៀវទេសចរ អញ្ជើញចូលក្រុងអង្គរធំ តាមខ្លោងទ្វារទន្លេអុំ

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣

# សូមថ្វាយមហាព្រះរាជកុសល ខួបគម្រប់ ១១ឆ្នាំ នៃការយាងសោយព្រះទិវង្គត របស់ព្រះករុណា សម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ (១៥ តុលា ឆ្នាំ២០១២ - ១៥ តុលា ឆ្នាំ២០២៣) នាថ្ងៃអាទិត្យ ១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣

# ប្រាសាទក្រវ៉ាន់

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣

## ទិដ្ឋភាពថ្ងៃរះគួរឱ្យគយគន់នៅស្រះស្រង់ ថ្ងៃទី១៥ តុលា ២០២៣

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣

# នៅថ្ងៃទី១៥ តុលា ២០២៣នេះ សង្កេតឃើញថាមានភ្ញៀវទេសចរជាតិ-អន្តរជាតិ យ៉ាងច្រើនកុះករបានអញ្ជើញមកទស្សនាតាមប្រាសាទនានា ក្នុងតំបន់អង្គរ តាមស្ថិតិដែលទទួលបាន គឺមានទេសចរប្រមាណ២ម៉ឺននាក់

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣

## ទិដ្ឋភាពភ្ញៀវទេសចរជាតិ-អន្តរជាតិ ប្រម៉ាណ៤000 ទៅ៥000 នាក់ បានអញ្ជើញមកទស្សនានៅបរិវេណប្រាសាទបាយ័ន នាថ្ងៃទី១៥ តុលា ២០២៣

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣

## សកម្មភាពក្រុមការងារថែទាំបរិស្ថាន កាត់សម្អាតស្មៅនៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣

## អាជ្ញាធរជាតិអប្សរា បើកសវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ISO 14001-2015

ផ្សាយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

ចាប់ផ្តើមពីថ្ងៃទី១៨-១៩ ខែតុលា ឆ្នាំ២០២៣ អង្គភាពគ្រប់គ្រងបរិស្ថាន-អង្គរនៃអាជ្ញាធរជាតិអប្សរា បើកសវនកម្មផ្ទៃក្នុងប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ស្របតាមស្តង់ដារអន្តរជាតិ ISO14001-2015 នៅគ្រប់នាយកដ្ឋាននិងអង្គភាពចំណុះអាជ្ញាធរជាតិអប្សរា ក្នុងគោលបំណងដើម្បីបញ្ជាក់នូវភាពអនុលោមជាប្រចាំនៃប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរតាមតម្រូវការនៃស្តង់ដារ ISO 14001: 2015 នៅក្នុងរយៈពេលនៃការអនុវត្តបន្តពីសវនកម្មឆ្នាំមុន។

ពិធីបើកនេះក្រោមអធិបតីភាព**ឯកឧត្តមសុខលក្ខិណា** តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងជាប្រធានប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ រួមទាំងថ្នាក់ដឹកនាំនាយកដ្ឋាន និងអ្នកជំរុញការងារបរិស្ថានគ្រប់នាយកដ្ឋានពាក់ព័ន្ធ៕

# សកម្មភាពដ៏មមាញឹកនៃការរៀបចំប្រព័ន្ធដោះទឹកភ្លៀង និងស្តារសម្អាតប្រឡាយ តាមបណ្តោយផ្លូវកៅស៊ូជុំវិញប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធនៃអាជ្ញាធរជាតិអប្សរា កំពុងរៀបចំប្រព័ន្ធរំដោះទឹកភ្លៀង និងស្តារសម្អាតប្រឡាយតាមបណ្តោយផ្លូវកៅស៊ូជុំវិញប្រាសាទ អង្គរ។ មុនមានការស្តារសម្អាតនេះប្រឡាយនេះមានសំរាម កំណាកដីក្រាស់ ស្លឹកឈើ ដែលធ្វើឱ្យស្ទះដល់លំហូរទឹក និងមានទឹកដក់ថែមទៀតដែលធ្វើឱ្យមានបរិស្ថានមិន ស្អាត។

សកម្មភាពខាងលើនេះ ចាប់ផ្តើមពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣មក ដោយក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានចុះធ្វើការរៀបចំប្រព័ន្ធប្រឡាយដោះទឹកភ្លៀង និងធ្វើការសម្អាតកំណាកដីសំរាម ស្លឹកឈើចេញដើម្បីកុំឱ្យស្ទះដល់លំហូរទឹកនៅពេលដែលមានភ្លៀងខ្លាំងម្តងៗ ។ រហូតមកដល់ពេលនេះក្រុមការងារនៅកំពុងមមារញឹកបន្តស្តារសម្អាត និងរៀបចំប្រព័ន្ធដោះទឹកនៅតាមបណ្តោយផ្លូវកៅស៊ូជុំវិញប្រាសាទអង្គរវត្តឱ្យដំណើរការល្អឡើងវិញ។

ក្រោយពេលការងារស្តារសម្អាតនេះរួចរាល់ អាជ្ញាធរជាតិអប្សរារំពឹងថានឹងធ្វើឱ្យបរិស្ថានស្អាត និងមានសោភ័ណភាពស្រស់ស្អាតដែលជាទីទាក់ទាញភ្ញៀវទេសចរមកកម្សាន្តនៅទីនេះបន្ថែម៕

# លិខិតគោរពជូនពររបស់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរជាតិអប្សរា គោរពជូន សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាឱកាសដ៏សែនមហានក្ខត្តឫក្ស ចម្រើនជន្មាយុ គម្រប់៤៦ឆ្នាំ ឈានចូល ៤៧ឆ្នាំ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# កម្មវិធីអប់រំបេតិកភណ្ឌកុមារក្មេងតំបន់អង្គរ ដឹកនាំសិស្សានុសិស្ស នៃសាលាបឋមសិក្សាវត្តលលៃ ចុះទស្សនកិច្ចសិក្សានៅប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារអប់រំបេតិកភណ្ឌ ក្រោមកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា និងអង្គការមរតកវប្បធម៌ខ្មែរ ដឹកនាំសិស្សានុសិស្សនៃសាលាបឋមសិក្សាវត្តលលៃ ថ្នាក់ទី៥ និងទី៦ សរុបចំនួន៦៥នាក់ ចុះទស្សនកិច្ចសិក្សានៅប្រាសាទលលៃ។

ការដឹកនាំកុមារចុះសិក្សាផ្ទាល់នៅទីតាំងប្រវត្តិសាស្រ្ត គឺដើម្បីឱ្យកុមារសិក្សាពីប្រវត្តិសាស្រ្តតាមភស្តុតាងដែលបន្សល់មកដល់បច្ចុប្បន្ន ស្គាល់ជាក់ស្ដែងនូវលក្ខណៈស្ថាបត្យកម្មខ្មែរបុរាណ។ ជាមួយគ្នានេះដែរក៏បង្រៀនសិស្សានុសិស្សបន្ថែមអំពីការផាត់ពណ៌ បង្កើតជាល្បែងសម្រាប់កុមារបឋមសិក្សា ផ្ដល់ឱ្យកុមារនូវចំណេះដឹង និងទេព្យកោសល្យចំពោះការផាត់ពណ៌ អប់រំកុមារឱ្យស្គាល់សម្បត្តិវប្បធម៌កាន់តែច្បាស់តាមរូបភាពនីមួយៗ ក៏ដូចជាបង្កើនស្មារតីកុមារឱ្យស្រឡាញ់ និងជួយថែរក្សា ការពារបេតិកភណ្ឌបន្ថែមទៀត។

សូមបញ្ជាក់ដែរថា ទាំងខ្លឹមសារ រូបភាព និងពាក្យពេចន៍ជំរុញឱ្យមនុស្សគ្រប់រូបយល់កាន់តែច្បាស់នូវសារសំខាន់នៃការថែរក្សា-ការពារ មរតកដូនតា ថែមទាំងជំរុញឱ្យសហគមន៍មនុស្សទាំងនេះ អាចធ្វើជាភ្នែក ជាត្រចៀក ជាច្រមុះ ជួយឃ្លាំមើល ជួយការពារ ជួយអភិរក្ស និងជួយលើកកម្ពស់ដល់កិច្ចអភិរក្សនូវសម្បត្តិវប្បធម៌ទាំងនេះឱ្យបានគង់វង្ស៕

# សេចក្តីជូនដំណឹង ស្តីពីការរៀបចំព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត"

ផ្សាយនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខៈ ៨៤៩ / រប.សជសា
២៣

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការរៀបចំព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**
**-ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត-**

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា នៃប្រទេសជប៉ុន គម្រោងអភិរក្ស និងជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្តបានបញ្ចប់រួចរាល់ជាស្ថាពរ។ តាមរយៈនេះ អាជ្ញាធរជាតិអប្សរា នឹងរៀបចំព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ **-ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត-** ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ខាងមុខនេះ។

ក្នុងន័យដើម្បីគ្រប់គ្រងនូវលំហូរការទស្សនានៅប្រាសាទអង្គរវត្តឱ្យបានល្អប្រសើរ ក្រោយព្រះរាជពិធីសម្ពោធជាផ្លូវការខាងលើនេះ អាជ្ញាធរជាតិអប្សរានឹងកំណត់ទិសដៅទស្សនាដូចខាងក្រោម៖

១- ប្រើប្រាស់ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ជាច្រកចូលសម្រាប់ការទស្សនា
២- បន្តប្រើប្រាស់ស្ពានបណ្តែតទឹកប្រាសាទអង្គរវត្ត ជាច្រកចេញសម្រាប់ការទស្សនា

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣
**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារមរតកវប្បធម៌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

# ប្រទះឃើញកាស សម័យបុរាណចំនួន១១៦កាស នៅជើងសសរនៃព្រះវិហារវត្តល្អក់ ក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣

ក្រុមការងារជួសជុលព្រះវិហារវត្តល្អក់របស់អាជ្ញាធរជាតិអប្សរា បានប្រទះឃើញប្រាក់កាស( ស្លឹង )បុរាណសរុបទាំងអស់ ប្រមាណ១១៦កាស ដែលគេបញ្ចុះនៅតាមជើងសសរ របស់ព្រះវិហារវត្តល្អក់ ឬហៅវត្តអរញ្ញរង្សី ដែលស្ថិតនៅ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីពេលថ្មីៗ។

កាសបុរាណ ដែលគេប្រទះឃើញទាំងនោះ មានបីប្រភេទ ដោយកាសនីមួយៗមានទំហំពី១៣-១៥មីលីម៉ែត្រមានរូបសត្វ«ហង្ស» មួយបែបទៀតក៏មានរូប«ហង្ស»ដែរ តែលាយដោយអក្សរចិនអានថា«ជី»មានន័យថា«សំណាងល្អ» និងកាសម្យ៉ាងទៀតមានអក្សរថា«ព្រះតំបង» ឯផ្ទៃម្ខាងទៀតមានរូបគ្រុឌ។

សហប្រធានសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្វៀសានវ៉្រេន លោក ប្លែស គីលីយ៉ង់ បានពន្យល់ថា កាសដែលមានរូប«ហង្ស»គឺបានបោះពុម្ព ឱ្យប្រើប្រាស់នៅស្រុកខ្មែរចាប់ពីអំឡុងសតវត្សរ៍ទី១៦-១៩នៃគ្រឹស្តសករាជ ឯកាសមួយបែបទៀត មានរូប«ហង្ស»ដែរនិងមានអក្សរចិនអានថា«ជី»នោះភាគច្រើនបានបោះពុម្ព និងដាក់ឱ្យចរាចរនៅខេត្តបាត់ដំបង ក្នុងអំឡុងសតវត្សរ៍ទី១៩។ ចំណែកកាសមួយប្រភេទទៀត មានអក្សរថា«ព្រះតំបង» ហើយផ្ទៃម្ខាងទៀតមានរូបគ្រុឌ គឺបោះពុម្ព និងចរាចរនៅខេត្តបាត់ដំបង អំឡុងនាសតវត្សរ៍ទី១៩។

គេដឹងថា ព្រះវិហារវត្តល្អក់ មានតម្លៃប្រវត្តិសាស្រ្ត ទាំងវិស័យសាសនា និងសិល្បៈដោយសារតែវត្តនេះមានអាយុកាលយូរលង់មកហើយ។ វត្តល្អក់ បានសាងសង់ឡើងដោយគ្រឿងបង្គុំធ្វើអំពីឈើ ដំបូលប្រក់ក្បឿង ជញ្ជាំងជុំវិញធ្វើពីឥដ្ឋបូកកំបោរបាយអរ។ សំណង់នេះ មានសសរ៤ជួរ ដោយមាន២ជួរនៅកណ្តាលជាសសរកន្លោងនិង២ជួរទៀតជាសសរជើងរាង។ បច្ចុប្បន្នសសរឈើរបស់ព្រះវិហារដែលកប់ក្នុងដីជាច្រើនឆ្នាំមកហើយ កំពុងមានភាពពុកផុយខូចខាតខ្លាំង ដែលអាចបង្កគ្រោះថ្នាក់ដល់ការស្នាក់នៅរបស់ព្រះសង្ឃ ហើយវាទាមទារឱ្យក្រុមអ្នកជំនាញធ្វើការជួសជុលជាចាំបាច់៕

## ប្រាសាទបក្សីចាំក្រុង

ផ្សាយនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣

# ប្រាសាទវត្តអធ្វា

ផ្សាយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣

# នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា កំពុងជួលជុលនិងកែលម្អកំណាត់ផ្លូវមុខអតីតព្រលានយន្តហោះអន្តរជាតិសៀមរាប ឆ្ពោះទៅប្រាសាទអង្គរវត្ត ក្នុងបំណងដើម្បីលើកតម្លៃ និងសម្រួលដល់ការធ្វើដំណើរ ឱ្យបានស្រួលឡើងវិញ

ផ្សាយនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣

# ការជួសជុលកំពង់ទឹកខាងកើតប្រាសាទព្រះខ័ននឹងបញ្ចប់នៅពេលឆាប់ៗ

ផ្សាយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣

គម្រោងជួសជុលការដ្ឋានកំពង់ទឹកប្រាសាទព្រះខ័ន ជិតរួចរាល់ជាស្ថាពរហើយ ដោយបច្ចុប្បន្ន ក្រុមអ្នកជំនាញនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា នៅតែជួសជុលបង្ហើយពង្រឹងជើងទំនប់ខាងលិច (នៃបារាយណ៍ជ័យតដាក)ដែលតភ្ជាប់ពីខឿនកំពង់ទឹកទៅកាន់ផ្លូវចូលប្រាសាទព្រះខ័នខាងកើតមានសភាពទ្រុឌទ្រោមខ្លាំង ដោយសារតែទឹកហូរច្រោះកំណកដី។

បុរាណវិទូ និងជាអ្នកគ្រប់គ្រងគម្រោងជួសជុលការដ្ឋានកំពង់ទឹកប្រាសាទព្រះខ័នលោកជាសារិទ្ធមានប្រសាសន៍ថា ក្រុមការងារកំពុងតែមមាញឹកការស្តារកំណកដីពីផ្លូវចូលខាងកើត ហើយយកទៅចាក់បិទខ្នងទំនប់បារាយណ៍ជ័យតដាក ដើម្បីបំពេញត្រង់ចំណុចដែលបាក់ស្រុតដោយសារទឹកហូរច្រោះ ឱ្យឃើញនូវរូបរាងដើមវិញ។ ម្យ៉ាងវិញទៀត ការស្តារកំណកដីផ្លូវចូលនេះ គឺដើម្បីជួយសម្រួលដល់ទេសចរ នឹងបង្ហាញឱ្យឃើញឡើងវិញនូវរចនាសម្ពន្ធផ្លូវដែលក្រាលដោយថ្មបាយក្រៀម និងថ្មគោលព្រះពុទ្ធសាសនានៅអមសងខាងផ្លូវ ជាសំណង់ប្រវត្តិសាស្ត្រមួយចំណោមសំណង់ផ្សេងទៀតនៅប្រាសាទព្រះខ័ន។ សព្វថ្ងៃ ទាំងកម្រាលថ្មបាយក្រៀម និងថ្មគោលព្រះពុទ្ធសាសនាកប់ក្នុងដីជម្រៅប្រមាណជាង១ម៉ែត្រ បណ្តាលឱ្យថ្មរងការពុកផុយ។ កន្លងមក អភិរក្សដ្ឋានអង្គរនៃសាលាបារាំងចុងបូព៌ាធ្លាប់ធ្វើកំណាយសម្អាតដីលើផ្លូវនេះរួចម្តងហើយ៕

# ក្រុមការងារអភិរក្ស ជួសជុលពង្រឹងគ្រឹះ និងរចនាសម្ពន្ធតួប្រាសាទឥដ្ឋ នៅទិសអាគ្នេយ៍ប្រាសាទបាគង

ផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

ក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បន្តជួសជុលគ្រឹះ និងរចនាសម្ពន្ធមួយចំនួនទៀត នៃតួប្រាសាទឥដ្ឋ នៅទិសអាគ្នេយ៍របស់ប្រាសាទបាគង ដែលរងការខូចខាតខ្លាំង ដោយសារអាយុកាលជាង១០០០ឆ្នាំ បញ្ចៀសពីការប្រឈមនឹងគ្រោះថ្នាក់ និងការខូចខាតជាបន្តទៀត។

បុរាណវិទូ និងជាប្រធានអភិរក្សតំបន់រលួស លោក សារាយ គឹមហួល ឱ្យដឹងថា បច្ចុប្បន្នតួប្រាសាទឥដ្ឋនេះ មានហានិភ័យខ្ពស់ ដោយគ្រឹះនៅជ្រុងអាគ្នេយ៍បានហែក ហើយផ្ទៃជញ្ជាំងបានប្រេះរហែកប្រមាណ៤ទៅ៥កន្លែង ដែលទាមទារឱ្យក្រុមការងារជួសជុលសង្គ្រោះដោយប្រើរយៈពេលវែង។

លោក គឹមហួល មានប្រសាសន៍ទៀតថា នៅក្នុងដំណាក់កាលនេះ ក្រុមការងារបានពង្រឹងគ្រឹះដែលហែកឡើងវិញ ដោយរៀបឥដ្ឋនៅកន្លែងដែលបានពុកផុយ ដើម្បីទល់ទ្រកម្លាំងសង្កត់របស់ជញ្ជាំង។ រីឯជញ្ជាំងដែលប្រេះរហែក គឺប្រើប្រាស់ដែកក្រវ៉ាត់ ដើម្បីជួយទប់កុំឱ្យកម្លាំងសង្កត់របស់ជញ្ជាំងធាក់មកទៀត។ ក្រៅពីនេះក្រុមការងារ បានបិទភ្ជិតស្នាមប្រេះនៅតាមជញ្ជាំង និងពង្រឹងរចនាសម្ពន្ធជាច្រើនកន្លែងទៀត នៅផ្នែកខាងលើនៃតួប្រាសាទ ដែលកំពុងមានស្ថានភាពពុកផុយខ្លាំងដែរ៕

# ក្រុមការងារទេសចរណ៍ ប្រចាំការនៅប្រាសាទតាព្រហ្ម បានប្រគល់ជូនកាបូបស្ពាយក្រោយ ជូនម្ចាស់ដើមវិញ

ផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារទេសចរណ៍ ប្រទះឃើញកាបូបស្ពាយក្រោយមួយនៅគល់ដើមឈើទាល នៅមុខស្ពានហាលខាងកើត បានប្រគល់ជូនម្ចាស់ភ្លាមៗ ក្រោយពេលភ្ញៀវភ្លេច។

# ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា ធ្វើការកាត់ត្រីមែកឈើដែលងាប់ៗ មានហានិភ័យទៅដល់ភ្ញៀវទេសចរ និងប្រាសាទ នៅបរិវេណមុខប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

# សិក្ខាកាមចំនួន២២រូប បានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញរៀបចំនិងកែលម្អសារមន្ទីរ ឱ្យក្លាយជាកន្លែងទាក់ទាញនិងគួរឱ្យចង់ទស្សនា

ផ្សាយនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា បានបិទវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំនិងកែលម្អសារមន្ទីរឱ្យក្លាយទៅជាកន្លែងទាក់ទាញគួរឱ្យចង់ទស្សនា នៅឯសារមន្ទីរវាយណភណ្ឌប្រពៃណីអាស៊ី នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣។

អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ លោក ប៉ែន ចំរុង មានប្រសាសន៍ថា សិក្ខាកាមចំនួន២២រូប ដែលបានទទួលវគ្គបណ្តុះបណ្តាលជំនាញនេះ មួយចំនួនគឺជាមន្ត្រី និងបុគ្គលិករបស់អាជ្ញាធរជាតិអប្សរា និងមួយចំនួនទៀត មកពីសារមន្ទីរទួលស្លែង អាជ្ញាធរជាតិសំបូរព្រៃគុក និងអាជ្ញាធរជាតិព្រះវិហារ។

សិក្ខាកាម បានទទួលការបណ្តុះបណ្តាលលើជំនាញជាច្រើន ដូចជា ឱ្យស្គាល់ពីអ្វីជាសារមន្ទីរ? តួនាទីរបស់អ្នករៀបចំតាំងពិព័រណ៍ (Curator) គោលការណ៍នៃការគ្រប់គ្រងវត្ថុសិល្បៈ តើសិល្បៈប្រភេទណាខ្លះដែលគួរលើកយកទៅដាក់តាំងពិព័រណ៍? ការបង្ហាញអំពីការរៀបចំពិព័រណ៍ បរិយាកាសជុំវិញការរៀបចំតាំងពិព័រណ៍និងសុវត្ថិភាពនៃការតាំងពិព័រណ៍ជាដើម។

អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ឡុង កុសល** បានចាត់ទុកវគ្គបណ្តុះបណ្តាលជំនាញរៀបចំនិងកែលម្អសារមន្ទីរឱ្យក្លាយជាកន្លែងទាក់ទាញនិងគួរឱ្យចង់ទស្សនានេះថា គឺជាកិច្ចការមួយដែលប្រព្រឹត្តឡើងក្នុងក្របខណ្ឌជាតិ ក្នុងគោលបំណងជំរុញធ្វើយ៉ាងណាដើម្បីឱ្យសារមន្ទីរមានភាពប្រសើរឡើង ក្នុងការទាក់ទាញភ្ញៀវទស្សនា ហើយក៏ធ្វើឱ្យសារមន្ទីរក្លាយទៅជាកន្លែងប្រវត្តិសាស្ត្រ និងកន្លែងអប់រំចំណេះដឹងផងដែរ៕

# អ្នកជំនាញ នឹងបញ្ចប់ការងារជួសជុលប្រាសាទតាព្រហ្មកិល ឱ្យរួចរាល់នាចុងឆ្នាំ២០២៣នេះ

ផ្សាយនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

ក្រុមអ្នកជំនាញ ជិតបញ្ចប់ការងារជួសជុលប្រាសាទតាព្រហ្មកិលហើយ ពោលគឺនៅបង្ហើយតែការងារនៅសេសសល់មួយចំនួនទៀតប៉ុណ្ណោះ បើសិនមិនមានបញ្ហារាំងស្ទះណាមួយទេ កិច្ចការនេះនឹងបញ្ចប់នៅចុងឆ្នាំ២០២៣ខាងមុខ។

លោក ម៉ៅ សុខនី ប្រធានការដ្ឋានជួសជុលប្រាសាទតាព្រហ្មកិល និងជាស្ថាបត្យករ នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបានឱ្យដឹងថា តាមរយៈការខិតខំប្រឹងប្រែងកន្លងមករបស់ក្រុមអ្នកជំនាញ បានដំណើរការជួសជុលប្រាសាទតាព្រហ្មកិល ដោយចាប់ផ្តើមកាលពីពាក់កណ្តាលឆ្នាំ២០២៣មក។

បច្ចុប្បន្នកិច្ចការងារនេះ សម្រេចលទ្ធផលបានប្រមាណ៧០ភាគរយ គ្រោងនិងបញ្ចប់គម្រោងជួសជុលនាចុងឆ្នាំ២០២៣ខាងមុខ។

លោកបន្តថា ប្រាសាទព្រហ្មកិលបានរងការខូចខាតទ្រុឌទ្រោមខ្លាំង ដោយសារថ្មខ្លះបានធ្លាក់កប់ដី នៅរាយប៉ាយ ហើយតួប៉មកណ្តាល បានបាក់រលុះអស់មួយចំហៀងនៅជ្រុងខាងត្បូង និងខាងលិច។ ដោយឡែកដំណើរការជួសជុលវិញ បានបែងចែកជាបីដំណាក់កាល រួមមាន៖ ជួសជុលខឿន ជញ្ជាំង និងកំពូលនៃប្រាសាទ។

ខណៈការជួសជុលផ្នែកខឿន និងជញ្ជាំង បានរួចរាល់ហើយ នៅសល់តែការជួសជុលរួតទាំង៥ នៃកំពូលប្រាសាទប៉ុណ្ណោះ។

លោក ម៉ៅ សុខនី បានបញ្ជាក់ទៀតថា ការងារបន្ទាប់ក្រោយបញ្ចប់ការជួសជុលតួប៉មនៃប្រាសាទតាព្រហ្មកិលហើយ ក្រុមអ្នកជំនាញគ្រោងរៀបចំកែសម្រួល នៅចំណុចខ្លោងទ្វារច្រកចូលនៃប្រាសាទ ឱ្យមានភាពរឹងមាំឡើងវិញ។

សូមជម្រាបថា ប្រាសាទតាព្រហ្មកិល មានតួនាទីជាហោសម្រាប់មនុស្សបន់ស្រន់ នៅក្នុងមន្ទីរពេទ្យមួយ ក្នុងចំណោមមន្ទីរពេទ្យទាំង៤ជុំវិញក្រុងអង្គរធំ កសាងឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ នាចុងសតវត្សទី១២ នៃគ្រឹស្តរាជ ប្រាសាទនេះ មានទីតាំងនៅផ្នែកខាងលិចឈៀងខាងជើង នៃប្រាសាទអង្គរវត្ត៕

# ខ្សែទស្សនាថ្មីនៅប្រាសាទចៅសាយទេវតានិងធម្មនន្ទ នឹងសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរកាន់តែងាយស្រួល

ផ្សាយនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា បានដាក់ឱ្យដំណើរការខ្សែទស្សនាថ្មី នៅប្រាសាទចៅសាយទេវតា និងប្រាសាទធម្មនន្ទ ដើម្បីសម្រួលដល់ការដើរទស្សនារបស់ភ្ញៀវទេសចរកាន់តែងាយស្រួល និងគ្រប់ជ្រុងជ្រោយ។

លោក ខឿន កុសល់ ប្រធានភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទចៅសាយទេវតា ធម្មនន្ទ និងខ្លោងទ្វារជ័យ លើកឡើងថា ខ្សែទស្សនាថ្មីនេះអាជ្ញាធរជាតិអប្សរា បានរៀបចំជាពីរខ្សែ ដោយសារខ្សែទី១ គឺមានចម្ងាយខ្លី ដែលភ្ញៀវអាចឈប់យានជំនិះនៅផ្នែកខាងជើង និងដើរចូលតាមច្រកខាងកើត ប្រាសាទចៅសាយទេវតា ហើយចេញតាមច្រកខាងជើងដដែល។ ចំណែកខ្សែទី២ ជាខ្សែទស្សនាវែង ដែលភ្ញៀវចាប់ផ្តើមចូលទស្សនានៅប្រាសាទធម្មនន្ទ ដើរចូលតាមសួនបណ្តុះកូនឈើប្រាសាទតាកែវ និងចូលតាមច្រកខាងកើតប្រាសាទចៅសាយទេវតា។

តាមការបញ្ជាក់ពីភ្នាក់ងារទេសចរណ៍ ការរៀបចំនេះ គឺដើម្បីសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរ ឱ្យកាន់តែងាយស្រួល ពិសេសធ្វើឱ្យការទស្សនាមានភាពលម្អិត និងគ្រប់ជ្រុងជ្រោយ ខណៈដែលកន្លងមក ភ្ញៀវចូលទស្សនារបៀបសេរី មិនមានគោលដៅចាប់ផ្តើម និងបញ្ចប់ត្រឹមត្រូវនោះទេ។ បច្ចុប្បន្នវង់ទស្សនានេះបានដាក់ឱ្យដំណើរការហើយ ចំណែកភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទនេះ កំពុងរៀបចំ និងកែលម្អ ចាក់ដីបំពេញជង្ហុកខ្លះ ដើម្បីឱ្យការដើររបស់ភ្ញៀវមានភាពងាយស្រួល។

ប្រាសាទចៅសាយទេវតា កសាងឡើងនៅចុងសតវត្សទី១១ ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២។ ដ្បិតជាប្រាសាទតូច តែចៅសាយទេវតាមានក្បូនក្បាច់ចម្លាក់ជាច្រើនមិនចាញ់ប្រាសាទធំប៉ុន្មានទេ និងមានស្ពានហាលដ៏ទាក់ទាញនៅច្រកចូលខាងកើត ដែលទេសចរអាចផ្តិតរូបភាពនៅទីនោះបាន៕

ផែនទីផ្លូវចូលទស្សនាប្រាសាទអង្គរវត្តច្រកចូលទិសខាងកើត
និងទីតាំងបិទសំរាប់ប្រារព្ធពិធី (ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣)




**សម្គាល់៖**

- ទីតាំងបិទសំរាប់ប្រារព្ធពិធី
- ផ្លូវបិទការដ្ឋាន
- ផ្លូវអាចធ្វើចរាចរបាន ទៅតាមច្រកចូលខាងកើតប្រាសាទអង្គរ

# សេចក្តីជូនដំណឹង ស្តីពីការផ្អាកចូលទស្សនាប្រាសាទអង្គរវត្ត តាមច្រកខាងលិច (ស្ពានបណ្តែតទឹក)

ផ្សាយនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

---

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខៈ ០៤៧៩/ ១៣/ អជអ.ហ៧

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការផ្អាកចូលទស្សនាប្រាសាទអង្គរវត្ត តាមច្រកខាងលិច(ស្ពានបណ្តែតទឹក)**

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទាំងអស់មេត្តាជ្រាបថា ក្នុងគោលដៅដើម្បីថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ «ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត» នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** អាជ្ញាធរជាតិអប្សរានឹងធ្វើការផ្អាកការចូលទស្សនាប្រាសាទអង្គរវត្ត តាមច្រកខាងលិច(ស្ពានបណ្តែតទឹក)ខាងមុខប្រាសាទអង្គរវត្ត ចាប់ពីព្រឹកព្រលឹមថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ចប់ព្រះរាជកម្មវិធី។

នៅក្នុងអំឡុងពេលនៃការផ្អាកខាងលើនេះ សាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ អាចចេញ-ចូលទស្សនាប្រាសាទអង្គរវត្ត តាមច្រកចូលខាងកើតបានជាធម្មតា ដូចមានផែនទីជូនភ្ជាប់មកជាមួយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងអនុវត្តដោយអនុគ្រោះ។

ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២៣
**អាជ្ញាធរជាតិអប្សរា**

APSARA National Authority
Website: apsaraauthority.gov.kh

# ប្រាសាទបន្ទាយសំរ៉ែ

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣

# ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិអញ្ជើញមកទស្សនាថ្ងៃរះ នៅប្រាសាទអង្គរវត្ត នាថ្ងៃទី២៨ តុលា ២០២៣

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣

# សូមថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដ៏មហាមង្គលថ្លៃថ្លា នៃព្រះរាជពិធីបុណ្យខួបលើកទី១៩ នៃការយាងគ្រងព្រះបរមរាជសម្បត្តិ របស់ព្រះករុណាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រាសាទបី

ផ្សាយនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាកំពុងរៀបចំរបាសុវត្ថិភាព នៅលើស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ក្រោយពេលបើកដំណើរការឱ្យភ្ញៀវទេសចរឆ្លងកាត់

ផ្សាយនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣

ដើម្បីធានាបាននូវសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិឆ្លងចូលទស្សនាប្រាសាទអង្គរវត្ត ក្រោយពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ឆាប់ៗខាងមុខនេះ អាជ្ញាធរជាតិអប្សរាកំពុងរៀបចំដាក់របាសុវត្ថិភាព បង្ការគ្រោះថ្នាក់ដោយយថាហេតុណាមួយសម្រាប់ភ្ញៀវធ្វើដំណើរនៅលើស្ពានហាលនេះ។

**ឯកឧត្តម ឡុង កុសល** អគ្គនាយករងអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា រចនាសម្ពន្ធរបស់ស្ពានហាល ត្រូវបានជួសជុលរួចរាល់ទាំងស្រុង នឹងបើកឱ្យភ្ញៀវជាតិ និងអន្តរជាតិបានឆ្លងចូលទៅទស្សនាប្រាសាទអង្គរវត្តឡើងវិញនាពេលខាងមុខ។ ដោយគិតគូរខ្ពស់អំពីសុវត្ថិភាពរបស់ភ្ញៀវដែលបានផ្តោតការចាប់អារម្មណ៍ទៅតែសម្រស់របស់ស្ពានដែលទើបជួសជុលរួចរាល់ និងប្រាង្គប្រាសាទអង្គរវត្តដ៏ទាក់ទាញនោះ ភ្ញៀវអាចនិងភ្លេចខ្លួនដើរហួសតួស្ពានអាចបណ្តាលឱ្យធ្លាក់ទឹក បង្កជាគ្រោះថ្នាក់ទៅវិញ អាជ្ញាធរជាតិអប្សរាកំពុងរៀបចំដាក់របាសុវត្ថិភាព នៅសងខាងនៃតួស្ពានហាលមានលក្ខណៈជាខ្សែបង្កប់ស្ទើរតែមិនអាចមើលឃើញនិងភ្នែកឡើយ។ ប៉ុន្តែ នៅពេលដើរចូលទៅកៀកភ្ញៀវទេសចរនឹងទទួលបានការពញ្ញាក់អារម្មណ៍ឱ្យបង្កើនការប្រុងប្រយ័ត្ននៅពេលធ្វើដំណើរ។

មួយវិញទៀត ឯកឧត្តម អគ្គនាយករង មានប្រសាសន៍បន្ថែមទៀតថា ដោយការព្រួយបារម្ភអំពីភាពសឹករិចរិលរបស់ថ្ម ទៅថ្ងៃអនាគត ដោយសារកំណើនរបស់ភ្ញៀវធ្វើដំណើរឆ្លងកាត់នោះ អាជ្ញាធរជាតិអប្សរា នៅតែបន្តរក្សាទុកស្ពានបណ្តែតទឹកឱ្យបន្តដំណើរការដដែល។ ដោយកំណត់ទិសដៅធ្វើដំណើរផ្សេងគ្នា គឺស្ពានហាលនឹងអនុញ្ញាតឱ្យភ្ញៀវធ្វើដំណើរឆ្លងចូលទៅទស្សនាប្រាសាទអង្គរវត្ត ស្ពានបណ្តែតទឹកនឹងជាទិសដៅសម្រាប់ភ្ញៀវចាកចេញពីទស្សនាប្រាសាទមកវិញ៕

# ព្រឹត្តិការណ៍ព័ត៌មាន
# ប្រចាំខែវិច្ឆិកា

# ក្រុមការងារភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា យកចិត្តចំពោះភ្ញៀវទេសចរមកទស្សនារមណីយដ្ឋាន

ផ្សាយនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ភ្ញៀវទេសចរជនជាតិឥណ្ឌា ភេទស្រីអាយុ៧០ឆ្នាំ មានអាការៈឈឺជើងដើរមិនរួច នៅចំណុចរានហានច្រកតារាជ។ ភ្លាមៗនោះក្រុមការងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា ប្រចាំការនៅប្រាសាទអង្គរវត្តបានជួយសម្រួលឱ្យរ៉ឺម៉កកង់បីចូលមកយកទៅសណ្ឋាគារវិញ។ ករណីទី២ ក្រុមភ្នាក់ងារទេសចរណ៍ បានសម្រួលឱ្យរ៉ឺម៉ក់មកយកភ្ញៀវជនជាតិកាណាដាម្នាក់ ដែលគាត់មានអាការៈ មិនស្រួលខ្លួន ពិបាកក្នុងការធ្វើដំណើរនៅចំណុចច្រកចុះទៅបន្ទប់ទឹកប្រាសាទអង្គរវត្ត៕

# «ស្ពានហាលអង្គរវត្ត» បើកដំណើរការឡើងវិញ ក្រោយជួសជុលជាមួយការធានានិរន្តរភាពរាប់រយឆ្នាំ

ផ្សាយនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរា ជួសជុលគំនូរបុរាណព្រះវិហារវត្តរាជបូណ៌ ក្រោមការឧបត្ថម្ភថវិការបស់រដ្ឋាភិបាលឥណ្ឌា

ផ្សាយនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៃប្រទេសកម្ពុជា និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា បានអញ្ជើញធ្វើជាអធិបតីក្នុងពិធីបើកសម្ពោធការដ្ឋានអភិរក្ស និងជួសជុលគំនូរបុរាណ ដែលមានអាយុរាប់រយឆ្នាំ នៅក្នុងព្រះវិហារនៃវត្តរាជបូណ៌ ក្នុងទីរួមខេត្តសៀមរាប នាព្រឹកថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣។

ព្រះវិហាររបស់វត្តរាជបូណ៌ បានសាងសង់ឡើងតាំងពីសតវត្សរ៍ទី១៨នៃគ្រឹស្តសករាជ។ ទាំងស្ថាបត្យកម្ម និងការដែលបង្ហាញឱ្យឃើញពីស្នាដៃការច្នៃប្រឌិត និងមរតកវប្បធម៌ខ្មែរដ៏សម្បូរបែប។ នៅលើជញ្ជាំងនៃវត្តរាជបូណ៌ មានគំនូរបុរាណចំនួនប្រមាណ១៥៧ផ្ទាំង ដែលបង្ហាញពីជីវិតរបស់ព្រះសម្មាសម្ពុទ្ធ រឿងរាមាយណៈ(រាមកេរ្តិ៍)មានបង្ហាញពីឋាននរក និងឋានសួគ៌ ព្រមទាំងជីវិតប្រចាំថ្ងៃរបស់មនុស្សដែរ។ បច្ចុប្បន្ន ស្ថានភាពរបស់ផ្ទាំងគំនូរទាំងអស់នេះ គឺស្ថិតក្នុងការប្រឈមពុកផុយដែលទាមទារឱ្យមានការជួសជុល និងអភិរក្សឡើងវិញជាបន្ទាន់។

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** មានប្រសាសន៍នៅក្នុងពិធីបើកសម្ពោធការដ្ឋានអភិរក្ស និងជួសជុលគំនូរបុរាណនោះថា លោកជំទាវក៏ដូចជាពលរដ្ឋកម្ពុជា គឺពិតជាមានមោទនភាពបំផុត ដែលបានចូលរួមក្នុងគម្រោងអភិរក្ស និងជួសជុលផ្ទាំងគំនូរបុរាណដ៏មានតម្លៃ និងកិត្យានុភាព។

**លោកជំទាវ ភឿង សកុណា** មានប្រសាសន៍ទៀតថា រាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលឥណ្ឌា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដើម្បីអភិរក្សគំនូរបុរាណនៅក្នុងព្រះវិហារនៃវត្តរាជបូណ៌នេះតាំងតែពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២។ លោកជំទាវជឿជាក់យ៉ាងមុតមាំថា ការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារគំនូរដ៏មានអត្ថន័យ និងមានតម្លៃទាំងនេះនៅតែរឹងមាំ។

លោកជំទាវបណ្ឌិត ឯកអគ្គរដ្ឋទូតសារណរដ្ឋឥណ្ឌា ដេវីយ៉ានី ខូប្រាកេឌី (Devyani KhoBragade) ក៏មានប្រសាសន៍ដែរថា ការគាំទ្រលើគម្រោងអភិរក្ស និងជួសជុលគំនូរបុរាណក្នុងព្រះវិហារនៃវត្តរាជបូណ៌នេះ គឺឥណ្ឌាមានគោលបំណងស្តារឡើងវិញ ព្រមទាំងពង្រឹងទំនាក់ទំនងវប្បធម៌ ការលើកកម្ពស់ការយល់ដឹងពីគ្នាទៅវិញទៅមក ការគោរព និងការដឹងគុណចំពោះប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសទាំងពីរ។តាំងពីឆ្នាំ២០០៥មក អ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចអភិរក្ស និងថែរក្សាសំណង់ទាំងឡាយរបស់វត្តរាជបូណ៌ ហើយចាប់ពីឆ្នាំ២០១៤-២០២០ វត្តរាជបូណ៌ត្រូវបានចុះទៅក្នុងបញ្ជីបេតិកភណ្ឌជាតិកម្ពុជា៕

## អាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា ចុះអនុស្សរណៈយោគយល់ចំនួន២ លើគម្រោងថែទាំស្ពានហាលអង្គរវត្ត និងការបណ្ដុះបណ្ដាលធនធានមនុស្ស

ផ្សាយនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣

នារសៀលថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ អាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ាប្រទេសជប៉ុន បានចុះអនុស្សរណៈយោគយល់ចំនួនពីរ ដែលរួមមាន ទី១ អនុស្សរណៈនៃការយោគយល់គ្នានៃគម្រោង ថែទាំស្ពានហាលខាងលិចប្រាសាទអង្គរវត្ត និងទី២ អនុស្សរណៈនៃការយោគយល់គ្នានៃគម្រោងបណ្ដុះបណ្ដាល និងស្រាវជ្រាវនៅរមណីយដ្ឋានអង្គរ។

កម្មវិធីនេះធ្វើឡើងក្រោមអធិបតីភាព**លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោក អូហ្គូស្ទីន សាលី ( AUGUSTINE Sali ) អធិការបតីសាកលវិទ្យាល័យសូហ្វីយ៉ា លោក យ៉ូស៊ីអាគី អ៊ីស៊ីហ្សាវ៉ា ប្រធានមជ្ឈមណ្ឌលអាស៊ីសូហ្វីយ៉ា ដើម្បីការសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាលធនធានមនុស្ស ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីអាជ្ញាធរជាតិអប្សរាជាច្រើនរូបទៀត៕

# ព្រះករុណា ព្រះមហាក្សត្រ ៖ «ប្រាសាទអង្គរ ជាសក្ខីភាពនៃការរីកចម្រើនដល់កំពូលនៃវប្បធម៌អរិយធម៌សិល្បៈ ក្នុងសតវត្សទី១២»

ផ្សាយនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣

**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** បានមានព្រះរាជបន្ទូលថា ប្រាសាទអង្គរជាសក្ខីភាពនៃការរីកចម្រើនដល់កំពូលនៃវប្បធម៌អរិយធម៌សិល្បៈក្នុងសតវត្សទី១២ នៃគ្រិស្តសករាជ ដែលសកលលោកចាត់ទុកថា ជាអច្ឆរិយវត្ថុផង ជាតំណាងនៃការច្នៃប្រឌិតដល់កំពូលនៃមនុស្សជាតិផង ។

ព្រះករុណា ព្រះមហាក្សត្រ បានមានព្រះរាជបន្ទូលដូច្នេះ នៅក្នុងព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានហាលខាងលិចនៃប្រាសាទអង្គរ នៃរមណីយដ្ឋានអង្គរ ខេត្តសៀមរាប ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ៕



# កម្រងរូបភាព ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត នាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣

## ទិដ្ឋភាពប្រាសាទតាកែវពីលើអាកាស

ផ្សាយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៣

## ភ្ញៀវទេសចរជាតិ និងអន្តរជាតិធ្វើដំណើរឆ្លងកាត់ស្ពានហាលមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៣

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករធ្វើដំណើរឆ្លងកាត់ស្ពានហាលមុខប្រាសាទអង្គរវត្ត ក្រោយពីព្រះរាជពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង **ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**៕

# នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរមន្ត្រីក្រសួងការបរទេសបារាំង ចុះពិនិត្យការវិវត្តនៃការងារជួសជុលប្រាសាទមេបុណ្យខាងលិច

ផ្សាយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៣

# ភ្ញៀវទេសចរជាតិ និងអន្តរជាតិ បង្ហាញពីមោទកភាពនៅពេលបានដើរឆ្លងកាត់ស្ពានហាលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣

ក្រោយពីបញ្ចប់ការងារជួសជុល និងសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវការ ក្នុងមួយថ្ងៃៗ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ជាច្រើនរយនាក់ដើរឆ្លងកាត់ស្ពានហាលខាងលិចដើម្បីចូលទៅទស្សនាប្រាសាទអង្គរវត្ត បានពោលពាក្យកោតសរសើរចំពោះអាជ្ញាធរជាតិអប្សរា ដែលបានខិតខំប្រឹងប្រែងជួសជុល និងអភិរក្សស្ពានហាលនេះបានល្អប្រសើរឡើងវិញ។ បន្ថែមលើនេះ ភ្ញៀវទេសចរក៏បង្ហាញពីមោទកភាពនៃកេរដំណែលដូនតាខ្មែរមួយនេះដែរ។

លោកតា កាយ កាន អាយុ៧៨ឆ្នាំ មកពីខេត្តកំពង់ធំ បានបង្ហាញអារម្មណ៍រីករាយក្រោយរូបគាត់បានដើរឆ្លងកាត់ស្ពានហាលសារជាថ្មី ដោយគាត់រៀបរាប់ថាគាត់ធ្លាប់ឆ្លងកាត់ស្ពានហាលនេះតាំងពីឆ្នាំ២០០៥ ដែលកាលណោះស្ពានមានស្ថានភាពបាក់បែក និងស្រុតដោយកន្លែងពិបាកធ្វើដំណើរ។ ប៉ុន្តែពេលនេះ គាត់បានដើរលើស្ពានបុរាណម្តងទៀត ឃើញថា មានភាពរឹងមាំឡើងវិញ ព្រមទាំងធ្វើឱ្យភ្ញៀវដែលមកលេងអង្គរងាយស្រួលធ្វើដំណើរជាងមុនផង។

ចំណែកពលរដ្ឋម្នាក់ទៀតរស់នៅខេត្តកណ្តាល អ៊ំស្រី នូ យ៉ន បានសរសើរថា ស្ពានហាលខាងលិចអង្គរវត្តពិតជាស្រស់ស្អាតប្លែក ស្រួលដើរជាងកាលពីមុន។ គាត់យល់ថា កាជួសជុលស្ពានហាលឱ្យប្រសើរឡើងវិញនេះ គឺបានថែរក្សាទុកស្នាដៃរបស់បុព្វបុរសខ្មែរឱ្យនៅគង់វង្សបានយូរអង្វែងសម្រាប់កូនចៅជំនាន់ក្រោយៗទៀតបានឃើញ។

លោកស្រី Linda និង អ្នកស្រី Hidi ជនជាតិអាមេរិក ដែលបានដើរឆ្លងកាត់ស្ពានហាលជាលើកដំបូង បានបង្ហាញការចាប់អារម្មណ៍ខ្លាំងលើសំណង់ប្រាសាទបុរាណដ៏អច្ឆរិយៈរបស់ប្រទេសកម្ពុជានេះ ពិសេស គឺការជួសជុលថែទាំស្ពានហាលនេះជាដើម។

អ្នកទេសចរបរទេសទាំង២ បង្ហាញអារម្មណ៍រំភើប ដោយចាត់ទុកថា រូបគាត់ទាំងពីរមានសំណាងណាស់ ពីព្រោះដំណើរកម្សាន្តនៅរមណីយដ្ឋានអង្គរ ស្របពេលសំណង់ស្ពានហាលបានជួសជុលរួចរាល់ ហើយបានដើរឆ្លងកាត់ជាលើកដំបូង។

ការពោលសរសើរអំពីការងាររបស់អាជ្ញាធរជាតិអប្សរា ក្នុងការជួសជុលព្រមទាំងសម្រស់ស្ពានហាលខាងលិចអង្គររបស់ភ្ញៀវទេសចរចម្រុះជាតិសាសន៍នេះកើតមានឡើងបន្ទាប់ពីស្ពានហាលខាងលិចអង្គរ បានជួសជុលរួចរាល់ព្រមទាំងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការឡើងវិញ៕

# មិត្តកាយឫទ្ធិនារីតំបន់អាស៊ីប៉ាស៊ីហ្វិករួមគ្នាដាំដើមឈើខាងលិចប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ មិត្តកាយឫទ្ធិនារីតំបន់អាស៊ីប៉ាស៊ីហ្វិក បានប្រារព្ធពិធីដាំដើមផ្កាពុល មហាសន្និបាតមិត្តកាយឫទ្ធិនារីតំបន់អាស៊ីប៉ាស៊ីហ្វិក ក្រោមប្រធានបទ "យើងរួមគ្នាអភិវឌ្ឍអនាគតកុមារី និងយុវតី" នាបរិវេណត្រពាំងសេស ខាងលិចប្រាសាទអង្គរវត្ត ស្ថិតក្រោមអធិបតីភាព **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អគ្គស្នងការនៃសមាគមកាយឫទ្ធិនារីកម្ពុជា និងជាសមាជិក Gold Award របស់ FAPW និងជាសមាជិក Global Award របស់សហគម OB-PS។

# អាជ្ញាធរជាតិអប្សរាបិទវគ្គបណ្តុះបណ្តាលស្តីពី៖ ការអប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្ស នៃសាលាបឋមសិក្សាក្របីរៀល សម្រាប់ឆ្នាំ២០២៣នេះ

ផ្សាយនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

បន្ទាប់ពីបានចាប់ផ្តើមកម្មវិធីសិក្សា អស់រយៈពេល១១ខែកន្លងមក នៅព្រឹកថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ នាបរិវេណសាលាបឋមសិក្សាក្របី ក្រុងសៀមរាប អាជ្ញាធរជាតិអប្សរា បានប្រារព្ធពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពី៖ ការអប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្ស ថ្នាក់ទី៥ និងទី៦ ចំនួន៤០០នាក់ នៃសាលាបឋមសិក្សា ក្របីរៀល សម្រាប់ឆ្នាំសិក្សា២០២៣នេះ។អញ្ជើញចូលរួមក្នុងឱកាសនោះ មាន **ឯកឧត្តម ឡុង កុសល** អគ្គនាយករង អាជ្ញាធរជាតិអប្សរា លោកអ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ និងជាសមាជិកក្រុមការងារអប់រំបេតិកភណ្ឌ លោកអ៊ុន មណីនីតា ប្រធានអង្គការមរតកវប្បធម៌ខ្មែរ លោកនាយកសាលា លោកគ្រូ អ្នកគ្រូ និងតំណាងអាជ្ញាធរមូលដ្ឋានជាច្រើនរូប។

**ឯកឧត្តម ឡុង កុសល** អគ្គនាយករងអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ ក្នុងឱកាសសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស ចំនួន៤០០នាក់ ដែលបានបញ្ចប់កម្មវិធីសិក្សាអប់រំបេតិកភណ្ឌថា កិច្ចខិតខំប្រឹងប្រែងរៀនសូត្រ មិនថាកម្មវិធីរបស់សាលារៀន ឬកម្មវិធីអប់រំអំពីបេតិកភណ្ឌ ផ្សារភ្ជាប់ការទំនាក់ទំនង និងភាពស្មោះត្រង់ គឺជាស្ពាននៃការកសាងអនាគតដ៏ប្រសើរក្នុងថ្ងៃខាងមុខរបស់ក្មួយៗទាំងអស់គ្នា ដើម្បីក្លាយទៅជាធនធានមនុស្ស ជាអ្នកបន្តវេន មរតកវប្បធម៌ដែលបុព្វបុរសបានបន្សល់ទុក។ ឯកឧត្តមបន្តថា អ្វីៗដែលអាជ្ញាធរជាតិអប្សរាបានបំពេញក្នុងពេលនេះ គ្រាន់តែជាការចូលរួមមួយផ្នែកប៉ុណ្ណោះ ដើម្បីជំរុញឱ្យក្មួយៗទទួលបានចំណេះដឹង អំពីការចូលរួមការពារ ថែរក្សា និងអភិរក្ស សម្បត្តិបេតិកភណ្ឌរបស់ជាតិ។

លោក ផយ សារូ នាយកសាលាបឋមសិក្សាក្របីរៀល បានឱ្យដឹងថា ក្នុងរយៈពេល១១ខែ នៃការបង្រៀនកម្មវិធីអប់រំបេតិកភណ្ឌ និងកម្មវិធីចុះកម្មសិក្សា របស់ក្មួយៗសិស្សានុសិស្ស ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះទាំងនេះជាមូលដ្ឋានគ្រឹះដ៏ល្អប្រសើរ សម្រាប់ពួកគាត់ស្វែងយល់ក្នុងពេលអនាគត ក្នុងនាមជាអ្នកបន្តវេនប្រពៃណី មរតកវប្បធម៌ខ្មែរ។ លោកបានថ្លែងអំណរគុណដល់ អាជ្ញាធរជាតិអប្សរា អង្គការមរតកវប្បធម៌ខ្មែរ រួមទាំងអាជ្ញាធរពាក់ព័ន្ធ ដែលបានគាំទ្រក្នុងដំណើរការបង្រៀនកម្មវិធីអប់រំបេតិកភណ្ឌនេះ តាំងពីចាប់ផ្ដើម រហូតដល់បិទបញ្ចប់វគ្គបណ្ដុះបណ្ដាល។

សូមជម្រាបថា កម្មវិធីអប់រំបេតិកភណ្ឌ ពិតមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលរស់នៅក្នុងតំបន់បេតិកភណ្ឌ ជាពិសេសសម្រាប់យុវជនជំនាន់ក្រោយ បានយល់ដឹងអំពីតម្លៃបេតិកភណ្ឌ និងផ្ដល់ឱកាសដល់យុវជន បានយល់ដឹងនូវតម្លៃមរតកវប្បធម៌ បេតិកភណ្ឌ បណ្ដុះគំនិតជាមួយនឹងបេតិកភណ្ឌ ឱ្យពួកគាត់ចេះស្រឡាញ់ និងចូលរួមថែរក្សាការពារ យល់ដឹងពីភារកិច្ច នៃការការពារ អភិរក្ស និងការងារគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា និងធ្វើជាគម្រូដល់សហគមន៍របស់ខ្លួន៕

# មន្ត្រីក្រសួងការបរទេសសាធារណរដ្ឋបារាំង ដឹកនាំដោយលោកស្រី Francine D’ORGEVAL និងលោក Stéphane BERN បានចុះពិនិត្យការងារដំណើរការកិច្ចការអភិរក្សប្រាសាទ នៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

# អបអរសាទរ ខួបលើកទី៧០ ទិវាបុណ្យឯករាជ្យជាតិ
# ៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៣

ផ្សាយនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

# ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធវីរៈយុទ្ធជន និងរំលឹកខួបលើកទី៧០ ទិវាបុណ្យឯករាជ្យជាតិ

ផ្សាយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី៩ វិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម គឹម សុធិន** អគ្គនាយករង តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា បានចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធវីរៈយុទ្ធជន យុទ្ធនារី និងរំលឹកខួបអនុស្សាវរីយ៍លើកទី៧០ ទិវាបុណ្យឯករាជ្យជាតិ និងថ្ងៃបង្កើតកងយោធពលខេមរភូមិន្ទ ៩ វិច្ឆិកា ១៩៥៣- ៩ វិច្ឆិកា ២០២៣ នៅវិមានរំលឹកគុណអតីតវីរៈយុទ្ធជន ខេត្តសៀមរាប។

ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា គឺជាការរំលឹកដល់ពលរដ្ឋកម្ពុជា ជាពិសេសយុវជនយុវនារីជំនាន់ក្រោយ ឱ្យបានយល់ដឹងអំពីព្រះរាជបេសកកម្មដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែររបស់**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបិតាឯករាជ្យជាតិ ព្រះបរមរតនកោដ្ឋ** ដែលព្រះអង្គបានលះបង់ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងក្លៀវក្លាបំផុត តស៊ូរំដោះជាតិទាមទារឯករាជ្យពីនឹមអាណានិគមនិយមបារាំង ដោយជោគជ័យទាំងស្រុង នៅថ្ងៃទី ៩ វិច្ឆិកា ឆ្នាំ ១៩៥៣៕

# រួតបាកាណជាកន្លែងដែលគេជឿថា មានបារមីសក្តិសិទ្ធិ ដែលអ្នកទេសចរគ្រប់ជាតិសាសន៍ឡើងទៅទស្សនា និងគោរពបូជា

ផ្សាយនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

រួតបាកាណ ឬកំពូលកណ្តាលនៃប្រាសាទអង្គរវត្តដែលមានកម្ពស់ប្រមាណ៦៥ម៉ែត្រ គឺជាគោលដៅដ៏សំខាន់បំផុតរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលតែងតែឡើងទៅទស្សនា។

ជារៀងរាល់ថ្ងៃមន្ត្រីអាជ្ញាធរជាតិអប្សរា បានរៀបចំសណ្តាប់ធ្នាប់ និងសុវត្ថិភាពជាប្រចាំសម្រាប់ភ្ញៀវទេសចរដែលឡើងទៅទស្សនាផង និងថ្វាយគ្រឿងសក្ការៈបូជាផងនៅលើរួតបាកាណនៃប្រាសាទអង្គរវត្តនេះ។

ប្រធានគ្រប់គ្រងភ្នាក់ងារទេសចរណ៍ នៃអាជ្ញាធរជាតិអប្សរាប្រចាំការប្រាសាទអង្គរវត្ត លោក ឡេក គិមលីន មានប្រសាសន៍ថា ដើម្បីសុវត្ថិភាពរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ អាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់ខ្ពស់បំផុតសម្រាប់ភ្ញៀវដែលឡើងទៅទស្សនារួតបាកាណ។ ការឡើងលើរួតបាកាណនេះ គឺមានបញ្ញត្តិមួយចំនួនដូចជា ទី១ ការឡើងទៅលើកំពូលប្រាសាទ គឺមិនឱ្យលើសពី ១០០នាក់ទេក្នុងពេលទស្សនាម្តងៗ ដើម្បីបង្ការពីសុវត្ថិភាពរបស់ភ្ញៀវ និងដើម្បីការពារប្រាសាទ។ ទី២ តម្រូវឱ្យភ្ញៀវទេសចរទាំងឡាយគោរពទៅតាម(ក្រមប្រតិបត្តិអង្គរ)មិនស្លៀកពាក់ខ្លីមិនសមរម្យ ត្រូវរក្សាភាពស្ងៀមស្ងាត់ និងសណ្តាប់ធ្នាប់ក្នុងកំឡុងពេលទស្សនា ហើយរយៈពេលទស្សនាទៀតសោត គឺមិនលើសពី១៥នាទីឡើយ។ ទី៣ ហាមក្មេងដែលមានអាយុក្រោម១២ឆ្នាំ ស្ត្រីមានផ្ទៃពោះ និងអ្នកដែលមានជំងឺខ្សោយបេះដូងឡើងទៅលើរួតបាកាណ ពីព្រោះតែជណ្តើរមានរាងចោតខ្លាំង៕

## ប្រាសាទតាសោម

ផ្សាយនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣

# កម្មវិធីអប់រំបេតិកភណ្ឌកុមារក្មេងតំបន់អង្គរ ចុះទស្សនកិច្ចសិក្សានៅក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣

នាព្រឹកថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ កម្មវិធីអប់រំបេតិកភណ្ឌ ក្រោមកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា និងអង្គការមរតកវប្បធម៌ខ្មែរ បានដឹកនាំសិស្សានុសិស្សចំនួន១៨៥នាក់ រួមមានថ្នាក់ទី៥ និងទី៦នៃសាលាបឋមសិក្សាក្របីរៀល ចុះទស្សនកិច្ចសិក្សានៅប្រាសាទបាយ័ន ដែលស្ថិតនៅក្នុងអតីតរាជធានីអង្គរធំសម័យអង្គរ ដើម្បីឱ្យកុមារដែលរស់នៅក្បែររមណីយដ្ឋានអង្គរ បានសិក្សាស្វែងយល់ពីអារ្យធម៌ ការរៀបចំក្រុងអង្គរធំ រួមទាំងផាត់ពណ៌រូបភាពផ្សេងៗជាផ្នែកមួយកម្មវិធីអប់រំបំណិនជីវិត។

ជាពិសេសបង្ហាញនូវភាពជាក់ស្តែងនៃកិច្ច ការពារ ថែរក្សា អភិរក្ស ការងារគ្រប់គ្រង និងការអភិវឌ្ឍចីរភាពជាអង្វែងសម្រាប់តំបន់អង្គរ៕

**រូបភាពប្រាសាទតាព្រហ្មពីលើអាកាស**

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបសាធារណជន ពាក់ព័ន្ធនឹងការចែករំលែកក្នុងបណ្តាញផ្សព្វផ្សាយសង្គមនូវវីដេអូខ្លីថតនៅប្រាសាទអង្គរ ដែលមានរូបភាពខ្លឹមសារប៉ះពាល់វប្បធម៌ និងបេតិកភណ្ឌដ៏ថ្លៃថ្លារបស់កម្ពុជា

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរជាតិអប្សរា

APSARA

លេខ: ៤៦៩៥/២៣ អ.ប.សរណ

## សេចក្តីជូនដំណឹង

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបសាធារណជន មេត្តាជ្រាបថា ថ្មីៗនេះមានការចែករំលែកក្នុងប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមនូវវីដេអូខ្លីថតនៅប្រាសាទអង្គរវត្ត អមដោយភ្លេងនិងរូបភាពកាត់តបញ្ចូលផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ និងបេតិកភណ្ឌដ៏ថ្លៃថ្លារបស់កម្ពុជា។ អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ជូននូវករណីនេះដូចខាងក្រោម៖

១- កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ក្រុមភ្នាក់ងារទេសចរណ៍របស់អាជ្ញាធរជាតិអប្សរាបានហាមឃាត់អ្នកទេសចរបរទេសមួយចំនួន ដែលមានបំណងថតសម្លៀកបំពាក់ខ្មែរប្រនិតជាមួយនឹងសម្ភារៈមួយចំនួន។ បន្ទាប់ពីហាមមិនឱ្យប្រើប្រាស់សម្ភារៈមួយចំនួនមក ភ្នាក់ងារទេសចរណ៍ ក៏បានតាមពិនិត្យ និងបានស្នើសុំឱ្យលុបចោលរូបភាពមួយចំនួនផ្សេងៗទៀតដែលមានលក្ខណៈមិនសមស្រប។ ជាយថាហេតុ សមាជិកនៅក្នុងក្រុមនោះដែលបានប្រើប្រាស់ទូរសព្ទដៃជាឧបករណ៍ថត អាចនឹងធ្វើការលាក់កំបាំងហើយប្រើប្រាស់រូបភាពមួយចំនួន ទាំងក្នុងនិងក្រៅប្រាសាទយកមកកាត់តបញ្ចូលគ្នាទាំងសម្លេង និងរូបភាពផ្សេងៗ ដើម្បីផ្សព្វផ្សាយក្នុងគោលបំណងមិនល្អ។

២- ដោយសកម្មភាពជាវីដេអូឃ្លីប មានលក្ខណៈញុះញង់ក្នុងសង្គម អាជ្ញាធរជាតិអប្សរាបានស្នើសុំក្រុមហ៊ុនបណ្តាញសង្គម Tik Tok ទប់ស្កាត់ការបង្ហោះវីដេអូឃ្លីប ក៏ដូចជាសំណូមពរដល់សាធារណជនទាំងអស់ សូមមេត្តាកុំចូលរួមចែករំលែកបន្ត ពីព្រោះជាការគាំទ្រនូវការញុះញង់ដល់សកម្មភាពអវិជ្ជមានទាំងនោះ។ ជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរាសូមអភ័យទោសចំពោះការខ្វះខាតមួយចំនួនដែលកើតមានឡើងជាយថាហេតុ ហើយប្តេជ្ញានឹងពង្រឹងកិច្ចការងារក្នុងការថែរក្សានូវរូបភាពដ៏បវរនៃរមណីយដ្ឋានអង្គរបន្ថែមទៀត។

៣- អាជ្ញាធរជាតិអប្សរា សូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះស្មារតីចូលរួមរបស់សាធារណមតិទាំងអស់ ដែលបានរួមចំណែកជួយទប់ស្កាត់នូវករណីអវិជ្ជមាននានា ដែលកើតមានឡើងក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលជាកិច្ចជួយពង្រឹងនូវតម្លៃនៃមរតកវប្បធម៌ ដែលជាដួងព្រលឹងរបស់ជាតិ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបអំពីបញ្ហាដែលបានកើតឡើងខាងលើ។

ថ្ងៃអាទិត្យ ១៤កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

សៀមរាប ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣

**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាយ ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

# អាជ្ញាធរជាតិអប្សរាពង្រឹងស៊ុមទ្វារផ្នែកខាងលិចរបស់ប្រាសាទបាយ័ន ដើម្បីសុវត្ថិភាពភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

ក្រុមអ្នកបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងជួសជុលស៊ុមទ្វារផ្នែកខាងលិចនៃប្រាសាទបាយ័ន ដែលរងការខូចខាតជាច្រើនដោយសារតែកត្តាអាយុកាល កម្ដៅថ្ងៃសំណើម និងទឹកភ្លៀងឡើងវិញ។

មន្ត្រីបច្ចេកទេសកិច្ចការងារជួសជុល លោក ជិន សុខម៉េង មានប្រសាសន៍ថា ក្រុមអ្នកបច្ចេកទេសបានប្រមូលបំណែកថ្មភក់ ដែលទទួលរងដោយទឹកភ្លៀងហូរច្រោះបាក់បែកធ្លាក់រាយប៉ាយមកជួសជុលពង្រឹងគ្រឹះឡើងវិញ ដើម្បីកុំឱ្យដីខ្សាច់ហូរចេញ ដែលនាំឱ្យមានការស្រុតស៊ុមទ្វារទាំងសងខាង និងធ្វើឱ្យមានការរង្អៀកផ្នែកខាងលើផង។

លោក សុខម៉េង មានប្រសាសន៍ទៀតថា ការជួសជុលស៊ុមទ្វារផ្នែកខាងលិចនៃប្រាសាទបាយ័ន គឺកំពុងរៀបផ្គុំឡើងវិញទៅតាមទីតាំងដើមនៃសំណង់បុរាណ។ ការជួសជុលនេះ គឺជាការងារអាទិភាពទី១ សម្រាប់ទប់ស្កាត់កុំឱ្យដួលរលំ និងម្យ៉ាងទៀត ផ្ដោតទៅលើការថែរក្សាសុវត្ថិភាពភ្ញៀវទេសចរដែលដើរឆ្លងកាត់នៅទីនេះផង។ បន្ទាប់ពីបញ្ចប់ការជួសជុលស៊ុមទ្វារនេះ អាជ្ញាធរជាតិអប្សរានឹងបន្តធ្វើការជួសជុលជញ្ជាំង និងជើងសរសរផ្នែកខាងលិចនៃប្រាសាទបាយ័ន៕

# ខ្លោងទ្វារទន្លេអុំជាគោលដៅទស្សនាមួយដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣

ខ្លោងទ្វារខាងត្បូង ឬខ្លោងទ្វារទន្លេអុំនៃក្រុងអង្គរធំ ជាគោលដៅទេសចរណ៍មួយដ៏ទាក់ទាញសម្រាប់ទេសចរ មកទស្សនា ហើយកន្លែងនេះតែងមានភាពមមាញឹកខ្លាំង នៅពេលព្រឹក។

ប្រធានភ្នាក់ងារទេសចរណ៍ប្រចាំខ្លោងទ្វារទន្លេអុំលោក ឈឹម សុវណ្ណដេត បានលើកឡើងថា ភ្ញៀវទេសចរតែង និយមទស្សនាខ្លោងទ្វារទន្លេអុំ ឬក្រុងអង្គរធំ បន្ទាប់ពីការ ទស្សនាថ្ងៃរះនៅអង្គរវត្ត។ ទីនេះមានចំណុចពិសេសៗ មួយចំនួនដូចជា ចម្លាក់ទេវតា និងយក្សនៃរឿងរ៉ាវកូរសមុទ្រ ទឹកដោះ កសិន្ធុទឹក និងខ្លោងទ្វារដ៏ធំស្កឹមស្កៃ។ លោក សុវណ្ណដេត បញ្ជាក់ថា ភាគច្រើនភ្ញៀវទេសចរចំណាយពេល ក្នុងការ ដើរទស្សនាខ្លោងទ្វារនេះចាប់ពី១០ទៅ២០នាទី ហើយពេលខ្លះ ពួកគាត់ទៅទស្សនាប្រាសាទក្បែរៗនោះ ដូចជាប្រាសាទបាយក្អែក និងប្រាសាទបក្សីចាំក្រុង ក៏ ដូចជាការជិះទូកកម្សាន្តនៅកសិន្ធុនៅជ្រុងខាងលិច ជាដើម។

ក្រៅពីនេះ ខ្លោងទ្វារទន្លេអុំក៏ជាកន្លែងទស្សនាថ្ងៃលិចដ៏ ទាក់ទាញផងដែរ ក្រៅពីភ្នំបាខែងដែលនៅក្បែរនោះ។ ពន្លឺ ពណ៌មាសបានចាំងប៉ះលើផ្ទៃទឹកនៃកសិន្ធុអង្គរធំ ដែលជា ទិដ្ឋភាពមួយដ៏ស្រស់ត្រកាលសម្រាប់ភ្ញៀវទេសចរ។

តាមការប៉ាន់ស្មានរបស់ប្រធានភ្នាក់ងារទេសចរណ៍នៅ ទីនោះ បច្ចុប្បន្ននេះក្នុងមួយថ្ងៃមានភ្ញៀវទេសចរ ចូលទស្សនា ខ្លោងទ្វារទន្លេអុំចន្លោះពី១០០០នាក់ទៅជាង២០០០នាក់។ ដើម្បីសម្រួលដល់កិច្ចការងារនេះ លោក សុវណ្ណដេត បានបញ្ជាក់ថា ក្រុមការងារលោកក៏បានជួយសម្រួល ការ ដើរទស្សនា ពិសេសសម្រួលចរាចរណ៍បង្កាកុំឱ្យមាន គ្រោះថ្នាក់ជាយថាហេតុដល់ទេសចរផងដែរ៕

## ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិឡើងទៅទស្សនារួតបាកាណ នៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករឡើងទៅទស្សនារួតបាកាណនៃប្រាសាទអង្គរវត្ត។ ជាមួយគ្នានេះដែរ ក្រុមការងារភ្នាក់ងារទេសចរណ៍ដែលប្រចាំការនៅគោលដៅនេះ បានយកចិត្តទុកដាក់រៀបចំសណ្តាប់ធ្នាប់ និងណែនាំឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិគោរពទៅតាមក្រមប្រតិបត្តិអង្គរទាំងអស់គ្នា៕

## លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជួបពិភាក្សាទ្វេភាគីជាមួយរដ្ឋមន្ត្រីក្រសួងវប្បធម៌បារាំង

ផ្សាយនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣

ក្នុងឱកាសដ៏មមាញឹកអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៤ នៃអន្តររដ្ឋាភិបាលស្តីពីការអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត**ព្រះករុណា ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយ**លោកជំទាវ អ៊ុន ម្ញូផាន់ណា** ឯកអគ្គរាជទូតប្រតិភូអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការយូណេស្កូនៅប៉ារីស **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឲ្យលោកជំទាវ Rima ABDUL MAAK រដ្ឋមន្ត្រីក្រសួងវប្បធម៌បារាំងចូលជួបពិភាក្សាការងារមួយចំនួនលើវិស័យវប្បធម៌ និងបេតិកភណ្ឌ។

## លោក ញ៉ុក ឡូ អ្នកជួសជុលប្រាសាទបុរាណក្នុងតំបន់អង្គររយៈពេល២៥ឆ្នាំ

ផ្សាយនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣

លោក ញ៉ុក ឡូ អាយុ៤៣ឆ្នាំ ជាអ្នកភូមិស្រះស្រង់ខាងជើង សង្កាត់នគរធំ ក្រុងសៀមរាប បានចូលរួមបម្រើការងារជាអ្នកជួសជុលប្រាសាទបុរាណធ្វើពីថ្មភក់នៅក្នុងតំបន់អង្គរប្រមាណ២៥ឆ្នាំមកហើយ និងទទួលបានជំនាញ និងបទពិសោធន៍ជាច្រើនពីការបង្ហាត់បង្រៀនរបស់អ្នកជំនាញលើផ្នែកនេះ។

លោក ញ៉ុក ឡូ មានប្រសាសន៍ថា ការងារជួសជុលប្រាសាទបុរាណមិនមែនងាយស្រួលនោះឡើយ ពីព្រោះប្រាសាទខ្លះរលំបាក់ធ្វើឱ្យដុំថ្មធំៗនៅរាយប៉ាយពេញដី ដែលទាមទារឱ្យអ្នកជួសជុលប្រើកម្លាំងកាយ ការអត់ធ្មត់ខ្ពស់ ភាពប៉ិនប្រសប់ បទពិសោធន៍ ការសង្កេត និងទឹកចិត្តស្រឡាញ់ទើបអាចជួសជុល និងរៀបផ្គុំប្រាសាទឱ្យរឹងមាំឡើងវិញបាន។ លោក ញ៉ុក ឡូ ឱ្យដឹងទៀតថា ដោយសារមានការតាំងចិត្ត និងស្រឡាញ់មរតកដូនតា ចង់ឃើញប្រាសាទបុរាណបាននៅគង់វង្សយូរអង្វែងតទៅទៀត ទើបលោកសម្រេចចិត្តធ្វើការងារជាអ្នកជួសជុលប្រាសាទបុរាណតាំងពីឆ្នាំ១៩៩៨។

បន្ទាប់ពីធ្វើការជាអ្នកជួសជុលប្រាសាទបុរាណរយៈពេល២៥ឆ្នាំមក លោក ញ៉ុក ឡូ បានក្លាយជាធនធានមនុស្សមួយរូបដែលកម្រ ដោយលោកមានជំនាញស្គាល់ថ្ម ចេះមើលថ្ម មើលក្បាច់ចម្លាក់ថ្មដែលនៅរ៉ាយបាយលើដីសម្រង់ប្លង់ ព្រមទាំងអាចរើសយកថ្មទាំងនោះ មករៀបផ្គុំនៅតាមទីតាំងដើមឡើងវិញ ដើម្បីថែរក្សាបាននូវតម្លៃដើមរបស់ប្រាសាទបុរាណទៀតផង។

ថ្វីត្បិតតែលោក ញ៉ុក ឡូ ជាអ្នកជំនាញផ្នែកជួសជុលប្រាសាទបុរាណមានជំនាញស្គាល់ថ្ម ចេះមើលថ្ម មើលក្បាច់ថ្មដែលនៅរ៉ាយបាយលើដី ដែលអាចយកថ្មទាំងនោះមករៀបផ្គុំនៅតាមទីតាំងដើមឡើងវិញ ក៏ប៉ុន្តែ ការងារជួសជុល អភិរក្សលើកតម្លៃប្រាសាទបុរាណឡើងវិញបានរឹងមាំ គឺដោយមានការចូលរួមពីអ្នកជំនាញជាច្រើនផ្នែកផ្សេងទៀត ដើម្បីឱ្យការងារទាំងនោះ អាចដំណើរការទៅបានដោយជោគជ័យ៕

## លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈអញ្ជើញពិនិត្យស្ថានីយ៍គ្រប់គ្រងទឹកស្វ័យប្រវត្តិរបស់សហជីពអន្តរសង្កាត់គ្រប់គ្រងទឹកនៃជ្រលងប៊ីយ៉ែវ ប្រទេសបារាំង

ផ្សាយនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣

ថ្មីៗនេះ នាខែវិច្ឆិកា ឆ្នាំ២០២៣ នាទីស្នាក់ការសហជីពអន្តរសង្កាត់គ្រប់គ្រងទឹកនៃជ្រលងប៊ីយ៉ែវ (SIAVB) ប្រទេសបារាំង **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយ ឯកឧត្តម អគ្គនាយកអាជ្ញាធរជាតិអប្សរា ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសមួយចំនួនទៀត បានអញ្ជើញពិនិត្យ និងសម្ពោធការដំឡើងសាកល្បងស្ថានីយ៍គ្រប់គ្រងទឹកស្វ័យប្រវត្តិ ដែលសហជីពអន្តរសង្កាត់នៃជ្រលងប៊ីយ៉ែវនឹងត្រូវយកទៅដំឡើងនៅរមណីយដ្ឋានអង្គរចំនួន៦ស្ថានីយ៍។

ក្នុងឱកាសការអញ្ជើញរបស់លោកជំទាវបណ្ឌិតសភាចារ្យ នាពេលនោះ លោក Francisque Vigouroux ប្រធានសហជីពអន្តរសង្កាត់គ្រប់គ្រងទឹកនៃជ្រលងប៊ីយ៉ែវ (SIAVB) បានបង្ហាញអំពីផលប្រយោជន៍នៃស្ថានីយទាំងនេះ ព្រមទាំងប្រសិទ្ធភាពនៃស្ថានីយក្នុងការគ្រប់គ្រងទឹក។

សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា និងសហជីពអន្តរសង្កាត់ជ្រលងប៊ីយ៉ែវបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការវិមជ្ឈការនៅក្នុងគម្រោងប្រព័ន្ធជំនួយស្វ័យប្រវត្តិក្នុងការគ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរ (SDGERA) នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២៕

# អាជ្ញាធរជាតិអប្សរាបិទវគ្គបណ្តុះបណ្តាលស្តីពី៖ អប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្ស នៅវិទ្យាល័យហ៊ុនសែនប្រាសាទបាគង និងសាលាបឋមសិក្សាលលៃ

ផ្សាយនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣

បន្ទាប់ពីបានចាប់ផ្តើមកម្មវិធីសិក្សា អស់រយៈពេលជាង១០ខែកន្លងមក នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ អាជ្ញាធរជាតិអប្សរា បានបិទបញ្ចប់វគ្គបណ្តុះបណ្តាលកម្មវិធី អប់រំបេតិកភណ្ឌ សម្រាប់សិស្សានុសិស្សចំនួនជិត១០០នាក់ នៅវិទ្យាល័យហ៊ុនសែនប្រាសាទបាគង និងសាលាបឋមសិក្សាលលៃ។

អញ្ជើញចូលក្នុងពិធីនោះរួមមាន៖ លោក ភ័ណ្ឌ ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា លោក អ៊ុន មុណីនីតា នាយកអង្គការមេតេកវប្បធម៌ខ្មែរ លោកប្រេន ប្រេម នាយកវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង តំណាងអាជ្ញាធរក្នុងតំបន់ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សជាច្រើននាក់។

លោក ភ័ណ្ឌ ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ប្អូនៗ ក្មួយៗ ជាប្រជាពលរដ្ឋ ជាសិស្ស រស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ពិតជាមានសំណាង និងមោទកភាពជាខ្លាំង ដែលបានកើត និងរស់នៅក្នុងតំបន់នេះ។ ហើយទទួលបានការយកចិត្តទុកដាក់ ជាពិសេសការបណ្តុះបណ្តាល ទៅលើមុខវិជ្ជាបេតិកភណ្ឌ ដែលបានបង្រៀនឱ្យបានយល់ដឹងពីតម្លៃថែរក្សា និងអភិរក្ស សម្បត្តិបេតិកភណ្ឌជាតិ។ ព្រោះថា ប្អូនៗ និងក្មួយៗ គឺជាអ្នកដែលរស់នៅ និងបន្តវេន ថែរក្សានូវសម្បត្តិវប្បធម៌ ដែលដូនតាបានបន្សល់ទុកក្នុងពេលអនាគត។

សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការមរតកវប្បធម៌ខ្មែរ អាជ្ញាធរមូលដ្ឋាន បានរៀបចំកម្មវិធី អប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្សនៅក្នុងតំបន់រលួស មកពីវិទ្យាល័យហ៊ុនសែនប្រាសាទបាគងថ្នាក់ទី១០ និងថ្នាក់ទី១១ ចំនួន៣៥នាក់ និងបឋមសិក្សាលលៃ ថ្នាក់ទី៥ និងទី៦ ចំនួន៦៥នាក់ សរុបចំនួន ១០០នាក់។ គោលបំណង ដើម្បីបង្កើនទាំងការយល់ដឹង ពីតម្លៃសម្បត្តិបេតិកភណ្ឌ ការស្រឡាញ់មរតកវប្បធម៌ និងការចូលរួមថែរក្សា។ កម្មវិធីអប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្ស ក្រៅពីបង្រៀនទ្រឹស្តីនៅក្នុងថ្នាក់ ក៏មានកម្មសិក្សានៅតាមរមណីយដ្ឋានផ្ទាល់ ដូចជា៖ ប្រាសាទ សារមន្ទីរ កិច្ចពិធីផ្សេងៗនៅក្នុងភូមិនៃតំបន់រមណីយដ្ឋានអង្គរ និងផ្តល់ចំណេះដឹងតាមរយៈការផាត់ពណ៌ផង។



## បក្សីចាំក្រុង

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣

បក្សីចាំក្រុង ជាប្រាសាទតូចច្រឡឹងមួយ ដែលមានឃឿន ៣ថ្នាក់ សាងឡើងរវាងដើមស.វទី១០ ក្រោយពេលដែលប្រាសាទលើភ្នំបាខែងសាងរួចហើយ។ នៅម្តុំនេះមានប្រាសាទតូចៗមួយចំនួនទៀតសាងអំពីឥដ្ឋ ខ្លះបាំងបាត់ដោយរុក្ខជាតិ។ កាលជំនាន់កសាងនោះ ពុំមានសិលាចារិកអ្វីឡើយ។ លុះដល់ព្រះបាទរាជេន្ទ្រវរ្ម័ននាំរាជធានីពីកោះកេរ្តិ៍មកតាំងនៅអង្គរសារថ្មីវិញ នៅគ.ស ៩៤៨ ទើបព្រះអង្គឱ្យគេចារិកកាព្យសំស្ក្រឹតនៅលើមេទ្វារ ដូចឃើញសព្វថ្ងៃនេះ។

សេចក្តីនៃអក្សរថ្មនោះគួរជាទីចាប់អារម្មណ៍ក្រៃលែង ព្រោះមាននិទានអំពីបុព្វការីជនដំបូងបង្អស់ នៃជនជាតិខ្មែរក្នុងលំនាំជារឿងព្រេង។ ក្នុងនោះនិយាយថា ខ្មែរចុះតំណពូជពង្សមកពីឥសីមួយអង្គព្រះនាម "កម្ពុ" ដែលកើតឡើងដោយខ្លួនឯង (ស្វយម្ភូ)។ ឥសីនោះទៅកប់ប្រសប់នឹងទេពកញ្ញាឈ្មោះ "មេរា" ទើបបង្កើតជាកូនចៅតរៀងមក។ បក្សីចាំក្រុងសាងនៅលើស្ថានីយ៍បុរេប្រវត្តិមួយនៃយុគសម្រឹត។

# ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាទទួលជួបសំណេះសំណាលជាមួយអគ្គស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ**ឯកឧត្តម គីម សុធិន** អគ្គនាយករងបានជួបសំណេះសំណាល និងពិភាក្សាការងារស្តីពីការបង្កើនកិច្ចសហប្រតិបត្តិការ រវាងអគ្គស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន ក្នុងបំណងស្វែងយល់ និងបង្កើនកិច្ចសហប្រតិបត្តិការ ផ្សព្វផ្សាយលើវិស័យទេសចរណ៍កម្ពុជា៕

# នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានអញ្ជើញជួបជាមួយលោក Nicolas Fiévé នាយកសាលាបារាំងចុងបូព៌ា (EFEO) ដើម្បីពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការរវាងសាលាបារាំងចុងបូព៌ា ជាមួយប្រទេសកម្ពុជា

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន ស្តីពី លទ្ធផលនៃសន្និសីទអន្តររដ្ឋាភិបាលលើកទី៤ ស្តីពីរមណីយដ្ឋានអង្គរ-សំបូរព្រៃគុក

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣

## ប្រាសាទបាពួន

ផ្សាយនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣

# នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានអញ្ជើញជួបជាមួយលោកស្រី Yannick Lintz ប្រធានសារមន្ទីរជាតិនៃសិល្បៈអាស៊ី - Guimet នៅសារមន្ទីរ Guimet ដើម្បីពិភាក្សាកិច្ចការងារមួយចំនួន

ផ្សាយនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣

# បង្កាន់ដៃនាគ និងខឿនជណ្តើរខាងត្បូងរបស់ប្រាសាទអង្គរវត្តនឹងបញ្ចប់ការជួសជុល នៅមុនដំណាច់ខែវិច្ឆិកាខាងមុខនេះ

ផ្សាយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទនិងបុរាណវិទ្យា លោក ស៊យ សុភារិទ្ធ ឱ្យដឹងថា រយៈពេលបីខែនេះ ក្រុមការងាររបស់លោក បានខិតខំប្រឹងប្រែងជួសជុល បង្កាន់ដៃនាគ និងខឿនជណ្តើរផ្នែកខាងត្បូងរបស់ប្រាសាទអង្គរវត្តបានសម្រេចជាង៩០ភាគរយហើយ។

ដំណាក់កាលទី៣ ជួសជុលបង្កាន់ដៃនាគប្រវែង១៥ម៉ែត្រ រួមទាំងរចនាសម្ពន្ធនៃគ្រឿងបង្គុំនាគ ដើម្បីឱ្យខ្លួននាគរត់ត្រង់ស្មើគ្នាដូចដើមឡើងវិញ។ ក្នុងនោះការជួសជុលតួខ្លួននាគ និងក្បាលនាគសម្រេចបានប្រវែងសរុប១៨ម៉ែត្រ។

លោក សុភារិទ្ធ បន្តថា ក្រុមការងារបានជួសជុលពង្រឹងគ្រឹះខឿនជណ្តើរ និងបង្កាន់ដៃនាគដោយបែងចែកជា៣ដំណាក់កាល គឺដំណាក់កាលទី១ ជួសជុលពង្រឹងខឿនជណ្តើរដែលស្រុត ដោយរៀបថ្មខឿន ទាំងឡាយដែលក្រៀកហែកឱ្យត្រូវតាមលំនាំដើម និងស្តារប្រព័ន្ធរំដោះទឹកបុរាណឡើងវិញ។ ដំណាក់កាលទី២ គឺជួសជុលក្បាលនាគដែលមិនមានលំនឹងឱ្យឈររឹងមាំឡើងវិញ ដោយថែមថ្មថ្មីជំនួសខ្លួននាគដែលបាត់បង់ផង។

លោក ស៊យ សុភារិទ្ធ បញ្ជាក់ថា ការងារជួសជុលបង្កាន់ដៃនាគ និងខឿនជណ្តើរខាងត្បូងនៃប្រាសាទអង្គរវត្តនេះ បានចាប់ផ្តើមជួសជុលតាំងតែពីពាក់កណ្តាលខែកក្កដា។ចំណែកការងារមួយចំនួនទៀត ដែលនៅសេសសល់មានដូចជាការដាប់រំលីងថ្មតួខ្លួននាគថ្មី ការបុកបង្ហាប់ដីនៅតាមជើងទ្រខាងក្រោមនៃទ្រនាប់ជើងនាគ ការពារការហូរច្រោះទឹក និងការបញ្ចៀសការខូចខាតជាបន្តទៀតហើយគ្រោងនឹងបញ្ចប់នៅមុនដំណាច់ខែវិច្ឆិកា ឆ្នាំ២០២៣ខាងមុខនេះ។

# អាជ្ញាធរជាតិអប្សរា សហការជាមួយវិស័យឯកជន បន្តដាំស្មៅ និងកូនឈើ នៅបរិវេណជុំវិញប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ អាជ្ញាធរជាតិអប្សរា សហការជាមួយក្រុមហ៊ុន ហាយលែន គ្រុប ( HIGHLAND GROUP ) ដែលមានអ្នកចូលរួមសរុបជិត៥០នាក់  បានដាំកូនឈើចម្រុះចំនួន៣៤០ដើម និងដាំស្មៅចំនួន៥០០ម៉ែត្រការ៉េ នៅបរិវេណកសិន្ធុខាងត្បូងប្រាសាទអង្គរវត្ត ទុកជាអនុស្សាវរីយ៍នៃការងចងចាំក្នុងការចូលរួមបង្កើតទេសភាពបៃតង និងលើកតម្លៃរមណីយដ្ឋានអង្គរផង៕

# សូមទស្សនាសកម្មភាពភ្ញៀវទេសចរចូលទស្សនាប្រាសាទតាព្រហ្ម នាព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣

## ភ្ញៀវទេសចរដើរកម្សាន្តយ៉ាងរីករាយនៅប្រាសាទនាគព័ន្ធ នាព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ

ផ្សាយនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣

## ពិព័រណ៍ស្តីពី "វត្ថុបុរាណសិតពីលោហៈមកពីប្រាសាទមេបុណ្យខាងលិច"

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ បានរៀបចំពិព័រណ៍មិនអចិន្ត្រៃយ៍នៅសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ រយៈពេលខ្លី ចាប់ពីថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ២០២៣នេះ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីតាំងបង្ហាញវត្ថុបុរាណចំនួន១៨ ដែលសិតពីលោហៈ មាន សំរឹទ្ធិ ទង់ដែង និងដែក ព្រមទាំងកុលាលភាជន៍មួយប្រភេទ ជាផ្នាំងដី ដែលមានរូបព្រះពុទ្ធបដិមាសិតពីក្រមួននៅក្នុងនោះផង មានប្រភពមកពីប្រាសាទមេបុណ្យខាងលិច។ វត្ថុសិល្បៈទាំងអស់នេះ គឺជាលទ្ធផលនៃការធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យានៅទីនោះ ក្នុងចន្លោះឆ្នាំ២០១២ ដល់ឆ្នាំ២០១៨។ បន្ទាប់ពីបានជួសជុល ថែទាំឱ្យមានសុវត្ថិភាព ទើបយកមកដាក់តាំងបង្ហាញឱ្យភ្ញៀវជាតិ អន្តរជាតិ សិស្សនិស្សិតបានស្គាល់ ព្រមទាំងផ្តល់ជាឱកាសដល់ការងារសិក្សាស្រាវជ្រាវនានាផង។

បើយោងតាមមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាបញ្ជាក់ថា វត្ថុបុរាណ ឬសមុច្ច័យចំនួន១៨នេះ ខ្លះប្រហែល ជាអាចមានអាយុកាលជំណាលគ្នានឹងប្រាសាទមេបុណ្យខាងលិច ក្នុងចន្លោះរាជព្រះបាទសូរ្យវរ្ម័នទី១ និងព្រះបាទឧទ័យាទិត្យវរ្ម័នទី២ ពោលគឺក្នុងសម័យអង្គរ។ ចំណែកភាជន៍ដែលមានរូបពុទ្ធបដិមានៅក្នុងវិញ អាចប្រហែលជាស្ថិតក្នុងសម័យក្រោយអង្គរ ឬក្រោយនោះទៀតក៏ថាបាន នេះបើផ្អែកលើប្រភេទរូបរាងនៃភាជន៍ និងបរិបទរបស់រូបបដិមា។

# អាជ្ញាធរជាតិអប្សរា ធ្វើការជួសជុលស៊ុមទ្វារប្រាសាទបក្សីចាំក្រុង

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

ចាប់តាំងពីដើមខែវិច្ឆិកា ឆ្នាំ២០២៣ អាជ្ញាធរជាតិអប្សរា បានជួសជុល ពង្រឹងស៊ុមទ្វារបញ្ឆោតទាំងបីដែលសាងសង់ពីថ្មភក់របស់ប្រាសាទបក្សីចាំក្រុង ដែលទទួលរងការខូចខាតពុកផុយដោយកត្តាផ្សេងៗ ក្នុងគោលបំណងថែរក្សាប្រាសាទបុរាណដ៏មានតម្លៃនេះឱ្យបានយូរអង្វែងបន្តទៀត។

បុគ្គលិកបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា លោក ទុយ សីហច័ន្ទ មានប្រសាសន៍ថា ដោយសារតែអាយុកាល កម្ដៅថ្ងៃ សំណើមលាមកសត្វ និងស្លែ ធ្វើឱ្យស៊ុមទ្វារទាំងបីទិសរបស់ប្រាសាទបក្សីចាំក្រុង រួមមានទិសខាងជើង ទិសខាងត្បូង និងជាពិសេសទិសខាងលិច បានរងការខូចខាតយ៉ាងខ្លាំងផ្នែកជើងខាងក្រោម៕

# អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលា ស្តីពីដំណើរការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ អង្គភាពគ្រប់គ្រងបរិស្ថាន-អង្គរនៃអាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាស្តីពីដំណើរការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ដើម្បីថែរក្សាតំបន់អង្គរ សម្បត្តិវប្បធម៌-បរិស្ថាន និងសង្គមមនុស្ស នៅស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា។

**ឯកឧត្តម សុខ លក្ខិណា** ប្រធានប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរថ្លែងថា នេះជាលើកទី៤ហើយដែលអង្គភាពគ្រប់គ្រងបរិស្ថាន-អង្គរបានរៀបចំសិក្ខាសាលានេះឡើង ក្នុងឆ្នាំ២០២៣នេះ។ ជាមួយគ្នានោះឯកឧត្តមបានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ នាយកដ្ឋាននានាដែលបានបំពេញភារកិច្ចលើការងារគ្រប់គ្រងបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរនេះ ប្រកបដោយលទ្ធផលគួរជាទីមោទន។ យ៉ាងណាមិញ ឯកឧត្តម សុខ លក្ខិណា ស្នើឱ្យនាយកដ្ឋានទាំងអស់មើលពីចំណុចខ្វះខាតរបស់ខ្លួន និងកែលម្អបំពេញចំណុចទាំងនោះ ឱ្យបានល្អប្រសើរឡើងថែមទៀត។

នៅក្នុងសិក្ខាសាលានេះដែរ ក៏មានការធ្វើបទបង្ហាញពីតំណាងនាយកដ្ឋានចំនួនពីរចូលរួម មាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក និងនាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល និងផ្សព្វផ្សាយ៕

## រូបភាពប្រចាំសប្តាហ៍÷ ប្រាសាទបន្ទាយក្រី

ផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣

# សូមអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ ចូលរួមស្តាប់បាឋកថា ក្រោមប្រធានបទស្តីអំពី រឿងខ្លះៗលើចម្លាក់ថែវខាងក្រៅបាយ័ន

ផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរា នឹងរៀបចំបាឋកថាស្តីអំពី រឿងខ្លះៗលើចម្លាក់ថែវខាងក្រៅបាយ័ន ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង៨:៣០នាទីព្រឹក នៅនាយកដ្ឋានសណ្តាប់ធ្នាប់។ បាឋកថានេះ ធ្វើឡើងដោយលោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ។



លិខិតអញ្ជើញ

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណៈជនទូទៅ មេត្តាអញ្ជើញចូលរួមស្តាប់ បាឋកថា

ក្រោមប្រធានបទ ៖ **រឿងខ្លះៗ លើចម្លាក់ថែវខាងក្រៅបាយ័ន្ត**

វាគ្មិន ៖ លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋាន ស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា

នៅថ្ងៃព្រហស្បតិ៍ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ០៨:៣០នាទី ព្រឹក
នៅ នាយកដ្ឋាន សណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា( មានទីតាំង តាមផ្លូវទៅប្រាសាទអង្គរវត្ត ច្រកចូលទល់មុខសួនរុក្ខជាតិអង្គរ ខាងឆ្វេងដៃចម្ងាយប្រហែល ១០០ម៉ែត្រ )

កំណត់សម្គាល់ ៖ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាផ្តល់ដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ/តេឡេក្រាម៖ ០១២ ៧៣៤ ៥២០ ឲ្យបាន០១ថ្ងៃមុន

## រូបភាពប្រចាំសប្ដាហ៍÷ ប្រាសាទស្រី

ផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣

# នៅក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក មានភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនានៅខេត្តសៀមរាប ជាពិសេស រមណីយដ្ឋានអង្គរ ក៏បានទាក់ទាញភ្ញៀវទេសចរ ចូលមកទស្សនាយ៉ាងច្រើនកុះករ

ផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣

# ប្រាសាទបាគួន

ផ្សាយនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣

ប្រាសាទបាគួន គឺជាប្រាសាទភ្នំតំណាងឱ្យភ្នំសុមេរុ ដែលជាទេវស្ថានរបស់ព្រះឥសូរ។ ប្រាសាទនេះមានឈ្មោះដើមហៅថា "ត្រីភូវនចូឌាមណី" ដែលក្រោយមកឈ្មោះនេះនៅសល់តែពាក្យភូវនក្លាយជាកុន ឬគួនវិញ ពាក្យកុវនមានន័យថា" អ្នកដែលគ្រប់គ្រងលើភពទាំងបី"។ នៅចំពីមុខតួរបស់ប្រាសាទបែរទៅទិសខាងកើត មានស្ពានដើរចូលប្រវែង ២០០ម៉ែត្រ x ២.៥០ម៉ែត្រ ទ្រដោយសសរមូលចំនួន ៥៤៧ដើម រៀបយ៉ាងស្មើស្ពាននេះកសាងឡើងដើម្បីជាតំណាងឱ្យផ្លូវភ្ជាប់ពីឋានមនុស្សទៅឋានសួគ៌។ នៅខាងឆ្វេងដៃស្ពាន មានស្រះមួយមានទំហំ ៣៧ម៉ែត្រx២៨ម៉ែត្រ លម្អដោយកាំជណ្តើរធ្វើអំពីថ្មភក់។

ប្រាសាទនេះជាពីរ៉ាមីតដ៏ធំមួយកំពស់៣៥ម៉ែត្រ ដែលចែកចេញបីថ្នាក់ ហើយដែលព្រះបាទឧទយាទិត្យវរ្ម័នទី២សាងឡើងនៅស.វ.ទី១១ ដើម្បីតម្កល់លិង្គមួយនៅជាន់លើបង្អស់។

អ្នកជំនាញធំៗដែលធ្លាប់បានស្រោចស្រង់ប្រាសាទនេះក្នុងលក្ខណៈជាសង្គ្រោះបន្ទាន់ក្តី ឬជួសជុលក្នុងបំណងឲ្យបានយូរអង្វែងនៅតាមទីដែលលំខ្លះក្តី សុទ្ធសឹងយល់ស្របគ្នាថាវិស្វកម្មដែលប្រើក្នុងការកសាងប្រាសាទជាលើកដំបូងមានខ្វះដោយសារគិតមិនដល់តាំងពីដើមទី។ ក្នុងប្រវត្តិនៃការជួសជុលបុរាណស្ថានអង្គរទាំងអម្បាលម៉ាន គឺប្រាសាទបាគួននេះហើយដែលទទួលការជួសជុលច្រើនលើក ហើយធំធេងវែងឆ្ងាយជាងគេ។ បើរាប់តែកម្មវិធីជួសជុលចុងក្រោយបង្អស់គឺចាប់ផ្តើមនៅទសវត្ស១៩៦០ អស់ច្រើនឆ្នាំហើយផ្អាកមួយរយៈវែង ទើបចាប់ផ្តើមបន្តមកទៀតនៅឆ្នាំ១៩៩៥អស់រយៈពេលប្រមាណ១៤ឆ្នាំទៀត។

ចម្លាក់រូបទាំងអម្បាលម៉ានជាទីត្រកាលភ្នែកពន់ពេក។ បើកុំនិយាយពីហោជាងនិងផ្តែរនានា ចម្លាក់ជាក្បាច់ក្រឡោត តែងតែបង្ហាញក្នុងស៊ុមដាច់ចេញពីគ្នាដោយមានរឿងខុសៗគ្នា។

ជួនកាលរូបនោះរំលេចឈុតណាមួយនៃទេពកថាដែលយើងស្គាល់ ខ្លះទៀតបង្ហាញពីទិដ្ឋភាពផ្សេងៗនៃការរស់នៅរាល់ថ្ងៃនៃប្រជាជនសាមញ្ញ។ ប៉ុន្តែជាញឹកញយដែរគេប្រទះឃើញរូបប្លែកៗដែលលំបាកនឹងបកស្រាយថាអ្នកឆ្លាក់ចង់បង្ហាញពីអ្វី។

ការឧទ្ទិសទៅព្រះឥសូរដែលជាន័យដើមនៃប្រាសាទនេះ គេបោះបង់ចោលជាស្ថាពរនៅស.វ.ទី១៦ ដើម្បីងាកទៅរកព្រះពុទ្ធសាសនាពេញទី។ នៅជំនាន់នោះគេរៀបចំឡើងវិញនូវថ្មជាច្រើនរាប់មិនអស់ដែលរលំធ្លាក់មកពីជាន់ទី២ នៅផ្នែកខាងលិច ឲ្យទៅជារូបព្រះពុទ្ធអង្គចូលនិព្វានប្រវែងជាង ៦០ម៉ែត្រ។ នៅសម័យនោះហើយដែលប្រាសាទបាភួនប៉ុំប្រើ្តងឡើងវិញមួយរយៈពេលជាថ្មីទៀត។ ការកែប្រែស្ថាបត្យកម្មដើមមកឲ្យបម្រើសាសនាថ្មីក្នុងកម្រិតធំធេងបែបនេះ មានតែនៅភ្នំបាខែងដែលនៅខាងត្បូងបរិវេណអង្គរធំនេះទេដែលអាចប្រៀបគ្នាបាន៕

# សេចក្តីជូនដំណឹង ស្តីពីការរៀបចំព្រឹត្តិការណ៍ "រំលឹកគុណអង្គរ" ឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៩២៩/រប.លដណ
២៣

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការរៀបចំព្រឹត្តិការណ៍ "រំលឹកគុណអង្គរ" ឆ្នាំ២០២៣**

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីចូលរួមអបអរសាទរខួប៣១ឆ្នាំនៃការចុះរមណីយដ្ឋានអង្គរ ទៅក្នុងបញ្ជីនៃសម្បត្តិបេតិកភណ្ឌពិភពលោកនាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ អាជ្ញាធរជាតិអប្សរានឹងរៀបចំប្រារព្ធពិធី **"រំលឹកគុណអង្គរ"** នៅក្នុងរមណីយដ្ឋានអង្គរ ចាប់ពីថ្ងៃទី០៧-១៦ ខែធ្នូ ឆ្នាំ២០២៣។ សម្រាប់ពិធីបើកព្រឹត្តការណ៍នេះនឹងប្រព្រឹត្តទៅនាពេលព្រឹកថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត**។

ក្នុងន័យដើម្បីឱ្យកម្មវិធីប្រព្រឹត្តទៅដោយរលូន និងជោគជ័យ អាជ្ញាធរជាតិអប្សរានឹងបិទការចូលទស្សនាស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ចាប់ពីថ្ងៃទី០៦-០៧ ខែធ្នូ ឆ្នាំ២០២៣។ ដោយឡែក ភ្ញៀវទេសចរជាតិ-អន្តរជាតិ អាចចេញ-ចូលទស្សនាប្រាសាទអង្គរវត្ត ដោយប្រើប្រាស់ស្ពានបណ្តែតទឹកបណ្តោះអាសន្ន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៣ រោចខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣
**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

# ព្រឹត្តិការណ៍ព័ត៌មាន
# ប្រចាំខែធ្នូ

# លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញជាអធិបតីក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមូលនិធិឯកអគ្គរដ្ឋទូតលើការអភិរក្សវប្បធម៌ នឹងគម្រោងជួសជុលប្រាសាទភ្នំបាខែងរវាងស្ថានទូតអាមេរិកប្រចាំកម្ពុជា និងអង្គការ World Monument Fund

ផ្សាយនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣

**លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញជាអធិបតីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងមូលនិធិឯកអគ្គរដ្ឋទូតដើម្បីការអភិរក្សវប្បធម៌លើគម្រោងជំនួយសម្រាប់ជួសជុលប្រាសាទភ្នំបាខែង រវាងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា លោក Patrick W. Murphy និងលោកស្រី Genovra Boatto តំណាងអង្គការ World Monument Fund នៅថ្ងៃទី១ ខែធ្នូឆ្នាំ២០២៣។

**លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** មានប្រសាសន៍ថា សហរដ្ឋអាមេរិកមិនត្រឹមតែផ្តល់ជំនួយសម្រាប់ជួសជុលប្រាសាទភ្នំបាខែង និងប្រាសាទដទៃទៀតក្នុងរមណីយដ្ឋានអង្គរប៉ុណ្ណោះទេ គឺកន្លងមក អាមេរិកក៏បានជួយជាច្រើនដូចជា គម្រោងជួសជុលជណ្តើរខាងជើងរបស់ប្រាសាទព្រះវិហារ ព្រមទាំងបានបញ្ជូនវត្ថុសិល្បៈបុរាណរបស់ខ្មែរមួយចំនួនឱ្យវិលត្រឡប់មកមាតុភូមិវិញផង។ **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** មានប្រសាសន៍ទៀតថា កិច្ចសហប្រតិបត្តិការនៃជំនួយរបស់អាមេរិកនេះ បានផ្តល់នូវផលប្រយោជន៍យ៉ាងខ្លាំងរវាងប្រទេសទាំងពីរលើវិស័យវប្បធម៌ និងជាពិសេស មិនត្រឹមតែបានជួយជ្រោមជ្រែងលើការជួសជុលប្រាង្គប្រាសាទទេ តែថែមទាំងបានជួយសម្របសម្រួលក្នុងការនាំយកមកវិញនូវវត្ថុសិល្បៈដែលកម្ពុជាបានបាត់បង់ជាយូរឆ្នាំកន្លងមកផងដែរ។

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា លោក Patrick W. Murphy មានប្រសាសន៍ថា មូលនិធិឯកអគ្គរដ្ឋទូតលើការអភិរក្សវប្បធម៌ និងគម្រោងជួសជុលប្រាសាទភ្នំបាខែង ដែលបានចុះកិច្ចព្រមព្រៀងនាពេលនេះ គឺជាគម្រោងមួយប្រកបដោយលទ្ធផលល្អប្រសើរនាពេលកន្លងមក និងសូមថ្លែងអំណរគុណដល់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរជាតិអប្សរា ដែលបានជួយជ្រោមជ្រែងដល់កិច្ចសហប្រតិបត្តិការ ជំរុញឱ្យគម្រោងនេះ ដំណើរការមានប្រសិទ្ធិភាពខ្ពស់ ហើយមានលទ្ធផលជាផ្លែផ្កាគួរឱ្យជាទីមោទន។ ការជួយជំរុញបន្តលើគម្រោងនេះ គឺជាការបង្ហាញការយកចិត្តទុកដាក់បន្ថែមទៀតរបស់រដ្ឋាភិបាលអាមេរិក ក៏ដូចជាប្រជាជនអាមេរិកមកលើការងារអភិរក្សសម្បត្តិបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក។

ប្រាសាទភ្នំបាខែងកសាងឡើងតាំងពីឆ្នាំ៩០៧នៃគ្រឹស្តសករាជ ក្នុងរាជកាលព្រះបាទយសោវរ្ម័នទី១ ស្ថិតនៅចំពីលើកំពូលភ្នំធម្មជាតិមួយដែលមានទីតាំងនៅចំកណ្តាលទីក្រុងយសោធរបុរៈហើយស្ថិតនៅចន្លោះប្រាសាទអង្គរវត្ត និងក្រុងអង្គរធំ ដែលបច្ចុប្បន្នប្រាសាទនេះ កំពុងទាក់ទាញភ្ញៀវទេសចរចម្រុះជាតិសាសន៍យ៉ាងខ្លាំងឱ្យឡើងទៅទស្សនាទេសភាពពេលថ្ងៃរៀបលិចព្រមទាំងជាកន្លែងដ៏ពេញនិយមសម្រាប់ប្រជាពលរដ្ឋឡើងទៅហាត់ប្រាណជារៀងរាល់៕

## ប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៣

# ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ «ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា ២ធ្នូ ១៩៧៨-២ធ្នូ ២០២៣»

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម គឹម សុធិន អគ្គនាយករង** តំណាង**ឯកឧត្តម ហង់ ពៅ អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា** រួមទាំងប្រធាន និងអនុប្រធាននាយកដ្ឋាន មន្ត្រី បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា អញ្ជើញចូលរួមពិធីមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ «ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា ២ធ្នូ ១៩៧៨-២ធ្នូ ២០២៣» នាបរិវេណមន្ទីរគណបក្សប្រជាជនកម្ពុជាខេត្តសៀមរាប។

## ទិដ្ឋភាពប្រាសាទប្រែរូបពីលើអាកាស

ផ្សាយនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣

## ព្រឹត្តិការណ៍រំលឹកគុណអង្គរ ឆ្នាំ២០២៣នេះ មានប្រារព្ធពិធីបែបប្រពៃណីសាសនា ការសម្តែងទស្សនីយភាពសិល្បៈជាច្រើនទម្រង់ សម្រាប់សាធារណៈទស្សនា និងសិក្សាស្វែងយល់

ផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣

**ឯកឧត្តម ឡុង កុសល** អគ្គនាយករងអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ថា ពិធីរំលឹកគុណអង្គរ នឹងរៀបចំឡើងរយៈពេល១០ថ្ងៃ ដោយចាប់ពីថ្ងៃទី០៧ ដល់ទី១៦ ខែធ្នូ ឆ្នាំ២០២៣ ដែលមានប្រារព្ធកម្មវិធីសាសនា ស្តង់ពិព័រណ៌ និងការសម្តែងសិល្បៈបុរាណនៅពេលរាត្រី។

ពិធីនឹងចាប់ផ្តើមបើកជាផ្លូវការ នៅព្រឹកថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ដោយមានពិធីបួងសួងព្រឹត្តិការណ៍រំលឹកគុណអង្គរ នៅបរិវេណមុខប្រាសាទអង្គរវត្ត នឹងប្រព្រឹត្តទៅក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ថ្នាក់ដឹកនាំខេត្តសៀមរាប ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា តំណាងអង្គការដៃគូ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ភ្ញៀវទេសចរជាតិ និងភ្ញៀវអន្តរជាតិ។ នៅព្រឹកថ្ងៃនោះដែរបន្ទាប់ពីកម្មវិធីបួងសួង ក៏មានពិធីរាប់បាតព្រះសង្ឃផងដែរ។

**ឯកឧត្តម ឡុង កុសល** បានឱ្យដឹងទៀតថា នៅថ្ងៃបន្តបន្ទាប់ក៏មាននូវទស្សនីយភាពជាច្រើនដូចជា៖ កម្មវិធីបែបសាសនាសំខាន់ៗ ការតាំងពិព័រណ៌បង្ហាញសមិទ្ធផលការងាររយៈពេល៣១ឆ្នាំកន្លងមករបស់អាជ្ញាធរជាតិអប្សរា ស្នាដៃសិល្បៈជាច្រើនដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌអរូបីនៃអង្គការយូណេស្កូ និងក្បួនព្យុះហយាត្រារបស់សិស្សានុសិស្សចំនួនជាង១,២៥០នាក់ ក្រោមពាក្យស្លោកអរគុណអង្គរ និងអរគុណសន្តិភាព ការសម្តែងសិល្បៈល្ខោនយីកេ ការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំជាដើម។ រាល់កម្មវិធីសាសនា សិល្បៈទស្សនីយភាពទាំងអស់ នឹងបើកជាសាធារណៈចូលទស្សនាដោយពុំមានបង់ប្រាក់នោះទេ។ អាស្រ័យដូចនេះ សូមបងប្អូនសាធារណជនអញ្ជើញចូលរួមឲ្យបានច្រើនកុះករ។

សូមជម្រាបដែរថា នេះជាឆ្នាំទីបីហើយ ដែលអាជ្ញាធរជាតិអប្សរាបានរៀបព្រឹត្តិការណ៍រំលឹកគុណអង្គរនេះ។ព្រឹត្តិការណ៍នេះ រៀបចំឡើងក្នុងគោលបំណងដើម្បីរំលឹកគុណអង្គព្រះមហាក្សត្រគ្រប់ព្រះអង្គ និងបុព្វការីជនដែលលោកបានកសាង និងថែរក្សាប្រាសាទទាំងអស់នៅក្នុងរមណីយដ្ឋានអង្គរ ដោយបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ជាតិមាតុភូមិតាំងពីដើមរហូតដល់សព្វថ្ងៃ៕

រូបភាពឯកសារ

# អាជ្ញាធរជាតិអប្សរា ជួបពិភាក្សាការងារជាមួយសាកលវិទ្យាល័យសូហ្វីយ៉ា ដើម្បីបន្តកិច្ចការងារអភិរក្សក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣

កាលពីរសៀលថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យបណ្ឌិត Yoshiaki ISHIZAWA ប្រធានមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្ស នៃសាកលវិទ្យាល័យសូហ្វីយ៉ា និងលោកបណ្ឌិត Yoshiaki TERUMICHI សាកលវិទ្យាធិការ នៃសាកវិទ្យាល័យសូហ្វីយ៉ា ដើម្បីជួបនិងស្គាល់គ្នារវាងអាជ្ញាធរជាតិអប្សរានិងលោកបណ្ឌិតសាកលវិទ្យាធិការ និងបន្តនូវស្មារតីនៃកិច្ចសហប្រតិបត្តិការក្នុងការសហការរវាងគ្នានៃស្ថាប័នទាំងពីរទៅថ្ងៃអនាគត រួមទាំងបណ្តុះបណ្តាលធនធានមនុស្សរួមគ្នា ជាពិសេសធ្វើយ៉ាងណាជំរុញនូវការបណ្តុះបណ្តាលរបស់អ្នកជំនាញជាតិឱ្យបានច្រើន។

ក្នុងជំនួបនោះដែរ **ឯកឧត្តម ហង់ ពៅ** បានថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យបណ្ឌិត Yoshiaki ISHIZAWA ដែលបានខិតខំជួយជ្រោមជ្រែងលើការងារអភិរក្សអង្គរតាំងពីទសវត្សរ៍៨០មក ហើយកិច្ចការទាំងអស់នេះអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា បានសហការគ្នាបានយ៉ាងល្អប្រសើរ និងបានសម្រេចលើការជួសជុលស្ពានហាលនៃប្រាសាទអង្គរវត្ត បានរួចរាល់ទាំងស្រុង និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

លើសពីនេះ **ឯកឧត្តម ហង់ ពៅ** បានកោតសរសើរ និងសម្តែងការអរគុណជាពន្លឹកចំពោះលោកសាស្ត្រាចារ្យបណ្ឌិត Yoshiaki ISHIZAWA។ បើទោះបីជាលោកមានវ័យចំណាស់យ៉ាងណាក៏ដោយ ក៏ស្មារតីនៃការស្រលាញ់វប្បធម៌ខ្មែរ និងអង្គរមិនថមថយ និងបានឯកភាពរួមគ្នាជាមួយនិងលោកបណ្ឌិតសាកលវិទ្យាធិការបន្តបំពេញនូវកិច្ចការសហការឲ្យកាន់តែល្អប្រសើរថែមទៀត៕

# អាជ្ញាធរជាតិអប្សរារៀបចំពិធីបួងសួង និងរាប់បាត្រ បើកព្រឹត្តិការណ៍រំលឹកគុណអង្គរឆ្នាំទី៣

ផ្សាយនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ អាជ្ញាធរជាតិអប្សរា បានរៀបចំពិធីបួងសួងសុំសេចក្តីសុខ និងរាប់បាត្រព្រះសង្ឃ ១៣១អង្គ បើកព្រឹត្តិការណ៍រំលឹកគុណអង្គរឆ្នាំទី៣។

មានវត្តមានក្នុងពិធីខាងលើនេះរួមមាន **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អភិបាលខេត្តសៀមរាប ព្រះសង្ឃ ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកអាជ្ញាធរជាតិអប្សរាជាច្រើនរយនាក់។

**លោកជំទាវ ភឿង សកុណា** មានប្រសាសន៍ថា ព្រឹត្តិការណ៍រំលឹកគុណអង្គរធ្វើឡើងក្នុងគោលបំណងពីរសំខាន់ៗ ពោលគឺដើម្បីអបអរសាទរខួប៣១ឆ្នាំនៃការចុះរមណីយដ្ឋានអង្គរទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ ក៏ដូចជារំលឹកនឹកគុណដល់បុព្វការីជន ព្រះមហាក្សត្រជំនាន់មុនគ្រប់ព្រះអង្គ ដែលបានកសាងប្រាង្គប្រាសាទនានា បន្សល់ទុកនូវសម្បត្តិ បេតិកភណ្ឌសិល្បៈ និងវប្បធម៌ជាច្រើន បម្រើនូវគុណប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជូនអ្នកជំនាន់នេះ និងទៅអនាគត។ ពិធីនេះក៏ឧទ្ទិសផងដែរចំពោះបុព្វបុរសខ្មែរ ឥស្សរជនខ្មែរគ្រប់ជំនាន់ អ្នកជំនាញការជាតិ អន្តរជាតិ ដែលបានលះបង់កម្លាំងកាយកម្លាំងចិត្ត រហូតដល់អាយុជីវិតដើម្បីរក្សាការពារ និងអភិរក្សមរតកវប្បធម៌ជាតិយើង។

នាឱកាសនោះដែរ **លោកជំទាវ ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ក៏បានរំលេចនូវគុណូបការៈរបស់បុព្វបុរសសម័យដើម ដែលបានកសាងនូវប្រាង្គប្រាសាទ កសាងប្រវត្តិសាស្ត្រជាដើម ស្របតាមពាក្យស្លោកខ្មែរដែលតែងពោលថា ផឹកទឹកឱ្យនឹកដល់ប្រភព។ លោកជំទាវបន្ថែមថា ព្រឹត្តិការណ៍រំលឹកគុណអង្គរនេះ គឺជាការបង្ហាញនូវមោទនភាពជាតិ អរិយធម៌ វប្បធម៌ និងប្រវត្តិសាស្ត្រដ៏សែនយូរលង់របស់ជាតិសាសនាខ្មែរដ៏ចំណាស់មួយ។

ពិធីនេះបានរួមចំណែកដល់ការផ្សព្វផ្សាយបន្ថែមនូវសក្តានុពលវប្បធម៌ និងទេសចរណ៍កម្ពុជា ដែលអ្នកទេសចរអាចបន្តមើលឃើញសក្ខីកម្ម ស្នាដៃដ៏អស្ចារ្យរបស់បុព្វបុរសខ្មែរប្រកបដោយទេពកោសល្យខ្ពស់៕

## កិច្ចប្រជុំលើកទី១ របស់ក្រុមអភិបាលកិច្ច «គម្រោងគ្រប់គ្រងទឹកក្នុងរមណីយដ្ឋានអង្គរដោយប្រសិទ្ធភាព និងចីរភាព ដើម្បីភាពធន់ និងការប្រែប្រួលអាកាសធាតុ និងសង្គម-សេដ្ឋកិច្ច» ដែលជាជំនួយរបស់ប្រទេសនូវែលសេឡង់

ផ្សាយនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

នារសៀលថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ក្រុមអភិបាលកិច្ចនៃគម្រោងគ្រប់គ្រងទឹកក្នុងរមណីយដ្ឋានអង្គរដោយប្រសិទ្ធភាព និងចីរភាព ដើម្បីភាពធន់ និងការប្រែប្រួលអាកាសធាតុ និងសង្គម-សេដ្ឋកិច្ច បានបើកដំណើរការកិច្ចប្រជុំលើកទី១ ដោយមានការចូលរួមពីសំណាក់ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** តំណាងអាជ្ញាធរជាតិអប្សរា លោក Matthew Allen តំណាងក្រសួងការបរទេស និងពាណិជ្ជកម្មក្រៅប្រទេសរបស់នូវែលសេឡង់ និងលោក Christian Nielsen តំណាងអង្គការ Live & Learn ក្នុងគោលបំណងពិនិត្យពិភាក្សាលើ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងដំណើរការគម្រោង ដើម្បីឱ្យការអនុវត្តប្រព្រឹត្តទៅទាន់ពេលវេលាដោយរលូន មានប្រសិទ្ធភាព និងប្រសិទ្ធិផលខ្ពស់។



# ប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៣

# ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាប្រាសាទអង្គរ និងស្តង់ពិព័រណ៍របស់អាជ្ញាធរជាតិ

ផ្សាយនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៣

នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៣នេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ បានចូលមកទស្សនាប្រាសាទអង្គរវត្ត និងស្តង់ពិព័រណ៍ស្តីពី៖ សមិទ្ធផលការងាររយៈពេល៣១ឆ្នាំ របស់អាជ្ញាធរជាតិអប្សរា និងស្តង់ពិព័រណ៍ផ្សេងៗទៀត នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ក្នុងការណ៍រំលឹកគុណអង្គរ។

សូមបញ្ជាក់ថាព្រឹត្តិការណ៍រំលឹកគុណអង្គរឆ្នាំ២០២៣នេះ ត្រូវបានប្រារព្ធឡើងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី០៧ រហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣៕

# ទិដ្ឋភាពប្រាសាទភ្នំបាខែងពីលើអាកាស

ផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣

# សិស្សានុសិស្ស១២៥០នាក់ ហែក្បួនព្យុហយាត្រា ក្នុងព្រឹត្តិការណ៍"រំលឹកគុណអង្គរ"

ផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា រួមជាមួយសិស្សានុសិស្សសរុប១២៥០នាក់ បានធ្វើព្យុហយាត្រាដង្ហែក្បួនជាលើកទី២ ក្នុងព្រឹត្តិការណ៍"រំលឹកគុណអង្គរ"ចាប់ផ្តើមចេញពីមុខប្រាសាទអង្គរ ឆ្ពោះទៅខ្លោងទ្វារទន្លេអុំនៃក្រុងអង្គរធំ និងឆ្ពោះទៅក្រុងសៀមរាប។ ព្យុហយាត្រានេះ ដើម្បីផ្សព្វផ្សាយឱ្យសាធារណជន ក៏ដូចជាប្រជាពលរដ្ឋខ្មែរ ភ្ញៀវទេសចរជាតិ អន្តរជាតិ មានការរំលឹកគុណដល់ប្រាសាទអង្គរ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកមិនអាចកាត់ថ្លៃបាន ដែលបុព្វបុរសខ្មែរបានបន្សល់ទុកឱ្យកូនខ្មែរជំនាន់ក្រោយ។

**ឯកឧត្តម ឡុង កុសល** អគ្គនាយករង និងជាអ្នកនាំពាក្យនៃអាជ្ញាធរជាតិអប្សរា តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយក មានប្រសាសន៍ក្នុងកម្មវិធីដង្ហែក្បួនព្យុហយាត្រាដលម្បីអបអរសាទរពិធីបុណ្យរំលឹកគុណអង្គរដ៏មានសារសំខាន់ សម្តែងចំណាប់អារម្មណ៍ចំពោះពាក្យស្លោកដែលមានអត្ថន័យថា កិច្ចការពារបេតិកភណ្ឌជាភារកិច្ចកូនខ្មែរគ្រប់ៗរូប និងអត្ថន័យនៃចម្រៀងពង្សាវតារខ្មែរដែលមានអត្ថន័យឧត្តុង្គឧត្តម ដក់ជាប់នៅក្នុងក្រអៅបេះដូងប្រជាជនខ្មែរ។ ជាពិសេស សិស្សានុសិស្សដែលជាទំពាំងស្នងឫស្សី ជាអ្នកបន្តវេនដ៏សំខាន់ទៅអនាគតក្នុងការថែរក្សានូវតម្លៃដួងព្រលឹងជាតិ និងអត្តសញ្ញាណជាតិរបស់យើង។

**ឯកឧត្តម ឡុង កុសល** បន្តថា ការដែលយើងរំលឹក និងផ្តល់នូវគុណតម្លៃដល់បុព្វការីជនរបស់យើង គឺជាការគោរពខ្លួនយើងផង ក៏ជាការផ្តល់នូវភាពថ្កុំថ្កើងនៃប្រវត្តិសាស្ត្ររបស់យើងដែរ។ ក្នុងនាមអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ឡុង កុសល** មានសេចក្តីសោមនស្ស និងមានភាពកក់ក្តៅដែលសិស្សានុសិស្សចំនួន១២៥០នាក់ បានចូលរួមក្នុងក្បួនព្យុហយាត្រានៃពិធីបុណ្យរំលឹកគុណអង្គរ។ នេះជារូបភាពមួយយ៉ាងសំខាន់ ដែលយើងបានប្រព្រឹត្តទៅដើម្បីបណ្តុះនូវស្មារតីស្រឡាញ់ស្នេហាជាតិ ក៏ដូចជាការបណ្តុះនូវគំនិតធ្វើយ៉ាងណាដើម្បីឱ្យប្រជាជាតិខ្មែររបស់យើងមានភាពរឹងមកទៅថ្ងៃអនាគត។

សូមបញ្ជាក់ថា ព្រឹត្តិការណ៍រំលឹកគុណអង្គរ នឹងរៀបចំឡើងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣ខាងមុខ នៅក្នុងរមណីយដ្ឋានអង្គរ ដើម្បីតបស្នងសងគុណដល់បុព្វបុរស ក៏ដូចជា អតីតព្រះមហាក្សត្រខ្មែរដែលបានកសាងប្រាសាទ និងថែរក្សាទុកឱ្យកូនខ្មែរជំនាន់ក្រោយបានស្គាល់។ ជាពិសេសសន្តិភាព ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងវប្បធម៌ ក៏ដូចជាការនាំមកនូវវឌ្ឍនភាពសម្រាប់ជាតិ។ ការដែលយើងរំលឹកគុណអង្គរនេះមិនត្រឹមតែរំលឹកគុណបុព្វការី ដែលបានខិតខំបូជាឈាមស្រស់សាច់ស្រស់ កម្លាំងកាយចិត្តក្នុងការកសាង ថែរក្សា ជួសជុលប្រាសាទ ការពារទឹកដី តាំងពីដើមរៀងមករហូតមកដល់បច្ចុប្បន្ននេះ។ ប៉ុន្តែ ក៏សម្តែងនូវការគោរពអរគុណចំពោះសន្តិភាពដែលនាំមកបានដល់ប្រជាជាតិខ្មែរយើងដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាអគ្គមហាបុរសរដ្ឋដែលជាស្ថាបនិកនយោបាយឈ្នះៗ នាំមកនូវសន្តិភាពដល់ប្រទេសកម្ពុជា និងជំរុញការអភិវឌ្ឍជាតិលើគ្រប់វិស័យ។ ដូច្នេះ យើងទាំងអស់គ្នាប្តេជ្ញាចិត្តថែរក្សាសន្តិភាព រំលឹកគុណដល់បុព្វការីជន និងសន្តិភាព៕

# ការគ្រប់គ្រងសណ្តាប់ធ្នាប់នៅតំបន់ប្រាសាទ មានសារសំខាន់ដែលពលរដ្ឋគ្រប់រូបគួរចូលរួម

ផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣

ការគ្រប់គ្រងសណ្តាប់ធ្នាប់ អនាម័យ និងការលក់ដូរក្នុងតំបន់រមណីយដ្ឋានអង្គរ មានសារសំខាន់ណាស់ ដើម្បីរៀបចំតំបន់នេះឱ្យមានសណ្តាប់ធ្នាប់ល្អ ស័ក្តិសមជាទីសក្ការៈបូជា និងជាគោលដៅទេសចរណ៍សម្រាប់ពិភពលោក។

លោកស្រី ចាន់ ឧត្តមបញ្ញា ប្រធានភ្នាក់ងារសណ្តាប់ធ្នាប់ប្រចាំក្រុងអង្គរធំ បានឱ្យដឹងថា ការងាររៀបចំសណ្តាប់ធ្នាប់តូបលក់ដូរនៅតំបន់នេះ គឺមានការរៀបចំចាប់ពីឆ្នាំ២០១១មកក្នុងន័យសម្រួលនិងរៀបចំតំបន់នេះឱ្យមានរបៀបរៀបរយសណ្តាប់ធ្នាប់ល្អ និងលើកតម្លៃរបស់រមណីយដ្ឋានអង្គរ។ លោកស្រីបន្តថា នៅក្រុងអង្គរធំ ក្រុមការងារអាជ្ញាធរជាតិអប្សរាបានរៀបចំទីតាំង៣សម្រាប់ឱ្យអាជីវករលក់ដូរ ដូចជានៅខាងលិចប្រាសាទបាយ័ន វត្តទេពប្រណម្យ និងមុខប្រាសាទព្រះពិធូរ។

ទាក់ទងនឹងការលក់ដូរនេះដែរ លោកស្រី ចាន់ ឧត្តមបញ្ញា បានបញ្ជាក់ថា ក្រុមការងារលោកស្រីជាបន្តបន្ទាប់ តែងចុះរៀបចំនៅតាមតូបលក់ដូរនីមួយៗ ទាំងការលក់ ការដាក់សំរាមបញ្ហាអនាម័យ និងការរៀបចំសម្ភារលក់ដូរ ឬកៅអីអង្គុយតម្រូវឱ្យអាជីវកររៀបចំឱ្យបានសមរម្យមិនឱ្យហៀរចេញមកមុខតូបលក់ដូរពេកនោះទេ។ ដោយឡែកក្នុងនោះក្រុមការងារក៏មានភារកិច្ចទប់ស្កាត់ការលក់ដូរចល័តថ្មីៗក្នុងតំបន់ប្រាសាទផងដែរ។ ចំណុចនេះ បញ្ញា ពន្យល់ថា

ប្រសិនបណ្តោយឱ្យអ្នកលក់ដូរថ្មីៗចូលមកលក់នៅតំបន់ប្រាសាទ នោះនឹងមានភាពរញ៉េរញ៉ៃ គ្មានសណ្តាប់ធ្នាប់ ហើយទេសចរក៏មិនពេញចិត្តនូវរូបភាពបែបនេះដែរ។

យ៉ាងណាមិញ ការងារទាំងនេះតែងមានបញ្ហាប្រឈមខ្លះពីសំណាក់អាជីវករអ្នកលក់ចល័តតាមរ៉ឺម៉ក ឬម៉ូតូ កង់ជាដើម។ ក្នុងនាមជារក្សាសណ្តាប់ធ្នាប់ និងអ្នកការពារអង្គរមួយរូប បញ្ញា ប្រាប់ថា ក្រុមការងាររបស់ខ្លួនមិននឿយហត់ចំពោះការណែនាំឱ្យអ្នកលក់យល់ពីបំណងនៃការរៀបចំទាំងនោះទេ ហើយចុងក្រោយតែងមានដំណោះស្រាយល្អរីឯអ្នកលក់ទាំងនោះយល់ពីកាតព្វកិច្ចរបស់ក្រុមការងារសណ្តាប់ធ្នាប់ផងដែរ៕

# អាជ្ញាធរជាតិអប្សរានិងស្ថាប័ន GIZ អាល្លឺម៉ង់ បើកវគ្គបណ្តុះបណ្តាលជំនាញអភិរក្សថ្ម និងអបអរសាទរខួប១៥ឆ្នាំនៃទំនាក់ទំនងរបស់ស្ថាប័នទាំងពីរនៅលើទឹកដីអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣

អាជ្ញាធរជាតិអប្សរាបានសហការជាមួយអង្គការ GIZ នៃប្រទេសអាល្លឺម៉ង់ បើកវគ្គបណ្តុះបណ្តាលជំនាញព្យាបាល និងអភិរក្សថ្មដល់សិក្ខាកាមខ្មែរចំនួន២០រូប នៅប្រាសាទបន្ទាយសំរ៉ែ អស់រយៈពេលពាក់កណ្តាលឆ្នាំមកហើយ បើគិតមកដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០២៣។

ការបើកវគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងក្នុងគោលបំណងចង់ឱ្យយុវជនខ្មែរក្លាយជាអ្នកជំនាញជំនាន់ថ្មីនៅតាមការដ្ឋានជួសជុលប្រាសាទបុរាណនានានៅក្នុងរមណីយដ្ឋានអង្គរទៅថ្ងៃអនាគត។ ក្នុងឱកាសថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ នេះដែរ ក៏ជាការរំលឹកខួបទី១៥ឆ្នាំ របស់អង្គការ GIZ អាល្លឺម៉ង់ ក្នុងកិច្ចសហការលើការងារអភិរក្សថ្មនិងបណ្តុះបណ្តាលធនធានមនុស្សខ្មែរលើជំនាញនេះដូចគ្នា។

លោក ឡុង ណារី ប្រធានក្រុមការងារអភិរក្សថ្មនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យាមានប្រសាសន៍ថា គម្រោងបង្រៀនអភិរក្សថ្មនៅក្នុងតំបន់អង្គរ មានរយៈពេល ២ឆ្នាំកន្លះ មកដល់បច្ចុប្បន្ន បានពាក់កណ្តាលឆ្នាំហើយ។ ការបណ្តុះបណ្តាលជំនាញអភិរក្សថ្ម មាន១៣វគ្គ ដែលផ្តោតសំខាន់លើការងារជួសជុល ការស្វែងយល់ពីកំណរកំណើតថ្ម យល់ដឹងអំពីការខូចខាតរបស់ថ្មដោយសារកត្តាអ្វីខ្លះ? វិភាគទៅលើជំងឺរបស់ថ្ម និងសិក្សាអំពីវត្ថុធាតុ និងវិធីសាស្ត្រព្យាបាលជាដើម។

ចំណែកគ្រូបង្រៀនជនជាតិអាល្លឺម៉ង់កញ្ញា Helen Jacobsen ឱ្យដឹងថាក្នុងរយៈពេល១៥ឆ្នាំកន្លងមកនេះ អង្គការGIZ បានបណ្តុះបណ្តាលយុវជនខ្មែរលើជំនាញព្យាបាលនិងអភិរក្សថ្ម បានប្រមាន៤០នាក់ហើយ។ កញ្ញា Helen សម្តែងការសប្បាយចិត្តដែលបានចូលរួមបណ្តុះបណ្តាលយុវជនខ្មែរឱ្យក្លាយជាអ្នកជំនាញសម្រាប់បន្តវេនក្នុងការអភិរក្សនិងថែរក្សាសម្បត្តិបេតិកភណ្ឌពិភពលោកនេះ ហើយកញ្ញាសង្ឃឹមថា នៅពេល១០ឆ្នាំខាងមុខទៀត អាជ្ញាធរជាតិអប្សរានឹងមានអ្នកជំនាញផ្នែកព្យាបាលនិងអភិរក្សថ្ម កើនឡើងដែលនឹងធ្វើឱ្យការងារអភិរក្ស និងជួសជុលប្រាសាទបុរាណនានាដោយខ្មែរខ្លួនឯង ពុំចាំបាច់ពឹងផ្អែកលើអ្នកជំនាញបរទេសទៀតទេ៕

# អាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យអង្គការលំនៅឋានមនុស្សជាតិ អន្តរជាតិនៅកម្ពុជា ជួបសម្តែងការគួរសមនិងឈ្វេងយល់អំពីគម្រោងពាក់ព័ន្ធមួយចំនួន

ផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣នេះ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាជាមួយតំណាងអង្គការលំនៅឋានមនុស្សជាតិ អន្តរជាតិនៅកម្ពុជា ដើម្បីឈ្វេងយល់អំពីគម្រោងពាក់ព័ន្ធការតាំងទីលំនៅក្នុងតំបន់អង្គរ និងការតាំងទីលំនៅថ្មី នៅតំបន់រុនតាឯក និងពាក់ស្នែង។ ជំនួបពិភាក្សានេះ មានគោលបំណងសំខាន់សិក្សាឈ្វេងយល់ អំពីការងារមួយចំនួន របស់អាជ្ញាធរជាតិអប្សរា លើការងារជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់អង្គរ និងមានបំណង ផ្តល់នូវកិច្ចសហការជាមួយគ្នាក្នុងថ្ងៃអនាគត៕

# សេចក្តីជូនដំណឹង ស្តីពីការសម្តែងល្ខោននិងសិល្បៈទស្សនីយភាពនានា ដើម្បីអបអរសាទរ ព្រឹត្តិការណ៍ "រំលឹកគុណអង្គរ" ប្រចាំឆ្នាំ២០២៣

ផ្សាយនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣



**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ក្រុមការងារសម្អាតបរិស្ថាននៃអាជ្ញាធរជាតិអប្សរា មមាញឹកសម្អាតសំរាមស្លឹកឈើ និងកាត់ស្មៅនៅខាងលិចជ្រុងខាងជើងកសិន្ធុប្រាសាទអង្គរវត្ត**

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

# ចាប់តាំងពីដើមខែធ្នូ មកដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣នេះ សម្ភារប្រើប្រាស់ មានកាបូប ទូរស័ព្ទដៃ និងសម្ភារមួយចំនួនទៀត ត្រូវបានភ្នាក់ងារទេសចរណ៍ ប្រចាំការនៅគោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញ និងប្រគល់ជូនម្ចាស់ដើមវិញ

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

ចាប់តាំងពីថ្ងៃទី០២ ខែធ្នូ មកដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣នេះ ក្រុមការងារភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទអង្គរវត្ត ភ្នាក់ងារសណ្តាប់ធ្នាប់ រួមទាំងនគរបាលការពារបេតិកភណ្ឌ បានប្រទះឃើញសម្ភារប្រើប្រាស់របស់ភ្ញៀវ រួមមាន៖ កាបូបលុយ ទូរស័ព្ទដៃ និងសម្ភារមានតម្លៃផ្សេងៗទៀត ដែលភ្ញៀវភ្លេច បានយកមករក្សាទុក និងប្រគល់ជូនម្ចាស់វិញទាំងអស់៕

# ទស្សនិកជនច្រើនកុះកររីករាយជាមួយការទស្សនាល្ខោនយីកេ ក្នុងព្រឹត្តិការណ៍បុណ្យរំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

ទស្សនិកជនច្រើនកុះករបានមកទស្សនាការសម្តែងល្ខោនយីកេ រឿងឈាមអកតញ្ញូ ដែលសម្តែងដោយក្រុមសិល្បៈល្ខោនយីកេ ភូមិនីពេជ្រ (ខ) ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាយប់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ នៅបរិវេណខាងត្បូងប៉ារីសអង្គរវត្ត។ ពួកគាត់បាននាំគ្រួសារ កូនៗ និងមិត្តភក្តិអង្គុយទស្សនាយ៉ាងរីករាយ លាយនឹងសំណើចការអាណិតតួអង្គនៅក្នុងសាច់រឿងជាដើម៕

## ក្រុមការងារអាជ្ញាធរជាតិអប្សរា បានជួសជុលកាំជណ្ដើរ ផ្នែកកណ្ដាលចំណុចស្ពានហាលអង្គរវត្ត ឱ្យមានភាពរឹងមាំឡើងវិញ សម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរ

## កាំជណ្ដើរថ្មីបានជំនួស កាំជណ្ដើរចាស់ ជាផ្នែកមួយនៃការលើកកម្ពស់សុវត្ថិភាព សោភ័ណភាពនៃរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងជំនាញបដិសណ្ឋារកិច្ចសម្រាប់ភ្នាក់ងារទេសចរណ៍

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា បានបើកវគ្គបណ្តុះបណ្តាលជំនាញស្តីពី ការពង្រឹងបដិសណ្ឋារកិច្ចដល់មន្ត្រី និងបុគ្គលិកដែលបម្រើការជាភ្នាក់ងារទេសចរណ៍ចំនួន៥០នាក់ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ នៅសារមន្ទីរវាយកណ្តប្រពៃណីអាស៊ី។

លោក សេង សុជាា៉ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ មានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារទេសចរណ៍របស់អាជ្ញាធរជាតិអប្សរា ទាំងការស្វាគមន៍ និងបម្រើសេវាយ៉ាងកក់ក្តៅ ក្នុងដំណើរការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរ ដើម្បីរួមចំណែកការលើកតម្លៃសម្បត្តិបេតិកភណ្ឌរបស់ពិភពលោក។

ខ្លឹមសារសំខាន់ៗផ្តោតលើដូចជា របៀបបដិសណ្ឋារកិច្ចសម្រាប់ភ្នាក់ងារទេសចរណ៍ ដំណោះស្រាយលើបញ្ហាប្រឈមនានានៅតាមប្រាសាទ។

វគ្គបណ្តុះបណ្តាលនេះ គឺពិតជាមានសារសំខាន់ណាស់ សម្រាប់មន្ត្រីភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា ដែលបម្រើសេវាកម្មទេសចរណ៍ ដោយត្រូវគិតគូរទាំងគុណភាពសេវាកម្មទេសចរណ៍ និងគិតគូរពីផលប៉ះពាល់នៃភ្ញៀវទេសចរដែលមកលើប្រាសាទបុរាណ៕

# អាជ្ញាធរជាតិអប្សរាចូលរួមធ្វើបទបង្ហាញស្តីពីបេតិកភណ្ឌអង្គរ និងអារាមព្រះពុទ្ធសាសនា ក្នុងអង្គពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣១

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

អង្គពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣១ ត្រូវបានប្រារព្ធពិធីបើកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ នៅសាលវិទ្យាស្ថានជាតិអប់រំរាជធានីភ្នំពេញ។

ក្នុងមហាសន្និបាតនេះក៏មានព្រះរាជវត្តមាន និងព្រះវត្តមានយ៉ាង និមន្តចូលរួមរបស់**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត** **សម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះពោធិវ័ង្ស កិត្តិបណ្ឌិត អ៊ំ លឹមហេង** សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា និងមានសម្តេចព្រះរាជាគណៈ ព្រះមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ សមណនិស្សិតនិស្សិត និងមន្ត្រីរាជការចូលរួមប្រមាណ ១០០០ អង្គ/ នាក់ ដែលរៀបចំដោយ ក្រសួងធម្មការ និងសាសនា។

ក្នុងពិធីបើកមហាសន្និបាតនេះ តំណាងអាជ្ញាធរជាតិអប្សរា ក៏បានទទួលការអញ្ជើញឲ្យ ចូលរួមឡើងធ្វើបទបង្ហាញស្តីអំពី បេតិកភណ្ឌអង្គរ និងអារាមព្រះពុទ្ធសាសនា ដែលមានចំណុចសំខាន់ៗមានដូចខាងក្រោម៖

ច្បាប់ស្តីអំពីសម្បត្តិបេតិកភណ្ឌចេញដោយព្រះរាជក្រឹត្យការចូលរួមដោះស្រាយបញ្ហាប្រឈមនានាចំពោះបេតិកភណ្ឌក្នុងវត្តអារាមអំពីកិច្ចការងារអភិរក្សសំណង់ចាស់ៗនៅទីវត្តអារាមមួយចំនួនអំពីការទប់ស្កាត់សំណង់នានានៅតាមវត្តអារាមមួយចំនួន អំពីវត្តអារាមដែលបានចូលរួមដោះស្រាយសណ្តាប់ធ្នាប់ និងបរិស្ថាន

ក្រោយបានបញ្ចប់បទបង្ហាញរួចមក គណៈសង្ឃ ព្រះមន្ត្រីសង្ឃក្នុងពិធីទាំងមូលបានចូលរួមអបអរសាទរ និងបានស្វាធ្យាយជយន្តោ ប្រសិទ្ធិពរដល់ប្រាង្គប្រាសាទជាបេតិកភណ្ឌពិភពលោក ហើយនិងប្រជាជនខ្មែរដែលកំពុងប្រារព្ធពិធីបុណ្យរំលឹកគុណអង្គរ នៅប្រាសាទអង្គរវត្ត ខេត្តសៀមរាប ឲ្យបានជួបតែនឹងពុទ្ធពរតរៀងទៅ។

សូមជម្រាបផងថា ថ្ងៃទី១៤ធ្នូនេះ ជាថ្ងៃពិសេស គឺជាថ្ងៃដែលប្រាសាទអង្គរវត្ត បានបញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោករយៈពេល៣១ឆ្នាំមកហើយ ស្របពេលជាមួយពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣១ផងដែរ។

# ក្រុមសិល្បករ យុវជន និងវិស័យឯកជនចូលរួមដង្ហែក្បួនព្យុហយាត្រា ដើម្បីអបអរសាទរព្រឹត្តិការណ៍រំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣

រសៀលថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា ក្រុមសិល្បករ សហភាពសហព័ន្ធយុវជនកម្ពុជា សិស្ស-និស្សិត រួមជាមួយវិស័យឯកជន ចំនួនប្រមាណ៤៥០នាក់ បានចូលរួមដង្ហែក្បួនព្យុហយាត្រា ចាប់ផ្តើមពីទីស្នាក់ការអង្គភាពនគរបាលបេតិកភណ្ឌប្រចាំតំបន់អង្គរ ឆ្ពោះមកស្ពានហាលមុខប្រាសាទអង្គរវត្ត ដើម្បីចូលរួមអបអរសាទរព្រឹត្តិការណ៍បុណ្យរំលឹកគុណអង្គរ។

លោក សេង សុធារ៉ា ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា បានសម្តែងនូវសេចក្តីរីករាយដែលក្រុមសិល្បករ និងវិស័យឯកជននៅក្នុងខេត្តសៀមរាប ចូលរួមអបអរសាទរក្នុងព្រឹត្តិការណ៍ខួបទី៣១ នៃការដាក់រមណីយដ្ឋានអង្គរចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក៏ដូចជា ការអបអរប្រចាំឆ្នាំនូវព្រឹត្តិការណ៍របស់អាជ្ញាធរជាតិអប្សរា គឺបុណ្យរំលឹកគុណអង្គរ ដើម្បីថ្លែងអំណរគុណដល់បុព្វបុរសដែលបានកសាងមរតកវប្បធម៌ទុកសម្រាប់ពួកយើង ទុកកេរដំណែលមួយ និងសង្ឃឹមថា ពួកយើងទាំងអស់គ្នារំលឹកថ្ងៃនេះ ហើយនឹងចូលរួមចំណែកអភិរក្សសម្រាប់កូនចៅជំនាន់ក្រោយបន្តទៀត។

លោក សេង សុធារ៉ា បានថ្លែងអំណរគុណដល់ក្រុមសិល្បករ យុវជន វិស័យឯកជនទាំងអស់ដែលចំណាយពេលវេលាដ៏មានតម្លៃចូលរួមអបអរសាទរព្រឹត្តិការណ៍ដែលអាជ្ញាធរជាតិអប្សរាប្រារព្ធកម្មវិធីនេះឡើង៕

# សូមអញ្ជើញទស្សនាកម្រងរូបភាពកម្មវិធី "រាត្រីចងចាំ" លើកទី៤ ដែលប្រព្រឹត្តទៅនាល្ងាចថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ នាព្រះលានជល់ដំរី ក្រុងអង្គធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងការអញ្ជើញចូលរួម លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣

# សារលិខិត របស់អាជ្ញាធរជាតិអប្សរា គោរពជូនពរ សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រសើរថ្លៃថ្លាវិសេសវិសាលនៃពិធីខួបចម្រើនជន្មាយុ របស់សម្ដេចកិត្តិព្រឹទ្ធ បណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២៣នេះ

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣

# សិស្សានុសិស្សសាលាបឋមសិក្សានគរក្រៅ ហ្វឹកហាត់គំនូរបេតិកភណ្ឌនៅប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣នេះ អាជ្ញាធរជាតិអប្សរា ដឹកនាំដោយលោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការ JASA នៃប្រទេសជប៉ុន ដឹកនាំដោយ លោកសាស្ត្រាចារ្យ NAKAGAWA Takeshi បាននាំសិស្សានុសិស្សថ្នាក់ទី៤ នៃសាលាបឋមសិក្សានគរក្រៅ ស្ថិតក្នុងសង្កាត់នគរធំ ក្រុងសៀមរាប ចំនួន៣០នាក់ មកទស្សនកិច្ចសិក្សាស្វែងយល់និងហ្វឹកហាត់គូររូបប្រាសាទនិងចម្លាក់នៅប្រាសាទបាយ័ន ក្នុងគោលបំណង បញ្ជ្រាបអំពីតម្លៃនៃមរតកវប្បធម៌ ដល់ក្មេងៗនៅកម្រិតបឋមសិក្សា ដែលមានឪពុកម្តាយ តាយាយ បម្រើការក្នុងការដ្ឋានអភិរក្សនិងជួសជុលនៅក្នុងស្ថាប័នJASA និងអាជ្ញាធរជាតិអប្សរា។

លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលនិងផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ថា មានរយៈពេលជិត៣០ឆ្នាំមកហើយ ដែលស្ថាប័នJASA នៃប្រទេសជប៉ុន បានចូលរួមជួយការងារជួសជុលអភិរក្សនៅក្នុងប្រាសាទបាយ័ន។ លោកថា គម្រោងរបស់អង្គការ JASAមួយនេះ ក្រៅពីការងារជួសជុលប្រាង្គប្រាសាទ ក៏បានយកចិត្តទុកដាក់គិតគូរទៅលើការរស់នៅ របស់សហគមន៍ ជាពិសេសការបង្ហាញទៅកាន់មនុស្សជំនាន់ក្រោយ ឱ្យបានយល់ដឹងអំពីតម្លៃបេតិកភណ្ឌវប្បធម៌អង្គរ។ លោកបានបន្តថា ដោយមើលឃើញអំពីគោលដៅរួមគ្នា ក្នុងពេលកន្លងមកអាជ្ញាធរជាតិអប្សរា និងអង្គការJASA បានរួមសហការគ្នា ផ្តល់ការបណ្តុះបណ្តាលជារឿយៗដើម្បីបង្ហាញដល់កុមារ ដែលរស់នៅក្នុងតំបន់បេតិកភណ្ឌ អំពីការបន្តកេមរតក ក្នុងការគ្រប់គ្រង និងបន្តថែរក្សាបេតិកភណ្ឌអង្គរស្របនិងកម្មវិធីអប់រំបេតិកភណ្ឌ ដែលអាជ្ញាធរជាតិអប្សរាកំពុងអនុវត្តក្នុងពេលសព្វថ្ងៃនេះ។

លោកសាស្ត្រាចារ្យ NAKAGAWA Takeshi បានលើកឡើងថា អង្គការ JASA នៃប្រទេសជប៉ុន រៀបចំសិក្ខាសាលានេះឡើង គឺក្នុងគោលបំណងឱ្យយុវជនជំនាន់ក្រោយបានជ្រាបច្បាស់អ្វីដែលជារបស់ដូនតាខ្មែរបានបន្សល់ទុក និងចេះស្រលាញ់ប្រាសាទបុរាណ។ លោកសាស្ត្រាចារ្យ បានបន្តថា ចំពោះការងារនេះលោកនិងខិតខំបន្ថែមទៀតក្នុងការសហការជាមួយអ្នកជំនាញមុនៗបន្ថែមទៀត ដើម្បីយកចំណេះទាំងនេះមកបង្ហាត់បង្រៀនយុវជនជំនាន់ក្រោយៗបន្តទៀត៕

**សាធារណជនជាច្រើនរីករាយអង្គុយទស្សនាការសម្តែងសិល្បៈស្បែកធំ ដែលសម្តែងដោយក្រុមសិល្បៈស្បែកធំវត្តរាជបូណ៌ខេត្តសៀមរាប នាយប់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ នៅខាងត្បូងប៉ាវីសអង្គរវត្ត**

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣

# ព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ នៅចំណុចក្បែរខ្លោងទ្វារកណ្តាលលោកតារាជ នៃប្រាសាទអង្គរវត្ត មានភ្ញៀវទេសចរជនជាតិអឺរ៉ុប ភេទប្រុស គ្រិចកជើង ខណៈកំពុងដើរទស្សនា ភ្លាមៗក្រុមការងារឆ្លាក់ងារទេសចរណ៍បានជួយសង្គ្រោះបឋម បន្ទាប់មកគាត់ក៏អាចបន្តដំណើរទស្សនាធម្មតាវិញ

ផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣

# ភ្ញៀវទេសចរជិត៨ម៉ឺននាក់ បានមកទស្សនាពិព័រណ៌ និងការសម្តែងទស្សនីយភាពសិល្បៈចម្រុះនានានៃព្រឹត្តិការណ៍រំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣

រយៈពេល១០ថ្ងៃ នៃព្រឹត្តិការណ៍រំលឹកគុណអង្គរ ចាប់ពីថ្ងៃទី០៧ដល់ថ្ងៃ១៦ ខែធ្នូ ឆ្នាំ២០២៣ ភ្ញៀវទេសចរជាតិ និងអន្តរជាតិសរុបជិត៨ម៉ឺននាក់ ចូលមកទស្សនាស្តង់ពិព័រណ៌ និងកម្មវិធីសម្តែងទស្សនីយភាពសិល្បៈចម្រុះនៅខាងមុខប្រាសាទអង្គរវត្ត និងព្រះលានជល់ដំរីនៃក្រុងអង្គរធំ។ ក្នុងនោះ ចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលទស្សនា រោងពិព័រណ៌របស់អាជ្ញាធរជាតិអប្សរាសរុបចំនួន៩៦៤៣នាក់ ភ្ញៀវជាតិចំនួន៤ ៥៩៥នាក់ (ព្រះសង្ឃ១២៦អង្គ)និងភ្ញៀវបរទេស៥០៤៨នាក់។ កម្មវិធីល្ខោនយីកេមហាជន ល្ខោនស្បែកធំ និងល្ខោនខោលរឿងរាមកេរ្តិ៍នៅខាងត្បូងប្រាសាទអង្គរវត្ត រយៈពេល០៣ថ្ងៃ ចាប់ពីថ្ងៃទី១៣ដល់១៥ និង១៦ខែធ្នូ ឆ្នាំ២០២៣ សរុបចំនួន១៤៣៩នាក់ ក្នុងនោះ ភ្ញៀវជាតិចំនួន១៣៨៦នាក់ (ព្រះសង្ឃ១៨អង្គ) និងភ្ញៀវបរទេសចំនួន ៣៥នាក់។ កម្មវិធីរាត្រីចងចាំ សិល្បៈចម្រុះ ល្ខោនបុរាណពោលស្រី និងប្រដាល់ក្បាច់គុណបុរាណខ្មែរ នៅព្រះលានជល់ដំរី ពីថ្ងៃទី១៤ដល់១៥ និង១៧ខែធ្នូ ឆ្នាំ២០២៣ សរុបចំនួន៦៩,០០៥នាក់ ភ្ញៀវជាតិ៦៨.៧០៥នាក់ (ក្នុងនោះ កម្មវិធីរាត្រីចងចាំ មានភ្ញៀវ៥៣.៨២៨នាក់) និងភ្ញៀវបរទេសចំនួន៣០០នាក់។

សូមជម្រាបផងដែរថា ដើម្បីចូលរួមអបអរសាទរខួប៣១ឆ្នាំនៃការចុះរមណីយដ្ឋានអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ អាជ្ញាធរជាតិអប្សរា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំប្រារព្ធពិធីបុណ្យ«រំលឹកគុណអង្គរ»នៅក្នុងតំបន់រមណីយដ្ឋានអង្គរ មានរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣។ ក្នុងរយៈពេល១០ថ្ងៃនៃព្រឹត្តិការណ៍រំលឹកគុណអង្គរ ក្រៅពីការប្រារព្ធនូវពិធីបែបសាសនា ដើម្បីសម្តែងនូវការដឹងគុណចំពោះអង្គព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ និងបុព្វការីជនទាំងអស់ដែលលោកបានខិតខំកសាង និងថែរក្សាប្រាសាទបុរាណទាំងអស់នៅក្នុងរមណីយដ្ឋានអង្គរ ដោយបានផ្តល់អត្ថប្រយោជន៍ជាច្រើន ដល់ជាតិមាតុភូមិតាំងពីដើមរហូតដល់សព្វថ្ងៃនេះ ក៏មានកម្មវិធីទស្សនាស្តង់ពិព័រណ៌ស្តីពីសមិទ្ធផលការងាររយៈពេល៣១ឆ្នាំរបស់អាជ្ញាធរជាតិអប្សរា ការសម្តែងទស្សនីយភាពសិល្បៈបុរាណជាច្រើនទម្រង់ ដើម្បីរួមចំណែកលើកកម្ពស់ស្នាដៃសិល្បៈបុរាណ និងផ្តល់ភាពសប្បាយរីករាយដល់ប្រជាពលរដ្ឋ ភ្ញៀវទេសចរជាតិ និងអន្តរជាតិផងដែរ៕

# ការជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្ម ជួសជុលសម្រេចបាន៦០ភាគរយហើយ

ផ្សាយនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣

ក្រុមការងារនៃកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងឥណ្ឌាឱ្យដឹងថា គម្រោងជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្មនឹងបញ្ចប់នៅដើមឆ្នាំ២០២៤ខាងមុខនេះ។

ប្រធានគ្រប់គ្រងការដ្ឋានជួសជុលនៅប្រាសាទតាព្រហ្ម លោក Chitranjan Kumar ឱ្យដឹងថា ដំណើរការជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្ម គឺធ្វើតាមបច្ចេកទេសអាណាស្ទីឡូ ដោយរើគំនរថ្មខ្លោងទ្វារទាំងមូលដែលដួលរលំបាក់បែក ដើម្បីស្វែងរកទីតាំងដើមឡើងវិញ។ ប្រធានគ្រប់គ្រងការដ្ឋានរូបនេះបន្តទៀតថា ការងាររយៈពេលជាច្រើនខែមកនេះ ក្រុមការងារជួសជុលបានពង្រឹងគ្រឹះ និងរៀបចំរចនាសម្ពន្ធនៃខ្លោងទ្វារទាំងមូលឡើងវិញ។ ស្វែងរកថ្មដែលបានបាត់មកដាក់នៅតាមទីតាំងដើម។

រីឯ ទីតាំងដែលបាត់បង់ថ្ម ឬថ្មខូចខាត គឺដាក់បន្ថែមថ្មថ្មីជំនួសដើម្បីទល់ទ្រចនាសម្ពន្ធផ្សេងៗ។ បច្ចុប្បន្នក្រុមការងារបានខិតខំជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្ម ដោយបានប្រមាណសម្រេច៦០ភាគរយហើយ។

លោក Chitranjan Kumar បញ្ជាក់ទៀតថា គម្រោងជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្មនេះ ការងារដែលនៅសេសសល់ គឺចាប់ពីផ្នែកកព្រហ្មឡើងទៅលើ ដោយសារតែថ្មមួយចំនួននៃផ្ទៃមុខព្រហ្មទាំងបួនទិសបានបាត់បង់ ដែលត្រូវរង់ចាំឆ្លងយោបល់ពីក្រុមអ្នកជំនាញការរបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ថាតើអាចយកថ្មថ្មីមកជំនួសបានឬយ៉ាងណា? ដើម្បីឱ្យស្របទៅតាមក្រមធម្មនុញ្ញអង្គរ៕

# ប្រាសាទបាយ័ននៅតែជាទីតាំងដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣

បន្ទាប់ពីប្រាសាទអង្គរវត្ត ប្រាសាទបាយ័នជាប្រាសាទមួយដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរ។ ស្នាមញញឹមនៃកំពូលព្រហ្មមុខបួន ចម្លាក់រៀបរាប់នៃសាច់រឿងចម្រុះ ប្រពៃណីវប្បធម៌ពីសម័យដើមនៅប្រាសាទនេះ សុទ្ធសឹងជាទីចាប់អារម្មណ៍របស់ភ្ញៀវទេសចរ អមដោយការឧទ្ទេសដ៏ប៉ិនប្រសព្វពីសំណាក់ក្រុមមគ្គុទ្ទេសក៍ជំនាញៗ។

## ប្រទះឃើញចម្លាក់បដិមាថ្មភក់ចំនួន៦នៅខ្លោងទ្វារខាងត្បូងរបស់ប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣

ក្រុមការងារជួសជុលប្រាសាទបុរាណរបស់អាជ្ញាធរជាតិអប្សរានៅការដ្ឋានប្រាសាទតាព្រហ្ម បានប្រទះឃើញចម្លាក់បដិមាបុរាណធ្វើពីថ្មភក់ចំនួន៦ដុំនៅក្នុងការដ្ឋានដែលពួកគេកំពុងតែជួសជុល។

បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរាអ្នកស្រីនេតស៊ីមនមានប្រសាសន៍ថា ចម្លាក់ថ្មបុរាណដែលគេប្រទះឃើញនោះ មានដូចជារូបព្រះពុទ្ធគង់ភ្នែនប្រក់នាគចំនួន២ រូបលោកកេស្វរៈចំនួន១ រូបព្រះពុទ្ធគង់ភ្នែនប្រក់នាគបាក់ព្រះកេសទម្រង់សមាធិ និងបាក់ព្រះហស្តទាំងសងចំនួន២ និងថ្មកំពូលហោជាង ដែលមានចម្លាក់រូបព្រះពុទ្ធគង់ភ្នែន មានទេពទ្រពីក្រោម១ផ្ទាំងទៀត។

អ្នកស្រី នេត ស៊ីមន បន្តទៀតថា រូបចម្លាក់ទាំងនោះបានកប់នៅក្រោមកំណកដីរបស់ខឿនខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្ម ហើយក្រុមការងារបានប្រទះឃើញនៅពេលដែលអាជ្ញាធរជាតិអប្សរាសហការជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) ចាប់ផ្តើមការងារជួសជុលខ្លោងទ្វារនេះឡើងវិញ ដោយបានរើថ្មនៃរចនាសម្ពន្ធខ្លោងទ្វារដែលនៅរាយប៉ាយដើម្បីរៀបចំទៅតាមទីតាំងដើមឡើងវិញតាមបច្ចេកទេសអាណាស្ទីឡូ កាលពីពាក់កណ្តាលខែវិច្ឆិកា៕

## ប្រាសាទតូបខាងកើត

ផ្សាយនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣

# ប្រាសាទព្រៃប្រាសាទ ឬប្រាសាទតាអួន

ផ្សាយនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣

# អាជ្ញាធរជាតិអប្សរា កំណាយស្រាវជ្រាវគ្រឹះខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្ម ដើម្បីឈានទៅដល់ការជួសជុល

ផ្សាយនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣

ក្រុមការងារបុរាណវិទ្យារបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា កំពុងធ្វើកំណាយស្រាវជ្រាវគ្រឹះខ្លោងទ្វារខាងត្បូងរបស់ប្រាសាទតាព្រហ្ម ដើម្បីសិក្សាពីស្ថានភាពគ្រឹះឱ្យបានគ្រប់ជ្រុងជ្រោយ មុនឈានទៅដល់ការជួសជុល ដែលមានកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា(ASI)។ កំណាយស្រាវជ្រាវនេះមានរយៈពេល៣ខែ ចាប់ផ្តើមពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០២៣ រហូតទៅដល់អំឡុងខែកុម្ភៈ ឆ្នាំ២០២៤ខាងមុខ។

បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា អ្នកស្រី នេត ស៊ីមន មានប្រសាសន៍ថាការកំណាយស្រាវជ្រាវនៅខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្មមានគោលបំណង ទី១ ស្វែងរកថ្មរបស់សំណង់ដែលបាត់បង់។ ទី២ សិក្សាមើលស្ថានភាពរបស់គ្រឹះនៃខ្លោងទ្វារ និងទី៣ សិក្សាស្វែងយល់ពីបច្ចេកទេសបុរាណរបៀបនៃការរៀបចំគ្រឹះសម័យបុរាណជាដើម។

អ្នកស្រី នេត ស៊ីមន ឱ្យដឹងទៀតថា តាមលទ្ធផលដំណាក់កាលដំបូងនៅក្នុងរណ្តៅទី១ ក្នុងជម្រៅ៨០សង់ទីម៉ែត្រ បានប្រទះឃើញ ដុំថ្មភក់ចំនួន៨ដុំ ដែលមានក្បាច់ និងអាចកំណត់អត្តសញ្ញាណ ជាថ្មកំពូលហោជាង និងផ្នែកផ្សេងៗទៀតរបស់ខ្លោងទ្វារ។ អ្នកស្រី នេត ស៊ីមន បញ្ជាក់ថា កំណាយស្រាវជ្រាវនេះ គឺបន្ទាប់ពីក្រុមការងារបានរើគំនរថ្មភក់របស់ខ្លោងទ្វារផ្នែកតួខាងលើដែលរលុះធ្លាក់មកគ្របលើរចនាសម្ពន្ធខ្លោងទ្វារទាំងមូល យកទៅផ្គុំសាកល្បងដើម្បីសិក្សាស្វែងរកទីតាំងដើម៕

# អាជ្ញាធរជាតិអប្សរាសូមធ្វើសេចក្តីបំភ្លឺជុំវិញការផ្សព្វផ្សាយព័ត៌មានផ្ទុយពីការពិតអំពីសកម្មភាពទប់ស្កាត់សំណង់មិនស្របច្បាប់នៅភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នៅព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ មានការផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក អំពីសកម្មភាពរុះរើសំណង់មិនស្របច្បាប់ របស់ក្រុមការងារសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា ដោយបង្ខំ ស្ថិតនៅក្នុងភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប។ ការផ្សព្វផ្សាយទាំងនេះគឺបានផ្ទុយពីការពិតជាក់ស្តែង បង្កើតឱ្យមានការយល់ច្រឡំពីសាធារណជនមកលើអាជ្ញាធរជាតិអប្សរា។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរាសូមជម្រាបជូនសាធារណៈជនឱ្យបានជ្រាបច្បាស់អំពីករណីនេះដូចខាងក្រោម៖

១- សំណង់ដែលជាកម្មវត្ថុនៃការរុះរើ គឺជាប្រភេទសំណង់មិនស្របច្បាប់ដែលសាងសង់គ្មានការអនុញ្ញាត កើតឡើងតាំងពីខែឧសភា ឆ្នាំ២០២៣ មកម្ល៉េះ។

២-ជាវិធានការណ៍ទប់ស្កាត់ ក្រុមការងារបានប្រគល់លិខិតជូនដំណឹងតម្រូវឱ្យម្ចាស់រុះរើចេញវិញដោយខ្លួនឯង ក្នុងនោះបានទុកពេលវេលាចំនួន០៣ថ្ងៃ គិតចាប់ពីថ្ងៃទី ២៥ ដល់២៧ ខែ ឧសភា ឆ្នាំ២០២៣ ជាកំហិត។ កិច្ចការនេះមានលោកមេភូមិសណ្តាន់ បានដឹងលឺ។

៣- ក្រោយមកដោយមានការស្នើសុំ ពីម្ចាស់សំណង់មិនស្របច្បាប់ខាងលើ ថានឹងរុះរើសំណង់ទាំងនេះដោយខ្លួនឯង ក្រុមការងារទប់ស្កាត់សំណង់មិនស្របច្បាប់បានឱ្យម្ចាស់សំណង់ចុះកិច្ចសន្យារុះរើស្ម័គ្រចិត្ត ដោយទុកពេលវេលា ចំនួន០៣ ថ្ងៃ គិតចាប់ពីថ្ងៃទី ១០ដល់១២ ខែវិច្ឆិកា ឆ្នាំ២០២៣។

៤- តាមរយៈនេះ អាជ្ញាធរជាតិអប្សរាបានទុកពេលវេលាសមស្រប សម្រាប់ម្ចាស់សំណង់ធ្វើការរុះរើដោយខ្លួនឯងអស់រយៈពេលជាច្រើនខែមកហើយ។

៥- បុគ្គលម្នាក់ដែលបានយំសោកក្នុងព័ត៌មានផ្សព្វផ្សាយតាមបណ្តាញសង្គមនោះ មិនមែនជា ម្ចាស់ផ្ទះខាងលើឡើយ។

ទង្វើរបស់ជននេះពិតជាមានបំណងបង្កាច់បង្ខូចកិត្តិយសមន្ត្រីអាជ្ញាធរជាតិអប្សរា ក្នុងសកម្មភាពទប់ស្កាត់សំណង់មិនស្របច្បាប់ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ មរតកដូនតា ព្រលឹងជាតិខ្មែរ។ សកម្មភាពនេះពិតណាស់ ធ្វើឡើងដើម្បីប្រយោជន៍បុគ្គលខ្លួនឯងផ្ទាល់ និងបានធ្វើឱ្យប៉ះពាល់ផងដែរដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

សេចក្តីដូចបានបញ្ជាក់ជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាប និងសូមមេត្តាបញ្ឈប់ការចូលរួមផ្សព្វផ្សាយព័ត៌មានមិនពិតនេះ៕

# ប្រាសាទនាគព័ន្ធនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ តែងតែប្រាថ្នាមកទស្សនាមិនដែលរំលង

ផ្សាយនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣

ប្រាសាទនាគព័ន្ធ ស្ថិតនៅចំកណ្ដាលបារាយណ៍ «ជ័យតដាក» អ្នកខ្លះហៅថា រាលរាជដាក បារាយណ៍ខាងជើង ឬបារាយណ៍នាគព័ន្ធ គឺជាស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨)។ មុននិងទៅដល់ប្រាសាទ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ត្រូវដើរឆ្លងកាត់ស្ពានដែលមានប្រវែងជិត២០០ម៉ែត្រ។ ជាមួយគ្នានេះ ភ្ញៀវទេសចរអាចគយគន់ផ្ទៃទឹកដែលមានផ្កាឈូក រុក្ខវារីជាតិផ្សេងៗ លាយលំខ្យល់ដ៏បរិសុទ្ធ ហាក់ប្លែកពីប្រាសាទផ្សេងៗដែលទស្សនីយភាពនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិតែងតែប្រាថ្នាមកទស្សនាមិនដែលរំលងសោះឡើយ៕

# ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ បានដឹកនាំក្រុមការងារចុះតាមការដ្ឋានការងារនានាក្នុងរមណីយដ្ឋានអង្គរ ដើម្បីពិនិត្យ កែលម្អ និងរៀបចំទិសដៅការងារបន្ទាប់នាពេលអនាគត

ផ្សាយនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

# សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

# សារលិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

# សារលិខិតជូនពរ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតជូនពរ

សូមគោរពជូន

# សារលិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតជូនពរ

# សារលិខិតជូនពរ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៤

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

សារលិខិតជូនពរ

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតជូនពរ

# ប្រាសាទបន្ទាយធំ លាក់ខ្លួនក្នុងព្រៃរងចាំភ្ញៀវទេសចរទៅទស្សនា

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣

មានទីតាំងស្ថិតនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប ប្រាសាទបន្ទាយធំ គឺជាស្នាព្រះហស្ត ព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨) ប្រាសាទនេះលាក់ខ្លួននៅក្នុងព្រៃរងចាំភ្ញៀវទេសចរមកទស្សនាស្វែងយល់ពីស្ថាបត្យកម្ម ប្រវត្តិសិល្បៈដ៏ល្អឯក ពិសេសចម្លាក់តូចៗគួរជាទីចាប់អារម្មណ៍៕

## រូបភាពប្រចាំសប្តាហ៍÷ ប្រាសាទធម្មនន្ទ

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣

## រូបភាពប្រចាំសប្តាហ៍÷ ប្រាសាទលាក់នាង

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

# ថ្ងៃចុងក្រោយនៃឆ្នាំ២០២៣ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាកម្សាន្តប្រាសាទអង្គរវត្តយ៉ាងច្រើនកុះករ

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

នៅព្រឹកថ្ងៃអាទិត្យ ទី៣១ ខែធ្នូ ឆ្នាំ២០២៣ ជាថ្ងៃចុងក្រោយនៃឆ្នាំ២០២៣ ត្រៀមឆ្លងចូលឆ្នាំសកល ឆ្នាំ២០២៤ មានភ្ញៀវទេសចរជាតិ និងអន្តរជាតិចម្រុះជាតិសាសន៍ជាច្រើនពាន់នាក់ បានមកទស្សនាកម្សាន្តនៅប្រាសាទអង្គរវត្ត។

ការមកទស្សនាកម្សាន្តរមណីយដ្ឋានអង្គរ សូមភ្ញៀវទេសចរជាតិ និងអន្តរជាតិប្រកបដោយសុខសុវត្ថិភាពក្នុងការធ្វើដំណើរ គោរពប្រតិបត្តិអង្គរ រក្សាសណ្តាប់ធ្នាប់ល្អ មានអធ្យាស្រ័យគ្នាទៅវិញទៅមក កុំធ្វេសប្រហែសរាល់ទ្រព្យសម្បត្តិដែលមានតម្លៃ និងប្រកាន់ខ្ជាប់នូវឥរិយាបថចូលរួមថែរក្សាបរិស្ថាន ដើម្បីលើកតម្លៃរមណីយដ្ឋានអង្គរទាំងអស់គ្នា។





## គ្រប់គ្រងការផលិតទូទៅ

ឯកឧត្តម ឡុង កុសល

អគ្គនាយករងអាជ្ញាធរជាតិអប្សរា

លោក អ៊ឹម សុខរិទ្ធី

ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ

## រចនា

លោក រ៉ុង អង្គូវែល

លោក ឆោម មករា

# កិច្ចការពារបេតិកភណ្ឌវប្បធម៌
# ជាភារកិច្ចរបស់កូនខ្មែរគ្រប់ៗរូប

## មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មត្រូវបានបង្កើតឡើងដើម្បីកែលម្អការផ្តល់សេវាសាធារណៈតាមយន្តការច្រកចេញ-ចូលតែមួយដោយគ្មានធ្វើប្រតិភូកម្មអំណាចក្នុងគោលដៅបម្រើប្រជាជនឱ្យបានប្រសើរជាងមុនតាមរយៈការប្រមូលផ្តុំសេវាកម្មរដ្ឋបាលឱ្យនៅកន្លែងតែមួយ និងកំណត់យ៉ាងច្បាស់លាស់នូវគុណភាព នីតិវិធី ពេលវេលាប្រគល់ឯកសារ និងថ្លៃសេវា។

## ទីតាំងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ( តាមបណ្តោយផ្លូវហ្សាលជីហ្សោលឆ្ពោះទៅប្រាសាទអង្គរវត្ត )
៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកប្រាសាទបាគង
៨- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុង-ស្រុកទាំង៥ ( ចំពោះការស្នើសុំជួសជុលតូចតាច )

**លេខទំនាក់ទំនង**

សារអេឡិចត្រូនិច
sca_apsara@yahoo.com
លេខទូរស័ព្ទ
+៨៥៥ ៦៣ ៧៦ ៥៥ ៧៧

**ម៉ោងបំពេញការងារ**

ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
ពេលព្រឹក ៖ ម៉ោង ៨:០០ព្រឹក - ម៉ោង ១២:០០ថ្ងៃត្រង់
ពេលរសៀល ៖ ម៉ោង ១៣:០០រសៀល - ម៉ោង ១៦:០០រសៀល

ផលិតដោយនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ
ឆ្នាំ២០២៣